

# ផែនការអភិវឌ្ឍន៍ទីក្រុងនិរន្តរភាព
# សម្រាប់រាជធានីភ្នំពេញ
# ២០១៨-២០៣០

Global Green Growth Institute



© GGGI

# មាតិកា


សារគន្លឹះ V

អារម្ភកថា VI

សេចក្តីថ្លែងអំណរគុណ VIII

បញ្ជីពាក្យកាត់ X

១. សេចក្តីផ្តើម ១

២. ចក្ខុវិស័យសម្រាប់ការអភិវឌ្ឍទីក្រុងនិរន្តរភាពចក្ខុវិស័យ៖ ៣

៣. គោលដៅ និងគោលបំណងសម្រាប់ការអភិវឌ្ឍទីក្រុងនិរន្តរភាព ៤

៣.១ គោលដៅជារួមនៃការអភិវឌ្ឍទីក្រុងនិរន្តរភាព ៤

៣.២ គោលបំណងនៅតាមវិស័យសំខាន់ៗនៃការអភិវឌ្ឍទីក្រុងនិរន្តរភាព ៤

៤. ការវិភាគយុទ្ធសាស្ត្រ ៧

៤.១ ផែនការមេរាជធានីភ្នំពេញស្តីពីការប្រើប្រាស់ដីធ្លី ឆ្នាំ២០៣៥ ៧

៤.២ ផែនការមេរៀបចំប្រព័ន្ធដឹកជញ្ជូនទីក្រុងនៅរាជធានីភ្នំពេញ ឆ្នាំ២០៣៥ ៩

៤.៣ ក្របខណ្ឌគោលនយោបាយសម្រាប់ការអភិវឌ្ឍទីក្រុងនិរន្តរភាពនៅប្រទេសកម្ពុជា ១១

៤.៤ ការវាយតម្លៃជាមូលដ្ឋាននៃស្ថានភាព/បរិបទទីក្រុងនៅរាជធានីភ្នំពេញ ១១

៤.៥ ការវិភាគវិស័យទីក្រុងសំខាន់ៗសម្រាប់ការអភិវឌ្ឍនិរន្តរភាពនៅក្នុងទីក្រុង ១៣

៤.៥.១ ការរៀបចំផែនការអភិវឌ្ឍន៍ទីក្រុង ១៤

៤.៥.២ ភាពងាយរងគ្រោះរបស់ទីក្រុង ១៧

៤.៥.៣ វិស័យថាមពល ២១

៤.៥.៤ វិស័យដឹកជញ្ជូន ២៥

៤.៥.៥ បរិស្ថានសំណង់ ២៨

៤.៥.៦ កម្មន្តសាល ៣០

៤.៥.៧ ការគ្រប់គ្រងសំរាម/សំណល់រឹង ៣៣

៤.៥.៨ ទីធ្លាសាធារណៈ និងបេតិកភណ្ឌវប្បធម៌ ៣៦

៥. សកម្មភាពអាទិភាពនៃការអភិវឌ្ឍទីក្រុងនិរន្តរភាព ៣៩

៥.១ សកម្មភាពអាទិភាពនៅក្នុងវិស័យ រៀបចំផែនការអភិវឌ្ឍន៍ក្រុង ៣៩

៥.២ សកម្មភាពអាទិភាពនៅក្នុងវិស័យ ភាពងាយរងគ្រោះរបស់ទីក្រុង ៣៩

៥.៣ សកម្មភាពអាទិភាពនៅក្នុងវិស័យថាមពល ៤០

៥.៤ សកម្មភាពអាទិភាពនៅក្នុងវិស័យដឹកជញ្ជូន ៤០

៥.៥ សកម្មភាពអាទិភាពនៅក្នុងវិស័យបរិស្ថានសំណង់ ៤១

៥.៦ សកម្មភាពអាទិភាពនៅក្នុងវិស័យផលិតកម្ម (កម្មន្តសាល) ៤១

៥.៧ សកម្មភាពអាទិភាពនៅក្នុងវិស័យនៃការគ្រប់គ្រងសំណល់រឹង ៤១

៥.៨ សកម្មភាពអាទិភាពក្នុងវិស័យអភិវឌ្ឍន៍ទីធ្លាសាធារណៈ និងបេតិកភណ្ឌវប្បធម៌ ៤២

## ៦. សេណារីយ៉ូនៃការអភិវឌ្ឍបៃតង ៤៣
៦.១ សេណារីយ៉ូនៃការព្យាករណ៍តាមទម្លាប់ធម្មតា ៤៣
៦.២ សេណារីយ៉ូនៃការសាកល្បងអនុវត្តតាមទស្សនៈទាននៃការអភិវឌ្ឍបៃតង ៤៤
៦.៣ សេណារីយ៉ូនៃការបញ្ជ្រាបការអភិវឌ្ឍបៃតង ៤៦

## ៧. សំណើរនៃការរៀបចំរចនាសម្ព័ន្ធស្ថាប័នអនុវត្ត និងយន្តការគាំទ្រ ៤៨
៧.១ គណៈកម្មការប្រឹក្សាយោបល់ ៤៨
៧.២ ក្រុមការងារបច្ចេកទេស ៤៩
៧.៣ ប្រភពធនធានហិរញ្ញវត្ថុ ៥០
៧.៤ ការតាមដាន និងការវាយតម្លៃការអនុវត្ត ៥២

## ឧបសម្ព័ន្ធ កៈ
## បញ្ជីឈ្មោះភាគីពាក់ព័ន្ធដែលត្រូវបានពិគ្រោះយោបល់ ៥៦

## ឧបសម្ព័ន្ធ ខៈ
## គម្រោងវិនិយោគអាទិភាពសម្រាប់ការអភិវឌ្ឍទីក្រុងនិរន្តរភាព * ៥៧

# សារគន្លឹះ

រាជរដ្ឋាភិបាលកម្ពុជា បានកំណត់យកការអភិវឌ្ឍបៃតងជាគោលការណ៍សំខាន់នៃការរៀបចំផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមរបស់ខ្លួន ព្រមទាំងប្រើប្រាស់ការអភិវឌ្ឍបៃតងធ្វើជាយន្តការមួយឈានទៅសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ដែលនឹងរួមចំណែករក្សាកំណើនសេដ្ឋកិច្ចជាតិ លើកកម្ពស់គុណភាពបរិស្ថាន និងកាត់បន្ថយភាពក្រីក្រ។

ការអភិវឌ្ឍទីក្រុងនិរន្តរភាពនៅប្រទេសកម្ពុជា គឺជាគោលនយោបាយអាទិភាពសំខាន់មួយរបស់ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព និងក្រសួងបរិស្ថាន។ ទីក្រុង គឺជាមជ្ឈមណ្ឌលនៃសកម្មភាពសេដ្ឋកិច្ច និងជំរុញការបង្កើតការងារ និងកំណើនផលិតផលក្នុងស្រុកសរុប។ ទីក្រុងក៏ជាមជ្ឈមណ្ឌលនៃការប្រើប្រាស់ធនធានដ៏ច្រើន ដែលក្នុងនោះធនធានថាមពល ទឹក និងធនធានធម្មជាតិផ្សេងទៀត ត្រូវបានប្រើប្រាស់ច្រើនក្នុងវិស័យឧស្សាហកម្ម និងសម្រាប់ការរស់នៅក្នុងទីក្រុង ដើម្បីជំរុញការអភិវឌ្ឍសេដ្ឋកិច្ច។ ប្រទេសកម្ពុជាមានកាលានុវត្តភាពក្នុងការពន្លឿនសក្តានុពលអភិវឌ្ឍន៍របស់ខ្លួនបន្ថែមទៀត តាមរយៈការអភិវឌ្ឍទីក្រុងនិរន្តរភាព និងប្រើប្រាស់កាលានុវត្តភាពទាំងនោះនៅក្នុងវិស័យវាយនភ័ណ្ឌ ទេសចរណ៍ និងវិស័យសំណង់អចលនទ្រព្យដែលកំពុងរីកដុះដាលយ៉ាងឆាប់រហ័ស។

ផែនការអភិវឌ្ឍន៍ទីក្រុងនិរន្តរភាពសម្រាប់រាជធានីភ្នំពេញ ឆ្នាំ ២០១៨-២០៣០ នេះ បានបង្ហាញនូវទិដ្ឋភាពទូទៅយ៉ាងច្បាស់លាស់ និងជាក់ស្តែង អំពីស្ថានភាពបច្ចុប្បន្ននៅរាជធានីភ្នំពេញ រួមទាំងបញ្ហាប្រឈម និងកាលានុវត្តភាពបច្ចុប្បន្ន នៃការអភិវឌ្ឍបៃតងនៅក្នុងទីក្រុង។ ផែនការនេះ បានបង្ហាញ នូវយុទ្ធសាស្ត្រមួយចំនួន ដើម្បីឈានទៅសម្រេចបានចក្ខុវិស័យ និងបេសកកម្មទីក្រុងបៃតង និងសកម្មភាពជាអាទិភាពក្នុងវិស័យសំខាន់ៗទាំង៨ ក្នុងការអភិវឌ្ឍតំបន់ទីក្រុង។ លើសពីនេះ ផែនការអភិវឌ្ឍន៍នេះ បានផ្តល់ឱ្យយើងនូវតារាងសង្ខេបគោលគំនិតនៃគម្រោងវិនិយោគបៃតងជាអាទិភាពចំនួន៤៨គម្រោង ដែលគម្រោងទាំងនោះនឹងជួយគាំទ្រទៅដល់យុទ្ធសាស្ត្រ និងផែនការមេសម្រាប់អភិវឌ្ឍន៍រាជធានីភ្នំពេញបច្ចុប្បន្ន។

ផែនការអភិវឌ្ឍន៍ទីក្រុងនិរន្តរភាពសម្រាប់រាជធានីភ្នំពេញ ឆ្នាំ២០១៨-២០៣០ ជាឯកសារ ត្រួសត្រាយផ្លូវសម្រាប់ការធ្វើស្ថាប័នភាវូបនីយកម្ម ការរៀបចំគោលនយោបាយសម្រាប់អនុវត្តសកម្មភាព អាទិភាព និងគម្រោងវិនិយោគទីក្រុងប្រកបដោយចីរភាព ដែលកិច្ចការនេះទាមទារឱ្យយើងធ្វើសកម្មភាពរួមគ្នា ដើម្បីជំរុញការងារនេះឱ្យមានវឌ្ឍនភាពចាប់ពីការរៀបចំគម្រោងទៅដល់ការរៀបចំផែនការ ការអនុវត្ត និងការត្រួតពិនិត្យ និងវាយតម្លៃ។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅសម្រាប់ការចូលរួម និងបានផ្តល់ការគាំទ្រ ដល់ការរៀបចំនូវផែនការដ៏សំខាន់មួយនេះឡើង ជាពិសេសក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព រដ្ឋបាលរាជធានីភ្នំពេញ និងវិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល។ ខ្ញុំជឿជាក់យ៉ាងមុតមាំថា ឯកសារនេះនឹងចូលរួមជាវិជ្ជមានដល់ការអភិវឌ្ឍរាជធានីភ្នំពេញ ដែលអាចធ្វើជាគំរូនៃការអភិវឌ្ឍនិរន្តរភាពសម្រាប់ទីក្រុងសំខាន់ៗផ្សេងទៀតនៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

ថ្ងៃ សុក្រ ៧រោច ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែមេសា ឆ្នាំ ២០១៩

**ប្រធានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព**

**និងជារដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**សាយ សំអាល់**

# អារម្ភកថា

ការវិវត្តន៍នៃសង្គមមនុស្សដើរស្របនឹងលំនឹងនៃធម្មជាតិ ហើយការរីកចំរើនបច្ចេកវិទ្យា និងការអភិវឌ្ឍរបស់មនុស្ស គឺជាសកម្មភាពធ្វើឱ្យបរិស្ថានមានការផ្លាស់ប្ដូរជាបន្តបន្ទាប់។ នៅក្នុងការដឹកនាំបែបទំនើបនីយកម្មនាពេលបច្ចុប្បន្ន មិនថាប្រទេសអភិវឌ្ឍន៍ ឬប្រទេសកំពុងអភិវឌ្ឍន៍ ការយកចិត្តទុកដាក់លើបរិស្ថាន និងការអភិវឌ្ឍប្រកបដោយនិរន្តរភាពត្រូវបានរាប់បញ្ចូល និងគិតគូរជាអាទិភាព។

ភ្នំពេញ ត្រូវបានទទួលស្គាល់ជារាជធានីនៃព្រះរាជាណាចក្រកម្ពុជា ជាមជ្ឈមណ្ឌលកណ្ដាលនៃការរក្សាស្ថិរភាពនយោបាយ ការអភិវឌ្ឍសេដ្ឋកិច្ច ការរក្សាកេរដំណែលវប្បធម៌ និងជាទីក្រុងរដ្ឋបាលសម្រាប់សហប្រតិបត្តិការអន្តរជាតិ។ រាជធានីភ្នំពេញជាទីក្រុងកំពុងអភិវឌ្ឍន៍ ជាទីក្រុងដែលមានប្រជាពលរដ្ឋរស់នៅជាង ២,៥លាននាក់ (រាប់បញ្ចូលលំហូរនៃអ្នកទេសចរណ៍ អ្នកចូលមកប្រកបរបរចិញ្ចឹមជីវិតជារៀងរាល់ថ្ងៃបន្ថែមលើចំនួនអ្នករស់នៅជាអចិន្ត្រៃយ៍ក្នុងទីក្រុង) និងជាទីក្រុងដែលមានប្រជាជនរស់នៅច្រើនជាងគេនៅក្នុងប្រទេសកម្ពុជា។ ដូច្នេះ ការអភិវឌ្ឍរាជាធានីភ្នំពេញត្រូវទទួលស្គាល់នូវបម្រែបម្រួលបរិស្ថាន ដោយមានការយកចិត្តទុកដាក់លើការបម្រែបម្រួលបរិស្ថាននេះហើយទើបរដ្ឋបាលរាជធានីភ្នំពេញយកចិត្តទុកដាក់ការអភិវឌ្ឍ និងការរក្សាបាននូវបរិស្ថានស្អាត ទីក្រុងល្អដែលត្រូវតែដើរទន្ទឹមគ្នា។ ក្នុងការអភិវឌ្ឍទីក្រុង យើងក៏បានគិតគូរផងដែរអំពីការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនានា ប្រព័ន្ធដឹកជញ្ជូនទីក្រុង ការរៀបចំសណ្ដាប់ធ្នាប់សាធារណៈ និងប្រព័ន្ធចរាចរណ៍ទីក្រុង ការការពារទឹកជំនន់ ការគ្រប់គ្រងសំណល់រឹង-រាវ ការកាត់បន្ថយភាពក្រីក្រ ទប់ស្កាត់ការប្រែប្រួលអាកាសធាតុ និងការអភិវឌ្ឍជាច្រើនទៀត ដែលសំដៅលើកកម្ពស់គុណភាពបរិស្ថាន សុខមាលភាពរបស់ប្រជាពលរដ្ឋ និងធានាបាននិរន្តភាពបរិស្ថានទីក្រុង។ មិនតែប៉ុណ្ណោះ រដ្ឋបាលរាជធានីភ្នំពេញក៏បានគិតគូរអំពីការរៀបចំប្លង់គោលសម្រាប់ការអភិវឌ្ឍទីក្រុង ការបញ្ចៀសទឹកជំនន់ ការធ្វើអាងចម្រោះសំណល់ទីក្រុងមុនបង្ហូរចូលទឹកបឹងធម្មជាតិ ការកាត់បន្ថយការបំពុល ក៏ដូចជាការអប់រំឱ្យប្រជាពលរដ្ឋយល់ដឹងអំពីកិច្ចគាំពារបរិស្ថាន និងការបម្រែបម្រួលអាកាសធាតុ។

ចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា គឺសំដៅឱ្យរាជធានីភ្នំពេញក្លាយទៅជាទីក្រុងបៃតង មានបរិស្ថានស្អាត មានផលប៉ះពាល់កំរិតទាប និងជាមជ្ឈមណ្ឌលពាណិជ្ជកម្ម សេដ្ឋកិច្ច វប្បធម៌ ដែលមានលក្ខណៈប្រកួតប្រជែងរបស់ប្រទេសកម្ពុជា ជាមួយនឹងការអភិវឌ្ឍប្រកបដោយចីរភាព និងសមធម៌ ដែលស្ថិតក្រោមផែនការមេនៃការប្រើប្រាស់ដីធ្លីរបស់រាជធានីភ្នំពេញឆ្នាំ២០៣៥។ ដូចនេះ យើងត្រូវមានទស្សនទាន និងគោលការណ៍អភិវឌ្ឍន៍បៃតងសម្រាប់ការអភិវឌ្ឍប្រកបដោយនិរន្តរភាពសម្រាប់រាជធានីភ្នំពេញ។ ខ្ញុំមើលឃើញថា ផែនការអភិវឌ្ឍន៍ទីក្រុងនិរន្តរភាពសម្រាប់រាជធានីភ្នំពេញ ឆ្នាំ២០១៨-២០៣០ មានលក្ខណៈគ្រប់ជ្រុងជ្រោយ មានទាំងដំណោះស្រាយលើបញ្ហាប្រឈមរបស់ទីក្រុង ក៏ដូចជាការបង្ហាញពីគម្រោងវិនិយោគបៃតងជាអាទិភាព ដែលបានរៀបចំឡើងស្របទៅនឹងផែនការមេរបស់រាជធានីភ្នំពេញដែលមានស្រាប់។ ខ្ញុំជឿជាក់ថា យើងអាចប្រើប្រាស់ផែនការនេះជាផែនទីបង្ហាញផ្លូវដើម្បីបន្តការអភិវឌ្ឍរាជធានីភ្នំពេញប្រកបដោយនិរន្តរភាព ហើយតាមរយៈផែនការនេះ យើងក៏អាចរួមចំណែកដោះស្រាយនូវបញ្ហាប្រែប្រួលអាកាសធាតុ ស្របពេលដែលយើងកំពុងខិតខំបន្តការអភិវឌ្ឍសេដ្ឋកិច្ច កាត់បន្ថយភាពក្រីក្រ ពង្រឹងការអភិវឌ្ឍ និងបរិយាប័ន្នសង្គមផងដែរ។

ផែនការអភិវឌ្ឍន៍ទីក្រុងនិរន្តរភាពឆ្នាំ២០១៨-២០៣០ សម្រាប់រាជធានីភ្នំពេញនេះ នឹងចូលរួមចំណែកនៅក្នុងកិច្ចខិតខំប្រឹងប្រែងរបស់រាជធានីភ្នំពេញ ដើម្បីសម្រេចឱ្យបាននូវចក្ខុវិស័យរួមដែលបានកំណត់នៅក្នុងផែនការមេស្តីពី "ការប្រើប្រាស់ដីធ្លីរបស់រាជធានីភ្នំពេញឆ្នាំ២០៣៥"។ ផែនការនេះត្រូវបានរៀបចំឡើងដោយការពិគ្រោះយោបល់ជាមួយនឹងភាគីផ្សេងៗ និងមានការផ្ដល់ធាតុចូលពីអ្នកពាក់ព័ន្ធទាំងអស់នៅរដ្ឋបាលរាជធានីភ្នំពេញ ព្រមទាំងខណ្ឌទាំង១២។ ដូចនេះ យើងអាចមើលឃើញអំពីតួនាទីសំខាន់នៃផែនការនេះ ក្នុងការបំពេញបន្ថែមទៅលើផែនការមេរបស់រាជធានីភ្នំពេញស្ដីពីការប្រើបាស់ដីធ្លី ការដឹកជញ្ជូនទីក្រុង ការគ្រប់គ្រងប្រព័ន្ធលូ-ប្រឡាយ និងការគ្រប់គ្រងសំណល់ទីក្រុងផងដែរ។

ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជា ជាពិសេសតាមរយៈរដ្ឋបាលរាជធានីភ្នំពេញផែនការអភិវឌ្ឍន៍ទីក្រុងនិរន្តរភាព ឆ្នាំ២០១៨-២០៣០ នេះនឹងត្រូវដាក់ឱ្យអនុវត្តដោយមានការចូលរួមពីក្រសួង ស្ថាប័នពាក់ព័ន្ធ ព្រមទាំងមានការគាំទ្រពីវិស័យឯកជន និងដៃគូអភិវឌ្ឍន៍នានា ដើម្បីចូលរួមនៅក្នុងការអភិវឌ្ឍរាជធានីភ្នំពេញប្រកបដោយនិរន្តរភាព។

ក្នុងនាមរដ្ឋបាលរាជធានីភ្នំពេញ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព និង វិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល (GGGI) ដែលបានផ្តួចផ្តើមខិតខំប្រឹងប្រែងរៀបចំផែនការនេះឡើង ដែលផែនការនេះនឹង ដើរតួនាទីសំខាន់នៅក្នុងការសម្រេចឱ្យបាននូវសក្តានុពលសេដ្ឋកិច្ចទីក្រុង ព្រមទាំងធ្វើឱ្យការរស់នៅរបស់ប្រជាពលរដ្ឋនៅក្នុង រាជធានីភ្នំពេញកាន់តែមានភាពល្អប្រសើរឡើង និងប្រកបដោយសុខដុមនីយកម្មបរិស្ថាន។

ថ្ងៃពុធ ៨រោច ខែអស្សុជ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ២០១៨

**អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ**

**ឃួង ស្រេង**

# សេចក្តីថ្លែងអំណរគុណ

ផែនការអភិវឌ្ឍន៍ទីក្រុងនិរន្តរភាពសម្រាប់រាជធានីភ្នំពេញនេះ គឺជាលទ្ធផលនៃកិច្ចសហការរវាងរដ្ឋបាលរាជធានីភ្នំពេញ នាយកដ្ឋានសេដ្ឋកិច្ចបៃតងនៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព (ក.ជ.អ.ច.) និងវិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល រួមជាមួយក្រុមជំនាញការមកពីមជ្ឈមណ្ឌលអន្តរជាតិសម្រាប់ការគ្រប់គ្រងបរិស្ថាន (International Centre for Environmental Management - ICEM)។

ការរៀបចំផែនការអភិវឌ្ឍន៍ទីក្រុងនិរន្តរភាពសម្រាប់រាជធានីភ្នំពេញ អាចធ្វើទៅបានដោយសារមានការចូលរួមពីស្ថាប័នពាក់ព័ន្ធជាច្រើន ដូចជាក្រសួងនានានៃរាជរដ្ឋាភិបាលកម្ពុជា អាជ្ញាធរខណ្ឌនិងមន្ទីរពាក់ព័ន្ធនៃរាជធានីភ្នំពេញ ដៃគូអភិវឌ្ឍន៍ សហគមន៍មូលដ្ឋាន អង្គការមិនមែនរដ្ឋាភិបាល  ស្ថាប័នសិក្សាស្រាវជ្រាវ និងតំណាងវិស័យឯកជនដែលមានគោលដៅ និងគោលបំណងដូចគ្នាជាមួយនឹងរាជរដ្ឋាភិបាលសម្រាប់ការអភិវឌ្ឍរាជធានីយើងប្រកបដោយនិរន្តរភាពទៅថ្ងៃអនាគត និងបង្ហាញពីការឆ្លើយតបដល់ក្តីប្រាថ្នារបស់ប្រជាពលរដ្ឋក្នុងការរស់នៅប្រកបដោយសុខដុមរមនានៅក្នុងរាជធានី។

សូមថ្លែងអំណរគុណដល់មន្ត្រីរាជរដ្ឋាភិបាលមកពីស្ថាប័នពាក់ព័ន្ធ ដែលបានដើរតួនាទីយ៉ាងសំខាន់ក្នុងការដឹកនាំ និងផ្តល់យោបល់ជាយុទ្ធសាស្ត្រដល់ការសិក្សា និងរៀបចំផែនការទីក្រុងនិរន្តរភាពសម្រាប់រាជធានីភ្នំពេញ រួមមាន៖

- **ឯកឧត្តម ទិន ពន្លក** អគ្គលេខាធិការ នៃ ក.ជ.អ.ច.
- **ឯកឧត្តម ឯ វុឌ្ឍី** អគ្គលេខាធិការរង នៃ ក.ជ.អ.ច.
- **ឯកឧត្តម កែន សេរីរដ្ឋា** អគ្គលេខាធិការរង នៃក.ជ.អ.ច.
- **ឯកឧត្តម នួន ផារ័ត្ន** អភិបាលរង រាជធានីភ្នំពេញ
- **ឯកឧត្តម ហួត ហៃ** អភិបាលរង រាជធានីភ្នំពេញ
- **ឯកឧត្តម អៀង អូននី** អតីត អភិបាលរង រាជធានីភ្នំពេញ
- **លោក លឹម វិចិត្រ** នាយករងរដ្ឋបាល នៃរដ្ឋបាលរាជធានីភ្នំពេញ
- **លោក តាំង ម៉េងអៀង** ប្រធាននាយកដ្ឋានសេដ្ឋកិច្ចបៃតង នៃក.ជ.អ.ច.
- **លោក ណុប សុខៃ** អនុប្រធាននាយកដ្ឋានសេដ្ឋកិច្ចបៃតង នៃក.ជ.អ.ច.
- **លោក យុន សុវិធា** អតីត អនុប្រធាននាយកដ្ឋានសេដ្ឋកិច្ចបៃតង នៃក.ជ.អ.ច.
- **លោក សាត ស៊ីតាក់** អនុប្រធានការិយាល័យ នាយកដ្ឋានសេដ្ឋកិច្ចបៃតង នៃក.ជ.អ.ច.
- **លោក ឃឹម សណ្តាប់** អនុប្រធានការិយាល័យ នាយកដ្ឋានសេដ្ឋកិច្ចបៃតង នៃក.ជ.អ.ច.
- **លោកស្រី សឿង លីលី** មន្ត្រីបច្ចេកទេស នាយកដ្ឋានសេដ្ឋកិច្ចបៃតង នៃក.ជ.អ.ច.

ក្រសួងពាក់ព័ន្ធដូចខាងក្រោមដែលបានចូលរួមតាក់តែង និងធ្វើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទីក្រុងនិរន្តរភាពសម្រាប់រាជធានីភ្នំពេញ តាមរយៈការសម្របសម្រួលរបស់ ក.ជ.អ.ច. (ឧបសម្ព័ន្ធ ក បង្ហាញលម្អិតពីស្ថាប័នពាក់ព័ន្ធផ្សេងទៀតដែលបានពិគ្រោះយោបល់សម្រាប់ការរៀបចំផែនការនេះ)

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមហាផ្ទៃ
- ក្រសួងផែនការ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងបរិស្ថាន
- ក្រសួងសាធារណការ និងដឹកជញ្ជូន

- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- ក្រសួងរ៉ែ និងថាមពល
- ក្រសួងធនធានទឹក និងឧតុនិយម
- ក្រសួងកិច្ចការនារី

បុគ្គលិកនៃវិទ្យាស្ថាន GGGI ដែលបានចូលរួមសម្របសម្រួលដំណើរការរៀបចំ និងត្រួតពិនិត្យផែនការអភិវឌ្ឍន៍ទីក្រុងនិរន្តរភាពនេះ រួមមាន៖

- **Ms. Fiona Lord** អតីតតំណាង GGGI ប្រចាំប្រទេសកម្ពុជា
- **Mr. Adam Ward** តំណាង GGGI ប្រចាំប្រទេសវៀតណាម
- **Dr. Pheakdey Heng** អតីតប្រធានផ្នែកគោលនយោបាយ GGGI ប្រចាំនៅកម្ពុជា
- **Dr. James Kang** អ្នកឯកទេសវិស័យដឹកជញ្ជូន GGGI
- **Dr. Okju Jeong** អ្នកឯកទេសផ្នែកអភិវឌ្ឍន៍ទីក្រុងបៃតង GGGI
- **Mr. Chantharo Khan** មន្ត្រីកម្មវិធី GGGI

ក្រុមការងារនៃមជ្ឈមណ្ឌលអន្តរជាតិសម្រាប់ការគ្រប់គ្រងបរិស្ថាន (ICEM) ដែលរួមមានសមាសភាពអ្នកជំនាញការអន្តរជាតិ និងអ្នកជំនាញការជាតិ ដែលបានចុះសិក្សាស្រាវជ្រាវ ប្រមូល និងវិភាគទិន្នន័យ ចាប់ពីខែតុលា ឆ្នាំ២០១៥ រហូតដល់ខែឧសភា ឆ្នាំ២០១៦។ សមាជិកក្រុមការងាររួមមាន៖

- **Mr. Anthony Gad Bigio** អ្នកឯកទេសរៀបចំផែនការទី និងប្រធានក្រុមការងារ
- **Dr. John Sawdon** អ្នកឯកទេសផ្នែកសេដ្ឋកិច្ចបៃតង
- **Dr. Wayne Stone** អ្នកឯកទេសវិភាគភាពងាយរងគ្រោះតំបន់ក្រុង
- **Mr. Soktharath Chreung** អ្នកជំនាញការវិនិយោគ និងហិរញ្ញប្បទានបៃតង
- **Mr. Vin Spoann** អ្នកជំនាញការផ្នែកហេដ្ឋារចនាសម្ព័ន្ធបៃតង
- **Mr. Kong Pagnarith** អ្នកឯកទេសផ្នែកថាមពលបៃតង
- **Mr. Chhun Bunlong** អ្នកជំនាញការផ្នែកគូរផែនទីតំបន់ក្រុង

បុគ្គលិក ICEM ដែលបានរួមចំណែកដល់គម្រោងនេះ រួមមានអ្នកគ្រប់គ្រងគម្រោងផ្ទាល់ គឺ **Mr. Nick Beresnev** អ្នកសម្របសម្រួលគម្រោង **Ms. Nguyen Thi Phuong Thao** និង អ្នកដឹកនាំគម្រោង **Dr. Jeremy Carew-Read** ។

# បញ្ជីពាក្យកាត់

| | |
|---|---|
| **ACLEDA** | ធនាគារអេស៊ីលីដា |
| **ADB** | ធនាគារអភិវឌ្ឍន៍អាស៊ី |
| **AFD** | ទីភ្នាក់ងារបារាំងដើម្បីអភិវឌ្ឍន៍ |
| **BAU** | ការព្យាករតាមទម្លាប់ធម្មតា |
| **CCCA** | សម្ព័ន្ធភាពការប្រែប្រួលអាកាសធាតុប្រទេសកម្ពុជា |
| **CDC** | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| **CDM** | យន្តការ/កម្មវិធីអភិវឌ្ឍន៍បរិស្ថានស្អាត |
| **DFAT** | នាយកដ្ឋានកិច្ចការបរទេស និងពាណិជ្ជកម្មអូស្ត្រាលី |
| **DPWT** | មន្ទីរសាធារណការ និងដឹកជញ្ជូន (រាជធានីភ្នំពេញ) |
| **EAC** | អាជ្ញាធរអគ្គិសនីកម្ពុជា |
| **EDC** | អគ្គិសនីកម្ពុជា |
| **EE** | ប្រសិទ្ធភាពថាមពល |
| **ESCO** | ក្រុមហ៊ុនផ្តល់សេវាកម្មផ្នែកថាមពល |
| **EUROCHAM** | សភាពាណិជ្ជកម្មអឺរ៉ុប ប្រចាំនៅប្រទេសកម្ពុជា |
| **FDI** | វិនិយោគផ្ទាល់ពីបរទេស |
| **GEF** | ឥណទានបរិស្ថានសកល |
| **GGGI** | វិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល |
| **GHG** | ឧស្ម័នផ្ទះកញ្ចក់ |
| **GIZ** | ភ្នាក់ងារកិច្ចសហប្រតិបត្តិការអាល្លឺម៉ង់ |
| **GMAC** | សមាគមអ្នកផលិតសម្លៀកបំពាក់នៅប្រទេសកម្ពុជា |
| **GWh** | ជីហ្គាវ៉ាត់ម៉ោង |
| **IFC** | សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ |
| **IFI** | ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ |
| **INDC** | ការរួមចំណែកអនុវត្តន៍អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ |
| **IPCC** | គណៈកម្មាធិការអន្តររដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុ |
| **JICA** | ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន |
| **KHR** | រៀលខ្មែរ (រូបិយវត្ថុ) |
| **KOICA** | ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ |

| | |
|---|---|
| KTOE | បរិមាណថាមពលគិតជាតោន ដែលសមមូលនិងបរិមាណប្រេង |
| kWh | គីឡូវ៉ាត់ម៉ោង |
| LCDF | មូលនិធិប្រទេសលូតលាស់តិចជាងគេ |
| LPG | ឧស្ម័នតេលសិលាពង្រាវ |
| MCA | ការវិភាគពហុលក្ខណៈវិនិច្ឆ័យ |
| MEF | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| MLMUPC | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |
| MME | ក្រសួងរ៉ែ និងថាមពល |
| MOE | ក្រសួងបរិស្ថាន |
| MOI | ក្រសួងមហាផ្ទៃ |
| MOIH | ក្រសួងឧស្សាហកម្ម និងសិប្បកម្ម |
| MOWM | ក្រសួងកិច្ចការនារី |
| MOWRAM | ក្រសួងធនធានទឹក និងឧតុនិយម |
| MPWT | ក្រសួងសាធារណការ និងដឹកជញ្ជូន |
| MW | មេហ្គាវ៉ាត់ |
| NCSD | ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព |
| NSDP | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ |
| OECD | អង្គការសហប្រតិបត្តិការសេដ្ឋកិច្ចនិងអភិវឌ្ឍន៍ |
| PPCA | សាលារាជធានីភ្នំពេញ |
| PPSEZ | តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ |
| SEZ | តំបន់សេដ្ឋកិច្ចពិសេស |
| SME | សហគ្រាសខ្នាតតូច និងមធ្យម |
| UNDP | កម្មវិធីអភិវឌ្ឍន៍នៃអង្គការសហប្រជាជាតិ |
| UNEP | កម្មវិធីបរិស្ថាននៃអង្គការសហប្រជាជាតិ |
| UNESCO | អង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌នៃអង្គការសហប្រជាជាតិ |
| UNICEF | មូលនិធិសង្គ្រោះបន្ទាន់សម្រាប់កុមារនៃអង្គការសហប្រជាជាតិ |
| UNIDO | អង្គការអភិវឌ្ឍន៍ឧស្សាហកម្មនៃអង្គការសហប្រជាជាតិ |


© GGGI

# ១. សេចក្តីផ្តើម

ផែនការអភិវឌ្ឍន៍ទីក្រុងនិរន្តរភាពសម្រាប់រាជធានីភ្នំពេញ គឺជាផែនទីបង្ហាញផ្លូវមួយសម្រាប់អ្នករៀបចំគោលនយោបាយទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងដៃគូអភិវឌ្ឍន៍ជាតិ និងអន្តរជាតិនានា ដើម្បីបន្តការអភិវឌ្ឍទីក្រុងប្រកបដោយនិរន្តរភាពក្នុងគោលដៅប្រយុទ្ធប្រឆាំងនឹងការប្រែប្រួលអាកាសធាតុនៅក្នុងដំណើរការអភិវឌ្ឍកំណើនសេដ្ឋកិច្ច កាត់បន្ថយភាពក្រីក្រ និងពង្រឹងបរិយាប័ន្នសង្គម[1]។ ដូច្នេះ ផែនការនេះមានសារៈប្រយោជន៍សម្រាប់គ្រប់ភាគីពាក់ព័ន្ធទាំងនៅរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់រាជធានី វិស័យឯកជន ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នសិក្សាស្រាវជ្រាវក្នុងការអភិវឌ្ឍរាជធានីភ្នំពេញ។

ផែនការអភិវឌ្ឍន៍ទីក្រុងនិរន្តរភាពសម្រាប់រាជធានីភ្នំពេញ មានភ្ជាប់មកជាមួយនូវវិធីសាស្ត្ររៀបចំផែនការយុទ្ធសាស្ត្រទីក្រុងនិរន្តរភាព ដែលជាគោលការណ៍ណែនាំជាជំហានៗសម្រាប់មន្ត្រី  ពាក់ព័ន្ធនានាទាំងនៅថ្នាក់រាជធានី ក្រុង/ស្រុក ឃុំ/សង្កាត់ ព្រមទាំងភាគីពាក់ព័ន្ធនៃទីក្រុងនីមួយៗនៅទូទាំងប្រទេសកម្ពុជា ដែលកំពុងបន្តអនុវត្តដំណើរការអភិវឌ្ឍន៍ទីក្រុងរបស់ខ្លួន សំដៅឆ្ពោះទៅរកការអភិវឌ្ឍប្រកបដោយចីរភាព។ វិធីសាស្ត្រនេះគាំទ្រដល់ទីក្រុងនានាក្នុងការសិក្សាវាយតម្លៃ និងកំណត់អាទិភាពអភិវឌ្ឍន៍និរន្តរភាព (គម្រោងវិនិយោគ និងកំណែទម្រង់គោលនយោបាយ) សម្រាប់អនុវត្ត។ វិធីសាស្ត្រនេះបានពិចារណាយ៉ាងគ្រប់ជ្រុងជ្រោយទៅលើគ្រប់ទិដ្ឋភាពនៃការអភិវឌ្ឍទីក្រុងនិរន្តរភាព ដូចជាការអភិវឌ្ឍដែលបំភាយកាបូនតិច ការបន្ស៊ាំនឹងការប្រែប្រួលអាកាសធាតុ ការប្រើប្រាស់ប្រសិទ្ធភាពធនធាន ព្រមទាំងបរិយាប័ន្នសង្គម និងការកាត់បន្ថយភាពក្រីក្រ។ វិធីសាស្ត្រនេះមាន ១០ ជំហាន ដូចខាងក្រោម៖

- **ជំហានទី ១៖** ការបង្កើតក្រុមការងារសម្រាប់រៀបចំផែនការអភិវឌ្ឍន៍ទីក្រុងនិរន្តរភាព
- **ជំហានទី ២៖** ការសិក្សាវាយតម្លៃបឋម ដើម្បីធ្វើជាមូលដ្ឋានវិភាគទៅលើបរិបទទីក្រុង
- **ជំហានទី ៣៖** ការកំណត់ចក្ខុវិស័យទីក្រុងនិរន្តរភាព បេសកកម្ម និងគោលដៅអភិវឌ្ឍន៍
- **ជំហានទី ៤៖** ការវិភាគវិស័យសំខាន់ៗសម្រាប់ការអភិវឌ្ឍនិរន្តរភាពក្នុងទីក្រុង
- **ជំហានទី ៥៖** ការបង្កើតវត្ថុបំណងអាទិភាពនៃការអភិវឌ្ឍបៃតងនៅទីក្រុង និងសកម្មភាពសម្រាប់វិស័យគន្លឹះៗនៃទីក្រុង
- **ជំហានទី ៦៖** ការកំណត់គម្រោងវិនិយោគសក្តានុពលសម្រាប់អភិវឌ្ឍន៍ទីក្រុងនិរន្តរភាព
- **ជំហានទី ៧៖** ការកំណត់អាទិភាពគម្រោងវិនិយោគសម្រាប់អភិវឌ្ឍន៍ទីក្រុងនិរន្តរភាព
- **ជំហានទី ៨៖** ការវិភាគសេណារីយ៉ូសម្រាប់ការអភិវឌ្ឍនិរន្តរភាពនៅទីក្រុង
- **ជំហានទី ៩៖** ការរៀបចំបញ្ជីគម្រោងអាទិភាពទីក្រុងនិរន្តរភាព
- **ជំហានទី ១០៖** ការរៀបចំរចនាសម្ព័ន្ធសម្រាប់អនុវត្តន៍ផែនការទីក្រុងនិរន្តរភាព

រាជធានីភ្នំពេញ គឺជាទីក្រុងដំបូងគេនៅប្រទេសកម្ពុជាដែលអនុវត្តវិធីសាស្ត្ររៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទីក្រុងបៃតងនេះ និងបានបង្កើតជាផែនការអភិវឌ្ឍន៍ទីក្រុងនិរន្តរភាពរបស់ខ្លួនដើម្បីធ្វើជាគម្រូឱ្យទីក្រុងផ្សេងទៀតអនុវត្តតាម។  ផែនការអភិវឌ្ឍន៍ទីក្រុងនិរន្តរភាពសម្រាប់រាជធានីភ្នំពេញ ត្រូវបានបង្កើតឡើងដើម្បីគាំទ្រដល់ការអនុវត្តផែនការមេរាជធានីភ្នំពេញស្តីពីការប្រើប្រាស់ដីធ្លី ឆ្នាំ២០៣៥ តាមរយៈការបង្កើតសកម្មភាពគម្រោងវិនិយោគអភិវឌ្ឍន៍បៃតងជាក់លាក់មួយចំនួនដែលឆ្លើយតបទៅនឹងយុទ្ធសាស្ត្រអាទិភាពកំណត់នៅក្នុងផែនការមេ។ លើសពីនេះទៀតផែនការអភិវឌ្ឍន៍ ទីក្រុងនិរន្តរភាពនេះ នឹងគាំទ្រដល់ការសម្រេចបានគោលដៅជាយុទ្ធសាស្ត្រដែលមានចែងនៅក្នុងផែនការមេរាជធានីភ្នំពេញស្តីពីការរៀបចំប្រព័ន្ធដឹកជញ្ជូនទីក្រុង និងផែនការមេរាជធានីភ្នំពេញស្តីពី  បណ្តាញលូទឹក និងប្រព័ន្ធលូទឹកកខ្វក់។

[1] បរិយាប័ន្នសង្គម (Social Inclusion) គឺជាការគិតគូរពីបញ្ហាសង្គមបានគ្រប់ជ្រុងជ្រោយ នៅក្នុងការធ្វើសេចក្តីសម្រេចចិត្តនានារបស់ថ្នាក់ដឹកនាំ ឬអ្នកធ្វើគោលនយោបាយ នៅលើគ្រប់វិស័យទាំងអស់ដែលពាក់ព័ន្ធ។

ផែនការអភិវឌ្ឍន៍ទីក្រុងនិរន្តរភាពសម្រាប់រាជធានីភ្នំពេញ ត្រូវបានសហការរៀបចំឡើងមានលក្ខណៈគ្រប់ជ្រុងជ្រោយ ដោយមានរួមបញ្ចូលនូវការពណ៌នាអំពីគោលគំនិតនៃគម្រោងវិនិយោគបៃតងសម្រាប់រាជធានីភ្នំពេញចំនួន ៤៨ គម្រោង ដែលមានការវិភាគលម្អិតដើម្បីគាំទ្រដល់ដំណើរការជ្រើសរើស ការផ្តល់អាទិភាព និងការអនុវត្តគម្រោងទាំងនោះ ក្នុងនោះក៏មានការវិភាគលម្អិតទៅលើកត្តាប្រឈម និងកាលានុវត្តភាពតាមវិស័យសំខាន់ៗនៃការអភិវឌ្ឍនិរន្តរភាពសម្រាប់រាជធានីភ្នំពេញ។

រូបភាពទី១៖ ទំនាក់ទំនងនៃផែនការអភិវឌ្ឍន៍ទីក្រុងនិរន្តរភាពសម្រាប់រាជធានីភ្នំពេញ ទៅនិងផែនការមេរាជធានីភ្នំពេញស្តីពីការប្រើប្រាស់ដីឆ្នាំ២០៣៥។

**ផែនការមេរាជធានីភ្នំពេញស្តីពីការប្រើប្រាស់ដីធ្លី ឆ្នាំ២០៣៥**

ចក្ខុវិស័យ៖ រាជធានីភ្នំពេញ គឺជាមជ្ឈមណ្ឌលមួយដែលមានសក្តានុពលប្រកួតប្រជែងផ្នែកនយោបាយ សេដ្ឋកិច្ច ជំនួញ និងវប្បធម៌នៃប្រទេសកម្ពុជា ដែលមានការអភិវឌ្ឍប្រកបដោយចីរភាព និងសមធម៌

**ផែនការមេវិស័យដឹកជញ្ជូនក្នុងទីក្រុង ឆ្នាំ២០៣៥**

គោលដៅ៖ ដើម្បីដោះស្រាយនូវបញ្ហាចរាចរណ៍នាពេលបច្ចុប្បន្ន និងគាំទ្រទៅដល់ចក្ខុវិស័យ និងរចនាសម្ព័ន្ធទីប្រជុំជនឆ្នាំ ២០៣៥

*(ផ្អែកលើការសិក្សារបស់ JICA ឆ្នាំ ២០១៤ ស្តីពីការរៀបចំផែនការមេស្តីពីវិស័យដឹកជញ្ជូនក្នុងរាជធានីភ្នំពេញ)*

**ផែនការមេរាជធានីភ្នំពេញ ស្តីពីបណ្តាញលូ និងប្រព័ន្ធលូទឹកកខ្វក់ ឆ្នាំ២០៣៥**

គោលដៅ៖ ដើម្បីកែលម្អដល់ការធ្វើប្រព្រឹត្តិកម្មទឹកកខ្វក់ និងការគ្រប់គ្រងប្រព័ន្ធលូបង្ហូរទឹកភ្លៀង នៅក្នុងតំបន់អភិវឌ្ឍន៍ខ្លាំងនៃទីក្រុង

*(ផ្អែកលើការសិក្សារបស់ JICA ឆ្នាំ ២០១៦ ស្តីពីការរៀបចំផែនការមេស្តីពីការកែលម្អប្រព័ន្ធលូ និងកែលម្អទឹកកខ្វក់នៅរាជធានីភ្នំពេញ)*

**ផែនការអភិវឌ្ឍន៍ទីក្រុងនិរន្តរភាពសម្រាប់រាជធានីភ្នំពេញ ឆ្នាំ២០១៨-២០៣០**

ចក្ខុវិស័យ៖ នៅឆ្នាំ២០៣០ រាជធានីភ្នំពេញនឹងក្លាយជាទីក្រុងស្អាត បៃតង និងប្រកបដោយការប្រកួតប្រជែង ដែលផ្តល់នូវការរស់នៅមានសុវត្ថិភាព និងគុណភាពដល់ប្រជាជន។

គោលដៅ៖

- ធ្វើឱ្យមានកំណើនសេដ្ឋកិច្ច ដោយមិនមានផលប៉ះពាល់លើបរិស្ថាន
- បង្កើនសមាហរណកម្មក្នុងសង្គម កាត់បន្ថយកម្រិតភាពក្រីក្រ និងកែលម្អសុខុមាលភាពទីក្រុង
- ផ្តល់ដល់ពលរដ្ឋទាំងអស់នៅទីក្រុងនូវភាពបន្សាំទៅនឹងហានិភ័យធម្មជាតិ អាកាសធាតុ និងហានិភ័យផ្សេងទៀត
- ផ្តល់ភាពប្រកួតប្រជែង និងភាពទាក់ទាញនៅទីក្រុងដល់កិច្ចការជំនួញ

# ២. ចក្ខុវិស័យសម្រាប់ការអភិវឌ្ឍទីក្រុងនិរន្តរភាព

ដើម្បីឈានទៅសម្រេចការអភិវឌ្ឍទីក្រុងនិរន្តរភាពសម្រាប់រាជធានីភ្នំពេញ ផែនការនេះបានកំណត់ចក្ខុវិស័យដូចខាងក្រោមៈ

**ចក្ខុវិស័យ**

នៅឆ្នាំ២០៣០ រាជធានីភ្នំពេញនឹងក្លាយជាទីក្រុងស្អាត បៃតង និងប្រកបដោយការប្រកួតប្រជែង ដែលផ្តល់នូវរបៀបរស់នៅមានសុវត្ថិភាព និងគុណភាពដល់ប្រជាជន។



© GGGI

# ៣. គោលដៅ និងគោលបំណងសម្រាប់ការអភិវឌ្ឍទីក្រុងនិរន្តរភាព

ដើម្បីសម្រេចបាននូវចក្ខុវិស័យសម្រាប់ការអភិវឌ្ឍទីក្រុងប្រកបដោយនិរន្តរភាព គោលដៅនិងគោលបំណងធំៗ ដូចខាងក្រោមត្រូវបានគេស្នើឡើង។ គោលដៅជាក់លាក់និងសូចនាករនឹងត្រូវបង្កើតឡើងដោយក្រុមការងារបច្ចេកទេស (TWGs) ដូចដែលបានរៀបរាប់នៅក្នុងផ្នែករៀបចំការអនុវត្ត (ផ្នែកទី ៧) នៃផែនការនេះ។

## ៣.១ គោលដៅជារួមនៃការអភិវឌ្ឍទីក្រុងនិរន្តរភាព

ក. ធ្វើឱ្យមានកំណើនសេដ្ឋកិច្ចដោយមិនប៉ះពាល់លើបរិស្ថាន

ខ. ពង្រឹងបរិយាប័ន្នសង្គម កាត់បន្ថយភាពក្រីក្រ និងបង្កើនសុខុមាលភាពទីក្រុង

គ. ផ្តល់ដល់ប្រជាពលរដ្ឋទាំងអស់នៅក្នុងទីក្រុង នូវការរស់នៅដែលមានភាពបន្សាំទៅនឹងហានិភ័យគ្រោះធម្មជាតិ ការប្រែប្រួលអាកាសធាតុ និងហានិភ័យផ្សេងៗទៀត

ឃ. បង្កើនភាពប្រកួតប្រជែង និងភាពទាក់ទាញសម្រាប់កិច្ចការជំនួញ និងវិនិយោគ

## ៣.២ គោលបំណងនៅតាមវិស័យសំខាន់ៗនៃការអភិវឌ្ឍទីក្រុងនិរន្តរភាព

### ក. គោលបំណងនៅក្នុងវិស័យ "ការរៀបចំផែនការអភិវឌ្ឍន៍ទីក្រុងនិរន្តរភាព"

- អនុវត្តអោយបាននូវផែនការមេរាជធានីភ្នំពេញស្តីពីការប្រើប្រាស់ដីធ្លី ឆ្នាំ២០៣៥ ស្របទៅតាមទិសដៅដែលបានគ្រោងទុក (ភាគរយដែលត្រូវបានអនុវត្តរួចស្របទៅតាមផែនការមេ)
- រៀបចំផែនទីលម្អិតស្តីពីការប្រើប្រាស់ដីធ្លី និងការបែងចែកតំបន់ប្រើប្រាស់ដីធ្លី (ភាគរយនៃវិសាលភាពតំបន់ទីក្រុងដែលបានកំណត់នៅក្នុងផែនទីលម្អិត)
- ធ្វើឱ្យមាននិរន្តរភាពនៃការអនុវត្តគម្រោងអភិវឌ្ឍន៍ទីក្រុងរណបទាំងប្រាំពីរដែលបានគ្រោងនឹងបញ្ចប់នៅឆ្នាំ២០៣០ (គម្រោងនីមួយៗមានប្រព័ន្ធគ្រប់គ្រងសំណល់រឹង និងរាវ និងការអនុវត្តស្របតាមបទដ្ឋានសាងសង់បៃតង)

### ខ. គោលបំណងនៅក្នុងវិស័យ "ភាពងាយរងគ្រោះរបស់ទីក្រុង"

- ការពារប្រជាជនក្នុងរាជធានីភ្នំពេញពីទឹកជំនន់ធ្ងន់ធ្ងរ (ភាគរយនៃប្រជាជនដែលទទួលរងផលប៉ះពាល់អវិជ្ជមាន)
- កែលម្អបឹងធម្មជាតិ និងតំបន់ដីសើមនៅទីក្រុងដែលអាចប្រើប្រាស់ជាប្រព័ន្ធគ្រប់គ្រងទឹកជំនន់ធម្មជាតិ និងទឹកកខ្វក់ឱ្យបានច្រើនដូចក្នុងឆ្នាំ២០០៣ (ក្រឡាផ្ទៃបឹងធម្មជាតិ និងតំបន់ដីសើមគិតជាហិកតា ឬជាអារ)
- បង្កើត ឬស្តារឡើងវិញនូវរបៀងបៃតងនៅក្នុងទីក្រុងទាំងមូល (ចំនួនរបៀង)
- ប្រព្រឹត្តកម្មសំណល់រាវទំហំតូចៗតាមតំបន់ ដែលនឹងត្រូវបង្កើតឡើងនៅក្នុងតំបន់ទីក្រុង (លានម៉ែត្រគូប / គិតជាភាគរយនៃបរិមាណសរុប)
- គ្រួសារនៅតំបន់ជុំវិញទីក្រុងប្រើប្រាស់ប្រព័ន្ធអនាម័យដែលមានការកែលម្អ និងមានសុវត្ថិភាព ដែលនឹងការពារការរាលដាលនៃការបំពុលនៅក្នុងករណីមានភ្លៀង និងមានការជន់លិចខ្លាំង (ចំនួនគ្រួសារជុំវិញទីក្រុងដែលមានប្រព័ន្ធអនាម័យល្អ និងមានសុវត្ថិភាព រួមជាមួយនឹងប្រព្រឹត្តកម្មទឹកកខ្វក់ គិតជាភាគរយនៃបរិមាណសរុប)

### គ. គោលបំណងក្នុងវិស័យ "ថាមពល"

- បង្កើនបរិមាណប្រើប្រាស់ថាមពលពន្លឺព្រះអាទិត្យនៅក្នុងការផ្គត់ផ្គង់អគ្គិសនី (ភាគរយកំណើនពីបច្ចុប្បន្ន < ១%)
- កាត់បន្ថយការប្រើប្រាស់អគ្គិសនីនៅក្នុងក្រុមហ៊ុនអាជីវកម្ម និងសេវាកម្មតាមរយៈការដាក់បញ្ចូលនូវវិធានការប្រសិទ្ធភាពថាមពល (ភាគរយនៃការកាត់បន្ថយធៀបនឹងទិន្នន័យមូលដ្ឋានស្តីពីការប្រើប្រាស់បច្ចុប្បន្ន)
- កាត់បន្ថយការប្រើប្រាស់អគ្គិសនីនៅក្នុងគ្រួសារ តាមរយៈការនាំមកនូវវិធានការប្រសិទ្ធភាពថាមពល (ភាគរយនៃការកាត់បន្ថយធៀបនឹងទិន្នន័យមូលដ្ឋានស្តីពីការប្រើប្រាស់បច្ចុប្បន្ន)
- អគាររដ្ឋបាលក្រុង និងរដ្ឋបាលផ្សេងទៀតដែលមានដំបូលសមស្របត្រូវបំពាក់ ផ្ទាំងកញ្ចក់ស្រូបថាមពលព្រះអាទិត្យ (ចំនួនអគាររដ្ឋបាលដែលបានរៀបចំ និងបំពាក់ផ្ទាំងកញ្ចក់ស្រូបថាមពលព្រះអាទិត្យ ធៀបនឹងចំនួនអគាររដ្ឋបាលសរុប)

### ឃ. គោលបំណងនៅក្នុងវិស័យ "ដឹកជញ្ជូន"

- កាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់នៅក្នុងវិស័យដឹកជញ្ជូន (ភាគរយនៃការកាត់បន្ថយលើទិន្នន័យមូលដ្ឋានបច្ចុប្បន្ន)
- ប្រព័ន្ធមធ្យោបាយដឹកជញ្ជូនសាធារណៈរថយន្តក្រុងត្រូវបានបង្កើតឡើងដោយគ្របដណ្តប់លើច្រកដឹកជញ្ជូនសំខាន់ៗនៅក្នុងទីក្រុង (ភាគរយនៃច្រកសរុប)
- កាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ (ភាគរយនៃការកាត់បន្ថយធៀបនឹងទិន្នន័យមូលដ្ឋានប្រចាំឆ្នាំបច្ចុប្បន្ន)
- កាត់បន្ថយការកកស្ទះចរាចរណ៍តាមដងផ្លូវ (កំណើនល្បឿនយានយន្តជាមធ្យមធៀបនឹងទិន្នន័យមូលដ្ឋានបច្ចុប្បន្ន)

### ង. គោលបំណងនៅក្នុងវិស័យ "បរិស្ថានសំណង់ (សំណង់អគារ)"

- អនុម័តបទដ្ឋានសាងសង់បៃតងសម្រាប់អគារដែលត្រូវសាងសង់ចាប់ពីឆ្នាំ២០២០ តទៅ (ចំនួនគម្រោងសាងសង់បៃតងធៀបនឹងចំនួនលិខិតអនុញ្ញាតសាងសង់ដែលត្រូវបានស្នើសុំ)
- កាត់បន្ថយការប្រើប្រាស់ថាមពលនៅក្នុងអគារបច្ចុប្បន្ន (ភាគរយនៃការកាត់បន្ថយធៀបនឹងទិន្នន័យមូលដ្ឋានបច្ចុប្បន្ន)
- លំនៅដ្ឋានសម្រាប់គ្រួសារមានចំណូលទាបត្រូវបានបង្កើតឡើង ឬបំពាក់បរិក្ខារឡើងវិញដើម្បីឱ្យធន់នឹងគ្រោះធម្មជាតិ (ចំនួនលំនៅដ្ឋានដែលត្រូវបានធ្វើឱ្យប្រសើរឡើងធន់នឹងគ្រោះធម្មជាតិ ធៀបនឹងបរិមាណលំនៅដ្ឋាននៅទីក្រុងសរុប)

### ច. គោលបំណងក្នុងវិស័យ "កម្មន្តសាល"

- បង្កើតតំបន់ឧស្សាហកម្មដែលមានហេដ្ឋារចនាសម្ព័ន្ធគាំទ្របៃតង (ចំនួនតំបន់ឧស្សាហកម្មដែលត្រូវបានរៀបចំ និងបំពាក់បរិក្ខារដែលគាំទ្របៃតង)
- កាត់បន្ថយការបំពុលទឹកនៅក្នុងវិស័យកម្មន្តសាល (ភាគរយនៃបរិមាណទឹកកខ្វក់សរុបដែលត្រូវបានធ្វើប្រព្រឹត្តកម្ម)
- បង្កើនប្រសិទ្ធភាពថាមពលនៅក្នុងឧស្សាហកម្មកម្មន្តសាល (ការកាត់បន្ថយចំនួនគីឡូវ៉ាត់ដែលត្រូវបានប្រើប្រាស់ក្នុងមួយតម្លៃនៃធាតុចេញ)
- ធ្វើសវនកម្មប្រសិទ្ធភាពថាមពល និងបង្កើតផែនការគ្រប់គ្រងទៅលើប្រសិទ្ធភាពថាមពលសម្រាប់រោងចក្រកម្មន្តសាលធំៗ (ចំនួនសវនកម្ម និងផែនការគ្រប់គ្រងធៀបនឹងចំនួនសរុបនៃរោងចក្រធំៗ)
- ក្រុមហ៊ុនកម្មន្តសាលធំៗបានអនុវត្តសវនកម្មលើការប្រើប្រាស់ទឹក និងបានបង្កើតផែនការគ្រប់គ្រងការប្រើប្រាស់ទឹក (ចំនួនសវនកម្ម និងផែនការគ្រប់គ្រងធៀបនឹងចំនួនសរុបនៃរោងចក្រធំៗ)

### ឆ. គោលបំណងនៅក្នុងវិស័យ "គ្រប់គ្រងសំណល់រឹង"

- ពង្រីកសេវាប្រមូល និងគ្រប់គ្រងសំណល់រឹងប្រកបដោយគុណភាព (ចំនួនខណ្ឌដែលត្រូវបានគ្របដណ្តប់)
- កាត់បន្ថយសំណល់សរីរាង្គដែលយកទៅចោលនៅកន្លែងចាក់សំរាម ឬកន្លែងដុតសំរាម (ភាគរយនៃសំណល់សរីរាង្គសរុប)
- ញែកសំណល់រឹងដើម្បីអាចធ្វើការកែច្នៃឡើងវិញនៅតាមផ្ទះប្រជាពលរដ្ឋ តាមទីផ្សារ និងតាមសហគ្រាសពាណិជ្ជកម្ម (ភាគរយនៃសំណល់ដែលត្រូវបានញែកធៀបនឹងចំនួនបរិមាណសរុប)
- អនុវត្តគោលការណ៍ 4R រួមមាន៖ កាត់បន្ថយ (reduce) ប្រើប្រាស់ឡើងវិញ (reuse) ជួសជុល (repair) កែច្នៃឡើងវិញ (recycle) (ភាគរយនៃការកាត់បន្ថយបរិមាណសំណល់ដែលត្រូវបានប្រមូល)

### ជ. គោលបំណងនៅក្នុងវិស័យ "ទីធ្លាសាធារណៈ និងបេតិកភណ្ឌវប្បធម៌"

- បង្កើនវិសាលភាពគម្របបៃតងទីក្រុង (ចំនួនដើមឈើក្នុងស្រុកដែលត្រូវបានដាំថ្មី)
- បង្កើនទីធ្លាសាធារណៈបៃតងនៅក្នុងទីក្រុង (ចំនួនផ្ទៃដីគិតជាហិកតាពីទិន្នន័យ មូលដ្ឋានបច្ចុប្បន្ន ៧០ ហាត)
- បង្កើតផែនការយុទ្ធសាស្ត្រដើម្បីអភិរក្សបេតិកភណ្ឌវប្បធម៌ទីក្រុង (ចំនួនអគារប្រវត្តិសាស្ត្រដែលត្រូវបានធ្វើបញ្ជីសារពើភ័ណ្ឌ និងការពារ)
- កំណើនភ្ញៀវទេសចរជាលទ្ធផលនៃការកែលម្អការគ្រប់គ្រងបេតិកភណ្ឌវប្បធម៌ (ចំនួនសំបុត្រដែលត្រូវបានលក់នៅតាមតំបន់រមណីយដ្ឋានក្នុងទីក្រុងសំខាន់)

# ៤. ការវិភាគយុទ្ធសាស្ត្រ

## ៤.១ ផែនការមេរាជធានីភ្នំពេញស្ដីពីការប្រើប្រាស់ដីធ្លី ឆ្នាំ២០៣៥

នៅខែធ្នូ ឆ្នាំ២០១៥ គណៈរដ្ឋមន្ត្រីបានអនុម័តផែនការមេថ្មីសម្រាប់ការគ្រប់គ្រងការអភិវឌ្ឍទីក្រុងនៅរាជធានីភ្នំពេញសម្រាប់រយៈពេល ២០ឆ្នាំបន្ទាប់។ ផែនការមេរាជធានីភ្នំពេញស្ដីពីការប្រើប្រាស់ដីធ្លី ឆ្នាំ២០៣៥ មានគោលដៅដោះស្រាយបញ្ហាកំណើនប្រជាជន និងការរីកដុះដាលយ៉ាងរហ័សជាបន្តបន្ទាប់នៃវិស័យសំណង់ ព្រោះប្រជាជនក្នុងរាជធានីបានកើនឡើងច្រើនជាងមួយភាគបី រហូតដល់ប្រមាណ ៣ លាននាក់នៅឆ្នាំ២០២០។ យោងតាមផែនការចក្ខុវិស័យដែលមានបានកំណត់របស់រាជធានីភ្នំពេញនៅឆ្នាំ២០៣៥ គឺ

" ក្លាយជាមជ្ឈមណ្ឌលមួយដែលមានការប្រកួតប្រជែង
ផ្នែកនយោបាយ សេដ្ឋកិច្ច ជំនួញ និងវប្បធម៌ នៃប្រទេសកម្ពុជា
ដែលមានការអភិវឌ្ឍប្រកប ដោយចីរភាព និងសមធម៌ "

ផែនការមេស្ដីពីការប្រើប្រាស់ដីធ្លីឆ្នាំ២០៣៥ សង្កត់ធ្ងន់លើគោលដៅធំៗចំនួនបីដើម្បីសម្រេចឱ្យបាននូវចក្ខុវិស័យដែលបានចែង៖

១. ដាក់ចេញសេចក្ដីណែនាំស្ដីពីការប្រើប្រាស់ដីធ្លី ដើម្បីធានាបាននូវសក្ដានុពល ប្រសិទ្ធភាព និរន្តរភាព និងសមធម៌ ដែលនឹងរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម សន្តិសុខស្បៀង និងបរិស្ថានស្អាតនៃប្រទេសកម្ពុជា

២. ដាក់ចេញសេចក្ដីណែនាំស្ដីពីការអភិវឌ្ឍនៅរាជធានីភ្នំពេញ ដោយថ្លឹងថ្លែងជាមួយការអភិវឌ្ឍនៃទីក្រុងតូចៗ និងទីរួមខេត្តផ្សេងទៀត

៣. ផ្ដល់អំណាចដល់អត្តសញ្ញាណរបស់ទីក្រុង និងអភិវឌ្ឍន៍ភាពប្រកួតប្រជែងជាមួយទីក្រុងផ្សេងទៀតនៅក្នុងតំបន់ ដែលនឹងផ្ដល់ឱ្យរាជធានីភ្នំពេញនូវលទ្ធភាពទទួលបានបច្ចេកទេស និងហិរញ្ញវត្ថុបន្ថែមទៀត។

ផែនការមេស្ដីពីការប្រើប្រាស់ដីធ្លីឆ្នាំ២០៣៥ ក៏ស្នើឡើងផងដែរនូវយុទ្ធសាស្ត្រចម្បងចំនួន៥សម្រាប់ការអភិវឌ្ឍ ការកែលម្អ និងការពង្រីករាជធានីភ្នំពេញ ដើម្បីធ្វើយ៉ាងណាឱ្យរាជធានីភ្នំពេញអាចឆ្លើយតបនឹងតម្រូវការរបស់ប្រជាជនទីក្រុងដែលកំពុងកើនឡើង និងបញ្ហាប្រឈមនានា៖

- **យុទ្ធសាស្ត្រទី១៖** រាជធានីភ្នំពេញត្រូវក្លាយជាមជ្ឈមណ្ឌលស្នូលសម្រាប់ការអភិវឌ្ឍ
- **យុទ្ធសាស្ត្រទី២៖** រៀបចំរាជធានីភ្នំពេញឱ្យក្លាយជាទីក្រុងដែលមានស្តង់ដារអន្តរជាតិ
- **យុទ្ធសាស្ត្រទី៣៖** បង្កើតធនបម្រុងសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តមេចាំបាច់
- **យុទ្ធសាស្ត្រទី៤៖** រៀបចំការអភិវឌ្ឍនគរូបនីយកម្មក្នុងកម្រិតទីក្រុងធំ (ស៊ីវិល័យ)
- **យុទ្ធសាស្ត្រទី៥៖** ការបង្កើតតំបន់ពិសេសសម្រាប់បិតិកភណ្ឌវប្បធម៌ និងទេសភាពទីក្រុង

តារាងទី១៖ សកម្មភាពជាអាទិភាពនៅក្នុងផែនការមេរាជធានីភ្នំពេញស្ដីពីការប្រើប្រាស់ដីធ្លី ឆ្នាំ២០៣៥

| | |
|---|---|
| **ផែនការសកម្មភាពទី១៖ ការផ្សព្វផ្សាយផែនការមេស្ដីពីការប្រើប្រាស់ដីធ្លី ឆ្នាំ២០៣៥** | • រៀបចំសិក្ខាសាលាដើម្បីផ្សព្វផ្សាយផែនការមេដល់ក្រុមការងារបច្ចេកទេសអ្នកវិនិយោគ និងប្រជាជនកម្ពុជាទាំងមូល<br>• ចែកចាយផែនការមេដល់សាធារណជនតាមរយៈគេហទំព័រអេឡិចត្រូនិចរបស់រដ្ឋបាលរាជធានីភ្នំពេញ |

| | |
|---|---|
| **ផែនការសកម្មភាពទី២៖ គម្រោងដែលជាសក្តានុពលត្រូវការចាំបាច់នូវការអនុម័តបន្ទាន់** | • ដាក់ចេញបទបញ្ញា និងការបែងចែកតំបន់ ការបម្រុងទុកដីសម្រាប់ការពង្រីកផ្លូវ ផ្លូវដែក និងប្រព័ន្ធលូទឹកកខ្វក់ទីក្រុង<br>• បង្កើតការបែងចែកតំបន់សម្រាប់ស្ថានីយផ្លូវដែក ជាពិសេសសម្រាប់ទំនិញ និងការបែងចែកតំបន់សម្រាប់កំពង់ផែស្ងួតធំនៅតំបន់សំរោងពោធិ៍សែនជ័យ<br>• អនុម័តគម្រោងផ្លូវដែកដើម្បីតភ្ជាប់ពីរាជធានីភ្នំពេញទៅកាន់ក្រុងហូជីមិញ<br>• បង្កើនទំហំផ្លូវយន្តហោះរត់នៃអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ<br>• កសាងទំនប់ និងច្រាំងបេតុងទន្លេបាសាក់<br>• ធ្វើឱ្យមានស្តង់ដារដល់អគារនៅក្នុងតំបន់មួយចំនួនដូចជា ច្បារអំពៅ បឹងក្រពើ បឹងពោងពាយ និងតំបន់ខាងមុខទន្លេបាសាក់ និងបឹងកក់<br>• កំណត់ទីតាំងថ្មីសម្រាប់ការចាក់សំរាម កែលម្អកន្លែងចាក់សំរាមបច្ចុប្បន្ននៅតំបន់ដង្កោ ដោយធ្វើការវិនិយោគទៅលើរោងចក្រកែច្នៃសំរាម និងបង្កើតសួនច្បារតាមបណ្តោយ ទីកន្លែងចាក់សំរាមនៅតំបន់មានជ័យ<br>• កំណត់តំបន់អេកូឡូស៊ីនៅព្រៃកញ្ចៅ<br>• លើកកម្ពស់ការអភិរក្ស និងការកែលម្អមជ្ឈមណ្ឌលប្រវត្តិសាស្ត្រ |
| **ផែនការសកម្មភាពទី៣៖ បទប្បញ្ញត្តិនគរូបនីយកម្ម** | • បង្កើតផែនទី និងការបែងចែកតំបន់នៃការប្រើប្រាស់ដីធ្លីនៅរាជធានីភ្នំពេញ (Zoning)<br>• ប្លង់អភិវឌ្ឍន៍ទៅតំបន់ភាគខាងជើង និងភាគខាងលិច<br>• រៀបចំអាងប្រព្រឹត្តកម្មទឹកកខ្វក់នៅបឹងជើងឯក<br>• បង្កើតការគូរផែនទីនៃការកែលម្អតំបន់សាធារណៈ (បឹង ព្រៃក ថ្នល់ ផ្លូវដែក ព្រលានយន្តហោះ កំពង់ផែ និងតំបន់បៃតង)<br>• បង្កើតផែនទីតំបន់អាទិភាពសម្រាប់ការអភិវឌ្ឍ<br>• ធ្វើឱ្យមានស្តង់ដារចំពោះកម្ពស់អគារ និងសេវាកិច្ចនៃកម្ពស់ហោះហើររបស់យន្តហោះ<br>• បង្កើតផែនទីអគារប្រវត្តិសាស្ត្រ និងបិតិកភណ្ឌនៅរាជធានីភ្នំពេញ<br>• បង្កើតផែនទី និងប្លង់មេនៃតំបន់ទេសភាព ការថែរក្សាដើមឈើ និងប្លង់តំបន់ទស្សនាទេសភាពដ៏ធំមួយដែលមានបរិក្ខាសាធារណៈជាតិនៅខាងចុងតំបន់ជ្រោយចង្វារ។ |
| **ផែនការសកម្មភាពទី៤៖ បន្តគម្រោងអភិវឌ្ឍ និងការវិនិយោគសាធារណៈ** | • ការអភិវឌ្ឍបន្ត និងកសាងទីក្រុងរណប ដូចជា កោះពេជ្រ ជ្រោយចង្វារ ខាំកូ (Camko)<br>• បន្តការអភិវឌ្ឍទីក្រុងរណបអូឡាំពិចនៅខាងជើងរាជធានីភ្នំពេញ<br>• បន្តការអភិវឌ្ឍតំបន់បឹងកក់ និងផ្លូវថ្នល់នៅក្នុងតំបន់នោះ<br>• បន្តការអភិវឌ្ឍកំពង់ផែស្ងួត និងស្ថានីយអាស៊ីនៅតំបន់សំរោងក្នុងខណ្ឌពោធិ៍សែនជ័យ<br>• បន្តការអភិវឌ្ឍផ្លូវក្រវ៉ាត់នៅក្នុងទីក្រុង (តភ្ជាប់ពីឫស្សីកែវទៅសែនសុខ និងបន្តទៅពោធិ៍សែនជ័យ)<br>• កសាងផ្លូវតាមបណ្តោយផ្លូវជាតិ (ផ្លូវជាតិលេខ១, ២, ៣, ៤, ៥) ដើម្បីកាត់បន្ថយការកកស្ទះចរាចរណ៍ច្រកចូលទីក្រុង<br>• កសាងផ្លូវអាកាសនៅរង្វង់មូលធំៗ<br>• កសាងផ្លូវនៅតំបន់ជុំវិញទីក្រុង<br>• កសាងអាងប្រព្រឹត្តកម្មទឹកកខ្វក់នៅតំបន់ជើងឯក និងដំឡើងប្រព័ន្ធលូទឹកកខ្វក់នៅរាជធានីភ្នំពេញ<br>• ពង្រឹងការអនុវត្តសារាចរលេខ ០៣ ស.រ ស្តីពីការដោះស្រាយសំណង់បណ្តោះអាសន្ននៅលើដីសាធារណៈ ដែលត្រូវបានប្រើប្រាស់ដោយខុសច្បាប់ នៅតំបន់កណ្តាលទីក្រុង និងតំបន់ទីក្រុង<br>• កែលម្អលទ្ធភាពផ្នែកសេដ្ឋកិច្ចនៃវិស័យសក្តានុពល ដូចជា សំណង់ វាយនភណ្ឌ ការនេសាទ ការដាំដុះ ការដឹកជញ្ជូន និងទេសចរណ៍ ឧស្សាហកម្មម្ហូបអាហារ សេវាកម្ម អេឡិចត្រូនិក ការវេចខ្ចប់ ការដំឡើងគ្រឿងមេកានិក និងការបណ្តុះបណ្តាលវិជ្ជាជីវៈ។ |

## ៤.២ ផែនការមេរៀបចំប្រព័ន្ធដឹកជញ្ជូនទីក្រុងនៅរាជធានីភ្នំពេញ ឆ្នាំ២០៣៥

សាលារាជធានីភ្នំពេញ ដោយមានជំនួយពីទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) ក៏បានបង្កើតផែនការមេរៀបចំប្រព័ន្ធដឹកជញ្ជូនទីក្រុងនៅរាជធានីភ្នំពេញ ឆ្នាំ២០៣៥ ផងដែរ ដើម្បីដោះស្រាយបញ្ហាចរាចរណ៍ពេលបច្ចុប្បន្ន និងគាំទ្រដល់ចក្ខុវិស័យទីក្រុងឆ្នាំ២០៣៥ ដែលកំណត់នៅក្នុងផែនការមេស្តីពីការប្រើប្រាស់ដីធ្លីឆ្នាំ២០៣៥។ ផែនការមេរៀបចំប្រព័ន្ធដឹកជញ្ជូនទីក្រុងមានគោលដៅការពារ និងរៀបចំវិស័យដឹកជញ្ជូនតំបន់ទីក្រុងដែលអំណោយផលដល់ប្រជាជន បរិស្ថាន និងផ្តល់ភាពរស់រវើកដល់សកម្មភាពទីក្រុងនៅរាជធានីភ្នំពេញ។

បេសកកម្មនៃផែនការមេរៀបចំប្រព័ន្ធដឹកជញ្ជូនទីក្រុង ឆ្នាំ២០៣៥ មានពីរផ្នែក៖

១. ផ្លាស់ប្តូរពីប្រព័ន្ធដឹកជញ្ជូនក្នុងទីក្រុងដែលមានការប្រើប្រាស់មធ្យោបាយដឹកជញ្ជូនឯកជនច្រើនលើសលុប ទៅជាប្រព័ន្ធដឹកជញ្ជូនសាធារណៈ និងឯកជនដែលមានតុល្យភាពគ្នា តាមរយៈការគ្រប់គ្រងជាប្រព័ន្ធទៅលើបណ្តាញផ្លូវថ្នល់ មធ្យោបាយដឹកជញ្ជូនសាធារណៈ និងការគ្រប់គ្រងចរាចរណ៍ដើម្បីកែលម្អការធ្វើដំណើររបស់ពលរដ្ឋ និង

២. សម្រេចសក្តានុពលអភិវឌ្ឍន៍របស់រាជធានីភ្នំពេញ។

ដើម្បីសម្រេចបេសកកម្មនេះ ផែនការមេមធ្យោបាយដឹកជញ្ជូនទីក្រុងឆ្នាំ២០៣៥ ស្នើឡើងនូវយុទ្ធសាស្រ្តចំនួនប្រាំ៖

- **យុទ្ធសាស្រ្តទី១៖** ការបង្កើតប្រព័ន្ធដឹកជញ្ជូនទីក្រុងដែលអំណោយផលដល់ប្រជាជន និងបរិស្ថាន ដែលនឹងធ្វើអោយប្រជាពលរដ្ឋមានលទ្ធភាពធ្វើដំណើរស្រួល
- **យុទ្ធសាស្រ្តទី២៖** ការបង្កើតក្របខណ្ឌរូបវន្តទីក្រុង និងការបង្កើតការតភ្ជាប់រលូនរវាងទីក្រុងធំៗនៅក្នុងអនុតំបន់មេគង្គ
- **យុទ្ធសាស្រ្តទី៣៖** ការប្រើប្រាស់អោយបានជាអតិបរមានូវទីធ្លាដែលមានស្រាប់សម្រាប់អភិវឌ្ឍន៍វិស័យដឹកជញ្ជូនបច្ចុប្បន្ន ក្នុងនោះ រួមមានតំបន់ក្រោមដី និងខ្ពង់រាបដែលមាននៅកណ្តាលទីក្រុង
- **យុទ្ធសាស្រ្តទី៤៖** ប្រសិទ្ធភាពនៃលំហូរចរាចរណ៍ដឹកជញ្ជូនទំនិញ
- **យុទ្ធសាស្រ្តទី៥៖** ការពិចារណាទៅលើបរិស្ថាន/សង្គម និងការរៀបចំស្ថាប័នគ្រប់គ្រងវិស័យដឹកជញ្ជូន គឺជាទស្សនទានមូលដ្ឋាននៃការធ្វើផែនការមេនេះ។

## តារាងទី២៖ ផែនការមេមធ្យោបាយដឹកជញ្ជូនទីក្រុងឆ្នាំ២០៣៥ ដែលស្នើឡើង

| | |
|---|---|
| (១) ប្រព័ន្ធដឹកជញ្ជូនសាធារណៈ | (១) ការកើនឡើងនូវមធ្យោបាយដឹកជញ្ជូនដើម្បីកែលម្អការធ្វើដំណើរនៅក្នុងទីក្រុង |
| | (២) ការនាំមកនូវប្រព័ន្ធមធ្យោបាយដឹកជញ្ជូនសាធារណៈ តាមផ្លូវទឹក មានដូចជាទូក កាណូតដឹកអ្នកដំណើរ |
| | (៣) សមាហរណកម្មទូលំទូលាយនៃមធ្យោបាយដឹកជញ្ជូនសាធារណៈ និងប្រតិវិធានការពាក់ព័ន្ធ ដូចជាការផ្ទេរលូនរវាងមធ្យោបាយដឹកជញ្ជូនដោយអភិវឌ្ឍតំបន់ផ្ទេរអ្នកដំណើរ និងការរៀបចំរចនាសម្ព័ន្ធឡើងវិញនូវការធ្វើដំណើររួមគ្នា ជាផ្លូវតភ្ជាប់នៃមធ្យោបាយដឹកជញ្ជូនសាធារណៈ |
| | (៤) សមាហរណកម្មជាមួយផែនការប្រើប្រាស់ដីធ្លី |
| | (៥) ការចងភ្ជាប់ជាមួយការអភិវឌ្ឍវិស័យទេសចរណ៍ |
| (២) ប្រព័ន្ធផ្លូវថ្នល់ (បណ្ដាញផ្លូវថ្នល់) | (១) ប្រព័ន្ធបណ្ដាញផ្លូវថ្នល់ក្រវ៉ាត់ក្រុង |
| | (២) ផែនការអភិវឌ្ឍន៍ផ្លូវថ្នល់ដែលពង្រឹងរបៀងកើត-លិច (ផ្លូវសម្រាប់រថយន្តមានទូអ្នកដំណើរកើត-លិចភាគខាងជើង និងភាគខាងត្បូង) និងជើង-ត្បូង (មហាវិថីហាណូយ និងមហាវិថីសម្ដេចហ៊ុន សែន)។ |
| (៣) វិធានការគ្រប់គ្រងចរាចរណ៍ - ដើម្បីគាំទ្រដល់ប្រព័ន្ធផ្លូវថ្នល់ និងដឹកជញ្ជូនសាធារណៈ | (១) វិធានការផ្សេងៗសម្រាប់ការបង្កើនភាពទាក់ទាញ និងផាសុខភាពនៃប្រព័ន្ធដឹកជញ្ជូនសាធារណៈ ដូចជាតំបន់ផ្ទេរអ្នកដំណើរងាយស្រួល (ស្ថានីយអ្នកដំណើរ ស្ថានីយ និងចំណតរថយន្តក្រុង) |
| | (២) វិធានការគ្រប់គ្រងចរាចរណ៍ផ្សេងៗ ដូចជាការកែលម្អផ្លូវបំបែក ការកែលម្អសញ្ញាចរាចរណ៍ និងការនាំមកនូវប្រព័ន្ធផ្លូវឯកទិស។ |
| | (៣) គោលនយោបាយ និងវិធានការស្ដីពីចំណត |
| | (៤) ការអភិវឌ្ឍបរិស្ថានសម្រាប់ថ្មើរជើង |
| | (៥) ការរៀបចំរចនាសម្ព័ន្ធឡើងវិញនូវការធ្វើដំណើររួមគ្នា ដូចជា ម៉ូតូឌុប ម៉ូតូរ៉ឺម៉កទំនើប (ម៉ូតូកង់បី) និងស៊ីក្លូ។ |
| | (៦) ការនាំមកនូវការគ្រប់គ្រងតម្រូវការចរាចរណ៍ ដែលរួមបញ្ចូលទាំងការគ្រប់គ្រងការធ្វើដំណើរ ដូចជាការគ្រប់គ្រងតម្រូវការចរាចរណ៍នៃប្រព័ន្ធឧទ្យាន និងមធ្យោបាយធ្វើដំណើរ។ |
| (៤) ការដឹកជញ្ជូនទំនិញ | (១) ប្រព័ន្ធដឹកជញ្ជូនទំនិញឆ្លងកាត់តំបន់ (អន្តរតំបន់) |
| | (២) ប្រព័ន្ធការងារដឹកជញ្ជូនទំនិញ (Logistics) ក្នុងទីប្រជុំជន |
| | (៣) ប្រព័ន្ធដឹកជញ្ជូនទំនិញនៅក្នុងតំបន់កណ្ដាលទីក្រុង |

ផែនការមេទាំងពីរត្រូវបានប្រើប្រាស់ជាមូលដ្ឋានសម្រាប់ការរៀបចំបង្កើតផែនការអភិវឌ្ឍន៍ទីក្រុងនិរន្តរភាពសម្រាប់រាជធានីភ្នំពេញ ដែលមានគោលដៅគាំទ្រដល់ផែនការមេ និងដើម្បីលើកកម្ពស់ការអភិវឌ្ឍនិរន្តរភាពនៅរាជធានីភ្នំពេញ ដែលនឹងរួមចំណែកដល់ការសម្រេចឱ្យបាននូវចក្ខុវិស័យដែលបានគូសបញ្ជាក់នៅក្នុងផែនការមេ។

## ៤.៣ ក្របខណ្ឌគោលនយោបាយសម្រាប់ការអភិវឌ្ឍទីក្រុងនិរន្តរភាពនៅប្រទេសកម្ពុជា

គោលនយោបាយស្តីពីការអភិវឌ្ឍបៃតងរបស់ប្រទេសកម្ពុជា ត្រូវបានអនុម័តដោយគណៈរដ្ឋមន្ត្រីនៅខែមីនា ឆ្នាំ២០១៣។ គោលនយោបាយនេះមានទស្សនៈវិស័យ *"រក្សាឱ្យបាននូវតុល្យភាពនៃការអភិវឌ្ឍសេដ្ឋកិច្ចជាមួយនឹងបរិស្ថាន សង្គម វប្បធម៌ និងការប្រើប្រាស់ប្រកបដោយនិរន្តរភាពនូវធនធានជាតិតាមរយៈសមាហរណកម្ម ការបន្សុំ និងការសម្របសម្រួល ព្រមទាំងសុខដុមនីយកម្មរវាងគោលការណ៍អភិវឌ្ឍន៍បៃតង និងគោលនយោបាយជាតិ"*។[2] គោលនយោបាយនេះមានគោលដៅធ្វើឱ្យប្រសើរឡើងដល់សុខុមាលភាព និងមុខរបរចិញ្ចឹមជីវិតរបស់ប្រជាជនទាំងអស់ដោយធ្វើឱ្យមានសុខដុមនីយកម្មជាមួយប្រព័ន្ធអេកូឡូស៊ីតាមរយៈការអភិវឌ្ឍបៃតង ការផ្តែកលើសេដ្ឋកិច្ចបៃតង និងខៀវ កិច្ចការការពារបរិស្ថាន ប្រព័ន្ធសុវត្ថិភាពសង្គម និងរក្សាអត្តសញ្ញាណវប្បធម៌ជាតិ។ ផែនការយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍបៃតងឆ្នាំ២០១៣-២០៣០ ក៏ត្រូវបានអនុម័តដោយគណៈរដ្ឋមន្ត្រីនៅខែមីនា ឆ្នាំ២០១៣ ផងដែរ។ ផែនការនេះផ្តោតសំខាន់លើសេចក្តីណែនាំយុទ្ធសាស្ត្រពាក់ព័ន្ធចំនួនប្រាំបួន[3] ៖

- ការវិនិយោគបៃតង និងការបង្កើតការងារបៃតង
- ការគ្រប់គ្រងសេដ្ឋកិច្ចបៃតងដែលមានតុល្យភាពជាមួយបរិស្ថាន
- ការអភិវឌ្ឍសេដ្ឋកិច្ចខៀវប្រកបដោយនិរន្តរភាព
- ការគ្រប់គ្រងបរិស្ថានបៃតង និងធនធានធម្មជាតិ
- ការអភិវឌ្ឍធនធានមនុស្ស និងការអប់រំបៃតង
- ការគ្រប់គ្រងបច្ចេកវិទ្យាបៃតងប្រកបដោយប្រសិទ្ធភាព
- ការលើកកម្ពស់ប្រព័ន្ធសុវត្ថិភាពសង្គមបៃតង
- ការរក្សា និងការការពារបេតិកភណ្ឌវប្បធម៌បៃតង និងអត្តសញ្ញាណជាតិ
- អភិបាលកិច្ចល្អនៃការអភិវឌ្ឍបៃតង

"ការអភិវឌ្ឍទីក្រុងនិរន្តរភាព" ត្រូវបានកំណត់ថាជាវិស័យអាទិភាពមួយសម្រាប់ការរៀបចំផែនការ និងអនុវត្តការអភិវឌ្ឍបៃតងដោយរាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព (ក.ជ.អ.ច.)។ ការអភិវឌ្ឍទីក្រុងនិរន្តរភាពមានគោលដៅផ្តល់វិធីសាស្ត្រពេញលេញ និងគ្រប់ជ្រុងជ្រោយនៃការរៀបចំក្រុង ការផ្តល់អាទិភាពដល់ការវិនិយោគ និងការអភិវឌ្ឍសេដ្ឋកិច្ចក្នុងបរិបទទីក្រុង ហើយក្នុងពេលដំណាលគ្នានោះដោះស្រាយការប្រែប្រួលអាកាសធាតុ អនុវត្តនូវប្រសិទ្ធភាព ធនធាននិរន្តរភាពបរិស្ថាន សមាហរណកម្មក្នុងសង្គម និងការកាត់បន្ថយភាពក្រីក្រ។

## ៤.៤ ការវាយតម្លៃជាមូលដ្ឋាននៃស្ថានភាព/បរិបទទីក្រុងនៅរាជធានីភ្នំពេញ

ភ្នំពេញ គឺជារាជធានី និងជាទីក្រុងធំជាងគេបំផុតនៃប្រទេសកម្ពុជា និងមានទីតាំងស្ថិតនៅលើច្រាំងទន្លេសាប និងទន្លេមេគង្គ។ ភ្នំពេញ គឺជារាជធានីជាតិតាំងពីសម័យបារាំងដាក់អាណានិគមលើប្រទេសកម្ពុជា និងបានរីកចម្រើនក្លាយជាមជ្ឈមណ្ឌលកណ្តាលនៃសកម្មភាពជាតិផ្នែកសេដ្ឋកិច្ច និងឧស្សាហកម្ម ព្រមទាំងជាមជ្ឈមណ្ឌលនយោបាយ បេតិកភណ្ឌវប្បធម៌ និងការទូត។

**ទីតាំងភូមិសាស្ត្រ៖** រាជធានីភ្នំពេញមានផ្ទៃក្រឡា ៦៧៨,៤៦ គីឡូម៉ែត្រការ៉េ និងត្រូវបានបែងចែកជាតំបន់រដ្ឋបាលចំនួន ១២ ហៅថាខណ្ឌ។ ខណ្ឌត្រូវបានបែងចែកបន្តជា ១០៥ សង្កាត់។

**អភិបាលកិច្ច៖** នាពេលបច្ចុប្បន្ន រាជធានីភ្នំពេញត្រូវបានគ្រប់គ្រងដោយគណៈអភិបាល ដែលក្នុងនោះរួមមានអភិបាលមួយរូប និងអភិបាលរងប្រាំមួយរូប។ គណៈអភិបាលទទួលខុសត្រូវផ្តល់សេវាសាធារណៈដល់ប្រជាពលរដ្ឋដើម្បីបំពេញតាមតម្រូវការរបស់ពួកគេ និងស្តារហេដ្ឋារចនាសម្ព័ន្ធគ្រប់ប្រភេទដើម្បីកែលម្អកម្រិតជីវភាពរបស់ប្រជាជននៅទីក្រុង[4] ។

[2] គោលនយោបាយជាតិស្តីពីការអភិវឌ្ឍបៃតង បោះពុម្ព ឆ្នាំ ២០១៣ ដោយក្រសួងបរិស្ថាននៃរាជរដ្ឋាភិបាលកម្ពុជា
[3] ផែនការយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍបៃតងឆ្នាំ ២០១៣-២០៣០ បោះពុម្ព ឆ្នាំ ២០១៣ ដោយក្រសួងបរិស្ថាននៃរាជរដ្ឋាភិបាលកម្ពុជា
[4] គេហទំព័ររបស់សាលារាជធានីភ្នំពេញ http://phnompenh.gov.kh/en/about-us/governor-message/

**ប្រជាជន៖** ប្រជាជនរាជធានីភ្នំពេញបានកើនឡើងច្រើនជាងបីដងគឺចាប់ពីប្រមាណ ០,៥៧ លាននាក់នៅឆ្នាំ១៩៩៨ ដល់ប្រមាណ ១,៥ លាននាក់នៅឆ្នាំ២០១៥។[5] ការពង្រីកទីក្រុង និងការបង្កើតខណ្ឌបន្ថែមចំនួនបី គឺដើម្បីសម្របតាមកំណើនចំនួនប្រជាជន។ នៅក្នុងព្រំដែនរដ្ឋបាលថ្មីនៃរាជធានីភ្នំពេញ ប្រជាជនត្រូវបានប៉ាន់ស្មានថាអាចមានចំនួនកើនឡើងដល់ ២,៨៦លាននាក់នៅឆ្នាំ២០៣៥ បើយោងតាមការព្យាករណ៍កំណើនប្រជាជននៅក្នុងការសិក្សារបស់ JICA សម្រាប់រៀបចំផែនការមេប្រព័ន្ធដឹកជញ្ជូន។[6]

**សេដ្ឋកិច្ច៖** ភាគច្រើននៃកំណើនសេដ្ឋកិច្ចប្រទេសកម្ពុជាប្រមូលផ្តុំនៅរាជធានីភ្នំពេញក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះ។ អត្រាកំណើនសេដ្ឋកិច្ចពីរខ្ទង់ក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ បានបង្កើតនូវការរីកដុះដាលសេដ្ឋកិច្ចយ៉ាងរហ័សនៅរាជធានីភ្នំពេញ ជាពិសេសការវិនិយោគនៅក្នុងវិស័យ សំណង់រួមទាំងសណ្ឋាគារ ភោជនីយដ្ឋាន ក្លឹបកំសាន្ត អគារស្នាក់នៅ និងអាគារពាណិជ្ជកម្មខ្ពស់ៗ។ អត្រាកំណើនខ្ពស់នៃវិស័យឧស្សាហកម្មផ្នែកកម្មន្តសាល ក្នុងនោះវិស័យកាត់ដេររួមចំណែក ៧៥% នៃទិន្នផលសរុបនៃវិស័យកម្មន្តសាលរបស់ជាតិនៅឆ្នាំ២០១០។[7] ទីក្រុងទទួលបានការវិនិយោគបរទេសប្រមាណជា ៧៥% ទៅលើវិស័យឧស្សាហកម្ម និងការមកដល់របស់ភ្ញៀវទេសចរណ៍ប្រមាណជាមួយលាននាក់នៅឆ្នាំ២០១៥។[8] ការរីកលូតលាស់នៅក្នុងវិស័យសេវាកម្មត្រូវបានជំរុញដោយកំណើនពាណិជ្ជកម្ម និងសេវាកម្មផ្សេងទៀត ភាគច្រើននៅរាជធានីភ្នំពេញដែលរួមបញ្ចូលជាមួយវិស័យហិរញ្ញវត្ថុ កើនឡើងយ៉ាងឆាប់រហ័ស (ក្នុងអត្រា១៩,៨% ក្នុងឆ្នាំ២០១៨)។[9]

**កម្រិតភាពក្រីក្រ៖** អត្រាភាពក្រីក្រនៅរាជធានីភ្នំពេញមានកម្រិតទាបជាងតំបន់ផ្សេងទៀតក្នុងប្រទេស។ គ្រួសារនីមួយៗនៅរាជធានីភ្នំពេញមានចំណូលកើនឡើងជិតពីរដងនៃកម្រិតជាមធ្យមថ្នាក់ជាតិ។ ទិន្នន័យដែលមានស្តីពីវិសមភាពនៃប្រាក់ចំណូលបង្ហាញនូវការធ្លាក់ចុះបន្តិចនៃកម្រិតវិសមភាពនៃប្រាក់ចំណូលនៅរាជធានីភ្នំពេញចន្លោះពីឆ្នាំ២០០៩ ដល់ឆ្នាំ២០១៤។ ប៉ុន្តែទោះបីជាមានការធ្លាក់ចុះវិសមភាពក៏ដោយ អត្រាភាពក្រីក្រនៅរាជធានីភ្នំពេញបានកើនឡើងក្នុងអំឡុងឆ្នាំ២០០៨-២០១២ ដែលឆ្លុះបញ្ចាំងនូវការកើនឡើងនៃតម្លៃទំនិញ និងសេវាប្រើប្រាស់ជាមូលដ្ឋាន។ គ្រួសារនៅរាជធានីភ្នំពេញក៏បានជួបប្រទះអត្រាកំណើនប្រាក់ចំណូលយឺតដែលមានអត្រាកំណើនមធ្យមប្រចាំឆ្នាំរវាងចន្លោះឆ្នាំ២០០៩ និងឆ្នាំ២០១៤ ប្រហែល៦,៨% និងកំណើនសរុបប្រហែល ៤១%។[10]

**បញ្ហាប្រឈមនៃការអភិវឌ្ឍទីក្រុង និងការប្រែប្រួលអាកាសធាតុ៖** ដោយសារការរីកលូតលាស់យ៉ាងឆាប់រហ័សនៃវិស័យនគរូបនីយកម្ម រាជធានីភ្នំពេញកំពុងប្រឈមមុខនឹងបញ្ហាជាច្រើន រួមមានការសាងសង់សំណង់អគារដោយមិនមានការត្រួតពិនិត្យស្តង់ដារត្រឹមត្រូវ ការកកស្ទះចរាចរណ៍ ការគ្រប់គ្រងសំណល់ ការបំពុល និងការជន់លិច។ បញ្ហាប្រឈមទាំងនេះអាចមានសភាពកាន់តែធ្ងន់ធ្ងរបន្ថែមទៀតដោយការគំរាមកំហែងពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។ ក្នុងចំណោមបណ្តាប្រទេសនៃទន្លេមេគង្គក្រោម ប្រទេសកម្ពុជារួមជាមួយនឹងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ត្រូវបានកំណត់ថាជាប្រទេសងាយរងគ្រោះបំផុតដោយសាររយៈកម្ពស់ទាបខ្លាំង និងនៅជិតមហាសមុទ្រ និងទន្លេមេគង្គ និងសមត្ថភាពនៅមានកម្រិតក្នុងការសម្របតាមហានិភ័យពីការប្រែប្រួលអាកាសធាតុ។[11] ទឹកជំនន់និងការប្រែប្រួលកម្រិតទឹកភ្លៀងក៏អាចមានផលប៉ះពាល់មិនល្អទៅលើបរិមាណ និងគុណភាពនៃការផ្គត់ផ្គង់ទឹកដល់ទីក្រុង និងបណ្តាលឱ្យមានផលអវិជ្ជមានដល់ប្រជាជនរាប់លាននាក់ផងដែរ។ ការគំរាមកំហែងផ្សេងៗទៀតរួមមានផលប៉ះពាល់នៃខ្យល់ព្យុះត្រូពិច ដែលបានកើនឡើងរួចហើយក្នុង រយៈពេលពីរបីទសវត្សរ៍ចុងក្រោយនេះ។ កម្រិតខ្យល់ព្យុះត្រូពិចត្រូវបានព្យាករថានឹងមានការកើនឡើងជាញឹកញាប់បន្តទៀត និងមានសន្ទុះ (អាំងតង់ស៊ីតេ) ខ្លាំងជាងមុន។ ការឡើងកម្ពស់ទឹកសមុទ្រ

[5] ព្រឹត្តិបត្រសាលារាជធានីភ្នំពេញលេខ៣៥ ខែកញ្ញា ឆ្នាំ២០១៧

[6] របាយការណ៍សិក្សារបស់ JICA ឆ្នាំ២០១៤ ស្តីពីការរៀបចំផែនការមេប្រព័ន្ធដឹកជញ្ជូនរាជធានីភ្នំពេញ

[7] របាយការណ៍របស់ធនាគារពិភពលោកស្តីពីបច្ចុប្បន្នភាពនៃការអភិវឌ្ឍសេដ្ឋកិច្ចប្រទេសកម្ពុជា ឆ្នាំ២ ០១៥(a) តាមរយៈគេហទំព័រ៖ http://documents.worldbank.org/curated/en/2015/04/24427602/cambodia-economic-update-maintaining-high-growth

[8] របាយការណ៍ស្ថិតិវិស័យទេសចរណ៍ ឆ្នាំ ២០១៥ របស់ក្រសួងទេសចរណ៍ តាមរយៈគេហ៍ទំព័រ http://www.tourismcambodia.org/images/mot/statistic_reports/tourism_statistics_2015.pdf

[9] របាយការណ៍របស់ធនាគាជាតិនៃកម្ពុជា ឆ្នាំ២០១៨

[10] ការគណនាអត្រាភាពក្រីក្ររបស់រាជរដ្ឋាភិបាលកម្ពុជារួមបញ្ចូលបន្ទាត់ក្រីក្រផ្នែកស្បៀង ដោយគិត 2.200 កាឡូរីក្នុងម្នាក់ក្នុងមួយថ្ងៃ និងធាតុផ្សំមិនមែនស្បៀងដែលត្រូវបានប៉ាន់ស្មានដាច់ដោយឡែកពីគ្នាសម្រាប់រាជធានីភ្នំពេញ ព្រមទាំងតំបន់ទីក្រុង និងជនបទផ្សេងទៀត។ ទទួលបានតាមរយៈរបាយការណ៍វិភាគពីភាពក្រីក្រនៅប្រទេសកម្ពុជាដោយ ADB ឆ្នាំ ២០១៤ ពីគេហទំព័រ http://www.adb.org/documents/cambodia-country-poverty-analysis-2014. ទិន្នន័យភាពក្រីក្ររាជធានីភ្នំពេញ មិនអាចរកបាននៅឆ្នាំបន្តបន្ទាប់។

[11] របាយការណ៍ស្តីពីភាពងាយរងគ្រោះនៃការប្រែប្រួលអាកាសធាតុនៅបណ្តាប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍ ដោយ Yusuf and Francisco ឆ្នាំ ២០០៩ https://www.idrc.ca/sites/default/files/sp/Documents%20EN/climate-change-vulnerability-mapping-sa.pdf

ក៏នឹងប៉ះពាល់ដល់ទឹកសាបរបស់រាជធានីភ្នំពេញផងដែរ ដោយបង្កើនការជន់លិចទឹកប្រៃនៅតំបន់ដែលមានរយៈកម្ពស់ទាប ហើយវារួមចំណែកធ្វើឱ្យសឹកច្រាំងសមុទ្រ។[12]

**បរិស្ថាន និងការបំពុលៈ** តាមរយៈទិន្នន័យតាមដានគុណភាពខ្យល់នក្នុងរយៈពេល ២៤ម៉ោង (real time air quality monitoring) នៅក្រសួងបរិស្ថានឃើញថាកម្រិតភាគល្អិតនិចល នៅក្នុងខ្យល់ជាមធ្យម ១០,២៤ ug/m$^{៣}$ ធៀបទៅនឹងកម្រិតស្តង់ដារ PM ២,៥ គឺ ៥០ ug/m$^{៣}$ ក្នុងរយៈពេល២៤ម៉ោងគិតចាប់ពីថ្ងៃទី ០៣ ដល់ ០៩ ខែមិថុនា ឆ្នាំ២០១៨ នេះ។[13] បើកម្រិតស្តង់ដានេះតំណាងឱ្យការវាស់គុណភាពខ្យល់នៅទូទាំងរាជធានី នេះបញ្ជាក់ថាគុណភាពខ្យល់នៅរាជធានីភ្នំពេញ មិនមានផលប៉ះពាល់អាក្រក់ដល់ការដកដង្ហើម និងសុខភាពរបស់ប្រជាពលរដ្ឋក្នុងរាជធានីទេ។ ទាក់ទងទៅនឹងបញ្ហាទឹកកខ្វក់ រាជធានីភ្នំពេញនៅមានកន្លែងមួយចំនួននៃប្រព័ន្ធទន្លេ និងបឹង នៅមានការបំពុលខ្លាំងដោយសារមិនមាននូវប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់នៅឡើយ។ ទឹកសំណល់ចេញពីផ្ទះ និងអគារអាជីវកម្មកំពុងត្រូវបានបញ្ចេញចោលដោយមិនមានការធ្វើប្រព្រឹត្តកម្ម ហើយចុងក្រោយទឹកសំណល់ទឹកទាំងនោះនឹងត្រូវបញ្ចេញទៅក្នុងទន្លេ ឬប្រឡាយសាធារណៈ។

## ៤.៥ ការវិភាគវិស័យទីក្រុងសំខាន់ៗសម្រាប់ការអភិវឌ្ឍនិរន្តរភាពនៅក្នុងទីក្រុង

យោងតាមវិធីសាស្ត្ររៀបចំផែនការយុទ្ធសាស្ត្រទីក្រុងបៃតងរបស់ប្រទេសកម្ពុជា មានវិស័យគន្លឹះចំនួនប្រាំបីដែលមានសារៈសំខាន់នៃការអភិវឌ្ឍនិរន្តរភាពនៅក្នុងទីក្រុង (រូបភាពទី២)[14] ។ ការប្រើប្រាស់វិធីសាស្ត្រនេះ គឺដើម្បីកំណត់ពីបញ្ហាប្រឈម និងឱកាសនៃការអភិវឌ្ឍនិរន្តរភាពនៅក្នុងបរិបទ នៃការប្រែប្រួលអាកាសធាតុ ប្រសិទ្ធភាពធនធាន និរន្តរភាពបរិស្ថាន កំណើនសេដ្ឋកិច្ច ការកាត់បន្ថយភាពក្រីក្រ និងបរិយាប័ន្នសង្គម។ ជាលទ្ធផលនៃការវិភាគ និងវាយតម្លៃបានឱ្យឃើញថា រាជធានីភ្នំពេញកំពុងមានបញ្ហាប្រឈមនៅក្នុងវិស័យទាំងប្រាំបីដូចខាងក្រោមៈ

- ការកើនឡើងនូវការចំណាយលើហេដ្ឋារចនាសម្ព័ន្ធ និងកង្វះលទ្ធភាពទទួលបានសេវាជា
- មូលដ្ឋានជាពិសេសសម្រាប់គ្រួសារដែលមានប្រាក់ចំណូលទាប
- ការរីកលូតលាស់នៃវិស័យនគរូបនីយកម្មឆាប់រហ័ស ប៉ុន្តែការរៀបចំផែនការនៅមានកម្រិត
- ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនមានកម្រិត និងការកើនឡើងនូវការកកស្ទះចរាចរណ៍
- ការចំណាយខ្ពស់លើថាមពល ចំណែកឯការប្រើប្រាស់ថាមពលកកើតឡើងវិញ និង បច្ចេកវិទ្យាបៃតងដែលមានប្រសិទ្ធភាពថាមពល នៅមានកម្រិត
- ការកើនឡើងសម្ពាធកាន់តែខ្លាំងទៅលើប្រព័ន្ធអេកូឡូស៊ីក្នុងទីក្រុង រួមបញ្ចូលទាំងលំហបៃតង បឹងធម្មជាតិ និងតំបន់ដីសើម
- ការកើនឡើងនូវភាពងាយរងគ្រោះទីក្រុងពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ក្នុងនោះរួមបញ្ចូលទាំងបញ្ហាទឹកជំនន់ និងគ្រោះរាំងស្ងួតធ្ងន់ធ្ងរ
- ការកើនឡើងនូវអត្រាភាពក្រីក្រនៅក្នុងទីក្រុង បើទោះជាមានការថយចុះនូវអត្រាភាពក្រីក្រទូទាំងប្រទេសក៏ដោយ
- លទ្ធភាពទទួលបានប្រកបដោយសមធម៌នូវលំនៅដ្ឋានដែលមានភាពធន់នឹងការប្រែប្រួលអាកាសធាតុ គឺនៅមានកម្រិតជាពិសេសសម្រាប់គ្រួសារក្រីក្រ
- កំណើនកម្រិតសារធាតុបំពុលបរិយាកាសពីឧស្សាហូបនីយកម្ម ជាពិសេសពីវិស័យកម្មន្តសាល
- បញ្ហាប្រឈមរបស់ទីក្រុងក្នុងការការពារសម្បត្តិបេតិកភណ្ឌវប្បធម៌ដែលបម្រើដល់វិស័យ ទេសចរណ៍ មានដូចជា អាគារបេតិកភណ្ឌជាដើម។

[12] ប្រភពព័ត៌មានដូចក្នុងចំណុចទី ១១

[13] គម្រោងស្ដីពីការតាមដានគុណភាពខ្យល់នៅកម្ពុជា ឆ្នាំ ២០១៦ តាមរយៈ http://aqicn.org/country/cambodia និង តាមរយៈសេចក្ដីជូនដំណឹងអំពីស្ថានភាពគុណភាពខ្យល់នៅក្នុងរាជធានីភ្នំពេញ http://www.moe.gov.kh/index/6143

[14] វិធីសាស្ត្ររៀបចំផែនការយុទ្ធសាស្ត្រទីក្រុងបៃតង ត្រូវបានអនុម័តផ្លូវការនៅឆ្នាំ២០១៦ ដោយក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព (ក.ជ.អ.ច.)

រូបភាពទី២៖ វិស័យអាទិភាពទាំង ៨ សម្រាប់ការអភិវឌ្ឍន៍បៃតងក្នុងទីក្រុង




## ៤.៥.១ ការរៀបចំផែនការអភិវឌ្ឍន៍ទីក្រុង

នៅខែធ្នូ ឆ្នាំ២០១៥ គណៈរដ្ឋមន្ត្រីបានអនុម័តលើផែនការមេ (ប្លង់គោល) ប្រើប្រាស់ដីរាជធានីភ្នំពេញ ឆ្នាំ២០៣៥ ដែលបានកែសម្រួល ហើយមានចក្ខុវិស័យ "ប្រែក្លាយរាជធានីភ្នំពេញឱ្យក្លាយជាបេះដូងនៃប្រទេសកម្ពុជា ដែលស្ថិតនៅចំណុចប្រសព្វនៃទន្លេចំនួនបួន ជាមជ្ឈមណ្ឌលប្រកួតប្រជែងផ្នែកនយោបាយ ជំនួញ និងវប្បធម៌ដោយមានការអភិវឌ្ឍប្រកបដោយសមធម៌ និងមានចីរភាពនៅត្រឹមឆ្នាំ២០៣៥"។

ផែនការមេប្រើប្រាស់ដីរាជធានីភ្នំពេញ ឆ្នាំ២០៣៥ បង្ហាញពីមហិច្ឆតានៃការចង់មើលឃើញតំបន់រាជធានីរីកចម្រើនលូតលាស់ ដែលអាចឆ្លើយតបការកើនឡើងចំនួនប្រជាជនបច្ចុប្បន្នដែលតិចជាង២លាននាក់ ទៅជាង៦លាននាក់ នៅឆ្នាំ២០៣៥ ដោយសារចំណាកស្រុកពីជនបទមកទីក្រុងនិងឆ្ពោះមកកាន់តំបន់រាជធានី។ ប្រការនេះបង្ហាញនូវតម្រូវការ និងជម្រើសជាផែនការយុទ្ធសាស្ត្រគ្រប់គ្រងទីក្រុង ក្នុងនោះមានចាប់ពីការរៀបចំតំបន់ក្រុងដែលរួមបញ្ចូលគ្នារវាងតំបន់នៃខេត្តកណ្តាល និងរាជធានីភ្នំពេញ រហូតដល់ការពង្រីកព្រំដែនទីក្រុងរួមជាមួយ នឹងការកាត់បញ្ចូលខេត្តកណ្តាលជិតពាក់កណ្តាល។ ក្រសួងមហាផ្ទៃនឹងសម្របសម្រួលដំណើរការរៀបចំផែនការចម្រុះនៃការកាត់បញ្ចូលខេត្តនេះ ហើយនឹងត្រូវធ្វើបច្ចុប្បន្នភាពព្រំដែនរដ្ឋបាលរាជធានីភ្នំពេញ។

## រូបភាពទី៣៖ ផែនទីរដ្ឋបាលរាជធានីភ្នំពេញ (ប្រភព៖ ផែនការមេសាលារាជធានីភ្នំពេញ)




ផែនការមេប្រើប្រាស់ដីរាជធានីភ្នំពេញ ឆ្នាំ២០៣៥ ក៏មានបញ្ចីគម្រោងអាទិភាពដែលនឹងត្រូវអនុវត្តនៅក្នុងរាជធានី ព្រមទាំងបទប្បញ្ញត្តិនានាទាក់ទងទៅនឹងការរស់នៅក្នុងទីក្រុងដែលនឹងត្រូវបង្កើត ឡើងក្នុងរយៈពេលដ៏ខ្លីខាងមុខ ដែលរួមមាន៖

- ផែនទីប្រើប្រាស់ដីធ្លី និងការបែងចែកតំបន់ប្រើប្រាស់ដីធ្លី
- ការរៀបចំក្រុងសម្រាប់ការអភិវឌ្ឍនៅភាគខាងជើង និងភាគខាងលិចរាជធានីភ្នំពេញ
- ការរៀបចំក្រុងសម្រាប់ការអភិវឌ្ឍនៅភាគខាងត្បូងទីក្រុង និងសម្រាប់ផែនការរៀបចំអាងប្រព្រឹត្តកម្មទឹកកខ្វក់នៅបឹងជើងឯក
- ការរៀបចំផែនការទីធ្លាសាធារណៈ (បឹង ព្រៃក ផ្លូវថ្នល់ ផ្លូវដែក កំពង់ផែ ព្រលានយន្តហោះ និងតំបន់បៃតង)
- ផែនទីតំបន់អភិវឌ្ឍន៍ពិសេស/ដែលត្រូវបានផ្តល់អាទិភាព
- ផែនទីសម្រាប់ការកំណត់ និងបង្ហាញពីអគារដែលមានកម្ពស់ខ្ពស់ និងការធ្វើសវនកម្មកម្ពស់របស់អគារនានាសម្រាប់សុវត្ថិភាពការហោះហើររបស់យន្តហោះ
- ផែនទីសម្រាប់អគារបេតិកភណ្ឌក្នុងទីក្រុង
- ផែនទីកំណត់តំបន់ និងបទប្បញ្ញត្តិនានាសម្រាប់អនុវត្តផែនការមេ ដើម្បីអភិរក្ស ឬការពារតំបន់ក្នុងទីក្រុងសម្រាប់ការដាំដើមឈើ ការគ្រប់គ្រងទីធ្លា និងទ្រព្យសម្បត្តិសាធារណៈ។

## គោលនយោបាយ និងក្របខណ្ឌបទប្បញ្ញត្តិ

ការរៀបចំផែនការមេគឺជាលក្ខខណ្ឌតម្រូវនៃច្បាប់*នគរូបនីយកម្មរបស់កម្ពុជា (១៩៩៤)*។បច្ចុប្បន្នក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់កំពុងធ្វើបច្ចុប្បន្នភាពច្បាប់នគរូបនីយកម្មតាមរយៈសេចក្តីព្រាងច្បាប់របស់ខ្លួនស្តីពី*ការរៀបចំដែនដី និងនគរូបនីយកម្ម (២០១៣) បានគាំទ្រយុទ្ធសាស្រ្តជាតិអភិវឌ្ឍន៍ទីប្រជុំជន* (កំពុងរៀបចំ) ដែលក្របខណ្ឌជាតិនេះត្រូវបានបង្កើតនៅក្នុងឆ្នាំ២០១៥-២០១៦។ បទប្បញ្ញត្តិក្រុងរបស់ប្រទេសកម្ពុជាត្រូវបានពង្រឹងតាមរយៈអនុក្រឹត្យលេខ ៤២ ស្តីពី នគរូបនីយកម្មរាជធានី ក្រុង និងទីប្រជុំជន (២០១៥) ដែលកំណត់ទំហំតំបន់ និងអនុតំបន់ សម្រាប់ការអភិវឌ្ឍនៅនឹងកន្លែង និងគម្រោងសំណង់ប្រភេទខុសៗគ្នា (លំនៅដ្ឋាន ពាណិជ្ជកម្ម ឬឧស្សាហកម្ម)។ កម្ពស់សំណង់ក៏ត្រូវបានបញ្ជាក់ រួមជាមួយនឹងលក្ខខណ្ឌចំណតនៅនឹងកន្លែងផងដែរ។ ដោយសារអនុក្រឹត្យលេខ៤២ មិនបានបញ្ជាក់អំពីបញ្ហាកំណត់តំបន់ ឬការប្រើប្រាស់ដី អនុក្រឹត្យនេះពង្រឹងនូវបទប្បញ្ញត្តិសម្រាប់សកម្មភាពសាងសង់នាពេលអនាគត។ គោលនយោបាយដីធ្លីរបស់ប្រទេសកម្ពុជា (២០០៩) ក៏ចែងផងដែរអំពីក្របខណ្ឌជាតិសម្រាប់រដ្ឋបាល និងការគ្រប់គ្រងដីក្នុងប្រទេសកម្ពុជា ដែលគាំទ្រដោយ *គោលនយោបាយជាតិស្តីពីការរៀបចំផែនការតំបន់ (២០១១) និងសៀវភៅណែនាំស្តីពីការរៀបចំតំបន់ (២០១៣)*។ ក្រៅពីនេះ យោងតាមច្បាប់ស្តីពី*ការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ២០០៨ កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិចែងអំពីការរៀបចំផែនការ ការផ្តល់ហិរញ្ញប្បទាន និងការគ្រប់គ្រងកាន់តែប្រសើរនូវសេវានៅកម្រិតរដ្ឋាភិបាលថ្នាក់ក្រោមជាតិ*។

## បញ្ហាប្រឈមសំខាន់ៗ

*នៅមុនការអនុម័តផែនការមេប្រើប្រាស់ដីធ្លីរាជធានីភ្នំពេញ ឆ្នាំ២០៣៥* ទីក្រុងភ្នំពេញមាន គម្រោងកម្មវិធីអភិវឌ្ឍន៍ពីវិស័យឯកជនជាច្រើន ប៉ុន្តែមានបទប្បញ្ញត្តិតិចតួចចែងអំពីការការពារចនាសម្ព័ន្ធទីក្រុង ការបែងចែកតំបន់បេតិកភ័ណ្ឌ តំបន់ធនធានធម្មជាតិ និងតំបន់សម្រាប់ប្រជាជនក្រីក្រ។ គេបានធ្វើការប៉ាន់ស្មានថា ចាប់តាំងពីឆ្នាំ១៩៩៩ មក ប្រជាជនប្រហែល១៥០.០០០នាក់បានត្រូវបានផ្លាស់ទីលំនៅពីទីតាំងកណ្តាលនៅក្នុងរាជធានីភ្នំពេញដើម្បីសម្របតាមការអភិវឌ្ឍទីក្រុង។[15] ការបន្តការអភិវឌ្ឍជាឯកជននៅតែជាហានិភ័យ សម្រាប់ប្រជាជនក្រីក្រក្នុងទីក្រុងដដែល។

ក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះទីក្រុងភ្នំពេញមានការរីកចម្រើនយ៉ាងឆាប់រហ័សនូវសំណង់អគារថ្មីៗ អគារខុនដូខ្ពស់ៗ ផ្សារទំនើប កាស៊ីណូ សហគមន៍ និងភូមិគ្រឹះទំនើបស្តឹមស្តែសម្រាប់គ្រួសារដែលមានប្រាក់ចំណូលខ្ពស់។ គម្រោងអភិវឌ្ឍន៍ទីក្រុងរណបចំនួនប្រាំពីរត្រូវបានគ្រោងបញ្ចប់នៅក្នុងរយៈពេល១០ ទៅ ១៥ឆ្នាំ បន្ទាប់ដែលនឹងគ្របដណ្តប់លើផ្ទៃដីចំនួន ៨០០០ហិចតា ឬស្មើ ១២% នៃផ្ទៃដីសរុបរបស់ទីក្រុង។ ការសាងសង់សំណង់ដោយមិនអនុឡោមតាមច្បាប់សាងសង់អាចមានផលប៉ះពាល់អវិជ្ជមានដល់ការបំពេញមុខងាររបស់ទីក្រុងទាំងមូល។ កង្វះការគ្រប់គ្រងទៅលើការវិនិយោគឯកជនអាចធ្វើឱ្យមានការរាំងស្ទះដល់ការអនុវត្តផែនការមេប្រើប្រាស់ដីធ្លីឆ្នាំ២០៣៥។

[15] សៀវភៅសរសេរដោយ Sebatian Strangio នៅឆ្នាំ២០១៤ ស្តីពីនាយករដ្ឋមន្ត្រីហ៊ុនសែន និងប្រទេសកម្ពុជា

រូបភាពនៃរាជធានីភ្នំពេញកំពុងផ្លាស់ប្តូរយ៉ាងឆាប់រហ័សដោយសារការរីកដុះដាលនៃវិស័យ សំណង់ អគារ និងការវិនិយោគឯកជនដ៏ច្រើន ។




## ៤.៥.២ ភាពងាយរងគ្រោះរបស់ទីក្រុង

រាជធានីភ្នំពេញ មានភាពងាយរងគ្រោះខ្លាំងចំពោះការជន់លិចដោយសារស្ថិតនៅក្នុងតំបន់ទំនាបដីល្បាប់ទន្លេមេគង្គ។ ប្រព័ន្ធលូរំដោះទឹកជំនន់មានភាពស្មុគស្មាញដោយសាររាជធានីភ្នំពេញមានសណ្ឋានទាបកណ្តាល។ ពេលខ្លះកម្រិតទឹកនៅរដូវវស្សាអាចឡើងដល់ជាង១០ម៉ែត្រ ដែលអាចបណ្តាលឱ្យមានការជន់លិចនៅផ្នែកជាច្រើននៃទីក្រុង។ ការសិក្សាមួយបានបង្ហាញថា ៣០% នៃតំបន់ក្រុងមានកម្ពស់ទាបជាង ៨ ម៉ែត្រ ៤៥% នៃតំបន់ក្រុង ទាបជាង ៩ ម៉ែត្រ និង ៦០%នៃតំបន់ក្រុង ទាបជាង ១០ម៉ែត្រ កម្រិតទឹកទន្លេ។[16] ការជន់លិចអាចបង្កឡើងដោយសារភ្លៀងមូសុងដែលអូសបន្លាយរយៈពេលយូរ ហេតុការណ៍ខ្យល់ព្យុះបោកបក់ញឹកញាប់ កម្រិតទឹកឡើងខ្ពស់តាមរដូវនៅទន្លេសាប និងទន្លេមេគង្គ ឬដោយសារហេតុការណ៍ផ្សេងទៀតបណ្តាលមកពីអាកាសធាតុប្រែប្រួល។ ផលប៉ះពាល់កាន់តែខ្លាំង និងធ្ងន់ធ្ងរពីការជន់លិចដោយសារការអភិវឌ្ឍវិស័យអចលនទ្រព្យដែលគ្មានការត្រួតពិនិត្យលើហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធលូ និងប្រព្រឹត្តកម្មទឹកកខ្វក់មិនគ្រប់គ្រាន់។

រាជធានីភ្នំពេញកំពុងកែលម្អហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធលូមេ ដោយសហការជាដៃគូជាមួយទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA)។ ប្រព័ន្ធបណ្តាញលូរឹងមាំដែលត្រូវបានសាងសង់នៅតំបន់កណ្តាលរាជធានីអាចការពារអគារបានមួយចំនួន ប៉ុន្តែតំបន់ជុំវិញទីក្រុង និងជាយក្រុងនៅតែប្រឈមហានិភ័យខ្លាំងដដែលចំពោះការជន់លិច។ ចាប់តាំងពីឆ្នាំ១៩៩៨មក ជំនួយឥតសំណងជាទឹកប្រាក់របស់ JICA បានជួយកាត់បន្ថយទឹកជំនន់នៅផ្នែកកណ្តាលទីក្រុងតាមរយៈការអនុវត្តគម្រោងបន្តបន្ទាប់ជាច្រើន។ ដំណាក់កាលទី១ និងទី២ បានទទួលជោគជ័យនៅក្នុងការកាត់បន្ថយការខូចខាតពីទឹកជំនន់នៅប៉ែកនិរតី ប៉ែកអាគ្នេយ៍ និងប៉ែកឥសាន្តរាជធានីភ្នំពេញ។ គម្រោងកម្ចីរបស់ ADB ចន្លោះឆ្នាំ២០០០ ដល់ឆ្នាំ ២០០៣ ក៏បានគាំទ្រដល់បណ្តាញលូការពារទឹកជំនន់ផងដែរ។

[16] របាយការណ៍វឌ្ឍនភាពពីការសិក្សាគម្រោងធ្វើអោយប្រសើរឡើងនៃប្រព័ន្ធលូទឹកកខ្វក់ និងទឹកភ្លៀងក្នុងតំបន់ទីប្រជុំជនរាជធានីភ្នំពេញ របស់ JICA បោះពុម្ពខែវិច្ឆិកា ឆ្នាំ ២០១៥ ។

នៅឆ្នាំ២០១៥ មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានីភ្នំពេញបានរៀបចំ*ការសិក្សាអំពីការកែលម្អប្រព័ន្ធលូ និងលូទឹកកខ្វក់នៅក្នុងតំបន់ទីក្រុងភ្នំពេញ ដោយមានការគាំទ្រពីអង្គការ JICA ដើម្បីផលិតចេញជា ផែនការមេសម្រាប់ប្រព័ន្ធលូ និងលូទឹកកខ្វក់ ដែលមានវិសាលភាពគ្របដណ្ដប់លើការធ្វើប្រព្រឹត្តកម្មទឹកកខ្វក់សម្រាប់រាជធានីភ្នំពេញទាំងមូល។* គេរំពឹងទុកថា ប្រព័ន្ធរួមដែលរួមមានបណ្ដាញលូទឹក និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ នឹងត្រូវបានសាងសង់ឡើងជាមួយគ្នាសម្រាប់តំបន់ដែលមានប្រជាជនច្រើនរស់នៅក្នុងរាជធានីភ្នំពេញ។ បឹងជើងឯក និងបឹងតាមោក គឺជាទីតាំងដែលត្រូវបានសិក្សា និងកំណត់ជាទីតាំងសម្រាប់ការសាងសង់ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ដាច់ដោយឡែក (off-site)។ បឹងត្របែក និងបឹងទំពុន ក៏ត្រូវបានកំណត់ថាជាទីតាំងសក្ដានុពលក្នុងការសាងសង់អាងប្រព្រឹត្តកម្មទឹកកខ្វក់ដាច់ដោយឡែក។ ការសាងសង់អាងប្រព្រឹត្តកម្មទឹកកខ្វក់ត្រូវបានរៀបចំផែនការជាដំណាក់កាល (តារាងទី ៣) អាស្រ័យលើលទ្ធភាពហិរញ្ញវត្ថុ ។

តារាងទី៣៖ តារាងកាលវិភាគសម្រាប់ការអនុវត្តអាងប្រព្រឹត្តិកម្មទឹកកខ្វក់

| ដំណាក់កាលអនុវត្ត | អនុគម្រោង | ឆ្នាំបំពេញការងារ | ប្រជាជន ដែលប្រើប្រាស់អាង នៅត្រឹមឆ្នាំ២០៣៥ |
|---|---|---|---|
| ដំណាក់កាលសាកល្បង និងការចាក់ចោលភក់ | ការសាងសង់អាងប្រព្រឹត្តិកម្មទឹកកខ្វក់ដែលមានចំណុះ ៥០០០ $m^3$/ថ្ងៃ | ឆ្នាំ២០២០ | ១៩.០០០ |
| ដំណាក់កាលទី១ | ការសាងសង់អាងប្រព្រឹត្តិកម្មទឹកកខ្វក់ដែលមានចំណុះ ៥៨.០០០ $m^3$/ថ្ងៃ | ឆ្នាំ២០២៦ | ២១៩.០០០ |
| ដំណាក់កាលទី២ | ការសាងសង់អាងប្រព្រឹត្តិកម្មទឹកកខ្វក់ដែលមានចំណុះ ៣៨.០០០ $m^3$/ថ្ងៃ | ឆ្នាំ២០៣១ | ១៥៣.០០០ |
| ដំណាក់កាលទី៣ | ការសាងសង់អាងប្រព្រឹត្តិកម្មទឹកកខ្វក់ដែលមានចំណុះ ១៨១.០០០ $m^3$/ថ្ងៃ | ឆ្នាំ២០៣៥ | ៧០៣.០០០ |

*ប្រភព៖ ឯកសារបទបង្ហាញរបស់ JICA ឆ្នាំ ២០១៥(b) ស្ដីពីការសិក្សាគម្រោងធ្វើអោយប្រសើរឡើងនៃប្រព័ន្ធលូទឹកកខ្វក់ និងទឹកភ្លៀងក្នុងតំបន់ទីប្រជុំជនរាជធានីភ្នំពេញ*

## គោលនយោបាយ និងក្របខណ្ឌបទប្បញ្ញត្តិ

ក្របខណ្ឌច្បាប់សម្រាប់អនុវិស័យពាក់ព័ន្ធភាពងាយរងគ្រោះរបស់ទីក្រុង នៅមានភាពស្មុគស្មាញ និងស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងខុសៗគ្នា។ក្រសួងបរិស្ថានទទួលខុសត្រូវលើការអនុវត្តអនុក្រឹត្យលេខ២៧ ស្ដីពីការគ្រប់គ្រងការបំពុលទឹក(១៩៩៩)ដែលកំណត់ស្តង់ដារសម្រាប់ទឹកកខ្វក់ដែលត្រូវបញ្ចេញទៅក្នុងទឹកសាធារណ (បឹង ស្ទឹង ព្រែក ទន្លេ) ស្របទៅនឹង ច្បាប់ស្ដីពីការការពារបរិស្ថាននិងគ្រប់គ្រងធនធានធម្មជាតិ (១៩៩៦) ។ ជាងនេះទៅទៀត អនុក្រឹត្យលេខ៧២ ស្ដីពី កិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (EIA) (១៩៩៩) គូសបញ្ជាក់អំពីលក្ខខណ្ឌ EIA សម្រាប់ដំណើរការកែច្នៃទឹកកខ្វក់ និងអាងស្តុកទឹកកខ្វក់គ្រប់ទំហំទាំងអស់។ បច្ចុប្បន្ននេះ ការគ្រប់គ្រងការបំពុលទាំងនេះកំពុងត្រូវបានធ្វើបច្ចុប្បន្នភាពតាមរយៈការរៀបចំសេចក្ដីព្រាង ក្រមបរិស្ថាន និងធនធានធម្មជាតិ ចាប់តាំងពីឆ្នាំ ២០១៥ មកម្ល៉េះ។

ប្រទេសកម្ពុជាពុំមានច្បាប់ស្ដីពីការគ្រប់គ្រងប្រព័ន្ធលូ និងអាងប្រព្រឹត្តកម្មទឹកកខ្វក់នៅឡើយ ប៉ុន្តែមានគោលនយោបាយ និងបទប្បញ្ញត្តិពាក់ព័ន្ធមួយចំនួន។ អនុក្រឹត្តលេខ៨៦ របស់ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ស្ដីពីអជ្ញាប័ណ្ណនៃការសាង

សង់គឺបានតម្រូវឱ្យផ្ទះ/អគារទាំងអស់ដំឡើងប្រព័ន្ធអាងស្តុកទឹកកខ្វក់។ ជាងនេះទៅទៀត អនុក្រឹតលេខ៣៩ស្តីពីការគ្រប់គ្រងបុរី (២០១១) តម្រូវឱ្យក្រុមហ៊ុនអភិវឌ្ឍន៍ទាំងអស់ត្រូវ "ដាក់បញ្ចូលនូវហេដ្ឋារចនាសម្ព័ន្ធជាមូលដ្ឋាន" សម្រាប់ "ស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់" (មាត្រា ៨)។ ក្រសួងសាធារណការ និងដឹកជញ្ជូន ក៏មានផងដែរនូវ*គោលនយោបាយជាតិសម្រាប់ការផ្គត់ផ្គង់ទឹក និងអនាម័យ (២០០៣)* និងបានចូលរួមជាមួយក្រសួងមហាផ្ទៃ និងក្រសួងបរិស្ថានបង្កើតនូវអនុក្រឹត្យស្តីពីការគ្រប់គ្រងប្រព័ន្ធទឹកកខ្វក់ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ (២០១៧) ដែលមានគោលបំណងផ្ទេរិមជ្ឍការលើការទទួលខុសត្រូវក្នុងការគ្រប់គ្រងទឹកកខ្វក់ទៅដល់កម្រិតរដ្ឋបាលថ្នាក់ក្រោមជាតិ (រដ្ឋបាលរាជធានី និង/ឬកម្រិតស្រុក-ខណ្ឌ)។

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ទទួលខុសត្រូវលើការអនុវត្ត និងគ្រប់គ្រងច្បាប់*ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម (២០០៦)* ដែលតម្រូវឱ្យមានការធ្វើប្រព្រឹត្តកម្មទឹកកខ្វក់មុនពេលបញ្ចេញចោល និងហាមឃាត់ការបញ្ចេញទឹកពីរោងចក្រដោយគ្មានការធ្វើប្រព្រឹត្តកម្ម។ ច្បាប់*ស្តីពីការគ្រប់គ្រងធនធានទឹក (២០០៧)* ដែលគ្រប់គ្រងដោយក្រសួងធនធានទឹក និងឧតុនិយម ក៏កំណត់ផងដែរនូវការទទួលខុសត្រូវរបស់ក្រសួងនេះ ដោយសហការជាមួយក្រសួងពាក់ព័ន្ធក្នុងការបង្កើតស្តង់ដារបច្ចេកទេស ត្រួតពិនិត្យ និងតាមដានរាល់ការបញ្ចេញចោលនូវសារធាតុនានាដែលបំពុលទឹក។

បញ្ហាមួយទៀតសម្រាប់ភាពងាយរងគ្រោះរបស់ទីក្រុង គឺការគ្រប់គ្រងកម្មវិធីតាំងទីលំនៅថ្មីក្នុងទីក្រុងសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងលំនៅដ្ឋាន។ រាជរដ្ឋាភិបាលបានចេញសារាចរ លេខ ៣ ស្តីពី *ដំណោះស្រាយលើការតាំងទីលំនៅថ្មីបណ្តោះអាសន្នពាក់ព័ន្ធនឹងដីធ្លីដែលត្រូវបានកាន់កាប់ដោយខុសច្បាប់នៅក្នុងតំបន់កណ្តាលរាជធានី និងតំបន់ជាយក្រុង (២០១០)*។ សារាចរណែនាំនេះមានគោលដៅដោះស្រាយបញ្ហានៃការតាំងទីលំនៅរបស់គ្រួសារមានប្រាក់ចំណូលទាបក្នុងក្រុង ដែលមិនស្របច្បាប់ និងកំណត់នូវស្តង់ដារអប្បបរមាសម្រាប់កម្មវិធីតាំងទីលំនៅថ្មី។

## បញ្ហាប្រឈមសំខាន់ៗ

ការជន់លិចក្លាយជាបញ្ហាកាន់តែធ្ងន់ធ្ងរឡើងៗនៅរាជធានីភ្នំពេញ។ ក្នុងរយៈពេល ៥០ឆ្នាំចុងក្រោយនេះ ការជន់លិចដែលមានសភាពធ្ងន់ធ្ងរ បានកើតឡើងប្រហែលជារៀងរាល់៥ឆ្នាំម្តង។[17] ការជន់លិចកាន់តែធ្ងន់ធ្ងរនេះគឺ ដោយសារការអភិវឌ្ឍពាណិជ្ជកម្មរបស់វិស័យឯកជននៅក្នុងតំបន់ដែលពីមុនមកគឺជាលំហបៃតងសាធារណៈ បឹងធម្មជាតិ ឬតំបន់ដីសើម និងដែលកន្លងមកវាជាប្រព័ន្ធគ្រប់គ្រងទឹកជំនន់ធម្មជាតិ និងប្រព័ន្ធគ្រប់គ្រងទឹកកខ្វក់។ ក្នុងអំឡុងឆ្នាំ២០០៣-២០១៥ គេបានប៉ាន់ស្មានថា តំបន់វាលភក់ បឹង និងតំបន់ដីសើមនៅរាជធានីភ្នំពេញបានថយចុះ ៥០%។[18]

ការជន់លិច និងការធ្លាក់ភ្លៀងខ្លាំងបំផុតនាពេលថ្មីៗនេះបង្ហាញថា ចន្លោះពេលនៃការជន់លិច រយៈពេល ៥ ឆ្នាំអាចនឹងកាន់តែរួញខ្លី។ នៅឆ្នាំ២០១១ និង២០១៣ រាជធានីភ្នំពេញបានជួបប្រទះការជន់លិចខ្លាំងបំផុតក្នុងប្រវត្តិសាស្ត្រ ដែលមានផលប៉ះពាល់ខាងសេដ្ឋកិច្ចធំធេង និងប៉ះពាល់ដល់គ្រួសាររាប់ពាន់គ្រួសារ។ ជាក់ស្តែង ទឹកជំនន់នៅឆ្នាំ ២០១១ (បង្ហាញនៅក្នុងរូបភាពទី៥) បានផ្តល់ផលប៉ះពាល់ទៅលើគ្រួសារជាង ១៧.០០០ គ្រួសារនៅរាជធានីភ្នំពេញ។ ទឹកជំនន់ឆ្នាំ ២០១៣ បានបង្កការខាតបង់អស់ប្រហែល ៦៦២ លានដុល្លារអាមេរិកនៅទូទាំងប្រទេសសម្រាប់ការខូចខាត និងការខាតបង់ដោយសារទឹកជំនន់ និងសម្រាប់ការស្តារ និងការកសាងឡើងវិញ។ ផលប៉ះពាល់នៃការជន់លិច ដែលបំផ្លាញខ្លាំងបំផុតកើតឡើងនៅតំបន់ជុំវិញទីក្រុង និងតំបន់មានរយៈកម្ពស់ទាប ជាងកន្លែងដែលប្រជាជនដែលមានប្រាក់ចំណូលទាបរស់នៅ។ ទឹកជំនន់បន្តនៅលិចរយៈពេលវែងនៅតំបន់ទាំងនេះ ដោយសារកង្វះហេដ្ឋារចនាសម្ព័ន្ធបណ្តាញលូ។ ដើម្បីសម្របតាមហេតុការណ៍នៃការជន់លិចញឹកញាប់នេះ គ្រួសារមានប្រាក់ចំណូលទាបត្រូវសាងសង់ផ្ទះ និងផ្លូវដើរខ្ពស់ផុតពីដី ឬរើទៅកាន់ជម្រកបណ្តោះអាសន្ន។

[17] របាយការណ៍ស្តីពីហានិភ័យគ្រោះមហន្តរាយនៃនគរូបនីយកម្ម ភាពងាយរងគ្រោះនៃតំបន់ក្រីក្រក្នុងក្រុងពីការលិចទឹកក្នុងទីក្រុង និងផលប៉ះពាល់ផ្សេងទៀត បោះពុម្ពឆ្នាំ ២០១៥ ដោយអង្គការ People In Need (PIN) ។

[18] របាយការណ៍វឌ្ឍនភាពពីការសិក្សាគម្រោងធ្វើអោយប្រសើរឡើងនៃប្រព័ន្ធលូទឹកកខ្វក់ និងទឹកភ្លៀងក្នុងតំបន់ទីប្រជុំជនរាជធានីភ្នំពេញ របស់ JICA បោះពុម្ពខែវិច្ឆិកា ឆ្នាំ ២០១៥ ។

បញ្ហាប្រឈមបន្ថែមទៀតនៃភាពងាយរងគ្រោះនៅទីក្រុងគឺ កង្វះហេដ្ឋារចនាសម្ព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់។ នៅតំបន់ទីប្រជុំជនក្រុងសំខាន់ៗ ទឹកកខ្វក់ចេញពីផ្ទះ និងអាគារពាណិជ្ជកម្មភាគច្រើនបង្ហូរចូលទៅក្នុងលូ/អាងស្តុកទឹកកខ្វក់ (Septic Tanks) នៅទីតាំងផ្ទាល់ដែលតភ្ជាប់ទៅប្រព័ន្ធបណ្តាញលូក្រុងដែលរួមមានលូក្រោមដី និងប្រឡាយបើក។ ការអង្កេតបានសន្និដ្ឋានថា គ្រួសារប្រហែល ៧០% មានលូ/អាងស្តុកទឹកកខ្វក់ដែលតភ្ជាប់ទៅប្រព័ន្ធបណ្តាញលូ ខណៈដែលប្រហែល ២០% មានលូ/អាងស្តុកទឹកកខ្វក់ដែរ តែមិនមានការតភ្ជាប់។[19]

ទឹកកខ្វក់ និងទឹកលូដែលហូរពីកណ្តាលរាជធានីភ្នំពេញហូរទៅបឹងរងទឹកភ្លៀង នៅភាគខាងជើង ឬខាងត្បូង។ ទឹកលូដែលហូរទៅភាគខាងជើងត្រូវបានបង្ហូរទៅបឹងពោងពាយ មុនពេលត្រូវបានបង្ហូរចាក់ទៅទន្លេសាប។ ទឹកកខ្វក់ទីក្រុងភាគច្រើន (ប្រហែល ៨០%) ហូរទៅភាគខាងត្បូង និងត្រូវបានធ្វើប្រព្រឹត្តកម្មដោយធម្មជាតិមួយផ្នែកនៅក្នុងបណ្តាញតំបន់ដីសើម វាលភក់ និងបឹង។ នៅបឹងទំពុន និងបឹងជើងឯក សារធាតុចិញ្ចឹមពីទឹកកខ្វក់ផ្តល់ជីជាតិដល់បឹងត្រកួន ដែលត្រូវបានប្រមូលផលដោយប្រជាជននៅក្នុងតំបន់នោះ និងលក់ទៅផ្សារក្នុងទីក្រុង។ គេបានប៉ាន់ស្មានថា ២០% នៃការបរិភោគបន្លែសរុបនៅរាជធានីភ្នំពេញបានមកពីការប្រមូលផលពីបន្លែនៅបឹងទាំងនេះ។ ប្រសិនបើមិនបានលាង និងចម្អិនឱ្យបានត្រឹមត្រូវទេ បន្លែដែលដាំនៅក្នុងស្ថានភាពបែបនោះអាចចោទបញ្ហាសុខភាពសាធារណៈបាន។[20]

រាជធានីភ្នំពេញក៏ពុំមានហេដ្ឋារចនាសម្ព័ន្ធសម្រាប់សំណល់ភក់ដែលបង្កកពីអាងទឹកកខ្វក់ដែរ។ កាលពីមុន សំណល់ទឹកកខ្វក់ពីអគារពាណិជ្ជកម្ម និងតាមផ្ទះសម្បែងប្រជាពលរដ្ឋ ត្រូវបានយកចេញដោយរថយន្តស៊ីទែនបូមភក់ បន្ទាប់មកយកទៅចាក់ចោលនៅកន្លែងចាក់សំណល់រឹង។ នៅពេលរណ្តៅពេញណែនដោយភក់ ប្រតិបត្តិករកន្លែងចាក់សំរាមបានផ្អាកការចាក់គរភក់។ ដោយសារមិនមានទីតាំងដើម្បីចាក់ចោលភក់ ប្រតិបត្តិករបូមភក់ភាគច្រើនពេលនេះកំពុងចាក់គរភក់ដោយខុសច្បាប់នៅប្រឡាយ និងនៅតំបន់ដីសើមដែលមានរយៈកម្ពស់ទាប។

នៅតំបន់ជុំវិញទីក្រុង និងតំបន់រស់នៅរបស់ប្រជាជនដែលមានប្រាក់ចំណូលទាប ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធលើការរក្សាអនាម័យនៅតែមានកម្រិតខ្សោយ។ គ្រួសារមួយចំនួនដែលមានបង្គន់អនាម័យចាក់ទឹក គឺបង្ហូរទឹកសំណល់ផ្ទាល់ទៅក្នុងបណ្តាញលូ និងខ្សែទឹកក្នុងមូលដ្ឋាន។ ប្រហែលមួយភាគបីនៃគ្រួសារនៅតំបន់ក្រីក្របំផុតកប់សំណល់លាមក ឬ បន្ទោបង់ពាសវាលពាសកាល ហើយមានការរាយការណ៍ថាមានអត្រាកើតមានជំងឺខ្ពស់ ដូចជាជំងឺរាករូស រលាកថ្លើមប្រភេទ A ជំងឺព្រូន និងជំងឺសត្វតេនញ្ញា ដែលបណ្តាលមកពីការឆ្លងចេញពីលាមក ដែលទាក់ទងទៅនឹងលក្ខខណ្ឌនៃការរស់នៅគ្មានអនាម័យ និងបន្សុំទៅនឹងកន្លែងបញ្ចេញទឹកសំណល់។[21]

ភាពអសន្តិសុខនៃការកាន់កាប់ដី ក៏ជាបញ្ហាប្រឈមមួយទៀតចំពោះភាពងាយរងគ្រោះរបស់ទីក្រុងផងដែរ។ ការបណ្តេញចេញដោយបង្ខំទៅលើប្រជាជនមានប្រាក់ចំណូលទាបដែលបង្កដោយគម្រោងអភិវឌ្ឍន៍ខ្នាតធំ បានបណ្តាលឱ្យគ្រួសារជាច្រើនកាន់តែងាយរងគ្រោះចំពោះផលប៉ះពាល់ដ៏ធ្ងន់ធ្ងរនៃការជន់លិច និងភាពក្រីក្រជាបន្ត ព្រោះពួកគេត្រូវបានប្តូរទីលំនៅជាញឹកញាប់ទៅកាន់តំបន់ ជាយទីក្រុង និងប្រឈមមុខនឹងហានិភ័យខ្ពស់។

[19] របាយការណ៍ស្ទង់មតិតំបូងស្តីពីការបង្កើតគម្រោងស្តីពីការគ្រប់គ្រងប្រព័ន្ធដឹកជញ្ជូនក្នុងទីក្រុងភ្នំពេញ បោះពុម្ពនៅឆ្នាំ ២០១៥(c) ដោយអង្គការ JICA ។

[20] អត្ថបទស្តីអំពីករណីសិក្សា៖ បឹងធម្មជាតិ Putrid ផ្តល់នូវការជួយសង្គ្រោះដ៏ល្អដល់ទីក្រុងដែលខ្វះខាតអាងប្រព្រឹត្តកម្មទឹកកខ្វក់ សរសេរដោយ Otis Daniel នៅថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ២០១៣ នៅក្នុងគេហ៍ទំព័រ៖ https://nextcity.org/daily/entry/putrid-lakes-offer-sweet-relief-to-a-city-lacking-water-treatment-plants.

[21] ឯកសាសិក្សាស្តីពីសូចនាករវាយតម្លៃភាពក្រីក្រក្នុងទីក្រុង ដែលបានធ្វើបច្ចុប្បន្នភាពដោយអង្គការ People in Need និងអង្គការ UNICEF។ អត្ថបទទទួលបានតាមរយៈ http://www.unicef.org/cambodia/PIN_URBAN_POOR_FA.PDF

ការជន់លិចរាជធានីភ្នំពេញមានផលប៉ះពាល់ជាអវិជ្ជមានខាងសេដ្ឋកិច្ច រួមទាំងទៅលើពាណិជ្ជកម្មទំនិញ និងសេវាកម្ម ។


© GGGI

### ៤.៥.៣ វិស័យថាមពល

ប្រទេសកម្ពុជាធ្លាប់ពឹងផ្អែកខ្លាំងទៅលើជីវម៉ាស និងផលិតផលប្រេងនាំចូល ប៉ុន្តែភាពចម្រុះនៃការផ្គត់ផ្គង់ថាមពលរបស់ប្រទេសកម្ពុជាកំពុងមានការផ្លាស់ប្តូរយ៉ាងឆាប់រហ័សដើម្បីបំពេញតាមតម្រូវការ និងការផ្លាស់ប្តូររចនាសម្ព័ន្ធលើផ្នែកសេដ្ឋកិច្ច។[22] ក្នុងឆ្នាំ ២០១៦ ការប្រើប្រាស់ថាមពលអគ្គិសនីសរុបរបស់ប្រទេសកម្ពុជាមានចំនួន ៧.០៣៣,១៥ GWh ក្នុងនោះ ៧៧,៩៦% ជាប្រភពអគ្គិសនីផលិតក្នុងស្រុក ១៦,៧៤% នាំចូលពីប្រទេសវៀតណាម ៤,៧៧% នាំចូលពីប្រទេសថៃ និង០,៥៣% នាំចូលពីប្រទេសឡាវ។ ការពឹងអាស្រ័យលើការនាំចូលអគ្គិសនីពីប្រទេសជិតខាងបានថយចុះគួរអោយកត់សំគាល់ពី ៦៤% នៅឆ្នាំ២០១១ មកនៅត្រឹម ២២% នៅឆ្នាំ ២០១៦។[23]

នៅក្នុងឆ្នាំ ២០១៨ ការផ្គត់ផ្គង់អគ្គិសនីរបស់ប្រទេសកម្ពុជាមានចំនួនសរុប ៩.៣០៧,៤៤ GWh ក្នុងនោះមានប្រភពក្នុងស្រុកចំនួន ៧.៩៥៣,៦៤ GWh (៨៥,៤៥%) និងនាំចូលពីប្រទេសជិតខាងដូចជាប្រទេសវៀតណាម ប្រទេសថៃ និងប្រទេសឡាវ សរុបមានចំនួន ១.៣៥៣,៨០ GWh (១៤,៥៥%) ។ ក្នុងចំណោមប្រភពថាមពលក្នុងស្រុក ប្រភពធំៗដែលទទួលបានគឺពីវារីអគ្គិសនីមានចំនួនច្រើនជាងគេប្រមាណ ៤៨,៤៧% និងប្រភពពីការដុតធ្យូងថ្ម ៣៤,៥០%។ ដោយឡែកប្រភពពីថាមពលកកើតឡើងវិញមានតែ ០,៤៦% ប៉ុណ្ណោះ។[24]

នៅកម្រិតថ្នាក់ជាតិ វិស័យដឹកជញ្ជូន គឺជាវិស័យដែលប្រើប្រាស់ថាមពលច្រើនជាងគេដែលមានចំនួន ៤៦% នៃការប្រើប្រាស់ថាមពលសរុបចុងក្រោយ (TFEC) និងមានចំនួន ៩១% នៃផលិតផលប្រេងឥន្ធនៈ។ បន្ទាប់មកគឺ វិស័យលំនៅដ្ឋាន (៣១%) វិស័យឧស្សាហកម្ម (១៦%) និង វិស័យសេវាកម្ម អាជីវកម្ម(៧%)។[25]

នៅរាជធានីភ្នំពេញ ក្នុងចំណោម ៩១៦ ភូមិ មានតែ ២ ភូមិប៉ុណ្ណោះដែលមិនទាន់មានបណ្តាញចែកចាយអគ្គិសនី ប៉ុន្តែអជ្ញាធរកំពុងគ្រោងសាងសង់បណ្តាញចែកចាយសម្រាប់ភូមិទាំង ២ ដើម្បីអោយការតបណ្តាញបានគ្រប់ ១០០%។ លទ្ធភាពទទួលបានអគ្គិសនីនៅរាជធានីភ្នំពេញមានលក្ខណៈល្អខ្លាំង ដោយគ្រួសារច្រើនជាង ៩០% ត្រូវបានតភ្ជាប់ទៅបណ្តាញ។ ប្រព័ន្ធអគ្គិសនីនៅរាជធានី

[22] ស្ថិតិជាតិស្តីពីថាមពលនៅក្នុងប្រទេសកម្ពុជា ឆ្នាំ២០១៦ ដោយក្រសួងរ៉ែ និងថាមពល (MME) គាំទ្រដោយ វិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ចសម្រាប់អាស៊ាន និងអាស៊ីខាងកើត (ERIA) តាមរយៈ http://www.eria.org/RPR_FY2015_08.pdf

[23] របាយការណ៍ស្តីពីប្រភពថាមពលអគ្គិសនី ទទួលបាននៅថ្ងៃទី ២០ ខែឧសភា ឆ្នាំ ២០១៧ ពីប្រភពគេហទំព័រ៖ https://opendevelopmentcambodia.net/topics/electricity-production/

[24] របាយការណ៍សង្ខេបបូកសរុបបញ្ចប់ឆ្នាំ ២០១៨ ស្តីពីវឌ្ឍនភាពសំខាន់ៗរបស់វិស័យអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដោយ អជ្ញាធរអគ្គិសនីកម្ពុជា ឆ្នាំ ២០១៨ ។

[25] តារាងតុល្យភាពថាមពលកម្ពុជា បោះពុម្ពឆ្នាំ ២០១៥

ភ្នំពេញ គឺទទួលបានការផ្គត់ផ្គង់ពីបណ្តាញជាតិតាមរយៈអនុស្ថានីយ៍តង់ស្យុង ២៣០ kV ជាមួយអនុភាពប្រមាណ ៩០០ MW ព្រមទាំងផលិតកម្មដោយប្រេងប្រមាណ ១៩៤ MW ដោយបញ្ចូលមកក្នុងប្រព័ន្ធភ្នំពេញ (ទិន្នន័យ ២០១៦)។ នៅឆ្នាំ ២០១៦ កន្លងមក តម្រូវការអនុភាពអតិបរមារបស់ប្រព័ន្ធភ្នំពេញមានប្រមាណ ៧៥៧ MW ដែលបានផ្គត់ផ្គង់។ ប្រព័ន្ធភ្នំពេញបានទាញថាមពលពីប្រភពបណ្តាញជាតិប្រមាណ ៤.៥៩៦ GWh ក្នុងឆ្នាំ ២០១៦ និងមានត្រឹម ៤.១១៣ GWh ក្នុងឆ្នាំ ២០១៥ ។[26]

ថាមពលក្នុងរាជធានីភ្នំពេញ ត្រូវបានប្រើប្រាស់ភាគច្រើននៅក្នុងវិស័យលំនៅដ្ឋាន សកម្មភាពអាជីវកម្ម ឬពាណិជ្ជកម្ម និងឧស្សាហកម្ម (រូបភាពទី ៤)។ ភ្នំពេញដែលជាមជ្ឈមណ្ឌលស្នូលសម្រាប់សកម្មភាពឧស្សាហកម្មរបស់ប្រទេសកម្ពុជា បាននិងកំពុងប្រើប្រាស់ចំណែកថាមពលដ៏ច្រើនជាងគេ ក្នុងនោះអនុវិស័យដែលប្រើប្រាស់ថាមពលច្រើន គឺវាយនភណ្ឌដែលជាអនុវិស័យប្រើប្រាស់ធំជាងគេបន្ទាប់មកគឺរោងចក្រផលិតផឹក រោងម៉ាស៊ីនកិនស្រូវ ផលិតកម្មជ័រកៅស៊ូ និងផលិតកម្មចំណីអាហារ។[27] វិស័យឧស្សាហកម្មប្រើប្រាស់ប្រភពថាមពលរបស់ខ្លួនភាគច្រើនបំផុតបានពីជីវឧស្ម័ន (៥៨% នៃការប្រើប្រាស់ថាមពលសរុបចុងក្រោយក្នុងវិស័យឧស្សាហកម្ម) បន្ទាប់មកគឺប្រេងឥន្ធនៈ (២១%) និងអគ្គិសនី (១៨%)។ ដោយឡែកសម្រាប់សហគ្រាសធុនតូច និងមធ្យម (SMEs) តាមរយៈការពិភាក្សាជាមួយភាគីពាក់ព័ន្ធ យើងឃើញថា SMEs ភាគច្រើនប្រើប្រាស់នូវប្រេងម៉ាស៊ូត ឬម៉ាស៊ីនភ្លើងប្រើប្រេងឥន្ធនៈធុនធ្ងន់ (Heavy Fuel Oil - HFO) ជាថាមពលត្រៀមបង្កាទុកដើម្បីបញ្ចៀសការរអាក់រអួលដំណើរការផលិតកម្មរបស់ខ្លួនក្នុងករណីដែលបណ្តាញអគ្គិសនីដាច់។

រូបភាពទី៤៖ ការផលិតអគ្គិសនីនៅរាជធានីភ្នំពេញ ឆ្នាំ២០០៩-២០១៤ (ខាងឆ្វេង) ចំណែកលក់ថាមពលគិតតាមអតិថិជន ឆ្នាំ២០១៤ (ខាងស្តាំ)




*ប្រភព៖ របាយការណ៍ប្រចាំឆ្នាំពីអគ្គិសនីកម្ពុជា (EDC) ឆ្នាំ២០១៥*[28]

## គោលនយោបាយ និងក្របខណ្ឌបទប្បញ្ញត្តិ

ច្បាប់អគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា (២០១១) កំណត់បទប្បញ្ញត្តិទៅលើប្រតិបត្តិការរបស់វិស័យថាមពលអគ្គិសនី និងក្រុមហ៊ុនផ្តល់សេវា។[29] គោលបំណងចម្បងមួយរបស់ច្បាប់នេះ គឺដើម្បីលើកទឹកចិត្តវិស័យឯកជនឱ្យធ្វើការវិនិយោគទៅលើវិស័យថាមពល និងដើម្បីបំពេញបន្ថែមលើសមត្ថភាពរបស់អគ្គិសនីកម្ពុជា។

[26] របាយការណ៍ប្រចាំឆ្នាំពីអគ្គិសនីកម្ពុជា (EDC) ឆ្នាំ ២០១៦

[27] ប្រភពដូចក្នុងកំណត់សំគាល់ខាងលើ លេខ ២៦

[28] ទិន្នន័យនៃចំណែកថាមពលនៅឆ្នាំបន្តបន្ទាប់មិនអាចស្វែងរកបាន

*គោលនយោបាយថាមពលថ្នាក់ជាតិ* របស់ប្រទេសកម្ពុជាមានគោលបំណងចំនួនបួន៖ (១) ផ្តល់ការផ្គត់ផ្គង់ថាមពលគ្រប់គ្រាន់នៅទូទាំងប្រទេសកម្ពុជាក្នុងតម្លៃសមរម្យ និងមានលទ្ធភាពបង់បាន។ (២) ធានាការផ្គត់ផ្គង់អគ្គិសនីជាទីទុកចិត្ត និងមានសុវត្ថិភាពនៅក្នុងតម្លៃសមរម្យ ដែលជួយសម្រួលដល់ការវិនិយោគក្នុងប្រទេសកម្ពុជា និងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ (៣) លើកទឹកចិត្តឱ្យមានការរុករក និងការអភិវឌ្ឍធនធានថាមពល ដែលអាចទទួលយកបានសម្រាប់បរិស្ថាន និងសង្គមដើម្បីផ្គត់ផ្គង់ទៅគ្រប់វិស័យទាំងអស់នៃសេដ្ឋកិច្ចកម្ពុជា និង(៤) លើកទឹកចិត្តការប្រើប្រាស់ថាមពលឱ្យមានប្រសិទ្ធភាពដើម្បីកាត់បន្ថយផលប៉ះពាល់បរិស្ថានធ្ងន់ធ្ងរដោយសារតែការផ្គត់ផ្គង់ និងការប្រើប្រាស់ថាមពល។

សកម្មភាពរបស់រាជរដ្ឋាភិបាលកម្ពុជានៅក្នុងការជំរុញវិស័យថាមពលកកើតឡើងវិញក្នុងពេលបច្ចុប្បន្ននេះគឺ ផ្តោតទៅលើការអភិវឌ្ឍវារីអគ្គិសនីទ្រង់ទ្រាយធំ និងការពង្រីកបណ្តាញអគ្គិសនីក្នុងតំបន់ជនបទ។ ទោះជាយ៉ាងនេះក្តី ការអភិវឌ្ឍថាមពលកកើតឡើងវិញត្រូវបានគាំទ្រដោយ*គោលនយោបាយជាតិស្តីពីការអភិវឌ្ឍបៃតង (២០១៣) ផែនការយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍបៃតង ២០១៣-២០៣០ និង ផែនការយុទ្ធសាស្ត្រការប្រែប្រួលអាកាសធាតុកម្ពុជា (២០១៤-២០២៣)* និងការរួមចំណែកថ្នាក់ជាតិរបស់ប្រទេសកម្ពុជានៅក្នុង*អនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) (២០១៥)*។

គោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិស្តីពីភាពប្រសិទ្ធភាពថាមពល ដែលបានរៀបចំសេចក្តីព្រាងនៅក្នុងឆ្នាំ២០១៣ ត្រូវបានគ្រោងបញ្ចប់ និងអនុម័តនៅក្នុងឆ្នាំ២០១៨។ ឯកសារនេះកំណត់គោលដៅនៃការកាត់បន្ថយតម្រូវការថាមពលទូទាំងប្រទេសចំនួន ៣0% និងការបញ្ចេញឧស្ម័នកាបូនឌីអុកស៊ីតនៅទូទាំងប្រទេសចំនួន ៣តោន ត្រឹមឆ្នាំ២០៣៥ បើប្រៀបធៀបជាមួយគម្រោងអនុវត្តតាមទម្លាប់ធម្មតា (BAU)។[30] ជាងនេះទៅទៀតសេចក្តីព្រាងស្តីពី ក្រមបរិស្ថាន និង ធនធានធម្មជាតិ ក៏មានចែងអំពីការលើកទឹកចិត្តផ្សេងៗ ដើម្បីជំរុញការប្រើប្រាស់ថាមពលកកើតឡើងវិញ និងប្រសិទ្ធភាពថាមពលផងដែរ។ នៅខែមករា ឆ្នាំ២០១៨ អជ្ញាធរអគ្គិសនីកម្ពុជាបានចេញនូវសេចក្តីប្រកាសស្តីពីលក្ខខណ្ឌទូទៅក្នុងការភ្ជាប់ថាមពលដែលផលិតចេញពីពន្លឺព្រះអាទិត្យ ទៅក្នុងប្រព័ន្ធចែកចាយអគ្គិសនី ឬប្រព័ន្ធប្រើប្រាស់អគ្គិសនីជាតិ។ សេចក្តីប្រកាសនេះ បានអនុញ្ញាតិឱ្យអ្នកប្រើប្រាស់ក្នុងការបំពាក់ប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យ ស្របតាមលក្ខខណ្ឌមួយចំនួនសម្រាប់ការបំពេញបន្ថែមតម្រូវការថាមពល អគ្គិសនីរបស់ខ្លួន។

## បញ្ហាប្រឈមសំខាន់ៗ

ការខាតបង់តាមប្រព័ន្ធបណ្តាញចែកចាយអគ្គិសនីនៅរាជធានីភ្នំពេញមានចន្លោះពី ៨,២% ដល់ ៩,៦% រវាងឆ្នាំ២០០៩ និងឆ្នាំ២០១៤។[31] វិស័យថាមពលក៏កំពុងជួបការលំបាកផងដែរដោយសារប្រសិទ្ធភាពផ្នែករដ្ឋបាល ការបញ្ជូន និងហេដ្ឋារចនាសម្ព័ន្ធផលិតថាមពលមិនទាន់មានលក្ខណៈល្អប្រសើរ។ គុណភាពនៃការផ្គត់ផ្គង់នៅមានកម្រិតទាប ការកាត់ផ្តាច់ចរន្តអគ្គិសនី និងការឡើងចុះតង់ស្យុងកើតឡើងជាទូទៅ។ នៅឆ្នាំ២០១៥ ចំនួនជាមធ្យមនៃការដាច់ភ្លើងអគ្គិសនីនៅរាជធានីភ្នំពេញ ដែលអាចប៉ាន់ប្រមាណបាន គឺ ២៤ដង ហើយរយៈពេលដាច់ជាមធ្យមគឺ ៧២០ នាទី (អត្រាខ្ពស់បំផុតក្នុងចំណោមបណ្តាប្រទេសសមាជិកអាស៊ាន) ហើយសហគ្រាសក្នុងស្រុក និងបរទេសភាគច្រើនយល់ឃើញថា តម្លៃខ្ពស់ និងកង្វះការផ្គត់ផ្គង់អគ្គិសនីគឺជាកត្តារាំងស្ទះចម្បងមួយនៅក្នុងការធ្វើអាជីវកម្មនៅប្រទេសកម្ពុជា។[32]

ប្រទេសកម្ពុជាមានសក្តានុពលថាមពលកកើតឡើងវិញយ៉ាងច្រើនដូចជាថាមពលព្រះអាទិត្យ ជីវម៉ាស និងការកែច្នៃសំណល់ទៅជាថាមពល។ ទោះជាយ៉ាងនេះក្តី ការប្រើប្រាស់ប្រភពថាមពលទាំងនេះនៅប្រទេសកម្ពុជានៅមានកម្រិតទាប។[33] សំណល់រឹង និងទឹកកខ្វក់

---

[29] របាយការណ៍ស្តីពីការអភិវឌ្ឍថាមពលកកើតឡើង និងសក្តានុពលនៅក្នុងមហាអនុតំបន់ទន្លេមេគង្គ បោះពុម្ពដោយADB នៅខែកក្កដា ឆ្នាំ ២០១៥(b) ដែលទទួលបានតាមរយៈគេហទំព័រ http://www.adb.org/publications/renewable-energy-developments-and-potential-gms

[30] ពង្រាងឯកសារគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិស្តីពីប្រសិទ្ធភាពថាមពលនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយរាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០១៣។

[31] របាយការណ៍ប្រចាំឆ្នាំរបស់អគ្គិសនីកម្ពុជា ឆ្នាំ២០១៤

[32] ឯកសារស្តីពីយុទ្ធសាស្ត្រសហប្រតិបត្តិការដៃគូ ២០១១-២០១៣ ជាមួយប្រទេសកម្ពុជា នៅក្នុងផ្នែកការវាយតម្លៃតាម វិស័យរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ឆ្នាំ២០១១ ដែលទទួលបានតាមរយៈគេហទំព័រ៖ http://www.adb.org/sites/default/files/linked-documents/cps-cam-2011-2013-oth-01.pdf.

[33] ឯកសារសិក្សាវាយតម្លៃ និងវិភាគស្តីពីប្រសិទ្ធភាពថាមពលសម្រាប់ទាំងអស់គ្នា ដោយ Dr. Magaret Njirambo Matinga ពង្រាង ទី១ ឆ្នាំ២០១២។

ក្នុងទីក្រុងអាចប្រើជាប្រភពជីវថាមពលដែលជាសក្តានុពលផ្សេងបន្ថែមទៀត។[34] ការផលិតជីវឧស្ម័នសម្រាប់គោលបំណងបង្កើត កម្តៅ និង ការផលិតអគ្គិសនីមានសក្តានុពលសំខាន់នៅរាជធានីភ្នំពេញ សម្រាប់រោងប្រព្រឹត្តកម្មទឹកកខ្វក់ និងរោងចក្រកម្មន្តសាលនៅក្នុងទីក្រុង។[35]

ការលើកកម្ពស់ថាមពលកកើតឡើងវិញមានបញ្ហាប្រឈមជាច្រើនដូចជា អត្រាការប្រាក់ខ្ពស់សម្រាប់កម្ចីតូចៗ ដែលធ្វើឱ្យមានការ ពិបាកក្នុងការបង់ថ្លៃចំណាយជាមុន ភាពស្ទាក់ស្ទើររបស់ឧស្សាហកម្មក្នុងការបណ្តាក់ទុនវិនិយោគ កង្វះការគាំទ្រផ្នែកច្បាប់ គោលនយោបាយ ឧទាហរណ៍លើការលក់អគ្គិសនីដែលបានពីប្រភពថាមពលកកើតឡើងវិញទៅក្នុងបណ្តាញអគ្គិសនីជាតិ (net-metering) ឬថ្លៃអនុគ្រោះលើបច្ចេកវិទ្យាថាមពលកើតឡើងវិញ (feed-in tariff) កង្វះការយល់ដឹងពីប្រព័ន្ធក្នុងចំណោមអតិថិជនជាសក្តានុពល និងកង្វះអ្នកផ្តល់សេវាថែទាំ។[36]

មកទល់ពេលនេះ មានការអនុវត្តមិនស្មើគ្នានូវគោលនយោបាយរបស់ប្រទេសកម្ពុជាក្នុងការលើកកម្ពស់ថាមពលកកើតឡើង វិញ។ ប្រទេសកម្ពុជាមិនទាន់អនុម័តយកគោលដៅនៃថាមពលកកើតឡើងវិញនៅឡើយទេ ហើយការព្យាករនាពេលអនាគត សម្រាប់ការផលិតអគ្គិសនីជាធម្មតាបង្ហាញតែទិន្នន័យលើវារីអគ្គិសនីខ្នាតធំ និងប្រេងឥន្ធនៈផូស៊ីលដែលជាប្រភពចម្បង។ ប្រសិនបើ មិនមានក្របខណ្ឌគោលនយោបាយ ឬកម្មវិធីដើម្បីលើកកម្ពស់ថាមពលកកើតឡើងវិញ ដែលមិនរាប់បញ្ចូលថាមពលពី វារីអគ្គិសនី នោះ ការអភិវឌ្ឍឧស្សាហកម្មថាមពលកកើតឡើងវិញត្រូវនាំមុខដោយវិស័យឯកជន។[37]

ដោយសារតម្លៃថាមពលនៅប្រទេសកម្ពុជាមានកម្រិតខ្ពស់ វិធានការប្រសិទ្ធភាពថាមពលគឺជាកាលានុវត្តភាពសេដ្ឋកិច្ច។ ការសន្សំ ដែលមានប្រសិទ្ធភាពថាមពលនៅរាជធានីភ្នំពេញរួមមាន៖

- ឧស្សាហកម្ម៖ សក្តានុពលនៃការសន្សំសំចៃថាមពលពី ១៥% ទៅ៥០% នៅក្នុងវិស័យ វាយនភណ្ឌ រោងចក្រទឹកកក ឧស្សាហកម្ម ម្ហូបអាហារ ។ល។
- សម្ភារប្រើប្រាស់ក្នុងផ្ទះ៖ រហូតដល់ ៥០% ដោយនាំមកនូវស្លាកសញ្ញាប្រសិទ្ធភាពថាមពល
- វិស័យសាងសង់៖ ២០-៣០% តាមរយៈការប្រើប្រាស់សម្ភារសាងសង់ និងគោលការណ៍សំណង់សមស្រប
- ការប្រើប្រាស់ជីវម៉ាស៖ ៣០-៥០% តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាចង្ក្រានចម្អិនថ្មី (Improved Cook Stoves – ICS) មានប្រសិទ្ធភាពជាងមុន សម្រាប់ឡដុតធ្យូង និងការ ប្រើប្រាស់ដុំធ្យូងតិចជាងមុន[38]
- សេវាក្រុង៖ វិធានការ រួមបញ្ចូលទាំងការបំភ្លឺដែលមានប្រសិទ្ធភាពថាមពល (ដោយប្រើប្រាស់អគ្គិសនី ៤០-៨០% តិចជាងមុន) ម៉ាស៊ីនបូមទឹកដែលមានប្រសិទ្ធភាព (១០-៣០% ការសន្សំដែលមានប្រសិទ្ធភាព)
- វិស័យថាមពល៖ កែលម្អប្រសិទ្ធភាពនៃការបញ្ជូន និងការចែកចាយ (កាត់បន្ថយការខាតបង់ចាប់ពី ៩,៦%) កាត់បន្ថយការ ប្រើប្រាស់ផ្ទាល់ខ្លួន កែលម្អប្រសិទ្ធភាពនៃទ្រព្យសកម្មសម្រាប់ការផលិត។

អវត្តមាននៃស្តង់ដារ និងស្លាកសញ្ញាប្រសិទ្ធភាពថាមពលមានន័យថា អ្នកប្រើប្រាស់ខ្វះព័ត៌មានអំពីប្រសិទ្ធភាពនៃគ្រឿង ប្រើប្រាស់ក្នុងផ្ទះ និងផលិតផលផ្សេងទៀត។ កត្តានេះធ្វើឱ្យឧបករណ៍ប្រើប្រាស់ដែលមានបច្ចេកវិទ្យាប្រសិទ្ធភាពថាមពលមាន តម្លៃថ្លៃ (គ្មានទីផ្សារ) ហើយស្របពេលជាមួយគ្នានេះ ឧបករណ៍ប្រើប្រាស់ដែលមិនមានបច្ចេកវិទ្យាប្រសិទ្ធភាពថាមពលមានការ រីកលូតលាស់ខ្លាំង (មានទីផ្សារ) ដោយសារមានតម្លៃថោក។[39] បច្ចុប្បន្ន ប្រទេសកម្ពុជាក៏មិនមានស្តង់ដារប្រសិទ្ធភាពថាមពលសម្រាប់ អគារ ឬស្តង់ដារបញ្ចេញឧស្ម័នរបស់យានយន្តនៅឡើយ។[40]

[34] ប្រភពដូចកំណត់សំគាល់ខាងលើ លេខ៣៣។
[35] ឯកសារស្តីពីសក្តានុពល និងការអភិវឌ្ឍថាមពលកកើតឡើងវិញនៅក្នុងមហាអនុតំបន់ទន្លេមេគង្គ ដោយ ADB ឆ្នាំ ២០១៥ ដែលទទួលបានតាមរយៈគេហទំព័រ http://www.adb.org/publications/renewable-energy-developments-and-potential-gms
[36] ប្រភពដូចកំណត់សំគាល់ខាងលើ។
[37] របាយការណ៍សិក្សាវាយតម្លៃសក្តានុពលសម្រាប់ការអភិវឌ្ឍថាមពលបៃតងនៅក្នុងប្រទេសកម្ពុជា ដោយវិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល (GGGI) ឆ្នាំ២០១៤។
[38] សេចក្តីព្រាងឯកសារគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិស្តីពីប្រសិទ្ធភាពថាមពលនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយរាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០១៣។
[39] ប្រភពដូចកំណត់សំគាល់ខាងលើ
[40] គោលនយោបាយជាតិស្តីពីការអភិវឌ្ឍបៃតង ឆ្នាំ២០១៣ ដោយរាជរដ្ឋាភិបាលកម្ពុជា

ឧបសគ្គផ្សេងទៀតចំពោះការបង្កើនប្រសិទ្ធភាពថាមពលនៅប្រទេសកម្ពុជារួមមាន៖

- កង្វះការយល់ដឹងអំពីកាលានុវត្តភាពនៃប្រសិទ្ធភាពប្រើប្រាស់ថាមពល ទោះបីជាថ្លៃថាមពលមានតម្លៃខ្ពស់ក៏ដោយ [41]
- កង្វះការយល់ដឹងអំពីការវិនិយោគដែលមានប្រសិទ្ធភាពថាមពលក្នុងចំណោមអ្នកផ្តល់កម្ចីពាណិជ្ជកម្ម ដែលនាំឱ្យមានភាពស្ទាក់ស្ទើរក្នុងការផ្តល់ហិរញ្ញប្បទានដល់គម្រោងអាជីវកម្មដែលមានប្រសិទ្ធភាពថាមពល
- កង្វះមូលនិធិសម្រាប់កម្មវិធីប្រកបដោយការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីប្រសិទ្ធភាពថាមពល[42] និង
- កង្វះស្ថាប័នដែលអាចធ្វើសវនកម្មថាមពល និងអនុវត្តវិធានការប្រសិទ្ធភាពថាមពល (ដូចជាក្រុមហ៊ុនសេវាថាមពល (ESCOs)។ [43]

មានសក្តានុពលយ៉ាងច្រើនសម្រាប់ PV ពន្លឺព្រះអាទិត្យលើដំបូលនៅរាជធានីភ្នំពេញដើម្បីបម្រើដល់លំនៅដ្ឋានប្រជាពលរដ្ឋ អាជីវកម្ម និងកម្មន្តសាល (រូបថតដោយ GGGI)។




### ៤.៥.៤ វិស័យដឹកជញ្ជូន

ការដឹកជញ្ជូននៅរាជធានីភ្នំពេញ គឺភាគច្រើនបំផុតនៅលើបណ្តាញផ្លូវថ្នល់ និងការប្រើប្រាស់យានយន្តឯកជន។ នៅឆ្នាំ ២០១៥ ចំនួនយានយន្តសរុបនៅទូទាំងប្រទេសដែលបានចុះបញ្ជីបង្ហាញថា ទោចក្រយានយន្តមានចំនួនប្រមាណ ២.៣០០.០០០គ្រឿង ចំនួនរថយន្តមានប្រមាណ ១៥៩.០០០គ្រឿង និងរថយន្តធំៗមានប្រមាណ ៧២.០០០គ្រឿង។[44] រាជធានីភ្នំពេញ មានកំណើនយ៉ាងឆាប់រហ័សនូវតម្រូវការវិស័យដឹកជញ្ជូនក្នុងរយៈពេលជាងមួយទសវត្សរ៍ចុងក្រោយដោយសារកំណើនប្រជាជនយ៉ាងឆាប់រហ័ស និងការកើនឡើងនូវសកម្មភាពសេដ្ឋកិច្ច។ ក្នុងពេលជាមួយគ្នានោះ ប្រាក់ចំណូលរបស់ប្រជាពលរដ្ឋមានការកើនឡើង ហើយយានយន្តនាំចូលមានតម្លៃថោកជាងមុន បាននាំឱ្យមានការកើនឡើងការធ្វើដំណើរតាមដងផ្លូវ និងកម្មសិទ្ធិយានយន្ត។ ខណៈដែលប្រជាជនរាជធានីភ្នំពេញបានកើនឡើងប្រមាណ ២,៣% ក្នុងមួយឆ្នាំចន្លោះពីឆ្នាំ២០០១ ដល់ឆ្នាំ២០១១ ការចុះបញ្ជីយានយន្តបានកើនឡើងច្រើនជាង ១១,៧% ក្នុងមួយឆ្នាំ ចំនួននៃការចុះបញ្ជីបានកើនឡើងច្រើនជាងបីដងក្នុងរយៈពេលមួយទសវត្សរ៍។[45]

[41] ព័ត៌មានពីកិច្ចប្រជុំជាមួយ EUROCHAM កាលពីថ្ងៃទី ២៩ ខែតុលា ឆ្នាំ២០១៥

[42] ប្រភពដូចកំណត់សំគាល់លេខខាងលើ

[43] ប្រភពដូចកំណត់សំគាល់លេខខាងលើ

[44] ការវាយតម្លៃគោលនយោបាយ និងបទបញ្ញត្តិសារពើពន្ធសម្រាប់យានយន្តនៅតាមដងផ្លូវនៅប្រទេសកម្ពុជា ដោយស្ថាប័ន Clean Air Asia ឆ្នាំ២០១៩ (ពង្រាង)

[45] របាយការណ៍គម្រោងស្តីពីការសិក្សាលម្អិតធ្វើផែនការប្រព័ន្ធដឹកជញ្ជូនក្នុងទីក្រុងសម្រាប់រាជធានីភ្នំពេញ ដោយ JICA ឆ្នាំ២០១៤ (របាយការណ៍សង្ខេប)។

ការរីកចម្រើនលូតលាស់យ៉ាងឆាប់រហ័សនូវការប្រើប្រាស់មធ្យោបាយដឹកជញ្ជូនឯកជននៅក្នុងទីក្រុង បាននាំឱ្យមានការកើនឡើងនូវបរិមាណចរាចរណ៍ និងការកកស្ទះ ដោយសារការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងការគ្រប់គ្រងចរាចរណ៍នៅរាជធានីភ្នំពេញដើរមិនទាន់ការអភិវឌ្ឍ។ ជាលទ្ធផលគឺការធ្វើចរាចរណ៍តាមដងផ្លូវមានសភាពយឺតយ៉ាវ (ខាតពេលវេលា) និងការកកស្ទះកើនឡើងខ្លាំង គ្រោះថ្នាក់ចរាចរណ៍កើនឡើង និងនាំអោយមានការបំពុលបរិយាកាស។ ល្បឿនបើកបរជាមធ្យមនៅក្នុងទីក្រុងបានថយចុះពី ២២,៩ គ.ម/ម៉ នៅឆ្នាំ២000 ដល់១៤,៦ គ.ម/ម៉ នៅឆ្នាំ២០១២[46] ដែលបញ្ជាក់នូវការកើនឡើងនូវការកកស្ទះចរាចរណ៍។ នៅម៉ោងមមាញឹក ល្បឿនចរាចរណ៍អាចមានលក្ខណៈយឺតខ្លាំងនៅតំបន់កណ្តាល ប្រហែល ១០ គ.ម/ម៉។[47]

ការដឹកជញ្ជូនទំនិញកំពុងមានចំនួនកើនឡើងនៅក្នុងរាជធានីភ្នំពេញ ដោយសារមានការរីកលូតលាស់ផ្នែកសេដ្ឋកិច្ចក្នុងទីក្រុង។ ការដឹកជញ្ជូនទំនិញផ្លូវគោកមានសារៈសំខាន់នៅរាជធានីភ្នំពេញ ដោយមើលឃើញពីបរិមាណចរាចរណ៍ទំនិញកំពុងកើនឡើងយ៉ាងខ្លាំង ជាពិសេសនៅក្នុងតំបន់ដែលបម្រើដល់ឧស្សាហកម្មកម្មន្តសាល (ភាគច្រើននៅក្នុងតំបន់ជាយទីក្រុង)។

រាជធានីភ្នំពេញ បច្ចុប្បន្នមិនទាន់មានប្រព័ន្ធដឹកអ្នកដំណើរសាធារណៈគ្រប់គ្រាន់នៅឡើយទេ។ រថយន្តក្រុង និងសាឡាង គឺជាមធ្យោបាយសាធារណៈដឹកអ្នកដំណើរតែ ២ ប្រភេទគត់ដែលកំពុងដំណើរការ។ ម៉ូតូឌុបវិញ គឺមិនទាន់បានរៀបចំបទប្បញ្ញត្តិសម្រាប់គ្រប់គ្រងជាផ្លូវការនៅឡើយទេ។ ចំនួនម៉ូតូរ៉ឺម៉កកង់បីដែលបានចុះបញ្ជីក៏បានកើនឡើងយ៉ាងខ្លាំងផងដែរក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ ដោយមានចំនួនសរុបប្រមាណ ៦.000គ្រឿង នៅក្នុងទីក្រុង។[48]

ប្រទេសកម្ពុជាមានអត្រាគ្រោះថ្នាក់ចរាចរណ៍កើនឡើងខ្លាំងបើ ដោយមានអត្រាស្លាប់ឡើងដល់ ២.២៣១ នាក់នៅឆ្នាំ២០១៥ ពោលគឺកើនឡើងជាងពាក់កណ្តាលនៃអត្រាស្លាប់ក្នុងឆ្នាំ២០០៦[49] ក្នុងនោះអ្នកប្រើប្រាស់ម៉ូតូ និងរឺម៉កកង់បី (តុក តុក) មានចំណែក ៧៧% នៃរបួសធ្ងន់ និង ៦៨% នៃអ្នកស្លាប់ពីគ្រោះថ្នាក់ចរាចរណ៍ ហើយគ្រោះថ្នាក់ម៉ូតូភាគច្រើនកើតឡើងនៅរាជធានីភ្នំពេញ។ មូលហេតុនាំមុខគេពីរនៃការស្លាប់គឺការបើកបរលឿន (៥១%) និងការពិសារគ្រឿងស្រវឹង (១៨%)។[50&51]

## គោលនយោបាយ និងក្របខណ្ឌបទប្បញ្ញត្តិ

ផែនការមេមធ្យោបាយដឹកជញ្ជូនទីក្រុង នៅរាជធានីភ្នំពេញ ឆ្នាំ២០៣៥ ត្រូវបានព្រាងឡើង ដើម្បីជួយដោះស្រាយបញ្ហាដឹកជញ្ជូនបច្ចុប្បន្ន និងគាំទ្រដល់ចក្ខុវិស័យទីក្រុង នៅក្នុងផែនការមេស្តីពីការប្រើប្រាស់ដីធ្លី ឆ្នាំ២០៣៥ (សូមមើលផ្នែក ៤.២)។ បេសកកម្មនៃផែនការមេមធ្យោបាយដឹកជញ្ជូនទីក្រុង ឆ្នាំ២០៣៥ មានពីរផ្នែក៖

១. ផ្លាស់ប្តូរពីប្រព័ន្ធដឹកជញ្ជូនទីក្រុងឯកជនទៅជាប្រព័ន្ធដឹកជញ្ជូនសាធារណៈ និងឯកជន ដែលមានតុល្យភាពគ្នា តាមរយៈការបញ្ចូលគ្នានូវផ្លូវថ្នល់ មធ្យោបាយដឹកជញ្ជូនសាធារណៈ និងការគ្រប់គ្រងចរាចរណ៍ដើម្បីកែលម្អការធ្វើដំណើររបស់ប្រជាពលរដ្ឋ និង
២. សម្រេចសក្តានុពលទីក្រុងនៃរាជធានីភ្នំពេញ។

---

46 ប្រភពដូចកំណត់សំគាល់លេខ ៤៨ ខាងលើ
47 ប្រភពដូចកំណត់សំគាល់លេខ ៤៨ ខាងលើ
48 បប្រភពដូចកំណត់សំគាល់ខាងលើ
49 ឯកសារសិក្សាស្រាវជ្រាវរបស់ Kitamura, Y., Hayashi, M., & Yagi, E. (2018). Traffic problems in Southeast Asia featuring the case of Cambodia's traffic accidents involving motorcycles. IATSS Research.
50 តួរលេខទទួលបានពីកាសែតភ្នំពេញប៉ុស្ត៍ (Phnom Penh Post) ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៤ ទទួលបានតាមរយៈ http://www.phnompenhpost.com/national/road-deaths-rise-minister
51 បន្ទាប់ពីការបញ្ចូលច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកនៅឆ្នាំ២០០៩ អ្នកបើកបរម៉ូតូត្រូវបានតម្រូវឱ្យពាក់មួកសុវត្ថិភាព ហើយច្បាប់នេះកំពុងត្រូវបានអនុវត្តនៅរាជធានីភ្នំពេញ ទោះបីជាមានភាពមិនច្បាស់លាស់ថាតើច្បាប់នេះមានផលប៉ះពាល់អ្វីខ្លះទៅលើការកាត់បន្ថយការគ្រោះថ្នាក់។

ផែនការមេដឹកជញ្ជូនទីក្រុង ឆ្នាំ២០៣៥ ផ្អែកលើផែនការមេដឹកជញ្ជូនទីក្រុងដំបូង ឆ្នាំ២០១៥ នៅរាជធានីភ្នំពេញ ដែលត្រូវបានបង្កើតនៅឆ្នាំ២០០១ ដោយមានជំនួយពីទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន។ ផែនការមេឆ្នាំ ២០០១ ត្រូវបានអនុវត្តមួយផ្នែក ដែលនាំឱ្យមានការដំឡើងសញ្ញាចរាចរណ៍នៅផ្លូវបំបែកសំខាន់ៗ។ ការដំឡើងនេះបានជួយសម្រួលបញ្ហាចរាចរណ៍បានមួយកម្រិត ប៉ុន្តែកង្វះមធ្យោបាយដឹកជញ្ជូនសាធារណៈមិនត្រូវបានដោះស្រាយនៅឡើយ។ ផែនការមេដឹកជញ្ជូនក្នុងទីក្រុង ឆ្នាំ២០៣៥ ព្យាយាមបង្កើនការប្រើប្រាស់មធ្យោបាយដឹកជញ្ជូនសាធារណៈអោយបានច្រើនជាង ៣០% នៃប្រភេទមធ្យោបាយដឹកជញ្ជូនសរុបនៅឆ្នាំ២០៣៥។ កិច្ចការនេះអាចសម្រេចបានដោយការបង្កើតនូវវិធានការមួយចំនួន ដូចជាការបង្កើត (ក្នុងចំណោមវិធានការផ្សេងទៀត) ផ្លូវរត់សម្រាប់តែរថយន្តក្រុងចំនួន១០ខ្សែ នៅឆ្នាំ២០២០ ដែលជាផ្នែកមួយនៃផែនការរៀបចំប្រព័ន្ធចរាចរណ៍រហ័សរបស់រថយន្តក្រុង (bus rapid transit scheme) និងប្រព័ន្ធផ្លូវរថភ្លើងដឹកជញ្ជូន សាធារណៈក្រោមដី (underground elevated rail transit system) នៅឆ្នាំ២០៣៥។

នៅកម្រិតថ្នាក់ជាតិ ការគ្រប់គ្រងចំណត និងចិញ្ចើមផ្លូវមានចែងនៅក្នុងច្បាប់ចរាចរណ៍ផ្លូវគោក (២០១៥) ច្បាប់ផ្លូវគោក (២០១៤) និងអនុក្រឹត្យ លេខ៨២ ស្តីពី នគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន (២០១៥)។ ក្រសួងសាធារណការ និងដឹកជញ្ជូនក៏បានបង្កើតផែនការសកម្មភាពស្តីពីការប្រែប្រួលអាកាសធាតុសម្រាប់វិស័យដឹកជញ្ជូនផងដែរ (២០១៤-២០១៨) ដែលកំណត់នូវសកម្មភាពអាទិភាពជាច្រើនសម្រាប់ការដឹកជញ្ជូនបៃតង រួមទាំងតម្រូវការប្រព័ន្ធដឹកជញ្ជូនសារធាតុរួមបញ្ចូលនៅក្នុងទីក្រុងធំៗក៏ដូចជាការលើកកម្ពស់ការថែទាំ និងការត្រួតពិនិត្យយានយន្តផងដែរ។

## បញ្ហាប្រឈមសំខាន់ៗ

ការផ្តល់ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន មិនអាចតាមទាន់ការកើនឡើងយ៉ាងឆាប់រហ័សនូវបរិមាណចរាចរណ៍ឡើយ។ ដោយធៀបនឹងទីក្រុងផ្សេងទៀតនៅក្នុងតំបន់រាជធានីភ្នំពេញមានដង់ស៊ីតេផ្លូវថ្នល់ទាប ជាពិសេសនៅខាងក្រៅតំបន់កណ្តាលទីក្រុង (ខណ្ឌកណ្តាលក្រុងមានផ្លូវថ្នល់ ៩៤%)។ គម្រោងលំនៅដ្ឋានមួយចំនួនកំពុងត្រូវបានបន្តធ្វើនៅតំបន់ជាយក្រុង ដោយមិនបានធ្វើការពិចារណាដល់លទ្ធភាពប្រើប្រាស់បណ្តាញផ្លូវថ្នល់ និងការរីកសាយចរាចរណ៍។ ស្រដៀងគ្នានេះដែរ កង្វះខាតការធ្វើផែនការសម្រាប់យានយន្តធុនធ្ងន់ដែលបម្រើដល់រោងចក្រ និងដេប៉ូគ្រឿងសំណង់បាននាំឱ្យមានការចុះទ្រុឌទ្រោមផ្លូវថ្នល់នៅតំបន់មួយចំនួន។

មានបញ្ហាប្រឈមជាច្រើនដែលត្រូវបានកំណត់នៅក្នុងការគ្រប់គ្រងចរាចរណ៍នៅរាជធានីភ្នំពេញ ដូចជាៈ ផ្លូវបំបែកដែលចោទជាបញ្ហា ប្រព័ន្ធដាក់សញ្ញាធ្វើដំណើរមិនគ្រប់គ្រាន់ កង្វះការដាក់សញ្ញាសម្គាល់ផ្លូវថ្នល់ និងចំណតមិនមានការត្រួតពិនិត្យ។ កន្លែងចតមិនគ្រប់គ្រាន់នៅតំបន់កណ្តាលទីក្រុងកំពុងក្លាយជាបញ្ហាចោតខ្លាំងដែលនាំឱ្យអ្នកបើកបរចតនៅលើផ្លូវថ្នល់ ឬនៅលើចិញ្ចើមផ្លូវ ដែលធ្វើឱ្យរាំងស្ទះផ្លូវថ្មើរជើង។ លើសពីនេះទៀត ចិញ្ចើមផ្លូវសម្រាប់ថ្មើរជើងនៅរាជធានីភ្នំពេញត្រូវបានបាត់បង់មួយចំនួនដោយសារការពង្រីកផ្លូវសម្រាប់រថយន្ត។ ការអនុវត្តបទប្បញ្ញត្តិស្តីពីការចតយានយន្ត គឺជាបញ្ហាប្រឈមចម្បង។ ការដឹកជញ្ជូនទំនិញក៏កំពុងប្រឈមមុខនឹងបញ្ហា ដូចជាការខូចខាតផ្លូវថ្នល់ និងកង្វះលំហក្រៅផ្លូវសាធារណៈសម្រាប់ការរើទំនិញចុះ។

ប្រព័ន្ធបណ្តាញដឹកជញ្ជូនកំពុងស្ថិតក្រោមសម្ពាធកាន់តែខ្លាំងនៅរាជធានីភ្នំពេញដែលមានផលប៉ះពាល់កើនឡើងសម្រាប់សេដ្ឋកិច្ច (រូបថតដោយ GGGI)។


© GGGI

## ៤.៥.៥ បរិស្ថានសំណង់

បរិស្ថានសំណង់នៅរាជធានីភ្នំពេញរួមមាន រចនាបទស្ថាបត្យកម្ម និងរចនាបទលំនៅដ្ឋានជាច្រើនប្រភេទ។ សំណង់អគារ និងវីឡាដែលមានរចនាបទសម័យអាណានិគមបារាំងគឺមានច្រើននៅពាសពេញទីក្រុងផងដែរ។ ពេលនេះ អគារទាំងនេះមួយចំនួនត្រូវបានស្តារឡើងវិញ ប៉ុន្តែអគារជាច្រើនត្រូវបានបំផ្លាញ ឬមានភាពទ្រុឌទ្រោម។ បច្ចុប្បន្ន សំណង់ផ្ទះសម្បែងទូទៅ គឺរួមមានផ្ទះបើកអាជីវកម្មតាមរចនាបទចិន ឬវីឡាទោលនៅដាច់តែឯង។ ផ្ទះបើកអាជីវកម្មមានចំនួនច្រើនជាងគេបំផុត ព្រោះផ្ទះប្រភេទនេះមានតម្លៃធូរថ្លៃ និងអាចប្រើប្រាស់បានសម្រាប់បើកអាជីវកម្មផង និងជួលបន្តជាបន្ទប់តូចៗផង។

ថ្មីៗនេះ មានការវិនិយោគយ៉ាងច្រើនទៅលើប្រភេទអគារប្រណិតខ្ពស់ៗ (Apartments) មណ្ឌលកម្សាន្ត អគារពាណិជ្ជកម្ម និងទីក្រុងរណប។ ហេដ្ឋារចនាសម្ព័ន្ធសំណង់ប្រភេទទាំងនេះនឹងមានតម្រូវការប្រើប្រាស់ថាមពលច្រើនបើមិនមានវិធានការ ឬគោលការណ៍សន្សំសំចៃថាមពល និងប្រសិទ្ធភាពថាមពលត្រូវបានបញ្ចូលទៅក្នុងបែបបទ ឬបទដ្ឋាននៃការសាងសង់ និងប្រតិបត្តិការរបស់សំណង់អគារប្រភេទនេះទេ តម្រូវការថាមពលក្នុងវិស័យនេះនឹងបន្តកើនឡើងជាលំដាប់។ ឧទាហរណ៍គម្រោងសាងសង់ថ្មីៗនៅរាជធានីភ្នំពេញរួមមានសំណង់អគារនៅតំបន់កោះពេជ្រ អគារស្នាក់នៅ Bodaiju និងក្រុង Booyoung ជាដើម។ ការប្រែប្រួលអាកាសធាតុ ការកើនឡើងសីតុណ្ហភាព និងការជន់លិចដែលបានព្យាករណ៍ទុកមុននោះអាចកាត់បន្ថយភាពធន់របស់អគារក្នុងទីក្រុង។ ការខូចខាតផ្នែករចនាសម្ព័ន្ធអាចកើតឡើងដោយសារហេតុការណ៍នៃការជន់លិចធ្ងន់ធ្ងរ និងញឹកញាប់នៅពេលអនាគត។ បទដ្ឋានគតិយុត្តនៃសំណង់គេហដ្ឋានមានភាពធន់នឹងការប្រែប្រួលអាកាសធាតុ អាចកាត់បន្ថយហានិភ័យដល់ប្រជាជនក្នុងរាជធានីភ្នំពេញ។ នេះគឺជាបញ្ហាប្រឈមដោយឡែកមួយសម្រាប់លំនៅដ្ឋាននៅតំបន់ជាយក្រុង ដែលគេហដ្ឋានសម្រាប់ស្នាក់នៅសមរម្យមានភាពខ្វះខាត។ គ្រួសារដែលត្រូវបានបណ្តេញចេញជាញឹកញាប់ត្រូវសាងសង់ផ្ទះរបស់ខ្លួនពីសម្ភារដែលត្រូវបានកែច្នៃឡើងវិញ ដែលនេះកាន់តែមានភាពងាយរងគ្រោះខ្លាំងចំពោះហេតុការណ៍នៃការជន់លិចទីក្រុង។

## គោលនយោបាយ និងក្របខណ្ឌបទប្បញ្ញត្តិ

អនុក្រឹត្យលេខ៤៣ស្តីពីការរៀបចំរាជធានី ក្រុង និងតំបន់ទីក្រុង គ្របដណ្តប់ការប្រើប្រាស់ដីធ្លី នៅក្នុងដីឡូត៍សាងសង់ និងកំណត់ព្រំដែននៃកន្លែងដាក់សម្ភារសំណង់នៅក្នុងក្បាលដី ដើម្បីធានាថាមានកន្លែងទំនេរគ្រប់គ្រាន់សម្រាប់ដើមឈើ និងសួនច្បារ។ អត្ថប្រយោជន៍នៃអនុក្រឹត្យនេះ មានដូចតទៅ៖ បរិស្ថានសំណង់មានលក្ខណៈត្រជាក់ និងបរិយាកាសល្អ ទីធ្លាអាចបំពាក់ប្រព័ន្ធរំដោះទឹកភ្លៀងនៅនឹងទីតាំងផ្ទាល់ដែលអាចជួយកាត់បន្ថយការជន់លិច អគារលំនៅដ្ឋានត្រូវបានសាងសង់ជាប្លុកៗមានទីធ្លាទំនេរដោយបញ្ចៀសការរស់នៅកកកុញ ពោលគឺបង្កើតទីធ្លាទំនេរអោយច្រើនដើម្បីបង្កើតជាច្រករបៀងខ្យល់ចេញចូលធម្មជាតិ។

បច្ចុប្បន្ន ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ កំពុងកែសម្រួលច្បាប់សំណង់ដើម្បីដាក់បញ្ចូលក្ខខណ្ឌស្តីពីសុខភាព និងសុវត្ថិភាព។[52] រាជរដ្ឋាភិបាលកម្ពុជាបានទទួលស្គាល់ថា កង្វះលំនៅដ្ឋានមានតម្លៃសមរម្យ គឺជាបញ្ហានៃការអភិវឌ្ឍវិស័យនគរូបនីយកម្ម ហើយបានអនុម័តគោលនយោបាយជាតិស្តីពីការអភិវឌ្ឍលំនៅដ្ឋានតម្លៃសមរម្យ (ឆ្នាំ២០១៧)។ គោលដៅនៃគោលនយោបាយនេះគឺដើម្បីផ្តល់ដល់គ្រួសារដែលមានប្រាក់ចំណូលទាប និងមធ្យម និងក្រុមងាយរងគ្រោះនូវលទ្ធភាពទទួលបានលំនៅដ្ឋានសមរម្យ ឬការកែលម្អលំនៅដ្ឋានបច្ចុប្បន្ន។ គោលនយោបាយនេះមានលក្ខណៈបរិយាប័ន្ន និងអំពាវនាវឱ្យមានកិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល អង្គការមនុស្សធម៌ វិស័យឯកជន និងអាជ្ញាធរថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិផងដែរ។ [53 & 54]

ថ្មីៗនេះក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ (MLMUPC) ក៏បានប្រឹងប្រែងដោះស្រាយ និងបំពេញតម្រូវការរបស់គ្រួសារងាយរងគ្រោះក្នុងទីក្រុង តាមរយៈផែនការសកម្មភាពស្តីពីការប្រែប្រួលអាកាសធាតុ ឆ្នាំ២០១៥-២០១៨ របស់ខ្លួនផងដែរ។ ផែនការសកម្មភាពនេះ បានជំរុញឱ្យមានទីជម្រកសមរម្យសម្រាប់គ្រួសារដែលមានប្រាក់ចំណូលទាប និងងាយរងគ្រោះ ព្រមទាំងកំណត់ចក្ខុវិស័យថា ការរៀបចំអគារបៃតង និងបច្ចេកទេសកាបូនទាបត្រូវតែកំណត់នៅក្នុងក្រមស្តីពីការសាងសង់នាពេលអនាគត។

## បញ្ហាប្រឈមសំខាន់ៗ

ទោះបីមានកិច្ចខិតខំប្រឹងប្រែងនៅក្នុងក្របខណ្ឌគោលនយោបាយដើម្បីការអភិវឌ្ឍលំនៅដ្ឋានតម្លៃសមរម្យក៏ដោយ ក៏ការផ្គត់ផ្គង់លំនៅដ្ឋានប្រភេទនេះនៅតែមានចំនួនមិនគ្រប់គ្រាន់នៅឡើយ។ គម្រោងអភិវឌ្ឍលំនៅដ្ឋានថ្មីៗស្ទើរតែទាំងអស់នៅក្នុងរាជធានីភ្នំពេញ គឺបានផ្តោតទៅលើអ្នកដែលមានប្រាក់ចំណូលខ្ពស់ និងជនបរទេស ដែលវាជាកត្តាប្រឈមធ្វើអោយការផ្គត់ផ្គង់លំនៅដ្ឋានតម្លៃសមរម្យនៅមានកម្រិត។ ដំណោះស្រាយ គឺត្រូវធ្វើយ៉ាងណាឱ្យគម្រោងវិនិយោគសាងសង់លំនៅដ្ឋានមានតម្លៃសមរម្យ និងមានលក្ខណៈបៃតងក្លាយជាអាទិភាពមួយរបស់រាជរដ្ឋាភិបាល ដើម្បីអោយមានភាពទាក់ទាញចំពោះវិនិយោគិនឯកជន។ ផ្ទះបើកអាជីវកម្មបច្ចុប្បន្នដែលមានតម្លៃសមរម្យ គឺមិនបានរចនាសាងសង់អោយស្របទៅនឹងបទដ្ឋានពាក់ព័ន្ធនឹងប្រសិទ្ធភាពថាមពល និងការតម្រូវអោយមានខ្យល់ចេញចូលធម្មជាតិឡើយ។ អ្នកធ្វើការដែលមានប្រាក់ចំណូលទាបមាននិន្នាការជួលបន្ទប់នៅក្នុងផ្ទះដែលមានមនុស្សច្រើនកុះករ និងបញ្ហាហប់ខ្យល់ដែលអាចបង្កឱ្យមានគ្រោះថ្នាក់ដល់អ្នកស្នាក់នៅ។ លើសពីនេះទៀត ផ្ទះបើកអាជីវកម្មភាគច្រើនត្រូវបានសាងសង់នៅជាប់នឹងចិញ្ចើមផ្លូវ ដោយមិនទុកលំហសម្រាប់តំបន់បៃតង ឬដើមឈើឡើយ។[55]

ខណៈពេលដែលការរីកដុះដាលយ៉ាងរហ័សនៃវិស័យសំណង់ មានឯកសារតិចតួចបំផុតដែលត្រូវបានចងក្រងស្តីអំពីទស្សនទាននៃការរចនាសំណង់អគារបៃតង[56] ហើយបញ្ចូលទៅក្នុងផែនការជាតិស្តីពីស្ថាបត្យកម្ម និងការគ្រប់គ្រងសំណង់អគារ។ ដោយមានការធ្វើបច្ចុប្បន្នភាពក្រមស្តីពីសំណង់អគារ គឺយើងមានឱកាសក្នុងការដាក់បញ្ចូលទស្សនទានស្តីពីអគារបៃតងទៅក្នុងក្រម។

[52] ឯកសារបទបង្ហាញរបស់តំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ស្តីពីបទប្បញ្ញត្តិនៃការកំណត់ក្រមនៃសំណង់អគារ

[53] ឯកសារស្តីពីការតាំងទីលំនៅថ្មី ដោយ UNOHCHR ប្រចាំនៅប្រទេសកម្ពុជា ឆ្នាំ ២០១២ ដែលទទួលបានតាមរយៈ http://cambodia.ohchr.org/WebDOCs/DocProgrammes/Resettlement_Study-28_Feb_2012_Eng.pdf

[54] គោលនយោបាយស្តីពីលំនៅដ្ឋាន ឆ្នាំ២០១៤ តាមរយៈ http://giz-cambodia.com/wordpress/wp-content/uploads/9-Summer-School_Beng-Hong-Socheat-Khemaro.pdf

[55] ប្រភពដូចកំណត់សំគាល់លេខខាងលើ

ប្លង់សាងសង់បៃតងមានភាពច្បាស់លាស់រួចហើយនៅក្នុងអគារមួយចំនួននៅរាជធានីភ្នំពេញ។ ប្លង់នេះអនុញ្ញាតឱ្យសន្សំសំចៃអគ្គិសនី តាមរយៈការប្រើប្រាស់ប្រព័ន្ធផ្តល់ភាពត្រជាក់ធម្មជាតិ (រូបថតដោយ **GGGI**)។




## ៤.៥.៦ កម្មន្តសាល

វិស័យកម្មន្តសាល (ផលិតកម្ម) គឺជាវិស័យចូលរួមចំណែកដ៏សំខាន់មួយក្នុងកំណើនសេដ្ឋកិច្ចប្រទេសកម្ពុជា។ វិស័យនេះមានចំណែកធំជាងគេបំផុតនៃកំណើនផលិតភាពនៅក្នុងប្រទេស ដោយ កើនឡើងក្នុងអត្រាប្រមាណ ១១% ក្នុងមួយឆ្នាំ ចាប់ពីឆ្នាំ២០១០–២០១៥។ បច្ចុប្បន្ន វិស័យនេះមានប្រមាណជា ៣២% នៃផលិតផលក្នុងស្រុកសរុបនៃប្រទេសកម្ពុជា។[57] សហគ្រាសកម្មន្តសាលធំៗនៃប្រទេសកម្ពុជាប្រមូលផ្តុំគ្នាទៅតាមទីតាំងភូមិសាស្ត្រ ក្នុងនោះ ៦៨% ស្ថិតនៅរាជធានីភ្នំពេញ និង ១៣% បន្ថែមទៀតស្ថិតនៅជាប់នឹងខេត្តកណ្តាល។[58]

ការផលិតសម្លៀកបំពាក់ គឺជាអនុវិស័យកម្មន្តសាលធំជាងគេនៅក្នុងប្រទេសកម្ពុជា ដែលមានចំនួន១៥,៥% នៃផលិតផលក្នុងស្រុកសរុបនៅក្នុងឆ្នាំ២០១៥ ហើយអត្រាកំណើនអនុវិស័យត្រូវបានគ្រោងថានឹងខ្ពស់ជាងអត្រាកំណើនផលិតផលក្នុងស្រុកសរុបរហូតដល់ឆ្នាំ២០១៩។[59] ទាំងចំនួន រោងចក្រផលិតសម្លៀកបំពាក់ និងចំនួនប្រជាពលរដ្ឋដែលបម្រើការងារនៅក្នុងវិស័យនេះបានកើនឡើងនៅក្នុងឆ្នាំ២០១២-២០១៥។ នៅទូទាំងប្រទេស វិស័យនេះបានជ្រើសរើសកម្មករឱ្យបម្រើការងារចំនួនប្រមាណ៨០%នៃកម្លាំងពលកម្មមិនមែនកសិកម្ម ដែលក្នុងនោះចំនួន៨៦% គឺជាស្ត្រី។[60]

[56] ប្លង់អគារបៃតងសំដៅដល់រចនាសម្ព័ន្ធផង និងការប្រើប្រាស់ដំណើរការដែលមានការទទួលខុសត្រូវផ្នែកបរិស្ថាន និងមានប្រសិទ្ធភាពធនធាននៅក្នុងអាយុកាលប្រើប្រាស់អគារ៖ ចាប់ពីការអង្គុយគូរប្លង់សាងសង់ ប្រតិបត្តិការ ការថែទាំ ការជួសជុល និងការបំផ្លាញ។ និយាយម្យ៉ាងទៀត ប្លង់អគារបៃតងមានការពាក់ព័ន្ធនឹងការរកឃើញតុល្យភាពរវាងអគារផ្ទះ និងបរិស្ថានប្រកបដោយនិរន្តរភាព។

[57] របាយការណ៍ពីធនាគារពិភពលោក ឆ្នាំ២០១៨. World Bank Database. Washington, D.C.: The World Bank. URL: http://data.worldbank.org/indicator/NV.IND.TOTL.ZS.

[58] របាយការណ៍ពី Central Intelligence Agency (CIA) ឆ្នាំ ២០១៥ តាមរយៈគេហទំព័រ https://www.cia.gov/library/ publications/the-world-factbook/geos/cb.html

[59] របាយការណ៍ពីវិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ ឆ្នាំ ២០១៥

[60] របាយការណ៍ពីអង្គការ ILO ឆ្នាំ២០១៥ តាមរយៈគេហទំព័រ http://betterfactories.org/?p=10557

ការបំពុលគឺជាបញ្ហាដែលកំពុងកើនឡើងសម្រាប់វិស័យកម្មន្តសាលនៅក្នុងទីក្រុង។ ការបំពុលរួមមានសារធាតុបំពុលខ្យល់ពីការផលិតថាមពល (រួមបញ្ចូលទាំងការផលិតថាមពលក្រៅបណ្តាញ និងការផលិតថាមពលបម្រុងដោយប្រើម៉ាស៊ូត) សំរាម និងសំណល់គ្រោះថ្នាក់ ការបំពុលដោយសំឡេង និងការបំពុលទឹកធ្ងន់ធ្ងរ។ ទោះបីជាមិនមានតួរលេខលម្អិតអំពីបញ្ហាបំពុលដោយសារវិស័យកម្មន្តសាលក៏ដោយ ការប៉ាន់ស្មានការបំពុលទឹកត្រូវបានធ្វើឡើងដោយប្រើតួរលេខនៃការប្រើប្រាស់ទឹកដែលរកបានពីរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (PPWSA) សម្រាប់ពាណិជ្ជកម្ម និងឧស្សាហកម្ម (រូបភាពទី៥)។

រូបភាពទី៥៖ ការបង្ហូរទឹកកខ្វក់ដែលត្រូវបានប៉ាន់ស្មានពីពាណិជ្ជកម្ម និងឧស្សាហកម្មនៅរាជធានីភ្នំពេញ ឆ្នាំ២០០៤-២០១៣




*ប្រភព៖ ការគណនារបស់ក្រុមការងារគម្រោងដោយផ្អែកលើតួលេខរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ដែលមាននៅក្នុងរបាយការណ៍ JICA ២០១៥a.*

## គោលនយោបាយ និងក្របខណ្ឌបទប្បញ្ញត្តិ

ច្បាប់*ស្តីពីគ្រប់គ្រងរោងចក្រ និងសិប្បកម្ម (២០០៧)* គ្របដណ្តប់លើការបង្កើត និងប្រតិបត្តិការរោងចក្រ។ ច្បាប់នេះចែងអំពីខ្លឹមសារខាងក្រោម៖

- កម្រាលរោងចក្រមិនត្រូវមានផ្សែង ល្អងធូលី និងគ្រឿងបំពុលផ្សេងៗទៀតឡើយ
- សំណល់ឧស្សាហកម្មគួរបញ្ចេញស្របទៅតាមស្តង់ដារ និងបទប្បញ្ញត្តិរបស់ "ស្ថាប័នមានសមត្ថកិច្ច"
- ហាមដាច់ខាតចំពោះការបញ្ចេញសំណល់ពុលឧស្សាហកម្ម និងសារធាតុគ្រោះថ្នាក់ដោយ ពុំបានធ្វើប្រព្រឹត្តកម្មជាមុន
- ការគ្រប់គ្រងសំណល់ឧស្សាហកម្មគឺជាការទទួលខុសត្រូវរបស់ម្ចាស់រោងចក្រ និងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល (បច្ចុប្បន្នក្រសួងឧស្សាហកម្ម និងសប្បកម្ម) មានសិទ្ធិក្នុងការដាក់ពិន័យ ព្យួរ ឬបញ្ឈប់ដំណើរការរោងចក្រប្រសិនបើបទប្បញ្ញត្តិបរិស្ថានមិនត្រូវបានអនុវត្តតាម។[61]

[61] ច្បាប់ស្តីពីរដ្ឋបាលរោងចក្រ និងសិប្បកម្ម ឆ្នាំ ២០០៧(b) ដោយរាជរដ្ឋាភិបាលកម្ពុជា ទទួលបានតាមរយៈគេហទំព័រ៖ http://www.opendevelopmentcambodia.net/pdf-viewer/?pdf=download/law/Law_on_Administration_of_ Factory_and_Handicraft_23_June_2006_Eng.pdf

*គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម របស់ប្រទេសកម្ពុជា២០១៥-២០២៥* បានដាក់ចេញនូវចក្ខុវិស័យក្នុងការធ្វើទំនើបកម្មមូលដ្ឋានឧស្សាហកម្មរបស់ប្រទេស ព្រមទាំងការបង្កើនការនាំចេញផលិតផលក្រៅពីសម្លៀកបំពាក់។[62] គោលបំណងមួយនៃគោលនយោបាយនេះគឺដើម្បីកាត់បន្ថយចំណែកនៃការនាំចេញសម្លៀកបំពាក់ និងស្បែកជើងរហូតដល់៥០% នៃការនាំចេញទំនិញសរុបនៅត្រឹមឆ្នាំ២០២៥។ គោលនយោបាយនេះក៏មានគោលដៅក្នុងការពង្រឹងការអភិវឌ្ឍជំនាញដើម្បីជានាស្ថិរភាពការផ្គត់ផ្គង់ពលកម្ម កំណើនផលិតភាព និងការលើកកម្ពស់កម្រិតជីវភាពរបស់កម្មករនិយោជិកផងដែរ។[63]

ស្តង់ដារនៃការបញ្ចេញទឹកត្រូវបានបញ្ចូលទៅក្នុងអនុក្រឹត្យស្តីពីការបំពុលទឹកលេខ២៧ *ស្តីពីការគ្រប់គ្រងលើការបំពុលទឹក (១៩៩៩)* ដែលកំណត់កម្រិតអប្បបរមា (បទដ្ឋាន) សម្រាប់ការបញ្ចេញទឹកសំណល់ទៅក្នុងបរិស្ថានស្របទៅតាមច្បាប់*ស្តីពីការការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ (១៩៩៦)* រួមទាំងលក្ខខណ្ឌតម្រូវផ្សេងៗក្នុងការធ្វើប្រព្រឹត្តកម្មទឹកផងដែរ ដើម្បីឱ្យស្របទៅតាមបទដ្ឋាននៃការបញ្ចេញ។ បទដ្ឋាននៃការបំពុលខ្យល់ និងសំឡេងមានចែងនៅក្នុងអនុក្រឹត្យលេខ៤២ *ស្តីពីការគ្រប់គ្រងការបំពុលខ្យល់ និងការរំខានដោយសំឡេង។*

## បញ្ហាប្រឈមសំខាន់ៗ

សម្រាប់វិស័យកម្មន្តសាលរបស់ប្រទេសកម្ពុជា បញ្ហាប្រឈមដែលត្រូវដោះស្រាយដើម្បីអោយមាននិរន្តរភាពក្នុងវិស័យនេះរួមមាន ការកាត់បន្ថយការបំពុល ការកាត់បន្ថយការប្រើប្រាស់ថាមពលតាមរយៈវិធានការប្រសិទ្ធភាពថាមពល និងការសន្សំសំចៃថាមពល ការថែរក្សាសុខភាព និងពង្រឹងសុវត្ថិភាពការងារ ព្រមទាំងការកែលម្អលក្ខខណ្ឌការងារផងដែរ។ ការតាមដាន និងការអនុវត្តបទដ្ឋានគ្រប់គ្រងការបំពុលតម្រូវឱ្យមានការពង្រឹងបន្ថែមទៀត។

បញ្ហាបរិស្ថានសំខាន់ចំពោះវិស័យកាត់ដេររួមមាន ការបំពុលខ្យល់ ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ (Green House Gas - GHG) ពីឡកម្តៅ និងសំណល់រាវដែលអាចមានជាតិពុលចេញពីដំណើរការលាយពណ៌ និងដាក់ថ្នាំឱ្យមានពណ៌ស។[64] ឧស្សាហកម្មទាំងនេះក៏ប្រើប្រាស់ថាមពលច្រើនដែរ និងជាទូទៅធ្វើប្រតិបត្តិការដោយប្រើប្រាស់បរិក្ខារចាស់ៗ និងគ្មានប្រសិទ្ធភាព។ លើសពីនេះទៀត ការផ្តល់នូវការបញ្ចេញបញ្ចូលខ្យល់នៅកន្លែងធ្វើការគ្រប់គ្រាន់ និងការបញ្ចៀសការប្រឈមរបស់កម្មករទៅនឹងសារធាតុគីមីពុលមានការចាំបាច់ដើម្បីកែលម្អបរិយាកាសធ្វើការ។

បញ្ហាមួយផ្សេងទៀត គឺការបោះទីតាំងរោងចក្រកម្មន្តសាលនៅក្នុងតំបន់ទីក្រុងពហុបំណង ដូចជានៅជាប់នឹងការប្រើប្រាស់ដីលំនៅដ្ឋាន និងកសិកម្ម។ ក្នុងកាលៈទេសៈទាំងនេះ ការបញ្ចេញសារធាតុបំពុលពីរោងចក្រអាចបណ្តាលឱ្យមានបញ្ហាច្រើនចំពោះប្រជាជនដែលរស់នៅ និងធ្វើការនៅក្បែរនោះ។ នេះគឺជាប្រភពសំខាន់នៃបណ្តឹងទៅអាជ្ញាធរទីក្រុង។ ស្រដៀងគ្នានេះដែរ ការបោះទីតាំងរោងចក្រកម្មន្តសាលនៅតំបន់ដែលមិនមានបណ្តាញផ្លូវដឹកជញ្ជូនសមស្រប អាចបង្កបញ្ហាកកស្ទះចរាចរណ៍សម្រាប់តំបន់ជុំវិញទីនោះ។

ការចំណាយលើថាមពល គឺជាបន្ទុកធ្ងន់ធ្ងរមួយសម្រាប់រោងចក្រកាត់ដេរ ទោះបីជាមានតម្លៃអគ្គិសនីចុះថ្លៃក៏ដោយ។ ការចំណាយទៅលើធ្យូង និងអុស (ដែលត្រូវបានប្រើប្រាស់ដើម្បីដាំស៊ីទែនកម្តៅទឹកដើម្បីផ្តល់កម្តៅដល់ឆ្នាំងអ៊ុតប្រើចំហាយ និងអាងជ្រលក់ពណ៌ក្រណាត់) ក៏កំពុងកើនឡើងជានិច្ចផងដែរ។ រោងចក្រដែលត្រូវបានជ្រើសរើសបានអនុវត្តសវនកម្មប្រសិទ្ធភាពថាមពលដែលបានរកឃើញថាការសន្សំសំចៃថាមពល ៣០% អាចសម្រេចបានតាមរយៈការកែលម្អប្រសិទ្ធភាពចំពោះការបំភ្លឺ ស៊ីទែនកម្តៅទឹក វុន្ទខ្យល់ ម៉ាស៊ីនដេរកំប្រែស័រ និងបរិក្ខារផ្សេងទៀត។[65]

[62] គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម ឆ្នាំ២០១៥ ដល់២០២៥ ដោយរាជរដ្ឋាភិបាលកម្ពុជា ទទួលបានតាមរយៈ http://eurocham-cambodia.org/uploads/97dae-idp_19may15_com_official.pdf

[63] ប្រភពដូចចំណុចសំគាល់ខាងលើ

[64] ឧទាហរណ៍ ផែនទីបង្ហាញផ្លូវកំណើនបៃតង់របស់រាជរដ្ឋាភិបាលកម្ពុជាបានកំណត់ការបំពុលពីវិស័យកាត់ដេរថាជាបញ្ហាប្រឈមពាក់ព័ន្ធបំផុតចំពោះកំណើនបៃតងទីក្រុង

[65] ឯកសារវិភាគពីវិស័យឯកជនទៅលើឱកាសនៃការអភិវឌ្ឍបៃតង ដោយ GGGI ឆ្នាំ ២០១៤

### ៤.៥.៧ ការគ្រប់គ្រងសំរាម/សំណល់រឹង

សំរាមនៅរាជធានីភ្នំពេញមានប្រហែល ១,៨៦៨ តោនក្នុងមួយថ្ងៃ (ទិន្នន័យឆ្នាំ២០១៥)។ ការសិក្សាមួយបានសន្និដ្ឋានថា សំរាមប្រហែល ៧២% គឺជាសំរាមសរីរាង្គ។[66] ការវិភាគលម្អិតផ្នែកបច្ចេកទេសបានបង្ហាញពីលក្ខណៈសំរាមនៅរាជធានីភ្នំពេញដូចខាងក្រោម៖

- ចំណុះសារធាតុឆេះ = ៩០% (ដោយសារចំណុះម្ហូបអាហារខ្ពស់នៅក្នុងសំណល់)
- ចំណុះសំណើម = ៦៤%
- តម្លៃកាឡូរី = ១.៥៩៨ គីឡូកាឡូរីក្នុងមួយគីឡូក្រាម និង
- សមាមាត្រកាបូន / អាស៊ូត = ២០:១[67]

ស្ថិតិពីលក្ខណៈរបស់សំរាមអាចបញ្ជាក់ថា សំរាមនៅរាជធានីមានភាពសមស្របក្នុងការធ្វើជាប្រភពបង្កើតថាមពល ឬសម្រាប់ការធ្វើជីកំប៉ុស្ដ៍ប្រើប្រាស់ឡើងវិញបាន។

ការគ្រប់គ្រងសំរាមនៅក្នុងតំបន់ទីក្រុង ត្រូវបានទទួលស្គាល់ពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ថាជាបញ្ហាប្រឈមផ្នែកបរិស្ថានដ៏ចម្បងមួយ ជាពិសេសពាក់ព័ន្ធទៅនឹងកង្វះការប្រមូលសំរាមឱ្យបានគ្រប់ជ្រុងជ្រោយនៅរាជធានីភ្នំពេញ ព្រោះការប្រមូលនៅតំបន់មួយចំនួនក្នុងទីក្រុង គឺនៅមិនទាន់មានសេវាប្រមូលសំរាមទៅដល់ ឬការប្រមូលមានភាពយឺតយ៉ាវ។ ជាលទ្ធផល សំណល់សំរាមជាច្រើនតោនត្រូវបានចាក់គរចោល ឬបោះទៅក្នុងទន្លេ ស្រះ ប្រឡាយ ឬត្រូវបានកប់ក្នុងរណ្ដៅនៅតាមផ្ទះ។ សំរាមដែលមិនបានប្រមូល គឺនៅរាយប៉ាយតាមទីធ្លាផ្លូវសាធារណៈ ហើយជាញឹកញាប់ធ្វើឱ្យស្ទះប្រព័ន្ធលូនៅតាមមូលដ្ឋាន និងបង្កើតជាបរិយាកាសខ្វះអនាម័យ។

ការប្រមូលសំរាមនៅមានកម្រិតនៅតំបន់ជាយរាជធានីភ្នំពេញ ដែលជាតំបន់ប្រជាជនរស់នៅមានមានប្រាក់ចំណូលទាបភាគច្រើន។ តាមរបាយការណ៍សិក្សាមួយបង្ហាញថា ប្រជាជនភាគច្រើនដែលរស់នៅក្នុងខណ្ឌជាយរាជធានីភ្នំពេញ មិនបានទទួលសេវាប្រមូលសំរាមគ្រប់គ្រាន់នៅឡើយ។ ខណ្ឌដែលមានការខ្វះខាតក្នុងការប្រមូលសំរាមជាងគេបំផុតរួមមាន៖ ខណ្ឌឫស្សីកែវ ខណ្ឌមានជ័យ ខណ្ឌច្បារអំពៅ ខណ្ឌជ្រោយចង្វារ និងខណ្ឌដង្កោ។ នៅកន្លែងដែលមិនមានសេវាប្រមូលសំរាម ឬមិនទាន់ពេល ប្រជាពលរដ្ឋជាទូទៅធ្វើការជីករណ្ដៅកប់ទុកចោលតាមដងផ្លូវ ឬដុតចោល។

សំរាមដែលមិនត្រូវបានប្រមូលជាញឹកញាប់បានកកស្ទះនៅក្នុងប្រព័ន្ធបណ្ដាញលូមេ និង បណ្ដាញផ្លូវទឹក (ប្រឡាយធម្មជាតិ)។ នៅពេលមានភ្លៀងខ្លាំង សមត្ថភាពលូបង្ហូរគឺនៅមានកម្រិតដោយសារការស្ទះសំរាមទាំងនោះ។ គេព្យាករណ៍ថា ដោយសារការប្រែប្រួលអាកាសធាតុ ភ្លៀងធ្លាក់កាន់តែខ្លាំង និងមានភាពញឹកញាប់ជាងមុន ដូច្នេះការប្រមូលសំរាម ចាំបាច់ត្រូវធ្វើការកែលម្អឱ្យបានគ្រប់ជ្រុងជ្រោយ និងទាន់ពេលវេលា ដើម្បីធានាថាបណ្ដាញលូក្នុងរាជធានីអាចដំណើរការយ៉ាង ត្រឹមត្រូវដោយមិនមានការកកស្ទះដោយសារសំរាមមិនបានប្រមូល។

សំរាមដែលបានប្រមូល ត្រូវបានដឹកជញ្ជូនទៅកន្លែងចាក់នៅទីលានចាក់សំរាមក្នុងខណ្ឌដង្កោ ដែលមានចម្ងាយ ១៥គម ពីតំបន់កណ្ដាលទីក្រុង។ នៅកន្លែងទីលានចាក់សំរាម សំរាមត្រូវបានចាក់លាយឡំគ្នា។ អ្នករើសសំរាមប្រហែល ៥០០ នាក់ ក្នុងនោះ ៨០% គឺជាស្ត្រីប្រកបរបរចិញ្ចឹមជីវិតតាមរយៈការកែច្នៃឡើងវិញមិនផ្លូវការ (ក្រៅប្រព័ន្ធ) នៅនឹងកន្លែងចាក់សំរាម។[68] ជាញឹកញាប់ គឺមានឃើញកុមារមកតាមម្ដាយរបស់ពួកគេនៅកន្លែងចាក់សំរាម។ នៅខែតុលា ឆ្នាំ២០០៩ រដ្ឋបាលរាជធានីភ្នំពេញបានសាកល្បងធ្វើការកំណត់

[66] ឯកសារបទបង្ហាញស្ដីពី ការគ្រប់គ្រងសំណល់រឹងនៅប្រទេសកម្ពុជា ដោយក្រសួងបរិស្ថាន ឆ្នាំ២០១៥(b) នៅក្នុងសិក្ខាសាលាថ្នាក់តំបន់ស្ដីពីយុទ្ធសាស្ត្រជាតិសម្រាប់ការគ្រប់គ្រងសំណល់រឹងដែលបានប្រព្រឹត្តទៅនៅប្រទេសវៀតណាម កាលពីថ្ងៃទី ២៨-២៩ កក្កដា ២០១០។

[67] របាយការណ៍សិក្សាស្ដីពីការគ្រប់គ្រងសំណល់រឹងទីក្រុងភ្នំពេញ រាជធានីនៃព្រះរាជាណាចក្រកម្ពុជា រៀបចំដោយ លោកបណ្ឌិត សេង ប៊ុនរិទ្ធ, Hidehiro Kaneko, Kimiaki Hirayama និង Keiko Katayama-Hirayama ឆ្នាំ ២០១១។

[68] កិច្ចប្រជុំជាមួយទីចាត់ការគ្រប់គ្រងកាកសំណល់រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៦។

តួនាទី តាមរយៈការចុះបញ្ជីអ្នករើសសំរាមជាផ្លូវការដោយកំណត់តួនាទីរបស់ពួកគេនៅក្នុងវិស័យគ្រប់គ្រងសំរាម ប៉ុន្តែផែនការនេះមិនបានឈានទៅដល់ការចុះបញ្ជីជាផ្លូវការរបស់ក្រុមអ្នករើសសំរាមទេ។[69]

នៅរាជធានីភ្នំពេញ ក្រុមហ៊ុនឯកជន ស៊ីនទ្រី (Cintri Ltd) គឺជាអ្នកគ្រប់គ្រងការប្រមូល និងដឹកជញ្ជូនសំរាម។ នៅឆ្នាំ២០០២ ក្រុមហ៊ុនស៊ីនទ្រី បានចុះកិច្ចព្រមព្រៀងបន្ថែមជាមួយរដ្ឋបាលរាជធានីភ្នំពេញ ដែលផ្តល់ឱ្យក្រុមហ៊ុននេះនូវសិទ្ធិបន្តពីក្រុមហ៊ុន PSBK លើការគ្រប់គ្រងការសម្អាតប្រមូល និងដឹកជញ្ជូនសំណល់រឹងក្នុងទីក្រុងយកទៅចាក់នៅទីលានចាក់សំរាម ដែលមានរយៈពេលរហូតទៅដល់ចុងឆ្នាំ២០៤៨។

## គោលនយោបាយ និងក្របខណ្ឌបទប្បញ្ញត្តិ

មានអាជ្ញាធរ និងស្ថាប័នជាច្រើនធ្វើការពាក់ព័ន្ធនៅក្នុងការគ្រប់គ្រងសំណល់រឹងក្នុងរាជធានីភ្នំពេញ (រូបភាពទី ៦)។ ក្រសួងបរិស្ថានទទួលខុសត្រូវក្នុងការរៀបចំគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងសំណល់ដែលរួមមានការប្រមូល ការដឹកជញ្ជូន ការរក្សាទុក និងការកែច្នៃឡើងវិញ។ ទោះជាយ៉ាងនេះក្តី លទ្ធភាពក្នុងការអនុវត្ត និងតាមដានគោលការណ៍ណែនាំនេះនៅមានកម្រិត។ នៅកម្រិតមូលដ្ឋានទីចាត់ការគ្រប់គ្រងសំណល់ និងបរិស្ថាន នៃរដ្ឋបាលរាជធានីភ្នំពេញ គឺទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់នៅក្នុងរាជធានីភ្នំពេញ។ នៅក្រោមទីចាត់ការមានការិយាល័យចំនួនពីរផ្សេងៗទៀតគឺការិយាល័យបច្ចេកទេសនិងត្រួតពិនិត្យផលប៉ះពាល់បរិស្ថាន និងការិយាល័យគ្រប់គ្រងសំណល់។ ការិយាល័យគ្រប់គ្រងសំណល់ ជាអង្គភាពទទួលខុសត្រូវលើការគ្រប់គ្រងសំណល់ទាំងអស់នៅក្នុង រាជធានីភ្នំពេញ រួមទាំងការសម្អាត ការប្រមូល ការដឹកជញ្ជូន ការចោលសំរាម និងការតាមដានក្រុមហ៊ុនឯកជនប្រមូលសំរាមផងដែរ។ នៅក្រោមរដ្ឋបាលរាជធានីភ្នំពេញ មានអង្គភាពគ្រប់គ្រងទីលានចាក់សំរាមដែលទទួលខុសត្រូវលើប្រតិបត្តិការទីលានចាក់សំរាមក្នុងខណ្ឌដង្កោ។

មន្ទីរបរិស្ថានរាជធានីភ្នំពេញ បានរៀបចំផែនការចំនួន ៨ សម្រាប់កែលម្អការគ្រប់គ្រងសំណល់រឹងនៅក្នុងរាជធានីភ្នំពេញ។ ផែនការទាំងនេះរួមមានដូចខាងក្រោម[70] ៖

- ប្រព័ន្ធទិន្នន័យគ្រប់គ្រងសំណល់
- ការបែងចែកសំណល់
- ការបញ្ចេញ និងការប្រមូលសំណល់
- ការបោះចោលសំណល់នៅទីលានចាក់សំរាមទៅតាមផែនការបែងចែកសំណល់
- ការកែច្នៃ និងការប្រើប្រាស់សំរាមឡើងវិញ
- ការធ្វើប្រព្រឹត្តកម្មសំណល់
- ការកសាងសមត្ថភាព និង
- ការអនុវត្ត និងការដាក់ពិន័យ

[69] ឯកសារក្របខណ្ឌគតិយុទ្ធ និងការរៀបចំស្ថាប័នស្តីពីការគ្រប់គ្រងសំណល់រឹង និងការអភិវឌ្ឍទីលានចាក់សំរាមនៅរាជធានីភ្នំពេញ ដោយអង្គការអប់រំ និងគ្រប់គ្រងសំណល់កម្ពុជា (Cambodia Education and Waste Management Organization) ឆ្នាំ២០១៤

[70] របាយការណ៍សិក្សាស្តីពីការកកើតសំណល់រឹង និងវដ្តនៃជីវិតសំណល់រឹង នៅរាជធានីភ្នំពេញ ដោយ KUOK Federo, IM Makara, HUL Seingheng, and SOY Ty, ឆ្នាំ ២០១៥។

## រូបភាពទី៦៖ អាជ្ញាធរ និងស្ថាប័នពាក់ព័ន្ធគ្រប់គ្រងសំណល់រឹងក្នុងរាជធានីភ្នំពេញ




*ប្រភព៖ ព័ត៌មានពីអង្គការមូលនិធិអាស៊ី និងតាមការប្រជុំពិភាក្សាជាមួយរដ្ឋបាលរាជធានីភ្នំពេញ*

នៅក្នុងអនុក្រឹត្យលេខ ១១៣ អនក្រ/បក ដែលត្រូវបានអនុម័តនៅថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងក្នុងទីប្រជុំជន ត្រូវបានផ្ទេរមជ្ឈការទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ហើយមានគោលដៅពង្រឹងការទទួលខុសត្រូវ ដោយបានផ្លាស់ប្តូរទៅថ្នាក់រាជធានី/ខេត្ត ក្រុង/ស្រុក/ខណ្ឌ។ ជាលទ្ធផល រដ្ឋបាលរាជធានីភ្នំពេញបានផ្ទេរការទទួលខុសត្រូវលើការប្រមូល និងចោលសំរាមទៅឱ្យខណ្ឌទាំង១២។ អនុក្រឹត្យនេះ មានគោលបំណងធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព សំដៅ ធានានូវសោភ័ណ្ឌភាព កិច្ចគាំពារ សុខភាពសាធារណៈ និងបរិស្ថាន។[71]

មានអង្គការជាច្រើនដូចជា UNEP, IGES, COMPED, និង Nexus បានសហការជាមួយនឹងក្រសួងបរិស្ថាន នាយកដ្ឋានសេដ្ឋកិច្ចបៃតងនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព (អ.ក.អ.ច.) និងរដ្ឋបាលរាជធានីភ្នំពេញ បច្ចុប្បន្នកំពុងធ្វើការសិក្សាពីស្ថានភាព និងរៀបចំយុទ្ធសាស្ត្រគ្រប់គ្រងសំរាម សំណល់រឹងសម្រាប់រាជធានីភ្នំពេញដើម្បីគ្រប់គ្រង និងដោះស្រាយហានិភ័យពីការប្រែប្រួលអាកាសធាតុ និងហានិភ័យលើបរិស្ថាន ដែលអាចកើតមាននៅក្នុងដំណើរការទាំងមូលនៃការគ្រប់គ្រងសំរាម ពោលគឺដើម្បីកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពីទីលានចាក់សំរាម និង កែលម្អបែបបទនៃការចោលសំណល់ដែលប្រមូលបានឱ្យមានលក្ខណៈ

[71] អនុក្រឹត្យលេខ ១១៣ អនក្រ.បក ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងនៅទីប្រជុំជន ចុះថ្ងៃទី ២៧ ខែសីហា ឆ្នាំ២០១៥

ស្អុំងដារ និងប្រកបដោយចីរភាពផងដែរ។ ការអនុវត្តយុទ្ធសាស្ត្រនេះនឹងធ្វើឱ្យទីក្រុងកាន់តែស្អាត មិនមានសំរាមតាមទីសាធារណៈ បរិយាកាសកាន់តែមានភាពស្រស់បំព្រង និងពុំមានក្លិនស្អុយ។ ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពីទីក្រុងគួរតែអាចកាត់បន្ថយចំនួនច្រើនជាង ២៥០.០០០តោន នៃឧស្ម័នកាបូនិច ($CO_{2e}$) ក្នុងមួយឆ្នាំនៅត្រឹមឆ្នាំ២០២៥។

## បញ្ហាប្រឈមសំខាន់ៗ

ប្រព័ន្ធនៃការគ្រប់គ្រងសំរាម សំណល់រឹងទីក្រុងនៅរាជធានីភ្នំពេញ គួរតែត្រូវធ្វើការកែលម្អពីដំណាក់កាលដំបូងនៃការកកើតសំរាម រហូតដល់ដំណាក់កាលចុងក្រោយ ពោលគឺការចោលសំរាមនៅទីលានចាក់សំរាម។ នៅដំណាក់កាលដំបូង សំរាមកើតចេញពីការប្រើប្រាស់នៅតាមផ្ទះ និងកន្លែងធ្វើអាជីវកម្ម/ពាណិជ្ជកម្មនានា សំរាមទាំងនោះគួរត្រូវបានធ្វើការបែងចែកទៅតាមប្រភេទសំរាមដើម្បីបង្កភាពងាយស្រួលក្នុងការប្រមូល និងធ្វើការកែច្នៃឡើងវិញ ការយកមកធ្វើជាកំប៉ុស្តិ៍ ឬបម្លែងទៅជាថាមពលប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព។ លើសពីនេះទៀត សំរាមនៅតំបន់ជាយក្រុងមួយចំនួនមិនត្រូវបានប្រមូលទេ ព្រោះក្រុមហ៊ុនប្រមូលសំរាមស៊ីនទ្រីមិនអាចចូលទៅដល់កន្លែងទាំងនោះបាន និងមិនមានសម្ភារបរិក្ខាសម្រួលដល់តំបន់ទាំងនោះក្នុងការទុកដាក់សំរាម។

បញ្ហាប្រឈមផ្សេងទៀត គឺតម្រូវការនូវទីលានចាក់សំរាមដែលមានលក្ខណៈសមស្របផ្នែកបច្ចេកទេស ពោលគឺទីលានចាក់សំរាមដែលមានសក្តានុពលក្នុងការបង្កើត និងប្រតិបត្តិការស្ថានីយ៍ធ្វើជីកំប៉ុស្តិ៍ពីសំរាម និង/ឬរោងចក្រដែលអាចបំលែងសំរាមទៅជាថាមពលជាដើម។ ទីលានចាក់សំរាមចាស់នៅស្ទឹងមានជ័យដែលមានប្រតិបត្តិការតាំងពីឆ្នាំ ១៩៦៥ គឺមិនមានលក្ខណៈសមស្របតាមបច្ចេកទេស ហើយក៏ធ្លាប់ជួបប្រទះការឆេះសំរាមផងដែរ។ ទីលានចាក់សំរាមនេះ ស្តុកសំរាមលើសចំណុះ ដូច្នេះត្រូវបានធ្វើការបិទបញ្ចប់ និងដាក់ឱ្យឈប់ដំណើរការចាប់តាំងពីឆ្នាំ២០០៩មក។

ចាប់តាំងពីខែកក្កដា ឆ្នាំ២០០៩ មក ទីលានចាក់សំរាមថ្មីមួយត្រូវបានបើកឱ្យដំណើរការនៅខណ្ឌដង្កោ ដោយមានរណ្តៅផ្ទុកសំរាមចំនួនបួន (A B C និង D)។ ទីលានចាក់សំរាមនេះស្ថិតនៅចម្ងាយ ១៥ គីឡូម៉ែត្រ ពីកណ្តាលរាជធានីភ្នំពេញ និងគ្របដណ្តប់លើផ្ទៃដីប្រមាណជាង ៣១ ហិចតា។ រណ្តៅចំនួនពីរ (A និង B) បានពេញចំណុះ ហើយរណ្តៅ C និង D ត្រូវបានបើកឱ្យដំណើរការនៅខែមេសា ឆ្នាំ២០១៦។ ទីលានចាក់សំរាមបានពេញយ៉ាងលឿន ហើយមានការសង្កេតឃើញថា ទីលានចាក់សំរាមនេះមានដំណើរការមិនទាន់សមស្របតាមផ្នែកបច្ចេកទេស និងមិនអំណោយផលទៅដល់ បរិស្ថាន។ ឧទាហរណ៍ បច្ចេកទេសក្នុងការបង្រួមសំរាមមិនត្រូវបានអនុវត្តនោះទេ ដែលនាំឱ្យមានការប្រើប្រាស់ទីលានចាក់សំរាមមិនសូវមានប្រសិទ្ធភាព។

### ៤.៥.៨ ទីធ្លាសាធារណៈ និងបេតិកភណ្ឌវប្បធម៌

តាមប្រវត្តិសាស្ត្រ រាជធានីភ្នំពេញសម្បូរទៅដោយឧទ្យាន តំបន់បៃតង ព្រមទាំងអគារ និងតំបន់បេតិកភណ្ឌវប្បធម៌។ ទោះជាយ៉ាងនេះក្តី ការអភិវឌ្ឍឡើងវិញរបស់ទីក្រុងចាប់តាំងពីទសវត្សឆ្នាំ១៩៩០ បានធ្វើឱ្យតំបន់បៃតង ព្រមទាំងអគារ និងតំបន់បេតិកភណ្ឌវប្បធម៌របស់ទីក្រុងជាច្រើនកំពុងត្រូវបានរុះរើ ដើម្បីគម្រោងអភិវឌ្ឍន៍ថ្មី ឬត្រូវបានទុកចោលឱ្យទ្រុឌទ្រោម។

ចំនួនលំហបៃតង និងតំបន់ចំហនៅរាជធានីភ្នំពេញបានថយចុះយ៉ាងខ្លាំងក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ។ យោងតាមផែនការមេស្តីពីមធ្យោបាយដឹកជញ្ជូនទីក្រុងនៅរាជធានីភ្នំពេញ ឆ្នាំ២០៣៥ រាជធានីភ្នំពេញមានតំបន់បៃតងក្នុងប្រជាជនម្នាក់តិចខ្លាំងជាងទីក្រុងធំៗផ្សេងទៀតដែលមានប្រជាជនច្រើននៅក្នុងពិភពលោក។ រាជធានីភ្នំពេញមានលំហបៃតងក្នុងមនុស្សម្នាក់តែ ១,១ $m^២$ ប៉ុណ្ណោះធៀបនឹងទីក្រុងញូវយ៉កដែលមាន ២៩,២ $m^២$ ក្នុងមនុស្សម្នាក់ និងទីក្រុងតូក្យូដែលមាន ៥,៥ $m^២$ ក្នុងមនុស្សម្នាក់។[72]

[72] របាយការណ៍គម្រោងស្តីពីការសិក្សាលម្អិតធ្វើផែនការប្រព័ន្ធដឹកជញ្ជូនក្នុងទីក្រុងសម្រាប់រាជធានីភ្នំពេញ ដោយ JICA ឆ្នាំ២០១៤ (របាយការណ៍សង្ខេប)។

ពាក់ព័ន្ធនឹងស្ថានភាពលំហសាធារណៈនៅរាជធានីភ្នំពេញ គួរកត់សម្គាល់ថា ផ្លូវដើរលំហែ មាត់ទន្លេនៅផ្លូវព្រះស៊ីសុវត្ថិនៅខណ្ឌកណ្តាលក្រុងត្រូវបានជួសជុលកែលម្អទៅជាលំហសាធារណៈដែល ត្រូវបានរៀបចំទេសភាព និងអាចចូលបាន ដែលបង្កើតកាលានុវត្តភាពសម្រាប់ការកម្សាន្តក្នុងទីក្រុងសម្រាប់ប្រជាជន និងអ្នកទស្សនាជាច្រើននៅក្នុងតំបន់។ ឧទ្យានសាធារណៈក្នុងទីក្រុងផ្សេងៗដែលមានភាពទ្រុឌទ្រោម ពេលនេះត្រូវបានជួសជុលកែលម្អដោយមានការរចនាទេសភាព។

រូបភាពទី៧៖ ឧទ្យាន និងលំហបៃតងនៅរាជធានីភ្នំពេញ (ប្រភព៖ JICA ២០១៤)




## គោលនយោបាយ និងក្របខណ្ឌបទប្បញ្ញត្តិ

បទប្បញ្ញត្តិសម្រាប់ការការពារចិញ្ចើមផ្លូវក្នុងទីក្រុងភ្នំពេញមានចែងនៅក្នុងអនុក្រឹត លេខ៤២ ស្តីពីនគរូបនីយកម្មរាជធានី ក្រុង និងទីប្រជុំជន។ ទោះជាយ៉ាងនេះក្តី ការអនុវត្តបទប្បញ្ញត្តិក្នុងអនុក្រឹត្យដើម្បីធានាថា ការអភិវឌ្ឍថ្មីផ្តល់នូវទីតាំងចំណតគ្រប់គ្រាន់ និងទុក "ចំណីផ្លូវសាធារណៈ" គ្រប់គ្រាន់សម្រាប់អគារសង់ថ្មីអាចមានការលំបាកក្នុងការអនុវត្ត។ ជាងនេះទៅទៀត បទប្បញ្ញត្តិនៅក្នុងច្បាប់ផ្លូវគោក (២០១៤) និងច្បាប់ចរាចរណ៍ផ្លូវគោក (២០១៥) ដើម្បីទុកចិញ្ចើមផ្លូវសម្រាប់អ្នកថ្មើរជើងក៏អាចជាបញ្ហាប្រឈមសម្រាប់អាជ្ញាធរមូលដ្ឋានក្នុងការអនុវត្តផងដែរ។

បច្ចុប្បន្ន ពុំមានប្រកាសស្តីពីការបែងចែកតំបន់ ឬបទបញ្ជាស្តីពីការអភិរក្សអគារចាស់លាស់ ដើម្បីការពាររចនាសម្ព័ន្ធប្រវត្តិសាស្រ្តទាំងនេះឡើយ។ បេតិកភណ្ឌវប្បធម៌ត្រូវបានគ្រប់គ្រងដោយច្បាប់ស្តីពីការការពារបេតិកភណ្ឌវប្បធម៌ ឆ្នាំ១៩៩៦ និងដោយអនុក្រឹត្យលេខ៩៨ ស្តីពីការគោរពតាមការអនុវត្តការការពារបេតិកភណ្ឌវប្បធម៌។ យោងតាមនិយមន័យនៃបេតិកភណ្ឌវប្បធម៌ដែលរៀបរាប់នៅក្នុងច្បាប់ និងបទបញ្ជា មានភាពមិនច្បាស់លាស់ថាតើរចនាសម្ព័ន្ធស្ថាបត្យកម្មដូចជាស្ថាបត្យកម្មខ្មែរថ្មី ឬស្ថាបត្យកម្មអាណានិគមបារាំង មានលក្ខណសម្បត្តិគ្រប់គ្រាន់ធ្វើជាតំបន់បេតិកភណ្ឌវប្បធម៌ដែរឬទេ។ វាមានការចាំបាច់ក្នុងការកំណត់ចេញជាបទប្បញ្ញត្តិសម្រាប់ការថែរក្សាអគារបេតិកភណ្ឌវប្បធម៌ និងបង្កើតយន្តការសម្រាប់ការផ្តល់ហិរញ្ញប្បទានដល់ការស្តារបេតិកភណ្ឌវប្បធម៌។

## បញ្ហាប្រឈមសំខាន់ៗ

ទីធ្លាសាធារណៈដែលសំខាន់មួយផងដែរនោះ គឺចិញ្ចើមផ្លូវក្នុងទីក្រុងសម្រាប់អ្នកថ្មើរជើង ត្រូវបានទន្ទ្រានយកដោយការចតរថយន្ត ម៉ូតូ និងអ្នកលក់ដូរក្រៅប្រព័ន្ធ ដែលធ្វើឱ្យការធ្វើដំណើរដោយថ្មើរជើងនៅរាជធានីភ្នំពេញមានការពិបាកយ៉ាងខ្លាំង ហើយពេលខ្លះមានគ្រោះថ្នាក់ផងដែរ។ ជាងនេះទៅទៀត ទីធ្លាសាធារណៈជាច្រើនដែលបានបង្កើតត្រូវបានរចនាមិនបានល្អពាក់ព័ន្ធនឹងការគ្រប់គ្រងទឹក និងការធ្វើឱ្យមានភាពត្រជាក់ដោយធម្មជាតិ។ ឧទ្យាន និងសួនច្បារនៅខណ្ឌក្នុងក្រុងជាច្រើនត្រូវបានក្រាលយ៉ាងពេញលេញដោយសម្ភារក្រាស់ ដែលការពារទឹកមិនឱ្យជ្រាបចូលក្នុងដី។ លើសពីនេះទៀត ដើមឈើ និងចុល្លព្រឹក្សលម្អនៅក្នុងសួនច្បារទាំងនេះដែលសមត្ថភាពនៅមានកម្រិតសម្រាប់ការផ្តល់ម្លប់ និងសម្រាប់ការរក្សាទុកទឹក។ អគារ និងតំបន់បេតិកភណ្ឌវប្បធម៌ប្រវត្តិសាស្រ្តជាច្រើនត្រូវបានបំផ្លាញចោល ដើម្បីផ្តល់ឱកាសដល់គម្រោងអភិវឌ្ឍន៍ទីក្រុងថ្មីៗ ឬត្រូវបានអនុញ្ញាតឱ្យបំផ្លាញចោល។ អគារទាំងនេះគឺជាឧទាហរណ៍នៃស្ថាបត្យកម្មពីសម័យអាណានិគមបារាំង ព្រមទាំងពីចលនាស្ថាបត្យកម្មខ្មែរថ្មីនៃទសវត្សរ៍ឆ្នាំ១៩៥០ និង១៩៦០។ អគារប្រវត្តិសាស្រ្តដែលរងការគំរាមកំហែងក្នុងនោះមាន ពហុកីឡាដ្ឋានជាតិ ប៉ុស្តិ៍នគរបាលរាជធានីភ្នំពេញចាស់ និងសណ្ឋាគាររណសិរ្សប្រវត្តិសាស្រ្ត។ អគារទាំងនេះមិនត្រឹមតែផ្តល់អត្តសញ្ញាណវប្បធម៌ដល់ទីក្រុងប៉ុណ្ណោះទេ ប៉ុន្តែ (ប្រសិន បើត្រូវបានស្តារឡើងវិញ) អគារទាំងនេះក៏មានសក្តានុពលសម្រាប់ការទាក់ទាញភ្ញៀវទេសចរផងដែរ។

# ៥. សកម្មភាពអាទិភាពនៃការអភិវឌ្ឍទីក្រុងនិរន្តរភាព

ផ្នែកនេះពិពណ៌នាអំពីសកម្មភាពអភិវឌ្ឍន៍បៃតង ដើម្បីឈានទៅសម្រេចឱ្យបានចក្ខុវិស័យ គោលដៅ និងគោលបំណងទាំងមូល ដូចដែលបានរៀបរាប់នៅក្នុងផ្នែកទី២ និងទី៣ ខាងលើ។

## ៥.១ សកម្មភាពអាទិភាពនៅក្នុងវិស័យ រៀបចំផែនការអភិវឌ្ឍន៍ក្រុង

- ផ្សព្វផ្សាយផែនការមេ (ប្លង់គោល) ស្ដីពីការប្រើប្រាស់ដីឆ្នាំ២០៣៥ ដើម្បីបង្ហាញពីហេដ្ឋារចនាសម្ព័ន្ធ/តំបន់សម្រាប់ពេលអនាគតនៃទីប្រជុំជនក្នុងទីក្រុង ទីតាំងនិងមុខងារនៃការកំណត់តំបន់ ដង់ស៊ីតេបរិស្ថាន អគារសំណង់ដែលនឹងត្រូវបានបង្កើត ទិសដៅនៃការរីកលូតលាស់ និងការបែងចែកតំបន់ជុំវិញរាជធានី
- កំណត់តំបន់អភិរក្ស (ធនធានធម្មជាតិ ទីធ្លាសាធារណៈ បេតិកភណ្ឌវប្បធម៌ និងបូជនីយដ្ឋានដែលត្រូវបានការពារអភិរក្ស) ដែលមិនអនុញ្ញាតិឱ្យមានសកម្មភាពសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ឬអគារណាមួយអាចធ្វើឡើងបានឡើយ
- កំណត់ទិសដៅនៃការពង្រីកទីប្រជុំជនក្រុង បញ្ចៀសទិសដៅដែលមានហានិភ័យធម្មជាតិ និងអាកាសធាតុ ដូចជាការជន់លិច ឬការសឹកច្រាំងទន្លេ
- រៀបចំផែនការសម្រាប់អភិវឌ្ឍន៍ទីក្រុងដែលបញ្ចេញកាបូនទាប ដែលនឹងបង្កើនដង់ស៊ីតេទីប្រជុំជនខ្ពស់ និងសម្រាប់ការប្រើប្រាស់ជាអតិបរមានូវហេដ្ឋារចនាសម្ព័ន្ធទីក្រុង
- ជៀសវាងការប្រើតែមធ្យោបាយដឹកជញ្ជូនដែលមានការចំណាយច្រើន គ្មានប្រសិទ្ធភាពថាមពល និងមានការបំពុលបរិយាកាស
- ផ្ដល់ដីដល់តំបន់លំនៅដ្ឋានសម្រាប់គ្រួសារមានប្រាក់ចំណូលទាប និងកំណត់តំបន់ប្រមូលផ្តុំរោងចក្រឱ្យនៅឆ្ងាយពីលំនៅដ្ឋាន
- កែលម្អការប្រមូល និងការគ្រប់គ្រង ទិន្នន័យមូលដ្ឋាន សម្រាប់ការធ្វើគោលនយោបាយ
- អភិវឌ្ឍន៍ទីក្រុងប្រកបដោយភាពជាក់លាក់ និងមានការវិភាគត្រឹមត្រូវ
- ពង្រឹងកិច្ចសហប្រតិបត្តិការ ការសម្របសម្រួល និងតម្លាភាពនៃដំណើរការរៀបចំផែនការ ដោយមានការចូលរួមពីភាគីពាក់ព័ន្ធទាំងអស់ និងសាធារណជន (ជាពិសេសអ្នកដែលទទួលរងផលប៉ះពាល់ដោយផ្ទាល់ពីសេចក្តីសម្រេចចិត្ត)
- អនុវត្តយុទ្ធនាការផ្សព្វផ្សាយព័ត៌មានជាសាធារណៈ តាមរយៈអាជ្ញាធរមូលដ្ឋានអំពីដំណើរការរៀបចំផែនការអភិវឌ្ឍន៍ទីក្រុង
- កែលម្អអភិបាលកិច្ចមូលដ្ឋាន និងការអនុវត្តបទប្បញ្ញត្តិនានាទាក់ទងនឹងសណ្តាប់ធ្នាប់ និងការរក្សាអនាម័យទីក្រុង ពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់។

## ៥.២ សកម្មភាពអាទិភាពនៅក្នុងវិស័យ ភាពងាយរងគ្រោះរបស់ទីក្រុង

- ការពារបឹងធម្មជាតិ ស្ទឹង ប្រឡាយ និងតំបន់ដីសើមក្នុងទីក្រុង និងមិនត្រូវអនុញ្ញាតិឱ្យមានការប្រើប្រាស់សម្រាប់ការវិនិយោគពាណិជ្ជកម្មបន្ថែមទៀតឡើយ
- ស្តារឡើងវិញច្រករបៀងបៃតង ឬបង្កើតច្រករបៀងទាំងនោះនៅក្នុងទីក្រុង
- បង្កើនទ្វេដងនូវទីធ្លាបៃតង ធៀបទៅនឹងពេលបច្ចុប្បន្នក្នុងមនុស្សម្នាក់ ១,១$m^2$ ដើម្បីជាប្រព័ន្ធផ្ទុក (ស្រូប) ជំនន់ទឹកភ្លៀង កាត់បន្ថយការជន់លិច និងបង្កើនជីវៈចម្រុះ
- ស្តារឡើងវិញប្រព័ន្ធជលវិទ្យាធម្មជាតិ ដើម្បីប្រើប្រាស់បានច្រើនមុខងារ (នេសាទ វារីវប្បកម្ម កម្សាន្ត និងការកែលម្អជីវៈចម្រុះ)
- ធ្វើឱ្យកាន់តែរឹងមាំ ប្រព័ន្ធបណ្តាញលូនៅតំបន់ងាយជន់លិច ដោយប្រើប្រាស់ប្រព័ន្ធទប់ស្កាត់ ទឹកភ្លៀង ប្រមូលទឹកភ្លៀង ការស្តារប្រព័ន្ធជលវិទ្យាធម្មជាតិ តំបន់បៃតង និងវិធានការវិស្វកម្ម
- ធ្វើជីវវិស្វកម្មដោយប្រើប្រាស់ប្រភេទរុក្ខជាតិដើមក្នុងស្រុកដើម្បីការពារការសឹក ការពារទឹកជំនន់ និងផ្ទុក (ស្រូប) ទឹកភ្លៀង

- ធ្វើប្រព្រឹត្តកម្ម (ចម្រោះ) ទឹកកខ្វក់ដែលកើតមាននៅក្នុងតំបន់ប្រជុំជនក្រុង ដោយប្រើប្រាស់យ៉ាងហោចណាស់ប្រព័ន្ធប្រព្រឹត្តកម្មបន្ទាប់បន្សំ
- បង្កើតប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់វិមជ្ឈការ (ខ្នាតតូចតាមតំបន់) និងពង្រឹងការអនុវត្តនៅក្នុងសហគមន៍ក្រីក្រដែលនៅជាយរាជធានី
- កាត់បន្ថយការខូចខាតផ្នែកទ្រព្យសម្បត្តិ ការបាត់បង់អាយុជីវិត និងការខូចខាតសេដ្ឋកិច្ចដែលបណ្តាលមកពីការជន់លិចនៅក្នុងទីក្រុង
- ជម្លៀសប្រជាជនដែលរស់នៅក្នុងតំបន់លិចទឹក ទៅតំបន់ទីតាំងលំនៅដ្ឋានដែលមានសុវត្ថិភាព និងសន្តិសុខជាងនៅក្នុងទីក្រុង
- ជំរុញ និងលើកទឹកចិត្តគ្រួសារទាំងអស់ដែលរស់នៅតំបន់ជុំវិញទីក្រុងប្រើប្រាស់ប្រព័ន្ធអនាម័យដែលមានការកែលម្អ និងមានសុវត្ថិភាព

## ៥.៣ សកម្មភាពអាទិភាពនៅក្នុងវិស័យថាមពល

- បង្កើនសកម្មភាពក្នុងវិស័យថាមពល គាំទ្រដល់ការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់
- អនុវត្តសវនកម្មប្រសិទ្ធភាពថាមពលនៅគ្រប់ស្ថាប័នក្រុងទាំងអស់ ហើយកំណត់ និងអនុវត្តផែនការគ្រប់គ្រងថាមពល និងប្រសិទ្ធភាពថាមពលដែលសមស្រប
- គ្រឿងអគ្គិសនី និងចង្កៀងអគ្គិសនីទាំងអស់ដែលត្រូវបានធ្វើតេស្ត និងបិទស្លាកសញ្ញាស្របតាមបទដ្ឋានជាតិ ស្លាកពិពណ៌នាប្រសិទ្ធភាពថាមពលសរសេរជាភាសាខ្មែរ
- បង្កើតទីផ្សារសម្រាប់សេវាប្រសិទ្ធភាពថាមពល និងហិរញ្ញវត្ថុដើម្បីបម្រើសេវាដល់វិស័យពាណិជ្ជកម្ម និងវិស័យឧស្សាហកម្ម
- បំពាក់បរិក្ខាដែលគាំទ្រទៅដល់ថាមពលកកើតឡើងវិញ នៅលើដំបូលអគារ និង/ឬស្ថាប័ន រាជរដ្ឋាភិបាល អគារពាណិជ្ជកម្ម និងឧស្សាហកម្មថ្មីទាំងអស់

## ៥.៤ សកម្មភាពអាទិភាពនៅក្នុងវិស័យដឹកជញ្ជូន

- បង្កើតប្រព័ន្ធគ្រប់គ្រងចរាចរណ៍ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ មានប្រសិទ្ធភាពធនធាន និងមានបុគ្គលិកគ្រប់គ្រាន់សម្រាប់ការអនុវត្ត
- អនុវត្ត បទប្បញ្ញត្តិនានាទាក់ទងនឹងការគ្រប់គ្រងចំណត
- កំណត់កម្រិតចំណុះសារធាតុស៊ុលហ្វួរសម្រាប់ឥន្ធនៈមធ្យោបាយដឹកជញ្ជូន ស្របតាមបទដ្ឋានតំបន់ (ក្នុងតំបន់៥0 ppm ត្រូវបានកាត់បន្ថយពីចំណុះបច្ចុប្បន្ន ១.000 ppm)
- បង្កើតប្រព័ន្ធតាមដានគុណភាពខ្យល់ប្រចាំថ្ងៃ (កើនឡើងពីស្ថានីយតាមដានដែលមានក្នុងពេលបច្ចុប្បន្នចំនួនបី) នៅទូទាំងរាជធានីដែលតាមដានសារធាតុបំពុលខ្យល់សំខាន់ៗ (PM១០ PM២.៥ SOx NOx CO និង O3)
- កាត់បន្ថយការប្រើប្រាស់មធ្យោបាយដឹកជញ្ជូនដែលប្រើម៉ាស៊ីន
- បង្កើតផែនការលើកទឹកចិត្តការប្រើប្រាស់ទោចក្រយានយន្ត (កង់) ឬថ្មើរជើង ដោយរួមបញ្ចូលទាំងការរៀបចំគន្លងផ្លូវសម្រាប់អ្នកជិះកង់ និងអ្នកថ្មើរជើង ដើម្បីបង្កភាពងាយស្រួលសម្រាប់ពួកគាត់
- លើកទឹកចិត្តការប្រើប្រាស់យានយន្ត ដែលមានការបំភាយឧស្ម័នទាប (ដូចជា យានយន្តដែលមានស្តង់ដារសមត្ថភាពបំភាយល្អប្រសើរក្នុងផ្នែក gCO2/km ឬស្រដៀងគ្នានេះ យានយន្តដែលមានប្រព័ន្ធហាយប្រ៊ីដ ឬយានយន្តដើរដោយអគ្គិសនី)

## ៥.៥ សកម្មភាពអាទិភាពនៅក្នុងវិស័យបរិស្ថានសំណង់

- បង្កើតលំនៅដ្ឋានដែលមានតម្លៃសមរម្យ និងមានភាពធន់នឹងគ្រោះធម្មជាតិនៅក្នុងទីក្រុង
- ជំរុញសំណង់លំនៅដ្ឋានទីក្រុងដែលរួមបញ្ចូលពីរចនាបទស្ថាបត្យកម្មទំនើប និងបូរាណលាយគ្នាដើម្បីថែរក្សាអត្តសញ្ញាណវប្បធម៌របស់ក្រុង
- ណែនាំតាមគ្រួសារ និងសហគ្រាសពាណិជ្ជកម្មនានាអំពីវិធានការណ៍ការពារទឹកជំនន់
- ណែនាំអំពីការសាងសង់ ឬការបំពាក់បរិក្ខារឡើងវិញនូវលំនៅដ្ឋាន និងអគារដែលមានប្រសិទ្ធភាពថាមពល
- គម្រោងសាងសង់ធំថ្មីៗត្រូវបែងចែកទីធ្លាគ្រប់គ្រាន់សម្រាប់របៀងបៃតង និងប្រកាន់ខ្ជាប់នូវបទដ្ឋានសំណង់អគារបៃតង
- អនុវត្តច្បាប់ថ្មីស្តីពីនគរូបនីយកម្ម ពាក់ព័ន្ធនឹងការបែងចែកទីធ្លាគ្រប់គ្រាន់នៅលើដីឡូត៍សាងសង់សម្រាប់ផ្ទៃបៃតង ។

## ៥.៦ សកម្មភាពអាទិភាពនៅក្នុងវិស័យផលិតកម្ម (កម្មន្តសាល)

- តាមដាន និងអនុវត្តបទប្បញ្ញត្តិស្តីពីប្រសិទ្ធភាពថាមពល ការប្រើប្រាស់ទឹក និងការបំភាយ សារធាតុពុលក្នុងវិស័យកម្មន្តសាល
- បង្កើតយន្តការហិរញ្ញប្បទានសម្រាប់ផ្តល់ឱ្យគម្រោងវិនិយោគប្រើប្រាស់ប្រសិទ្ធភាពថាមពល និងគ្រប់គ្រងការបំពុលនៅក្នុងវិស័យកម្មន្តសាល
- បង្កើតក្រុមហ៊ុនសេវាប្រើប្រាស់ថាមពល (ESCO) នៅក្នុងទីក្រុងដើម្បីជំរុញឱ្យមានប្រសិទ្ធភាពនៃការប្រើប្រាស់ថាមពល និងធនធាននៅតាមសហគ្រាសកម្មន្តសាល
- តម្រូវឱ្យរោងចក្រ ឬសហគ្រាសដែលមានការបញ្ចេញទឹកកខ្វក់ទាំងអស់ ត្រូវមានអាង ប្រព្រឹត្តកម្មទឹកកខ្វក់នៅនឹងកន្លែង
- ការវាយតម្លៃលើការប្រើប្រាស់ធនធាន ត្រូវបានធ្វើឡើងសម្រាប់វិស័យឧស្សាហកម្មធំៗនៅក្នុងទីក្រុង ដោយក្រឡេកមើលជាពិសេសទៅលើលំហូរសម្ភារ និងកាលានុវត្តភាពសម្រាប់ការ ប្រើប្រាស់សំណល់ពីរោងចក្រមួយចំនួនជាធាតុចូលទៅក្នុងឧស្សាហកម្មផ្សេងទៀត
- បង្កើនការងារបៃតងនៅក្នុងវិស័យកម្មន្តសាល រួមបញ្ចូលទាំងនៅក្នុងវិស័យសិប្បកម្ម។

## ៥.៧ សកម្មភាពអាទិភាពនៅក្នុងវិស័យនៃការគ្រប់គ្រងសំណល់រឹង

- បង្កើនធនធាន និងសមត្ថភាពសម្រាប់ខណ្ឌនីមួយៗក្នុងការគ្រប់គ្រងការប្រមូលសំរាម
- បង្កើតការប្រកួតប្រជែង ដើម្បីឱ្យខណ្ឌទាំងអស់ជ្រើសរើសក្រុមហ៊ុនប្រមូលសំរាមដែល សមស្របបំផុតចំពោះតម្រូវការគ្រប់គ្រងសំរាមរបស់ខ្លួន
- បង្កើតឱ្យមានសហគ្រិនភាពដើម្បីប្រមូលសំរាមនៅខណ្ឌមួយចំនួន ប្រសិនបើមិនទាន់មានក្រុមហ៊ុនប្រមូលសំរាមទៅដល់ទេនោះ
- បង្កើតយុទ្ធនាការផ្សព្វផ្សាយការយល់ដឹងជាសាធារណៈដើម្បីណែនាំគ្រួសារ សហគ្រាស ពាណិជ្ជកម្ម និងអាជីវករតាមផ្សារអំពីវិធីសាស្រ្តញែកសំរាម និងអត្ថប្រយោជន៍
- ជំរុញការញែកសំរាមតាមទីតាំងឧស្សាហកម្ម
- យុទ្ធនាការបង្កើនការយល់ដឹងជាសាធារណៈ ដើម្បីផ្តល់ព័ត៌មានដល់ពលរដ្ឋអំពីជម្រើសផ្សេងៗជំនួសឱ្យការប្រើប្រាស់ថង់ផ្លាស្ទិច និងផលវិបាកទៅលើបរិស្ថានពីការបន្តប្រើប្រាស់ថង់ផ្លាស្ទិចទាំងនោះ
- ហាមឃាត់ការប្រើប្រាស់ថង់ផ្លាស្ទិច និងជំនួសដោយថង់អាចប្រើឡើងវិញបាន (ថង់ដែលមានមេត្រីភាពបរិស្ថាន - Eco Bags)

## ៥.៨ សកម្មភាពអាទិភាពក្នុងវិស័យអភិវឌ្ឍន៍ទីធ្លាសាធារណៈ និងបេតិកភណ្ឌវប្បធម៌

- ពង្រីកបន្ថែមឧទ្យាន សួនច្បារ និងរបៀងបៃតងសាធារណៈ នៅទូទាំងទីក្រុង
- សាងសង់ឬរចនាឡើងវិញតំបន់សាធារណៈដែលមានស្រាប់មួយចំនួន ដើម្បីបញ្ចូលដើមឈើដែលផ្តល់ម្លប់ ជីវៈចម្រុះ ផ្ទៃជ្រាបទឹក និងបន្លែដែលអាចស្រូបយកទឹកភ្លៀងបន្ថែមទៀតដើម្បីគ្រប់គ្រងការហូរទឹកភ្លៀង
- បង្កើតតំបន់បៃតងបន្ថែមទៀតដើម្បីកាត់បន្ថយដោយឥទ្ធិពលតំបន់ក្តៅក្នុងទីក្រុង
- អភិវឌ្ឍតំបន់កម្សាន្តពហុមុខងារបន្ថែមទៀត ដើម្បីគាំទ្រដល់ការហាត់ប្រាណ សកម្មភាពកីឡា និងការរាប់អានគ្នាក្នុងសង្គម
- អភិរក្ស ជួសជុលនិងកែលម្អ តំបន់ អគារបេតិកភណ្ឌវប្បធម៌ប្រវត្តិសាស្ត្រនៅរាជធានីភ្នំពេញ
- អនុម័ត និងអនុវត្ត បទបញ្ជា ដើម្បីការពារ និងជួសជុលកែលម្អអគារ និងតំបន់បេតិកភណ្ឌវប្បធម៌សំខាន់ៗ
- បង្កើតថវិកាទីក្រុង ឬជាតិ តាមរយៈការបង់ថ្លៃរបស់ភ្ញៀវទេសចរ ឬថ្លៃអ្នកប្រើប្រាស់ផ្សេងទៀត ដើម្បីអភិរក្សអគារ និងតំបន់បេតិកភណ្ឌវប្បធម៌
- យុទ្ធនាការវិស័យទេសចរណ៍ដើម្បីបង្កើនការយល់ដឹងអំពីបេតិកភណ្ឌវប្បធម៌។

# ៦. សេណារីយ៉ូនៃការអភិវឌ្ឍបៃតង

ផ្នែកនេះបង្កើត និងវិភាគសេណារីយ៉ូដើម្បីឆ្លុះបញ្ចាំងការអភិវឌ្ឍបៃតង/និរន្តរភាពសម្រាប់ទីក្រុង ដោយសន្មត់ថានិន្នាការប្រជាសាស្ត្រ សេដ្ឋកិច្ច និងអាកាសធាតុដែលត្រូវបានពិពណ៌នានៅក្នុងផ្នែកទី ២ នឹងមិនមានការប្រែប្រួលទេ។ ដោយកង្វះទិន្នន័យ ការបង្កើតសេណារីយ៉ូមិនអាចស្របតាមលក្ខណៈបែបវិទ្យាសាស្ត្របរិមាណទាំងអស់ទេ។ ទោះជាយ៉ាងណាក៏ដោយ សេណារីយ៉ូទាំងនេះអាចផ្តល់នូវទិដ្ឋភាពទូទៅមួយអំពីអត្ថប្រយោជន៍ ដែលអាចទទួលបានពីការអភិវឌ្ឍទីក្រុងប្រកបដោយនិរន្តរភាព។

សេណារីយ៉ូទាំងនេះត្រូវបានបង្ហាញនៅខាងក្រោមសម្រាប់ការព្យាករណ៍ដល់ឆ្នាំ២០៣០៖

១. **ការព្យាករណ៍តាមទម្លាប់ធម្មតា៖** បង្ហាញនូវការបន្តនិន្នាការដែលកំពុងអនុវត្តនាពេលបច្ចុប្បន្ន

២. **ការសាកល្បងកម្មវិធីអភិវឌ្ឍន៍បៃតង៖** បង្ហាញនូវការអនុវត្តកំណែទម្រង់វិស័យជាមូលដ្ឋានសម្រាប់ការអភិវឌ្ឍដោយចីរភាព រួមជាមួយនឹងការសាកល្បងបច្ចេកវិទ្យាបៃតងថ្មីៗ

៣. **ការបញ្ជ្រាបការអភិវឌ្ឍបៃតង៖** បង្ហាញនូវការអនុវត្តកំណែទម្រង់វិស័យស៊ីជម្រៅ និងការបញ្ជ្រាបទស្សនទានបច្ចេកវិទ្យាអភិវឌ្ឍន៍បៃតងថ្មី និងវិធីសាស្ត្រអភិវឌ្ឍន៍ទីក្រុង។

## ៦.១ សេណារីយ៉ូនៃការព្យាករណ៍តាមទម្លាប់ធម្មតា

សេណារីយ៉ូការព្យាករណ៍តាមទម្លាប់ធម្មតា គឺសន្មត់ថានឹងមិនមាការកែលម្អណាមួយនៅក្នុងដំណើរការនៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មទីក្រុង ត្រូវបានធ្វើឡើងក្នុងចន្លោះពេលបច្ចុប្បន្នទៅដល់ឆ្នាំ២០៣០ឡើយ។ ចំណុចនេះរួមបញ្ចូលទាំងការមិនមានកំណែទម្រង់តាមវិស័យ សំខាន់ៗដូចជាវិស័យដឹកជញ្ជូន គ្រប់គ្រងសំណល់ ថាមពល ទឹក និងអនាម័យ។ ដូច្នេះជាទូទៅ ប្រសិនបើមិនមានការផ្លាស់ប្តូរសំខាន់ចំពោះការគ្រប់គ្រងទីក្រុងទេ ហើយក្នុងខណៈពេលដែលសកម្មភាព សេដ្ឋកិច្ច និងចំនួនប្រជាជននៅរាជធានីភ្នំពេញមានការកើនឡើង គុណភាពបរិស្ថាន គុណភាពនៃការរស់នៅនឹងធ្លាក់ចុះ ហើយមុខងារ និងភាពប្រកួតប្រជែងរបស់តំបន់ទីក្រុងនឹងប្រឈមទៅនឹងបញ្ហា ហើយទីក្រុងនឹងដាក់សម្ពាធកាន់តែខ្លាំង និងគ្មាននិរន្តរភាពទៅលើធនធានជាតិ។ បញ្ហាជាក់លាក់ដែលត្រូវបានព្យាករណ៍ក្រោមសេណារីយ៉ូព្យាករណ៍តាមទម្លាប់ធម្មតារួមមានដូចខាងក្រោម៖

- **ការប្រើប្រាស់ថាមពល៖** ការប្រើប្រាស់ថាមពលនឹងកើនឡើងយ៉ាងឆាប់រហ័ស។ កំណើនតម្រូវការមធ្យោបាយដឹកជញ្ជូន បូកផ្សំជាមួយប្រព័ន្ធដឹកជញ្ជូនមិនទាន់មានប្រសិទ្ធភាព នាពេលបច្ចុប្បន្ន នឹងជំរុញឱ្យមានកំណើនយ៉ាងឆាប់រហ័សនូវតម្រូវការឥន្ធនៈផូស៊ីល។ តម្រូវការអគ្គិសនីត្រូវបានរំពឹងទុកថានឹងបន្តកើនឡើង ឆាប់រហ័សបំផុតពីគ្រប់វិស័យ។
- **ការប្រើប្រាស់ទឹក៖** ការប្រើប្រាស់ទឹកនឹងបន្តកើនឡើងយ៉ាងឆាប់រហ័ស។ ការប្រើប្រាស់ទឹកក្នុងគ្រួសារនៅរាជធានីភ្នំពេញនឹងកើនឡើងទៅតាមកំណើនប្រជាជនក្នុងក្រុង ការរីកលូតលាស់នៃតំបន់ជុំវិញទីក្រុង និងការកើនឡើងប្រាក់ចំណូលរបស់ប្រជាពលរដ្ឋ។ កំណើននៃរោងចក្រកម្មន្តសាល និងការរីកលូតលាស់នៃផលិតកម្មអនុវិស័យផ្សេងៗទៀតដែលប្រើប្រាស់ធនធានទឹកច្រើនក៏នឹងនាំឱ្យមានការកើនឡើងនូវតម្រូវការទឹកផងដែរ។
- **ការបំពុលខ្យល់៖** ការបំពុលខ្យល់ក្នុងមូលដ្ឋាននឹងកើនឡើងយ៉ាងឆាប់រហ័ស ហើយគុណភាពខ្យល់ទំនងជាធ្លាក់ចុះ។ មូលហេតុធំបំផុតតែមួយគត់នៃការធ្លាក់ចុះគុណភាពខ្យល់គឺសារធាតុផ្សែងដែលបញ្ចេញក្នុងវិស័យដឹកជញ្ជូន (ពោលគឺការកកស្ទះចរាចរណ៍)។ ទីតាំងរោងចក្រកម្មន្តសាលដែលនៅជាប់នឹងការប្រើប្រាស់សម្រាប់ពាណិជ្ជកម្ម និងការស្នាក់នៅនឹងធ្វើឱ្យកាន់តែអាក្រក់ដល់បញ្ហាគុណភាពខ្យល់។
- **ការបំពុលទឹក៖** ការបំពុលទឹកនឹងកើនឡើងយ៉ាងឆាប់រហ័ស។ ការកើនឡើងនូវការបញ្ចេញទឹកកខ្វក់ក្នុងទីក្រុងនឹងក្លាយជាផលវិបាកមួយនៃការប្រើប្រាស់ទឹកកើនឡើងនៅរាជធានីភ្នំពេញ។ ជាផលវិបាក គុណភាពទឹកនៅក្នុងប្រភពទឹកនៅទូទាំងទីក្រុងនឹងធ្លាក់ចុះយ៉ាងខ្លាំង។ ប្រភពទឹកទាំងអស់នៅតំបន់ក្បែរទីក្រុងនឹងខូចទាំងស្រុង។

- **សំណល់រឹង៖** បរិមាណសំណល់រឹងនឹងកើនឡើងយ៉ាងខ្លាំង។ កំណើនផលិតកម្ម សេដ្ឋកិច្ច កំណើនប្រជាជន និងកម្រិតនៃការប្រើប្រាស់ផ្ទាល់ខ្លួនខ្ពស់នឹងទំនងជានាំឱ្យមានការកើនឡើងនូវបរិមាណសំណល់រឹងដែលត្រូវបានបង្កើត។
- **ទម្រង់ និងមុខងារទីក្រុង៖** ដោយសារមិនមានយុទ្ធសាស្ត្រអភិវឌ្ឍន៍ទីក្រុងដែលនឹងស្របគ្នា នឹងការអភិវឌ្ឍ និងមិនមានការគ្រប់គ្រងល្អ រចនាសម្ព័ន្ធរូបវន្តទីក្រុងនឹងបន្តអភិវឌ្ឍន៍ក្នុងរបៀបដែលធ្វើឱ្យខូចដល់មុខងារ និងកាត់បន្ថយគុណភាពរស់នៅរបស់ប្រជាជនក្នុងទីក្រុង។ ការអភិវឌ្ឍនៃវិស័យអចលនទ្រព្យដែលមិនមានការតាមដាន និងត្រួតពិនិត្យត្រឹមត្រូវ នឹងមានឥទ្ធិពលធ្វើឱ្យខូចប្រយោជន៍ជាច្រើន
- **ភាពក្រីក្រ និងការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម៖** និន្នាការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គម បន្តអនុវត្តតាមទម្លាប់នាពេលបច្ចុប្បន្ន។ ភាពក្រីក្រនៅតែជាបញ្ហាដដែលដោយសារការផ្តល់លំនៅដ្ឋានសម្រាប់អ្នកមានប្រាក់ចំណូលទាបនៅមានកម្រិត ក្រុមជនក្រីក្រ និងមានប្រាក់ចំណូលទាបនឹងត្រូវបង្ខំកាន់តែខ្លាំង ឱ្យទៅរស់នៅក្នុងលំនៅដ្ឋានដែលមិនទាន់មានលក្ខណៈសមស្រប ហើយបណ្តោះអាសន្នជាញឹកញាប់គឺនៅតំបន់ជាយក្រុង ឬនៅលើដីដែលមិនសមស្របសម្រាប់ការអភិវឌ្ឍលំនៅដ្ឋាន។

ក្នុងសេណារីយ៉ូព្យាករណ៍តាមទម្លាប់ធម្មតានៅឆ្នាំ២០៣០ ការបញ្ចូលគ្នានូវកត្តាទាំងនេះដូចជា ការកើនឡើងនៃកម្រិតបំពុលការកកស្ទះតាមដងផ្លូវ និងការវិនិយោគវិស័យឯកជនដែលមិនមានការត្រួតពិនិត្យត្រឹមត្រូវ នឹងនាំឱ្យមានការអន់ថយបន្តិចម្តងៗ ដល់បរិស្ថានរស់នៅក្នុងរាជធានីភ្នំពេញ។ នៅឆ្នាំ២០៣០ មុខងារ និងភាពប្រកួតប្រជែងរបស់ទីក្រុងនឹងចាប់ផ្តើមខូចខាតធ្ងន់ធ្ងរ និងចុះខ្សោយ។ បំណងប្រាថ្នានៃការបង្កើនខ្សែសង្វាក់តម្លៃ យោងតាមគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មរបស់ប្រទេសកម្ពុជាឆ្នាំ ២០១៥-២០២៥ នឹងត្រូវបានរារាំង ហើយទីក្រុងនេះនឹងនៅតែជាមជ្ឈមណ្ឌលសម្រាប់ផលិតកម្មដែលមានតម្លៃទាប។ ហេដ្ឋារចនាសម្ព័ន្ធទីក្រុងខ្វះខាត (ថាមពល ទឹក ការដឹកជញ្ជូន ការគ្រប់គ្រងកាកសំណល់) នឹងបង្កបញ្ហាបន្ថែមទៀតដល់ភាពប្រកួតប្រជែងរបស់ទីក្រុងនេះធៀបទៅនឹងបណ្តាប្រទេសមានចំណាយទាបផ្សេងទៀត ដែលធ្វើឱ្យវឌ្ឍនភាពនៃការអភិវឌ្ឍទីក្រុងមានភាពមិនទៀងទាត់កាន់តែខ្លាំង។ កំណើននៃវិស័យទេសចរណ៍នឹងរងការប៉ះពាល់ដោយសារទីក្រុងក្លាយជាកន្លែងគ្មានការទាក់ទាញសម្រាប់ការមកទស្សនា ដោយសារការកកស្ទះខ្លាំង កម្រិតការបំពុលខ្ពស់ និងការបាត់បង់តំបន់វប្បធម៌ និងតំបន់មានភាពរស់រវើក។ ការអភិវឌ្ឍបែបទំនើបនៅតំបន់ជុំវិញទីក្រុងនឹងអាក់ខាន ឬមិនបានគ្រប់ជ្រុងជ្រោយ ទីតាំងនៅជាប់នឹងឧស្សាហកម្មផលិតកម្មនិងរងការបំពុល និងប្រភពខ្សែទឹកដែលពោរពេញដោយសំណល់រឹង ហើយទឹកកខ្វក់ដោយសារធាតុចិញ្ចឹមដែលកំពុងទទួលរងនឹងមានលក្ខណៈអាក្រក់។ ជារួម មុខងាររបស់ទីក្រុង ហើយកំណើនសេដ្ឋកិច្ចក្នុងទីក្រុងនឹងរងការប៉ះពាល់។

## ៦.២ សេណារីយ៉ូនៃការសាកល្បងអនុវត្តតាមទស្សនៈទាននៃការអភិវឌ្ឍបៃតង

ក្នុងសេណារីយ៉ូនេះ ផែនការសំខាន់ៗជាច្រើនត្រូវបានអនុវត្ត ដែលគ្របដណ្តប់លើការផ្តល់សេវាកម្ម និងហេដ្ឋារចនាសម្ព័ន្ធទីក្រុងរួមបញ្ចូលទាំងផែនការមេសម្រាប់រៀបចំប្រព័ន្ធដឹកជញ្ជូនសម្រាប់រាជធានីភ្នំពេញ ផែនការមេដែលទើបបង្កើតថ្មីសម្រាប់ការអភិវឌ្ឍទីក្រុង ផែនការមេសម្រាប់រៀបចំ បណ្តាញលូ និងប្រព័ន្ធលូទឹកកខ្វក់ ផែនការធ្វើឱ្យប្រសើរដល់ការចែកចាយអគ្គិសនីនៅក្នុងទីក្រុង និងការពង្រាងគោលនយោបាយជាតិស្តីពីប្រសិទ្ធភាពថាមពល យុទ្ធសាស្ត្រ និងផែនការសកម្មភាព។[73] លើសពីនេះគម្រោងវិនិយោគមួយចំនួនសម្រាប់ការអភិវឌ្ឍទីក្រុងនិរន្តរភាពត្រូវបានអនុវត្តសាកល្បង។ បញ្ហាជាក់លាក់ និងការផ្លាស់ប្តូរដែលត្រូវបានព្យាករណ៍ក្រោមសេណារីយ៉ូ " ការសាកល្បងអភិវឌ្ឍន៍បៃតង" សម្រាប់ទីក្រុងរួមមាន៖

- **ការប្រើប្រាស់ថាមពល៖** ការប្រើប្រាស់ថាមពលនឹងកើនឡើងយ៉ាងឆាប់រហ័ស ជាមួយនឹងការកើនឡើងនូវវិធានការអាំងតង់ស៊ីតេថាមពល (ការប្រើប្រាស់ក្នុងប្រជាជនម្នាក់ និងការប្រើប្រាស់ថាមពលក្នុងមួយឯកតាតម្លៃបន្ថែម) ប៉ុន្តែការកើនឡើងនេះគឺនៅទាបបើធៀបទៅនឹងការប្រើប្រាស់ដែលបានព្យាករណ៍ក្រោមសេណារីយ៉ូព្យាករណ៍តាមទម្លាប់ធម្មតា។ រួមជាមួយនឹងការធ្លាក់ចុះជាមធ្យមនៃតម្លៃអគ្គិសនី ពោលគឺអត្រាធ្លាក់ចុះដល់ ០,១០ ដុល្លារអាមេរិក/kWh នៅឆ្នាំ២០២០ (តាមគោលនយោបាយបច្ចុប្បន្ន) នោះ អ្នកប្រើប្រាស់ធំៗដែលពីមុនពឹងផ្អែកលើការផលិតថាមពលដោយប្រើប្រាស់ម៉ាស៊ីនភ្លើង នឹងប្តូរទៅប្រើថាមពលដែលតភ្ជាប់ពីបណ្តាញវិញ ហើយលែងមានតម្រូវការលើការប្រើប្រាស់ម៉ាស៊ីនភ្លើង បម្រុងទុក។ ក្នុងពេលដំណាលគ្នានេះដែរតម្រូវការថាមពលសម្រាប់ប្រើប្រាស់នៅក្នុងឧស្សាហកម្មកម្មន្តសាល នៅតាមផ្ទះសម្បែងប្រជាពលរដ្ឋ និងនៅតាមអគារពាណិជ្ជកម្ម នឹងបន្តកើនឡើងយ៉ាងលឿន។

[73] ការពង្រាងគោលនយោបាយនេះត្រូវបានបញ្ចប់ និងកំពុងត្រួតពិនិត្យដោយគណៈរដ្ឋមន្ត្រី មុនដាក់អោយអនុម័តជាផ្លូវការ

- **ប្រសិទ្ធភាពថាមពល និងថាមពលកកើតឡើងវិញ៖** ការរីកចម្រើននៅក្នុងការប្រើប្រាស់ បច្ចេកវិទ្យាប្រសិទ្ធភាពថាមពល នឹងនាំឱ្យមានការកើនឡើងនូវការប្រើប្រាស់ថាមពលប្រកបដោយប្រសិទ្ធភាព។ ស្រដៀងគ្នាដែរ ការប្រើប្រាស់ថាមពលកកើតឡើងវិញ នឹងមានការរីកចម្រើនខ្លះក្នុងការផលិតថាមពលសម្រាប់ទីក្រុង។ បន្ទះថាមពលពន្លឺព្រះអាទិត្យ នឹងត្រូវបានប្រើប្រាស់ជាផ្នែកមួយនៃប្រព័ន្ធថាមពលហាយប្រ៊ីដនៅក្នុងរោងចក្រផលិតកម្មមួយចំនួន។ សម្រាប់អគារដែលមានតម្រូវការថាមពលច្រើនជាពិសេសសម្រាប់ប្រព័ន្ធដំណើរការត្រជាក់នៅក្នុងអគារ នោះការប្រើប្រាស់ប្រព័ន្ធ បន្ទះស្រូបថាមពលពន្លឺព្រះអាទិត្យ គឺកាន់តែសមស្រប និងពេញនិយម។ ស្រដៀងគ្នាដែរ រោងចក្រកែច្នៃសំរាម នឹងព្យាយាមបំពេញតម្រូវការថាមពលផ្ទាល់របស់ខ្លួនខ្លះតាមរយៈបច្ចេកវិទ្យាបម្លែងសំរាមឱ្យទៅជាថាមពល។
- **ការគ្រប់គ្រងលើវិស័យដឹកជញ្ជូន៖** ការកើនឡើងនូវតម្រូវការលើករដឹកជញ្ជូននឹងក្លាយជាកត្តាជំរុញសំខាន់បំផុតនៃការប្រើប្រាស់ប្រេងឥន្ធនៈផូស៊ីលកាន់តែច្រើន។ ទោះជាយ៉ាងនេះការធ្វើឱ្យប្រសើរឡើងនូវមធ្យោបាយដឹកជញ្ជូនសាធារណៈ ការរួមបញ្ចូលផែនការប្រើប្រាស់ដីធ្លីជាមួយលក្ខខណ្ឌនៃការប្រើប្រាស់ផ្លូវថ្នល់ ការបង្កើតចំណត និងប្រព័ន្ធគ្រប់គ្រងចរាចរណ៍ឱ្យមានប្រសិទ្ធភាពបន្ថែមទៀត ទាំងនេះនឹងបន្ធូរបន្ថយការកកស្ទះចរាចរណ៍ទោះបីជាមានតម្រូវការនូវការដឹកជញ្ជូនកើនឡើងក៏ដោយ។ ប្រសិទ្ធភាពថាមពលរបស់យានយន្តក៏នឹងត្រូវបានកែលម្អជាទូទៅផងដែរតាមរយៈការអនុវត្តប្រព័ន្ធធ្វើតេស្តយានយន្ត។
- **ការប្រើប្រាស់ទឹក៖** ហេដ្ឋារចនាសម្ព័ន្ធ ក៏ជាកត្តាជំរុញឱ្យមានតម្រូវការទឹកកើនឡើងយ៉ាងឆាប់រហ័សផងដែរ។ ការនាំមកនូវការអនុវត្ត និងដំណើរការប្រើប្រាស់ទឹកប្រកបដោយប្រសិទ្ធភាពបន្ថែមទៀតនៅតាមឧស្សាហកម្មកម្មន្តសាល បើធៀបនឹងការអនុវត្តតាមទម្លាប់ធម្មតា គឺជាកត្តារួមចំណែកសំខាន់ចំពោះការកាត់បន្ថយការប្រើប្រាស់ទឹក។
- **ការបំពុលខ្យល់៖** ការបំពុលខ្យល់ក្នុងមូលដ្ឋាននឹងត្រូវបានកាត់បន្ថយយ៉ាងខ្លាំង ធៀបនឹងសេណារីយ៉ូព្យាករណ៍តាមទម្លាប់ធម្មតា ប៉ុន្តែមានការកើនឡើងយ៉ាងខ្លាំងធៀបនឹងស្ថានភាពបច្ចុប្បន្ន។ ការកែលម្អប្រសិទ្ធភាពថាមពលនៃវិស័យដឹកជញ្ជូន (សូមអានផ្នែកខាងលើ) នឹងរួមចំណែកនៅក្នុងការកាត់បន្ថយការបំពុលខ្យល់ទាំងនេះ។
- **ការបំពុលទឹក៖** ដោយសារតែការផ្លាស់ប្តូរវិធាននៃការប្រើប្រាស់ទឹកប្រកបដោយប្រសិទ្ធភាពមិនទាន់បានគ្រប់ជ្រុងជ្រោយធៀបនឹងសេណារីយ៉ូព្យាករណ៍តាមទម្លាប់ធម្មតា ការបញ្ចេញទឹកកខ្វក់នឹងនៅតែជាបញ្ហាប្រឈមដដែល។ ការរៀបចំអោយមានអាងប្រព្រឹត្តកម្មទឹកកខ្វក់នៅក្នុងតំបន់ទីក្រុងនឹងមានការវិវឌ្ឍទៅមុខបន្តិចម្តងៗ បើទោះបីជាការរៀបចំពេលបច្ចុប្បន្ននេះនៅមានកម្រិតតូចក៏ដោយ។ ដូច្នេះ វាបរិមាណទឹកកខ្វក់បញ្ចេញចោលដោយមិនបានធ្វើប្រព្រឹត្តកម្មក្នុងទីក្រុង នឹងអាចលើសពីសមត្ថភាពក្នុងការធ្វើប្រព្រឹត្តកម្មក្នុងពេលបច្ចុប្បន្ន។
- **សំណល់រឹង៖** ដូចសេណារីយ៉ូព្យាករណ៍តាមទម្លាប់ធម្មតាដែរ គឺបរិមាណសំណល់រឹងជាទូទៅនឹងមានការកើនឡើងដ៏គួរឱ្យកត់សម្គាល់គិតទៅដល់ឆ្នាំ២០៣០។ នៅក្នុងខណ្ឌដែលទទួលបានវិធានការថ្មីសម្រាប់កាត់បន្ថយ និងប្រមូលសំរាមគឺបរិមាណសំរាមត្រូវបានកាត់បន្ថយយ៉ាងខ្លាំង ហើយសំរាមនៅសល់ត្រូវបានប្រមូលយ៉ាងមានប្រសិទ្ធភាព។ ទោះជាយ៉ាងនេះក្តីការចាក់គរសំរាមដោយគ្មានការត្រួតពិនិត្យនឹងនៅតែជាបញ្ហា ជាពិសេសនៅតំបន់ជុំវិញទីក្រុង ហើយកង្វះកន្លែងកប់សំរាមប្រកបដោយអនាម័យ នឹងបង្កឱ្យមានផលវិបាកទៅលើគុណភាពទឹក។

សេណារីយ៉ូការសាកល្បងនៃការអភិវឌ្ឍបៃតងនេះ បង្ហាញនូវលទ្ធផលល្អជាច្រើនគួរឱ្យកត់សម្គាល់បើធៀបនឹងសេណារីយ៉ូការព្យាករតាមទម្លាប់ធម្មតា។ នៅតាមតំបន់សំខាន់ៗដែលមានផលប៉ះពាល់ផ្ទាល់ទៅលើដំណើរការសហគ្រាស ដូចជាការដឹកជញ្ជូន និងការប្រើប្រាស់ថាមពល គឺនឹងមានការកែលម្អបានច្រើនបើអនុវត្តតាមសេណារីយ៉ូនៃការសាកល្បងការអភិវឌ្ឍបៃតងធៀបទៅនឹងសេណារីយ៉ូការព្យាករតាមទម្លាប់ធម្មតា។ ជាលទ្ធផល វានឹងនាំឱ្យមានការកាត់បន្ថយកម្រិតបំពុលខ្យល់។ លើសពីនេះគម្រោងធ្វើផែនការបែងចែកតំបន់នៅក្នុងខណ្ឌសំខាន់ៗកណ្តាលក្រុងមួយចំនួន នឹងកែលម្អបានច្រើនទៅលើមុខងារទីប្រជុំជននៃតំបន់ទាំងនោះ ហើយវានឹងជួយកាត់បន្ថយនូវគម្រោងការអភិវឌ្ឍណាដែលមិនមានភាពច្បាស់លាស់ ផ្ទុយទៅវិញវានឹងផ្តល់នូវទីធ្លាសាធារណៈកាន់តែច្រើនការការពារបេតិកភណ្ឌ ការកែលម្អបរិយាកាសសម្រាប់អ្នកថ្មើរជើង និងការកាត់បន្ថយហានិភ័យនៃការជន់លិចក្នុងមូលដ្ឋាន។ បរិស្ថានក្នុងមូលដ្ឋាននឹងត្រូវបានកែលម្អបន្ថែមទៀត នៅពេលអនុវត្តកិច្ចអន្តរាគមន៍កែលម្អការប្រមូលសំណល់រឹង។

គំនិតផ្តួចផ្តើមដល់ការអភិវឌ្ឍតំបន់ជុំវិញទីក្រុង ដូចជាការអភិវឌ្ឍលើលំនៅដ្ឋានសម្រាប់អ្នកមានប្រាក់ចំណូលទាប ហើយការអភិវឌ្ឍឧស្សាហកម្ម នឹងកែលម្អមុខងារ និងបរិស្ថាន របស់ទីក្រុងបន្ថែមទៀត។ ទោះជាយ៉ាងណា កម្រិតនៃការបំពុលខ្យល់ទំនងជានៅតែកើនឡើង ហើយបញ្ហាសំណល់រាវ និងសំណល់រឹងនឹងនៅតែជាបញ្ហាសំខាន់បំផុត។ ការអភិវឌ្ឍដែលមិនមានការត្រួតពិនិត្យត្រឹមត្រូវមួយចំនួន នឹងបន្តបង្កឱ្យមានបញ្ហាសម្រាប់ទីក្រុង ពោលគឺវាស្រដៀងគ្នាទៅនឹងបញ្ហាដែលបានព្យាករណ៍នៅក្នុងសេណារីយ៉ូព្យាករណ៍តាមទម្លាប់ធម្មតា។ ជារួមនៅក្នុងសេណារីយ៉ូនៃការសាកល្បងការអភិវឌ្ឍបៃតង គឺទីក្រុងនឹងមានការកែលម្អផ្នែកបរិស្ថានខ្លះ ដែលអាចធ្វើឱ្យទីក្រុងភ្នំពេញនៅតែមានភាពប្រកួតប្រជែងសម្រាប់វិស័យឧស្សាហកម្មផលិតកម្មតាមរយៈការកាត់បន្ថយការចំណាយ និងអាចរក្សាមុខងារចម្បងរបស់ទីក្រុងនាពេលបច្ចុប្បន្ន។

## ៦.៣ សេណារីយ៉ូនៃការបញ្ជ្រាបការអភិវឌ្ឍបៃតង

ក្នុងសេណារីយ៉ូនេះ គ្រប់ផែនការ និងកំណែទម្រង់តាមវិស័យទាំងអស់ដែលត្រូវបានកំណត់នៅក្នុងសេណារីយ៉ូ "ការសាកល្បងការអភិវឌ្ឍបៃតង" នឹងត្រូវយកមកអនុវត្ត ក្នុងនោះរួមទាំងគម្រោងវិនិយោគហេដ្ឋារចនាសម្ព័ន្ធទីក្រុង និងកំណែទម្រង់ទូទាំងវិស័យក្នុងទីក្រុង។ សេណារីយ៉ូនេះរួមមាន កំណែទម្រង់តាមវិស័យដើម្បីគាំទ្រដល់ការអនុម័តការប្រើប្រាស់យានយន្តអគ្គិសនី ការកែលម្អបទដ្ឋានប្រេងឥន្ធនៈសម្រាប់មធ្យោបាយដឹកជញ្ជូន ការគាំទ្រអន្តរវិស័យដល់ថាមពលកកើតឡើងវិញ និងប្រសិទ្ធភាពថាមពល ការគាំទ្រដល់ការអនុវត្តប្រព្រឹត្តកម្មទឹកកខ្វក់នៅក្នុងទីក្រុង និងទឹកកខ្វក់ដែលចេញពីឧស្សាហកម្មផលិតកម្ម ការកាត់បន្ថយ ការប្រមូល និងការចាត់ចែងសំណល់រឹងប្រកបដោយប្រសិទ្ធភាព ការបែងចែកតំបន់ប្រើប្រាស់ដីធ្លីទូទាំងក្រុង ការការពារ និងការលើកស្ទួយបេតិកភណ្ឌវប្បធម៌ និងការផ្តល់ទីធ្លាសាធារណៈ និងតំបន់បៃតង។ ការផ្លាស់ប្តូរដែលត្រូវបានព្យាករណ៍ក្រោមសេណារីយ៉ូ "ការបញ្ជ្រាបការអភិវឌ្ឍបៃតង" សម្រាប់ទីក្រុងរួមមាន៖

- <u>**ការប្រើប្រាស់ថាមពល៖**</u> ដូចនៅក្នុងសេណារីយ៉ូផ្សេងទៀតដែរ ការប្រើប្រាស់ថាមពលនឹងមានកើនឡើងយ៉ាងឆាប់រហ័ស ទោះបីជាមានគោលនយោបាយប្រសិទ្ធភាពថាមពល និងការលើកកម្ពស់ការប្រើប្រាស់ថាមពលកកើតឡើងវិញដែលនឹងជួយកាត់បន្ថយនូវតម្រូវការថាមពលលក្ខណៈបុរាណ (conventional energy) ដូចដែលយើងបានឃើញនៅក្នុងសេណារីយ៉ូព្យាករណ៍តាមទម្លាប់ធម្មតា។ ការប្រើប្រាស់អគ្គិសនី ក៏ទំនងជាមានការកើនឡើងយ៉ាងឆាប់រហ័សផងដែរ ទោះបីជាវាមានកម្រិតទាបជាងការប្រើប្រាស់អគ្គិសនីដែលបានវិភាគនៅក្នុងសេណារីយ៉ូព្យាករណ៍តាមទម្លាប់ធម្មតា (BAU) និងក្នុងសេណារីយ៉ូការសាកល្បងការអភិវឌ្ឍបៃតង (PGG) ក៏ដោយ។
- <u>**ប្រសិទ្ធភាពថាមពល និងថាមពលកកើតឡើងវិញ៖**</u> នឹងមានអត្រាខ្ពស់នៃការផលិតថាមពលកកើតឡើងវិញ និងការប្រើប្រាស់គោលការណ៍ប្រសិទ្ធភាពថាមពល។ ទោះបីតម្លៃអគ្គិសនីជាមធ្យមធ្លាក់ចុះក៏ដោយ ការបំពាក់បន្ទះស្រូបថាមពលពន្លឺព្រះអាទិត្យ លើដំបូលនឹងមាននៅគ្រប់អគារសំខាន់ៗ។ ការទទួលយក បន្ទះស្រូបថាមពលពន្លឺព្រះអាទិត្យ មកប្រើប្រាស់ គឺត្រូវបានជំរុញដោយកត្តាជាច្រើនដូចជា វានឹងជួយឱ្យតម្លៃនៃការប្រើប្រាស់អគ្គិសនីធ្លាក់ចុះ ការអាចកំណត់បាននូវកម្រិតបរិមាណថាមពលប្រើប្រាស់ និងការកំណត់ពេលប្រើប្រាស់ថាមពល (net metering and timeof-day pricing) ដែលវានឹងមានផលប្រយោជន៍គួរឱ្យកត់សម្គាល់ទៅលើតម្រូវការថាមពល។ ជម្រើសថាមពលកកើតឡើងវិញផ្សេងទៀតដូចជាការបំលែងសំណល់ទៅជាថាមពល នឹងត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយនៅរោងចក្រប្រព្រឹត្តកម្មសំណល់។ ការប្រកាន់យកវិធានការប្រសិទ្ធភាពថាមពលទ្រង់ទ្រាយធំ នឹងនាំឱ្យមានតម្រូវការថាមពលថយចុះពីគ្រប់វិស័យ។
- <u>**កំណែទម្រង់ការដឹកជញ្ជូន៖**</u> ដូចនៅក្នុងសេណារីយ៉ូផ្សេងទៀតដែរ ការកើនឡើងនូវតម្រូវការនៃវិស័យដឹកជញ្ជូន នឹងមានលក្ខណៈខ្ពស់គួរឱ្យកត់សម្គាល់ ហើយនៅតែជាកត្តាជំរុញចម្បងមួយនៃការប្រើប្រាស់ប្រេងឥន្ធនៈផូស៊ីលកាន់តែច្រើន។ ដូចគ្នាទៅនិងសេណារីយ៉ូ ការសាកល្បងការអភិវឌ្ឍបៃតង (PGG) តាមរយៈប្រសិទ្ធភាពថាមពលនៅក្នុងវិស័យដឹកជញ្ជូននឹងត្រូវបានកែលម្អបើធៀបនឹងសេណារីយ៉ូព្យាករណ៍តាមទម្លាប់ធម្មតា (BAU)។ យានយន្តដើរដោយអគ្គិសនី នឹងមានកាន់តែច្រើន ហើយនឹងមានការប្រើប្រាស់កង់អគ្គិសនី និងម៉ូតូកង់បីដើរដោយថាមពលពន្លឺព្រះអាទិត្យ ដែលនឹងជួយគាំទ្រដល់វិស័យនេះ។

- **ការប្រើប្រាស់ទឹក៖** ការប្រើប្រាស់ទឹកនឹងបន្តកើនឡើងយ៉ាងឆាប់រហ័ស ទោះបីជាក្នុងអត្រាមួយសមស្រប បើធៀបនឹងសេណារីយ៉ូព្យាករណ៍តាមទម្លាប់ធម្មតា (BAU) ឬសេណារីយ៉ូ ការសាកល្បងការអភិវឌ្ឍបៃតង (PGG) ក៏ដោយ។ ការប្រើប្រាស់ទឹកតាមគ្រួសារត្រូវបានរំពឹងថានឹងកើនឡើង ប៉ុន្តែនៅក្នុងអត្រាមួយសមស្រប ពោលគឺទាបជាងអត្រានៃការប្រើប្រាស់ទឹកនៅក្នុងសេណារីយ៉ូ ២ផ្សេងទៀត ដោយសារលទ្ធភាពអាចរកបានកាន់តែច្រើននៃឧបករណ៍ប្រើប្រាស់ដែលមានប្រសិទ្ធភាព (សន្សំសំចៃ) ថាមពល និងទឹក។
- **ការបំពុលខ្យល់ក្នុងមូលដ្ឋាន៖** ការបំពុលខ្យល់ក្នុងមូលដ្ឋាននឹងផ្លាស់ប្តូរសមាសភាពរបស់ខ្លួននៅក្នុងសេណារីយ៉ូនេះ ហើយការបំពុលខ្យល់នឹងមានការកើនឡើងបន្តិចបន្តួចធៀបនឹងស្ថានភាពបច្ចុប្បន្ន ប៉ុន្តែតិចជាងកម្រិតបំពុលដែលព្យាករណ៍នៅក្នុងសេណារីយ៉ូព្យាករណ៍តាមទម្លាប់ធម្មតា (BAU) ឬសេណារីយ៉ូការសាកល្បងការអភិវឌ្ឍបៃតង (PGG)។ ទោះជាយ៉ាងណា នៅក្នុងសេណារីយ៉ូនេះ យើងឃើញមានការកែលម្អប្រសើរជាងមុន ដែលអាចទទួលបានដោយសារមានការកែលម្អលើហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងមានការគ្រប់គ្រងចរាចរណ៍ល្អប្រសើរ ការធ្វើតេស្តការបញ្ចេញផ្សែងរបស់យានយន្ត បទដ្ឋានឥន្ធនៈសម្រាប់មធ្យោបាយដឹកជញ្ជូនប្រសើរឡើង ការផ្តល់មធ្យោបាយដឹកជញ្ជូនសាធារណៈបានល្អជាងមុន និងកម្រិតនៃការកកស្ទះក៏ទាបជាងមុន។ ការអនុវត្តល្អប្រសើរនូវបទដ្ឋានការពារបរិស្ថាននៅក្នុងវិស័យកម្មន្តសាល ក៏នឹងជួយកាត់បន្ថយបានយ៉ាងខ្លាំងនូវការបំពុលខ្យល់ពីវិស័យនេះ។
- **ការបំពុលទឹក៖** ដូចជាមួយសេណារីយ៉ូផ្សេងទៀតដែរ ការបំពុលទឹកទំនងជាកើនឡើង ប៉ុន្តែការកើនឡើងនេះមានកម្រិតទាបល្មម ដោយសារមានការអនុវត្តវិធានការនានាដូចជាប្រសិទ្ធភាពនៃការប្រើប្រាស់ធនធានទឹក ការពង្រឹងគុណភាពទឹកជាដើម មានលក្ខណៈល្អប្រសើរ និងអនុវត្តបានច្រើនជាងសេណារីយ៉ូមុន (ការសាកល្បងការអភិវឌ្ឍបៃតង - PGG)។ ក្នុងសេណារីយ៉ូនេះ យើងនឹងឃើញមានការអភិវឌ្ឍបានច្រើនទៅលើអាងប្រព្រឹត្តកម្មទឹកកខ្វក់ទីក្រុង ទឹកសំណល់ ពីវិស័យឧស្សាហកម្មកម្មន្តសាលព្រោះមូលនិធិដែលទទួលបានសម្រាប់ការរៀបចំអាងប្រព្រឹត្តកម្មទឹកកខ្វក់ គឺបានតាមរយៈការបង់ថ្លៃ និងប្រាក់ផាកពិន័យជាច្រើននៅពេលប្រើប្រាស់ ឬពេលការបញ្ចេញទឹកកខ្វក់។
- **សំណល់រឹង៖** ក្នុងសេណារីយ៉ូនេះ ការបង្កើតសំណល់រឹងនឹងកើនឡើង ធៀបនឹងស្ថានភាពបច្ចុប្បន្ន។ ទោះជាយ៉ាងនេះក្តី កិច្ចខិតខំប្រឹងប្រែងសម្រាប់ទីក្រុងទាំងមូលដើម្បីជំរុញការអនុវត្តវិធានការការប្រើប្រាស់ឡើងវិញ ការកាត់បន្ថយ និងការកែច្នៃឡើងវិញនូវបរិមាណសំរាម ឬសំណល់រឹង វានឹងជួយកាត់បន្ថយការបង្កើតសំណល់បានយ៉ាងច្រើន បើធៀបទៅនឹងសេណារីយ៉ូផ្សេងទៀត។ ការប្រមូលសំណល់រឹង ដែលបានវិភាគក្នុងសេណារីយ៉ូនេះ គឺត្រូវបានគ្រប់គ្រងយ៉ាងមានប្រសិទ្ធភាពក្នុងទីក្រុងទាំងមូលហើយជាលទ្ធផល វានឹងជួយកាត់បន្ថយការបំពុលខ្យល់ ដែលកើតចេញពីការដុតសំណល់រឹងនៅកណ្តាលវាល និងការស្ទះប្រឡាយលូបង្ហូរ និងបំពង់បង្ហូរដោយសារសំណល់រឹង។

នៅត្រឹមឆ្នាំ២០៣០ កម្រិតនៃការបំពុល និងការប្រើប្រាស់ធនធាន នឹងមានការកើនឡើងខ្លាំង។ ទោះជាយ៉ាងនេះក្តី បើមានការគ្រប់គ្រងវិស័យដឹកជញ្ជូនប្រសើរជាងមុន ការរៀបចំនិងអនុវត្តផែនការប្រើប្រាស់ដីបានគ្រប់ជ្រុងជ្រោយ បើមានប្រព័ន្ធគ្រប់គ្រងការបំពុល និងការពង្រឹងប្រសិទ្ធភាពថាមពល រួមជាមួយនិងឥណទានហិរញ្ញប្បទានដែលត្រូវបានបង្កើត និងពង្រីកសម្រាប់ការវិនិយោគផ្នែកបរិស្ថាន នឹងនាំឱ្យមានការកែលម្អបន្តិចម្តងៗចំពោះបរិស្ថានរស់នៅសម្រាប់ប្រជាជនបានច្រើននៅក្នុងទីក្រុង។ មុខងារ និងភាពប្រកួតប្រជែងរបស់ទីក្រុងនឹងមានការកែលម្អបន្តិចម្តងៗ។ ការផ្តល់ហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មទីក្រុងដែលមានប្រសិទ្ធភាពបន្ថែមទៀត នឹងធ្វើឱ្យការធ្វើវិនិយោគមានភាពងាយស្រួលជាងមុន ហើយរាជធានីភ្នំពេញនឹងមានលទ្ធភាពទាក់ទាញការវិនិយោគដែលមានផលិតភាពខ្ពស់ និងមានគុណតម្លៃបន្ថែមខ្ពស់។ បរិស្ថានរស់នៅល្អប្រសើរ មានកន្លែងទីធ្លាសាធារណៈ និងការការពារសម្បត្តិបេតិកភណ្ឌវប្បធម៌ នឹងធ្វើឱ្យទីក្រុងក្លាយជាកន្លែងកាន់តែទាក់ទាញចង់ឱ្យរស់នៅ និងធ្វើអាជីវកម្ម។ ការកែលម្អទាំងនេះក៏នឹងធ្វើឱ្យប្រសើរឡើងដល់ភាពទាក់ទាញរបស់ទីក្រុងចំពោះភ្ញៀវទេសចរផងដែរ។ ការអនុម័ត និងការផ្សព្វផ្សាយបច្ចេកវិទ្យាបៃតងថ្មីនៅក្នុងទីក្រុង ក៏នឹងបង្កើតឱ្យមានទីផ្សារសម្រាប់ការផ្តល់ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាខ្ពស់ និងរោងចក្រក្នុងវិស័យ កម្មន្តសាលដែលចូលរួមនៅក្នុងទីផ្សារដែលកំពុងរីកលូតលាស់យ៉ាងឆាប់រហ័សសម្រាប់បច្ចេកវិទ្យាបៃតងផងដែរ ដែលរោងចក្រទាំងនោះ ជាច្រើនអាចជ្រើសរើសស្ថិតនៅក្នុងទីក្រុង។ ជាទូទៅ ការបញ្ជ្រាបវិធីសាស្រ្តអភិវឌ្ឍន៍ទីក្រុងនិរន្តរភាពមិនត្រឹមតែធ្វើឱ្យប្រសើរឡើងដល់បរិស្ថានតាមមូលដ្ឋាន និងសម្រាប់ប្រទេសទាំងមូលប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងធ្វើឱ្យមានភាពប្រសើរឡើងនាពេលអនាគតពោលគឺផលប្រយោជន៍ផ្នែកផលិតភាព និងភាពប្រកួតប្រជែងរយៈពេលវែងសម្រាប់ទីក្រុង។

# ៧. សំណើរនៃការរៀបចំរចនាសម្ព័ន្ធស្ថាប័នអនុវត្ត និងយន្តការគាំទ្រ

គណៈកម្មការប្រឹក្សាយោបល់ចំនួន១ក្រុម និងក្រុមការងារបច្ចេកទេសចំនួន៤ក្រុម នឹងត្រូវបានបង្កើតឡើងដើម្បីជាយន្តការគាំទ្រដល់សាលារាជធានីភ្នំពេញ អនុវត្តនូវផែនការអភិវឌ្ឍទីក្រុងនិរន្តរភាពនេះឱ្យមានប្រសិទ្ធភាព។ នៅផ្នែកខាងក្រោមនេះ នឹងផ្តល់នូវការពិពណ៌នាលម្អិតអំពី តួនាទី និងទំនួលខុសត្រូវរបស់ក្រុមគណៈកម្មការប្រឹក្សាយោបល់ និងក្រុមការងារបច្ចេកទេស។

រូបភាពទី៨៖ ការរៀបចំស្ថាប័នគាំទ្រសម្រាប់អនុវត្តផែនការអភិវឌ្ឍន៍ទីក្រុងនិរន្តរភាពនៅរាជធានីភ្នំពេញដែលស្នើឡើង




## ៧.១ គណៈកម្មការប្រឹក្សាយោបល់

តួនាទីចម្បងរបស់គណៈកម្មការប្រឹក្សាយោបល់ គឺការផ្តល់យោបល់ជាយុទ្ធសាស្ត្រ និងធ្វើការត្រួតពិនិត្យលើការអនុវត្តផែនការយុទ្ធសាស្ត្រ។ គណៈកម្មការនេះ មានគោលដៅធានាថា ចក្ខុវិស័យដែលបានចែងនឹងត្រូវសម្រេចបានគោលដៅនឹងត្រូវបានបំពេញ ហើយផែនការយុទ្ធសាស្ត្រជាទូទៅត្រូវបានអនុវត្តយ៉ាងជោគជ័យក្នុងក្របខណ្ឌពេលវេលាដែលបានកំណត់។

គណៈកម្មការប្រឹក្សាយោបល់ នឹងមានការទទួលខុសត្រូវដូចខាងក្រោម៖

១. ផ្តល់ការត្រួតពិនិត្យ និងសេចក្តីណែនាំជាយុទ្ធសាស្ត្រដល់ការអនុវត្តផែនការយុទ្ធសាស្ត្រ និងធានាថា ចក្ខុវិស័យនៃផែនការត្រូវបានសម្រេច គោលដៅត្រូវបានបំពេញតាម ហើយផែនការយុទ្ធសាស្ត្រនឹងត្រូវបានអនុវត្ត យ៉ាងជោគជ័យទៅតាមកាលកំណត់

២. តែងតាំងមន្ត្រីមកពីក្រសួងពាក់ព័ន្ធឱ្យក្លាយជាសមាជិកនៃក្រុមការងារបច្ចេកទេសមួយ ឬច្រើនទៅតាមវិស័យពាក់ព័ន្ធ[74]

៣. ឯកភាព និងគាំទ្រការប្រគល់សកម្មភាពរបស់រដ្ឋបាលរាជធានីភ្នំពេញ

៤. ធ្វើការប្រជុំជាទៀងទាត់ដើម្បីពិនិត្យឡើងវិញ និងតាមដានវឌ្ឍនភាពនៃការអនុវត្ត និងការសម្រេចបាន។

[74] នឹងមានក្រុមការងារបច្ចេកទេសទៅតាមវិស័យចំនួនបួន នៅក្រោមគណៈកម្មការប្រឹក្សាយោបល់ដែលបង្កើតឡើង ដើម្បីគាំទ្រដល់សកម្មភាពរបស់ផែនការអភិវឌ្ឍន៍ទីក្រុងនិរន្តរភាព នៅក្នុង ៨ វិស័យ។ ក្រុមការងារបច្ចេកទេសនីមួយៗនឹងទទួលខុសត្រូវលើវិស័យចំនួនពីរ។ លក្ខខណ្ឌយោងសម្រាប់ក្រុមការងារបច្ចេកទេសនីមួយៗក៏នឹងត្រូវបានបង្កើតឡើងទៅតាមនោះផងដែរ។

គណៈកម្មការប្រឹក្សាយោបល់ រួមមានតំណាងជាន់ខ្ពស់មកពីក្រសួង រដ្ឋបាលរាជធានីភ្នំពេញ និងស្ថាប័នរដ្ឋាភិបាលដែលពាក់ព័ន្ធ។ គណៈកម្មការនេះនឹងមានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព (ក.ជ.អ.ច.) ជាប្រធាន ដោយសារថាក្រុមប្រឹក្សានេះមានបទពិសោធន៍ច្រើនផ្នែកសម្របសម្រួលក្នុងចំណោមក្រសួងពាក់ព័ន្ធ (ខ្សែបណ្តោយ) និងតួនាទីរបស់ក្រុមប្រឹក្សានេះនៅក្នុងការអភិវឌ្ឍទីក្រុងនិរន្តរភាពនៅប្រទេសកម្ពុជា ហើយអនុប្រធាន គឺក្រសួងមហាផ្ទៃ ដោយសារថាការទទួលខុសត្រូវរបស់ក្រសួងនេះក្នុងការរៀបចំផែនការ និងតាមដានការអភិវឌ្ឍនៅថ្នាក់ក្រោមជាតិ។

## ៧.២ ក្រុមការងារបច្ចេកទេស

គោលបំណងចម្បងរបស់ក្រុមការងារបច្ចេកទេស គឺការគាំទ្រដល់រដ្ឋបាលរាជធានីភ្នំពេញនៅក្នុងការអនុវត្តផែនការយុទ្ធសាស្រ្ត ដោយផ្តល់យោបល់ និងការគាំទ្រផ្នែកបច្ចេកទេស ដើម្បីឈានទៅសម្រេចគោលដៅដែលបានកំណត់នៅក្នុងផែនការ។ តួនាទី និងទំនួលខុសត្រូវរបស់ក្រុមការងារបច្ចេកទេស មានដូចខាងក្រោម៖

- ផ្តល់ធាតុចូលបច្ចេកទេសសម្រាប់ការអនុវត្ត
- រៀបចំផែនការសកម្មភាពរយៈពេលខ្លី និងមធ្យមសម្រាប់វិស័យនីមួយៗ
- ប្រើប្រាស់ធនធានសម្រាប់ការអនុវត្តគម្រោងទីក្រុងនិរន្តរភាពជាអាទិភាព
- តាមដានការរីកចម្រើនឈានទៅកាន់គោលដៅទីក្រុងនិរន្តរភាពនៅក្នុងវិស័យនីមួយៗ
- រៀបចំរបាយការណ៍អំពីវឌ្ឍនភាពប្រចាំឆ្នាំ
- រាយការណ៍ជូនរដ្ឋបាលរាជធានីភ្នំពេញជាទៀងទាត់

រដ្ឋបាលរាជធានីភ្នំពេញ នឹងធ្វើការរាយការណ៍ទៅគណៈកម្មការប្រឹក្សាយោបល់អំពីដំណើរការនិងវឌ្ឍនភាពនៃការអនុវត្តរបស់ក្រុមការងារបច្ចេកទេស។ ក្រុមការងារបច្ចេកទេសទាំងបួនដូចរៀបរាប់ខាងក្រោមត្រូវបានបង្កើតឡើងដើម្បីដឹកនាំការអនុវត្តតាមវិស័យចំនួនប្រាំបីដែលត្រូវបានលើកឡើងនៅក្នុងផែនការទីក្រុងនិរន្តរភាព។

១. ក្រុមការងារបច្ចេកទេសទី១៖ ការរៀបចំក្រុង និងដឹកជញ្ជូន ក្រុមការងារបច្ចេកទេសនេះនឹងធ្វើការងារលើប្រធានបទដូចជាការធ្វើផែនការប្រើប្រាស់ដី ការបែងចែកតំបន់ ការធ្វើផែនការតំបន់ឧស្សាហកម្មថ្មី ការបង្កើតដែនបម្រុងដីទីក្រុងសម្រាប់លំនៅដ្ឋានរបស់អ្នកដែលមានប្រាក់ចំណូលទាប ការដឹកជញ្ជូនសាធារណៈការគ្រប់គ្រងចរាចរណ៍ ការត្រួតពិនិត្យយានយន្តការបំពុលខ្យល់ ចំណត។ល។

២. ក្រុមការងារបច្ចេកទេសទី២៖ កម្មន្តសាល និងថាមពល ប្រធានបទដែលត្រូវបានគ្របដណ្តប់រួមមានថាមពលកកើតឡើងវិញ ប្រសិទ្ធភាពថាមពល ដំណើរការផលិតកម្មបៃតង ការប្រើប្រាស់ទឹកនៅក្នុងសហគ្រាសខ្នាតតូច និងមធ្យម និងក្នុងតំបន់សេដ្ឋកិច្ចពិសេស ។ល។

៣. ក្រុមការងារបច្ចេកទេសទី៣៖ ក្រុមការងារលើកិច្ចការគ្រប់គ្រងសំណល់ និងភាពងាយរងគ្រោះរបស់ទីក្រុង។ ក្រុមការងារបច្ចេកទេសនេះទទួលខុសត្រូវដឹកនាំការងារបច្ចេកទេស ទៅលើការគ្រប់គ្រងសំណល់រឹង និងរាវ អនាម័យតាមផ្ទះ អាងប្រព្រឹត្តកម្មទឹកកខ្វក់ខ្នាតតូច ការបង្ហូរទឹកជំនន់ បណ្តាញលូ។ល។

៤. ក្រុមការងារបច្ចេកទេសទី៤៖ លើកិច្ចការទីធ្លាសាធារណៈ បេតិកភណ្ឌវប្បធម៌ និងបរិស្ថានសំណង់។ ប្រធានបទដែលត្រូវពិភាក្សានៅក្នុងក្រុមការងារបច្ចេកទេសនេះអាចរួមមានបេតិកភណ្ឌវប្បធម៌ ការអភិរក្ស និងការស្តារឧទ្យានកម្សាន្តពហុមុខងារជាដើម។

រដ្ឋបាលរាជធានីភ្នំពេញ ដោយមានការជួយគាំទ្រពីក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព វិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល និងដៃគូអភិវឌ្ឍន៍ផ្សេងទៀត ត្រូវធ្វើការដឹកនាំ និងសម្របសម្រួលក្នុងចំណោមក្រុមការងារបច្ចេកទេសទាំងបួន។ រដ្ឋបាលរាជធានីភ្នំពេញក៏អាចប្រើប្រាស់នូវរចនាសម្ព័ន្ធ ដែលមានស្រាប់ជាយន្តការអនុវត្ត និងសម្របសម្រួលការអនុវត្តផែនការនេះ។

សមាជិកនៃក្រុមការងារបច្ចេកទេសនីមួយៗ ត្រូវមានតំណាងបច្ចេកទេសមកពីមន្ទីរពាក់ព័ន្ធនៃរដ្ឋបាលរាជធានីភ្នំពេញ តំណាងខណ្ឌទាំង១២ នៃរដ្ឋបាលរាជធានីភ្នំពេញ នាយកដ្ឋានពាក់ព័ន្ធនៃក្រសួងនីមួយៗ ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិល វិស័យឯកជន និងស្ថាប័នសិក្សាស្រាវជ្រាវដែលធ្វើការងារនៅក្នុងវិស័យពាក់ព័ន្ធ។ ក្រុមការងារបច្ចេកទេសនីមួយៗ ត្រូវមានប្រធានម្នាក់ និងសហប្រធានម្នាក់ ដែលនឹងរាយការណ៍អំពីវឌ្ឍនភាពការងារទៅដល់រដ្ឋបាលរាជធានីភ្នំពេញ។

## ៧.៣ ប្រភពធនធានហិរញ្ញវត្ថុ

ក្រុមការងារបច្ចេកទេសនីមួយៗ នឹងស្នើឡើងនូវផែនការកៀរគរប្រភពហិរញ្ញវត្ថុរបស់ខ្លួនដែលបង្ហាញនូវធនធានដែលត្រូវការដើម្បីអនុវត្តសកម្មភាព និងផែនការយុទ្ធសាស្ត្រក្នុងការទទួលបានធនធានទាំងនោះ។ ប្រភពមូលនិធិដែលអាចទទួលបានរួមមាន ថវិកាចំណូលរបស់រដ្ឋបាលរាជធានីភ្នំពេញ និងថវិកាតាមបណ្តាក្រសួងពាក់ព័ន្ធនានា ដៃគូអភិវឌ្ឍន៍ មូលនិធិអន្តរជាតិ និងថវិកាដែលបានមកពីការ វិនិយោគរបស់វិស័យឯកជន។ នៅឆ្នាំ ២០១៦ វិស័យឯកជនបានរួមចំណែកដល់ទៅ ៦២% នៃហិរញ្ញប្បទានអាកាសធាតុសកល។ តាមរយៈការបង្កើតនូវគោលនយោបាយគាំទ្រ យន្តការហិរញ្ញប្បទាន (រូបភាពទី ៩) និងយន្តការកាត់បន្ថយហានិភ័យហិរញ្ញប្បទាន (តារាងទី៤) រដ្ឋាភិបាលនឹងអាចទទួលបានជោគជ័យក្នុងការទាក់ទាញ និងជំរុញការវិនិយោគឯកជនក្នុងការអនុវត្តផែនការនេះ។

រូបភាពទី៩៖ យន្តការហិរញ្ញប្បទានសម្រាប់ការអភិវឌ្ឍទីក្រុង



តារាងទី ៤៖ ហិរញ្ញប្បទានអភិវឌ្ឍន៍បៃតង - ហានិភ័យ

| ប្រភេទនៃហានិភ័យ | ឧទាហរណ៍ទូទៅ |
|---|---|
| ហានិភ័យនយោបាយ | • មិនមានបរិយាកាសនយោបាយស្ថិតស្ថេរ ការព្រួយបារម្ភពីសន្តិសុខ<br>• ការផ្លាស់ប្តូរនៃរដ្ឋបាលថ្នាក់ជាតិ ឬថ្នាក់ក្រោមជាតិ ក្នុងការគាំទ្រគម្រោងវិនិយោគបៃតង |
| ហានិភ័យបទបញ្ញត្តិ | • គោលនយោបាយដែលជួយគាំទ្រការអភិវឌ្ឍដែលមិនមានភាពបៃតង (ឧទាហរណ៍ការអនុគ្រោះឬឧបត្ថម្ភទៅលើការប្រើប្រាស់ប្រេងឥន្ធនៈផូស៊ីល)<br>• មិនមានគោលនយោបាយគាំទ្រគ្រប់គ្រាន់ ការផ្លាស់ប្តូរបទបញ្ញត្តិ<br>• ក្របខណ្ឌបទបញ្ញត្តិមិនមានភាពរឹងមាំ និងការអនុវត្តនៅមានកម្រិត |
| ហានិភ័យបច្ចេកវិទ្យា | • ការប្រើប្រាស់បច្ចេកវិទ្យាមិនបានពេញសមត្ថភាពការខ្វះខាតនូវជំនាញបច្ចេកវិទ្យានៅក្នុងប្រទេស<br>• ហេដ្ឋារចនាសម្ព័ន្ធគាំទ្រមិនមានគ្រប់គ្រាន់ (ឧទាហរណ៍ ការចែកចាយ) |
| ហានិភ័យឥណទាន | • លទ្ធភាពសងនៃភាគីខ្ចីឥណទាន ហានិភ័យនៃការមិនសង<br>• អ្នកប្រើប្រាស់ចុងក្រោយជាអ្នកបង់សេវាសាធារណៈ |
| ហានិភ័យផ្នែកទីផ្សារហិរញ្ញវត្ថុ | • ការដល់ការកំណត់មុននៃតម្លៃទីផ្សារហិរញ្ញវត្ថុ ការប្រែប្រួលនៃតម្លៃអចលនទ្រព្យក្នុងទីផ្សារហិរញ្ញវត្ថុ<br>• ការកើនឡើងចុះនៃតម្លៃហិរញ្ញវត្ថុ |

ក្របខណ្ឌមូលនិធិអន្តរជាតិ ឬយន្តការផ្តល់ជំនួយមួយចំនួន គឺមានសារៈសំខាន់ក្នុងការកៀរគរយកមកអនុវត្តផែនការនេះក្នុងនោះមានដូចជា យន្តការផ្តល់ជំនួយរបស់សម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា (CCCA) គឺជាប្រភពមូលនិធិចម្បងមួយ។ ជំនួយហិរញ្ញវត្ថុដែលត្រូវបានគ្រប់គ្រងដោយនាយកដ្ឋានប្រែប្រួលអាកាសធាតុ ក៏មានគោលដៅគាំទ្រដល់ការអនុវត្តផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុកម្ពុជា (CCCSP) ឆ្នាំ២០១៤-២០២៣ ដោយផ្តល់ការគាំទ្រដល់គំនិតផ្តួចផ្តើមនានាដែលជាកត្តាជំរុញជួយដល់ការបង្កើនធនធានមនុស្ស ស្ថាប័ន និងហិរញ្ញវត្ថុដែលចាំបាច់នៅក្នុងវិស័យផ្សេងៗនៃការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។ ចន្លោះពីឆ្នាំ២០១១ ដល់ឆ្នាំ២០១៤ គម្រោងបង្ហាញចំនួន ២០ ដែលដឹកនាំដោយស្ថាប័នរាជរដ្ឋាភិបាល សាកលវិទ្យាល័យ និងអង្គការមិនមែនរដ្ឋាភិបាលត្រូវបានផ្តល់ហិរញ្ញប្បទានក្រោមការអញ្ជើញឱ្យដាក់សំណើចំនួនពីរលើកដាច់ដោយឡែកពីគ្នាក្នុងតម្លៃសរុបជាង ៦ លានដុល្លារអាមេរិក។[75]

ប្រភពមូលនិធិមួយទៀតដែលគួរគិតពិចារណា គឺមូលនិធិដែលគ្រប់គ្រងដោយ មូលនិធិបរិស្ថានពិភពលោក (Global Environmental Facilities - GEF)។ GEF ផ្តល់ការគាំទ្រដល់សកម្មភាពនានាដែលការពារបរិស្ថានជាសកល តាមរយៈមូលនិធិបរធនបាលកិច្ច (Trust Fund) ផ្សេងៗដែលស្ថាប័ន GEF គ្រប់គ្រង។ មូលនិធិបរធនបាលកិច្ចរបស់ GEF ត្រូវបានផ្តល់សម្រាប់សកម្មភាពជីវៈចម្រុះ ការកាត់បន្ថយការប្រែប្រួលអាកាសធាតុ ការបាត់បង់ដីជាតិដី វិស័យទឹក និងសារធាតុគីមី និងសំរាម។ មូលនិធិប្រែប្រួលអាកាសធាតុពិសេស (Special Climate Change Fund - SCCF) ផ្តល់ហិរញ្ញប្បទានដល់កម្មវិធីបន្សាំ និងការផ្ទេរបច្ចេកវិទ្យានៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ទាំងអស់ដែលជាភាគីនៃអនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC)។

[75] ព័ត៌មានបន្ថែមអំពីរបៀបដាក់ពាក្យស្នើសុំថវិកាអាចរកបាននៅក្នុងគេហៈទំព័រខាងក្រោមនេះ http://www.camclimate.org.kh/en/grant-facility/description.html។

មូលនិធិនេះផ្តល់ការគាំទ្រដល់បន្ទុកចំណាយបន្ថែមនៃការបន្សុាំដើម្បីបង្កើតអត្ថប្រយោជន៍នៃការបន្សុាំដែលអាចវាស់វែងបាន។ មូលនិធិសម្រាប់ប្រទេសមានការអភិវឌ្ឍតិចតួចបំផុត (Least Developed Countries Fund - LDCF) ដោះស្រាយតម្រូវការនៃការបន្សុាំបន្ទាន់ និងភ្លាមៗរបស់ប្រទេសដែលមានការអភិវឌ្ឍតិចតួចបំផុតទាំង ៥១ ប្រទេសដែលមានភាពងាយរងគ្រោះជាពិសេសចំពោះផលប៉ះពាល់អវិជ្ជមាន នៃការប្រែប្រួលអាកាសធាតុ។ មូលនិធិសម្រាប់កម្មវិធី បន្សុាំ (The Adaptation Fund) គាំទ្រដល់គម្រោង និងកម្មវិធីបន្សុាំនៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ដែលជាភាគីនៃពិធីសារក្យូតូ (Kyoto Protocol) ហើយដែលជាប្រទេសមានភាពងាយរងគ្រោះជាពិសេសចំពោះផលប៉ះពាល់អវិជ្ជមាន នៃការប្រែប្រួលអាកាសធាតុ។[76]

មូលនិធិអាកាសធាតុបៃតង (Green Climate Fund - GCF) គឺជាយន្តការផ្តល់មូលនិធិអន្តរជាតិ ចុងក្រោយមួយ ដែលនឹងជួយដល់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍នានានៅក្នុងការអនុវត្តយន្តការបន្សុាំ និងកាត់បន្ថយការប្រែប្រួលអាកាសធាតុ។ GCF គាំទ្រដល់គម្រោង កម្មវិធី គោលនយោបាយ និងសកម្មភាពផ្សេងៗទៀតនៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ដែលជាដៃគូរភាគី ដោយប្រើប្រាស់នូវច្រកមូលនិធិទៅតាមប្រធានបទ (thematic funding windows) ដែលចាំបាច់។ យន្តការនេះមានគោលបំណងក្លាយជាយន្តការស្នូលនៃកិច្ចខិតខំប្រឹងប្រែងជាអន្តរជាតិក្នុងការកៀរគរកប្រភពហិរញ្ញវត្ថុ (មូលនិធិ) អាកាសធាតុឱ្យបាន ១០០ ពាន់លានដុល្លារក្នុងមួយឆ្នាំ ត្រឹមឆ្នាំ ២០២០។ យន្តការ GCF ផ្តល់លទ្ធភាពដល់បណ្តាប្រទេសជាដៃគូរអាចទទួលបាននូវមូលនិធិនេះមកប្រើប្រាស់ តាមរយៈស្ថាប័ន និងអង្គភាពអន្តរការី ដែលជាអ្នកអនុវត្តកម្មវិធីដែលមានការទទួលស្គាល់ទាំងនៅថ្នាក់ជាតិ ក្រោមជាតិ និងថ្នាក់តំបន់។ ប្រទេសនីមួយៗក៏អាចទទួលបានមូលនិធិនេះ តាមរយៈស្ថាប័នថ្នាក់អន្តរជាតិ និងថ្នាក់តំបន់ ដែលមានការទទួលស្គាល់ផងដែរ (ដូចជាធនាគារអភិវឌ្ឍន៍ពហុភាគី និងតំបន់ និងទីភ្នាក់ងារនៃអង្គការសហប្រជាជាតិ) ក្រោមលទ្ធភាពចូលទៅកាន់មូលនិធិតាមរយៈស្ថាប័នអន្តរជាតិ (international access)។ មូលនិធិខ្លះនឹងត្រូវបានផ្តល់ឱ្យតាមរយៈ ការធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពទទួលបានដោយផ្ទាល់ (Enhanced Direct Access) ដែលវាមានន័យថា មូលនិធិនឹងផ្តល់ឱ្យស្ថាប័នដែលមានមូលដ្ឋាននៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍នោះផ្ទាល់ ហើយដែលមានការទទួលស្គាល់ ដើម្បីឱ្យស្ថាប័នទាំងនោះយកទៅធ្វើការតាក់តែង និងអនុវត្តកម្មវិធីរបស់ខ្លួនដោយផ្ទាល់។ នៅខែតុលា ឆ្នាំ២០១៦ GCF បានអនុម័តថវិកាចំនួន ៧៤៥ លានដុល្លារអាមេរិកនៅក្នុងសំណើសុំមូលនិធិ។ មានគម្រោង និងកម្មវិធីចំនួន ១០ ដែលមានតម្លៃបូកចូលគ្នាចំនួន ២,៦ ពាន់លានដុល្លារអាមេរិក និងជួយដល់ប្រទេសចំនួន ២៧ ទូទាំងពិភពលោក ដើម្បីកាត់បន្ថយការបញ្ចេញកាបូនរបស់ខ្លួន និងបន្សុាំទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។ គម្រោង និងកម្មវិធីទាំងនេះផ្តោតជាចម្បងទៅលើការបន្សុាំ (៥២%) ចម្រុះ (២២%) និងការកាត់បន្ថយ (២៦%)[77]។

## ៧.៤ ការតាមដាន និងការវាយតម្លៃការអនុវត្ត

ការអនុវត្តផែនការអភិវឌ្ឍន៍ទីក្រុងនិរន្តរភាពសម្រាប់រាជធានីភ្នំពេញ នឹងត្រូវធ្វើការតាមដាន និង វាយតម្លៃយ៉ាងហ្មត់ចត់។ រដ្ឋបាលរាជធានីភ្នំពេញ ក៏អាចប្រើប្រាស់នូវរចនាសម្ព័ន្ធ ដែលមានស្រាប់ជាយន្តការអនុវត្ត តាមដាន និងវាយតម្លៃក្នុងការអនុវត្តផែនការនេះ។ ក្រៅពីការតាមដានវាយតម្លៃប្រចាំឆ្នាំ ក៏នឹងមានការវាយតម្លៃពាក់កណ្តាល អាណត្តិដែលនឹងត្រូវអនុវត្តនៅឆ្នាំ២០២៤ និងការវាយតម្លៃពេលបញ្ចប់ការអនុវត្តដែលនឹងត្រូវធ្វើនៅក្នុងឆ្នាំ២០៣០ ផងដែរ។ ក្រុមការងារបច្ចេកទេសនីមួយៗត្រូវបង្កើតគោលដៅ និងសូចនាករជាក់លាក់សម្រាប់ការវាយតម្លៃ ហើយត្រូវសរសេររបាយការណ៍ប្រចាំឆ្នាំទៅរដ្ឋបាលរាជធានីភ្នំពេញ ដើម្បីបង្ហាញពីវឌ្ឍនភាព និងបញ្ហាប្រឈមក្នុងការអនុវត្តសកម្មភាពអាទិភាពនិងការកៀរគរធនធាន។ បន្ទាប់មក រដ្ឋបាលរាជធានីភ្នំពេញ នឹងចងក្រងរបកគំហើញទាំងអស់របស់ក្រុមការងារបច្ចេកទេស ហើយបង្កើតជារបាយការណ៍បូកសរុបមួយសម្រាប់ក្រុមទីប្រឹក្សា។ ដំណើរការវាយតម្លៃពាក់កណ្តាលអាណត្តិ និងពេលបញ្ចប់ការអនុវត្ត អាចត្រូវបានធ្វើឡើងដោយមានអ្នកជំនាញការខាងក្រៅ ក្រោមការដឹកនាំរបស់រដ្ឋបាលរាជធានីភ្នំពេញ។ លទ្ធផលនៃការតាមដាន និងវាយតម្លៃ ក៏នឹងត្រូវបានចែកចាយទូលំទូលាយដល់សាធារណជនផងដែរ៕

[76] ព័ត៌មានបន្ថែមអំពីរបៀបដាក់ពាក្យសុំមូលនិធិទាំងនេះអាចរកបានតាមរយៈគេហៈទំព័រនេះ https://www.thegef.org/gef/who_can_apply
[77] ព័ត៌មានបន្ថែមអំពីមូលនិធិអាចរកបាននៅទីនេះ http://www.greenclimate.fund/home

# ឯកសារយោង

ADB. 2011. 'Country Partnership Strategy: Cambodia, 2011-2013'. Sector assessment (summary): energy. URL: http://www.adb.org/sites/default/files/linked-documents/cps-cam-2011-2013-oth-01.pdf.

ADB. 2014. Cambodia: diversifying beyond garments and tourism - country diagnostic study. URL: http://www.adb.org/sites/default/files/publication/149852/cambodia-diversifying-country-diagnostic-study.pdf

ADB. 2014. Cambodia: Country Poverty Analysis 2014. URL: http://www.adb.org/documents/cambodia-country-poverty-analysis-2014

ADB. 2015. Renewable energy developments and potential in the Greater Mekong Subregion. URL: http://www.adb.org/publications/renewable-energy-developments-and-potential-gms.

Beng Hong Socheat Khemro. 2014. 'Housing Policy and Circular No. 3 on Squatter Settlement Resolution'. URL: http://giz-cambodia.com/wordpress/wp-content/uploads/9-Summer-School_Beng-Hong-Socheat-Khemaro.pdf

Cambodian Air Quality Monitoring Project 2016. URL: http://agicn.org/country/cambodia

Cambodian Education and Waste Management Organization. 2014. Policy Framework and Institutional Arrangement on Solid Waste Management and the Development Landfills in Phnom Penh.

Central Intelligence Agency (CIA). 2015. "The World Factbook – Cambodia". URL: https://www.cia.gov/library/publications/the-world-factbook/geos/cb.html

Deau, R. 2016. Energy in Cambodia – a situation analysis. Presentation delivered at the 'Clean Energy in Cambodia: An Economic Opportunity for the Private Sector' workshop, Phnom Penh, 26 May 2016

Electricity Authority of Cambodia. 2015. Report on power sector of the Kingdom of Cambodia: 2015 edition. URL: http://eac.gov.kh/wp-content/uploads/2015/07/report-2014en.pdf.

Electrity Authority of Cambodia. 2018. Summary Report on power sector of the Kindgom of Cambodia: 2018. URL: https://eac.gov.kh/uploads/salient_feature/khmer/salient_feature_2018_kh.pdf

Electricite Du Cambodge. 2014. Annual Report, Phnom Penh, Cambodia.

Electricite Du Cambodge. 2016. Annual Report, Phnom Penh, Cambodia

FDI. 2012. Asia-Pacific Cities of the Future 2011/2012. URL: www.fDiIntelligence.com

Global Green Growth Institute (GGGI). 2014a. 'GGGI Cambodia project: energy report - an assessment of the potential for improved green energy outcomes in Cambodia'. Unpublished report.

GGGI. 2014b. Cambodia Private Sector Analysis - Green Growth Opportunities Perspective

International Energy Agency (IEA). 2015. 'Cambodia: Electricity and Heat for 2013'. URL: www.iea.org/statistics/statisticssearch/report/?country=Cambodia&product=electricityandheat

International Labor Organization Cambodia. 2015. "Cambodian Garment and Footwear Sector Bulletin, Issue 2". URL: http://betterfactories.org/?p=10557

JICA. 2014. The project for comprehensive urban transport plan in Phnom Penh Capital City (PPUTMP). Final report – Executive summary.

JICA 2015a. The Study on Drainage and Sewerage Improvement Project in Phnom Penh Metropolitan Area. Progress Report II, November 2015.

JICA 2015b. The Preparatory Survey for Project of Development of Traffic Management System in Phnom Penh. Preparatory Survey Report.

Kitamura, Y., Hayashi, M., & Yagi, E. (2018). Traffic problems in Southeast Asia featuring the case of Cambodia's traffic accidents involving motorcycles. IATSS Research.

Kuok Federo, Im Makara, Hul Seingheng, and Soy Ty. 2015. Solid Waste Generation and Life-Span with Credible Growth Forecasts of Waste Generation, Volume and Composition

Matinga, M.N. 2012. 'Sustainable Energy for All - Rapid Assessment and Gap Analysis - Royal Kingdom of Cambodia'. Draft 1.

Ministry of Environment. "Solid Waste Management of Cambodia". Presentation at a Regional

Ministry of Mines and Energy and Economic Research Institute for ASEAN and East Asia, 2016. Cambodia's National Energy Statistic 2016. URL: http://www.eria.org/RPR_FY2015_08.pdf

Ministry of Tourism 2015. Tourism Statistics Report – Year 2015. URL: http://www.tourismcambodia.org/images/mot/statistic_reports/tourism_statistics_2015.pdf

Nara, H. Undated. "Regulations of the Building Regulations and Codes". PowerPoint presentation by MLMUPC

National Council for Sustainable Development (NCSD) and GGGI, 2016. Green City Strategic Planning Methodology. Phnom Penh, Cambodia.

National Institute of Statistic. 2015. Cambodia Socio-Economic Survey 2014. URL: http://www.nis.gov.kh/nis/CSES/CSES_2014_Report.pdf.

Njirambo, M. 2012. 'Sustainable Energy for All - Rapid Assessment and Gap Analysis - RGC'. Draft 1.

OHCHR Cambodia 2012. Resettlement Study. URL: http://cambodia.ohchr.org/WebDOCs/DocProgrammes/Resettlement_Study-28_Feb_2012_Eng.pdf

Otis Daniel, 2013. Putrid Lakes Offer Sweet Relief to a City Lacking Water Treatment Plants. Resilient Cities, 18 November 213. URL: https://nextcity.org/daily/entry/putrid-lakes-offer-sweet-relief-to-a-city-lacking-water-treatment-plants.

People in Need Cambodia, 2015. Urbanizing Disaster Risk, Vulnerability of the Urban Poor in Cambodia to Flooding and Other Hazards.

People in Need Cambodia and UNICEF. Undated. Multiple Indicator Assessment of the Urban Poor. URL: http://www.unicef.org/cambodia/PIN_URBAN_POOR_FA.PDF

Phnom Penh Capital Administration (PPCA), Bulletin No.35, September 2017.

PPCA's website http://phnompenh.gov.kh/en/about-us/governor-message/

Phnom Penh Post. 18/11/2014. "Road deaths to rise: minister". URL: http://www.phnompenhpost.com/national/road-deaths-rise-minister.

Royal Government of Cambodia. 2007b. Law on Administration of Factory and Handicraft, enacted 23 June 2006. URL: http://www.opendevelopmentcambodia.net/pdf-viewer/?pdf=download/law/Law_on_Administration_of_Factory_and_Handicraft_23_June_2006_Eng.pdf

RGC. 2013a. National Policy on Green Growth. Phnom Penh, Cambodia.

RGC. 2013b. National Policy, Strategy and Action Plan on Energy Efficiency in Cambodia, Drafted. Phnom Penh, Cambodia

RGC. 2015. Industrial Development Policy 2015-2025. Phnom Penh, Cambodia.
Sebatian Strangio. 2014. p.155. Hun Sen's Cambodia. Yale University Press.

Seng et al. 2011. Seng, B., Kaneko, H., Hirayama, K. and Katayama-Hirayama, K. 2011. "Municipal solid waste management in Phnom Penh, capital city of Cambodia". Waste Management Research Group, May 2011, 29(5): 491-500.

Trac Thai Sieng. 2015. "Welcome to Phnom Penh Smart City Master Plan". Presentation at the Sustainable Urban Transport Workshop, 8-10 July 2015, Danag, Viet Nam.

UN-HABITAT, UNESCAP and UNEP. 2010. The State of Asian Cities 2010/11. URL: http://mirror.unhabitat.org/pmss/listItemDetails.aspx?publicationID=3078&AspxAutoDetectCookieSupport=1

Workshop on National Strategy for Integrated Solid Waste Management / 3R, Hai Phong, Viet Nam, 28–29 July 2010.

World Bank 2015. Cambodia - Economic Update: maintaining high growth. URL: http://documents.worldbank.org/curated/en/2015/04/24427602/cambodia-economic-update-maintaining-high-growth

World Bank. 2018. World Bank Database. Washington, D.C.: The World Bank. URL: http://data.worldbank.org/indicator/NV.IND.TOTL.ZS.

Yusuf A.A. & Francisco H. (2009). Climate change vulnerability mapping for Southeast Asia. Economy and Environment Program for Southeast Asia (EEPSEA). URL: https://www.idrc.ca/sites/default/files/sp/Documents%20EN/climate-change-vulnerability-mapping-sa.pdf

Photo credit:
Front cover photo from www.google.com

# ឧបសម្ព័ន្ធ ក៖
## បញ្ជីឈ្មោះភាគីពាក់ព័ន្ធដែលត្រូវបានពិគ្រោះយោបល់

### ស្ថាប័នរាជរដ្ឋាភិបាល

- ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ប្រកបដោយចីរភាព (NCSD)
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (MEF)
- ក្រសួងមហាផ្ទៃ (MOI)
- ក្រសួងផែនការ (MOP)
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (MLMUPC)
- ក្រសួងបរិស្ថាន (MOE)
- ក្រសួងសាធារណការ និងដឹកជញ្ជូន (MPWT)
- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម (MOIH)
- ក្រសួងរ៉ែ និងថាមពល (MME)
- ក្រសួងធនធានទឹក និងឧតុនិយម (MOWRAM)
- ក្រសួងកិច្ចការនារី (MOWM)
- ក្រសួងទេសចរណ៍ (MOT)
- ក្រសួងពាណិជ្ជកម្ម (MOC)

### អង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នសិក្សា

- NEXUS
- GERES
- វិទ្យាស្ថានកម្ពុជានគរូបនីយវិទ្យា (CIUS)
- វេទិកាអង្គការមិនមែនរដ្ឋាភិបាល (NGOF)
- មូលនិធិអាស៊ី (Asia Foundation)
- World Wide Fund for Nature (WWF)
- Heinrich Böll Foundation (HBF)
- សាកលវិទ្យាល័យភូមិន្ទភ្នំពេញ (RUPP)
- Netherlands Development Organization (SNV)
- វិទ្យាស្ថាន Enrich
- វិទ្យាស្ថាន IGES

### រដ្ឋបាលមូលដ្ឋាននៅរាជធានីភ្នំពេញ

- សាលារាជធានីភ្នំពេញ
- ខណ្ឌចំការមន
- ខណ្ឌដូនពេញ
- ខណ្ឌ ៧ មករា
- ខណ្ឌទួលគោក
- ខណ្ឌដង្កោ
- ខណ្ឌមានជ័យ
- ខណ្ឌឫស្សីកែវ
- ខណ្ឌសែនសុខ
- ខណ្ឌពោធិ៍សែនជ័យ
- ខណ្ឌច្បារអំពៅ
- ខណ្ឌជ្រោយចង្វារ
- ខណ្ឌព្រែកព្នៅ

### ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន

- សម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា
- ធនាគារអភិវឌ្ឍន៍អាស៊ី (ADB)
- ធនាគារពិភពលោក (WB)
- ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID)
- JICA, KOICA
- ភ្នាក់ងារកិច្ចសហប្រតិបត្តិការអាល្លឺម៉ង់
- នាយកដ្ឋានកិច្ចការបរទេសនិងពាណិជ្ជកម្ម
- ទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍន៍
- UNDP, UNHABITAT, UNIDO, UNESCO, UNCDF, UNEP,
- KFW, IFC
- WaterAid
- EU, EuroCham Green Biz
- etc.,

# ឧបសម្ព័ន្ធ ខ៖
## គម្រោងវិនិយោគអាទិភាពសម្រាប់ការអភិវឌ្ឍទីក្រុងនិរន្តរភាព*

| ឈ្មោះគម្រោងទៅតាមវិស័យអាទិភាព | រយៈពេល | ស្ថាប័នអនុវត្តន៍ |
|---|---|---|
| **១. ការធ្វើផែនការលម្អិតស្តីពីការប្រើប្រាស់ដី និងការបែងចែកតំបន់សម្រាប់ខណ្ឌដូនពេញ**<br>ការធ្វើផែនការលម្អិតស្តីពីការប្រើប្រាស់ដី និងការកំណត់បែងចែកតំបន់នៅក្នុងខណ្ឌដូនពេញ នឹងនាំឱ្យមានការការពារសណ្ឋានផ្លូវថ្នល់ បណ្តុំអគារ និងទីធ្លាសាធារណៈដែលមានសារៈសំខាន់ខ្លាំងចំពោះអត្តសញ្ញាណរបស់ទីក្រុង។ ផែនការនេះនឹងបង្កើនភាពរស់រវើកនិងសកម្មភាពរបស់តំបន់នោះ ព្រមទាំងបន្តបង្កើនភាពទាក់ទាញដល់ប្រជាជន និងភ្ញៀវទេសចរណ៍ផងដែរ។ | រយៈពេលខ្លី | • រដ្ឋបាលរាជធានីភ្នំពេញ<br>• ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់<br>• អាជ្ញាធរឃុំសង្កាត់<br>• សង្គមស៊ីវិលធ្វើការក្នុងវិស័យបេតិកភណ្ឌវប្បធម៌<br>• សមាគមពាណិជ្ជកម្មក្នុងស្រុក<br>• សាកលវិទ្យាល័យនានាដែលមានកម្មវិធីពាក់ព័ន្ធ និងស្ថាបត្យកម្ម។ |
| **២. ផែនការលម្អិតស្តីពីប្រើប្រាស់ដី និងការបែងចែកតំបន់លម្អិតសម្រាប់តំបន់អភិវឌ្ឍន៍ក្រុងតាខ្មៅ**<br>ផែនការនេះនឹងធានាថាតំបន់ក្រុងនេះប្រកបដោយការអភិវឌ្ឍសម្រាប់ការពង្រីកក្រុងតាខ្មៅ។ ផែនការនេះក៏នឹងធានាផងដែរថា ការដឹកជញ្ជូន និងការប្រើប្រាស់ដីត្រូវបានគ្រោងដោយសមស្រប ទៅតាមគោលដៅដែលបានកំណត់ដើម្បីឱ្យការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធតំបន់ក្រុងទទួលបានផលប្រយោជន៍ជាអតិបរមា។ ដោយយោងទៅតាមផែនការមេស្តីពីការប្រើប្រាស់ដីឆ្នាំ ២០៣៥ ក្រុងតាខ្មៅនឹងក្លាយជាតំបន់ទីប្រជុំជនដ៏សំខាន់មួយក្នុងចំណោមទីប្រជុំជនធំៗទាំង ៤ ។ | រយៈពេលខ្លី | • រដ្ឋបាលរាជធានីភ្នំពេញ<br>• ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់<br>• អាជ្ញាធរខេត្ត(រួមបញ្ចូលទាំងអាជ្ញាធរថ្នាក់ឃុំ និងស្រុក)<br>• សាកលវិទ្យាល័យ និងវិទ្យាស្ថានដូចជា CIUS |
| **៣. ការធ្វើផែនការលើតំបន់ឧស្សាហកម្មថ្មីៗ និងវិស័យឧស្សាហកម្មផ្សេងទៀត**<br>ការធ្វើផែនការលើតំបន់ឧស្សាហកម្មថ្មីៗ និងវិស័យឧស្សាហកម្មផ្សេងទៀតនឹងត្រូវធ្វើឡើងតាមរយៈការពិនិត្យលើកត្តាជាច្រើន ដូចជាលទ្ធភាពនៃការប្រកួតប្រជែង ភាពធន់នៃទីប្រជុំជន ចរាចរណ៍ក្នុងទីប្រជុំជន ក៏ដូចជាគោលដៅក្នុងការបង្កើតវាឱ្យនៅឆ្ងាយពីតំបន់រស់នៅ ដើម្បីធានាការពារសុខភាពសាធារណៈ។ ដំណើរការនៃផលិតកម្មត្រូវធ្វើឡើងតាមគោលការណ៍ផលិតកម្មស្អាត។ | រយៈពេលមធ្យម | • រដ្ឋបាលរាជធានីភ្នំពេញ<br>• ក្រសួងរៀបចំដែនដី នគរូនីយកម្ម និងសំណង់<br>• ក្រសួងឧស្សាហកម្ម និងសិប្បកម្ម<br>• សមាគមរោងចក្រកាត់ដេរនៅកម្ពុជា (GMAC)<br>• ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍កម្ពុជា |

**បញ្ជាក់៖ សម្រាប់គម្រោងវិនិយោគទាំង ៤៨ គម្រោង គឺមានការសរសេរលម្អិតពីគោលគំនិតរបស់គម្រោង ការសង្ខេបពីបរិបទគម្រោង និងទិន្នន័យមូលដ្ឋាន ដែលមាននៅក្នុងឯកសារសិក្សាដាច់ដោយឡែក។*

| ឈ្មោះគម្រោងទៅតាមវិស័យអាទិភាព | រយៈពេល | ស្ថាប័នអនុវត្តន៍ |
|---|---|---|
| **៤. ការបង្កើតដីតំបន់ក្រុងបម្រុងសម្រាប់គ្រួសារដែលមានចំណូលទាប**<br>ការបង្កើតដីបម្រុងតំបន់ក្រុងនឹងផ្តល់ជា ក) ការកំណត់អត្តសញ្ញាណដីឯកជនរបស់រដ្ឋ ដែលអាចបម្រើដល់ការសាងសង់លំនៅដ្ឋាន និង ខ) ការទទួលបានដីឯកជនក្នុងទម្រង់ជាកសិកម្ម ឬលក្ខណៈផ្សេងទៀត។ ការបង្កើតដីបម្រុងនេះនឹងត្រូវពាក់ព័ន្ធនឹងផ្នែកគ្រប់គ្រង ស្ថាប័ន ធនធានហិរញ្ញវត្ថុ ដែលនឹងត្រូវផ្តល់ដោយរដ្ឋាភិបាល និងការកំណត់យន្តការច្បាស់លាស់ក្នុងការបែងចែកដីឱ្យទៅផែនការអភិវឌ្ឍការសាងសង់លំនៅដ្ឋានសម្រាប់គ្រួសារដែលមានចំណូលទាប។ | រយៈពេលមធ្យម | • រដ្ឋបាលរាជធានីភ្នំពេញ<br>• ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |
| **៥. ការផ្តល់សុពលភាពលើផែនការមេសម្រាប់តំបន់ក្រុងនៃ រាជធានីភ្នំពេញ**<br>ដំណើរការប្រឹក្សានិងការចូលរួមនេះ នឹងជាដំណាក់កាលដ៏សំខាន់ក្នុងការបង្កើតប្រព័ន្ធអភិបាលកិច្ចក្នុងតំបន់ដែលផ្តល់ភាពទុកចិត្តបានកាន់តែច្រើន។ ដំណើរការនេះនឹងតម្រូវឱ្យមានធនធាននិងជំនាញច្បាស់លាស់ ក៏ដូចជាប្រព័ន្ធព័ត៌មានដែលដំណើរការដើម្បីតំណាង បង្ហាញសេចក្តីស្នើ និងកត់ត្រាព័ត៌មានត្រឡប់ជាដើម។ | រយៈពេលមធ្យម | • រដ្ឋបាលរាជធានីភ្នំពេញ<br>• ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |
| **៦. ការសិក្សាលើការរៀបចំ ប្រព័ន្ធគ្រប់គ្រងតំបន់ទីប្រជុំជនធំៗ នៅក្នុងរាជធានីភ្នំពេញ**<br>គម្រោងសិក្សាស្រាវជ្រាវនេះនឹង ក) ពិនិត្យលើបទពិសោធន៍អន្តរជាតិអំពីប្រព័ន្ធគ្រប់គ្រងតំបន់ប្រជុំជនធំៗក្នុងរាជធានី ពីបណ្តាប្រទេសនានា ទាំងប្រទេសដែលមានចំណូលទាប និងទាប-មធ្យម តាមរយៈការពិនិត្យ និងវាយតម្លៃទៅលើកត្តាស្រដៀងៗគ្នាដែលប្រទេសគេបានអនុវត្ត ខ) ពិនិត្យលើជម្រើសនានាទាក់ទងទៅនឹងការរៀបចំស្ថាប័នគ្រប់គ្រងវិស័យច្បាប់ និងសារពើពន្ធនៅក្នុងបរិបទប្រទេសកម្ពុជានាពេលបច្ចុប្បន្ន គ) ធ្វើការប្រឹក្សាយោបល់ជាមួយភាគីពាក់ព័ន្ធទាំងនៅក្នុងកម្រិតថ្នាក់ជាតិ និងកម្រិតតំបន់ ក៏ដូចជាជាមួយនឹងសង្គមស៊ីវិល និងវិស័យឯកជន និង ឃ) ផ្តល់អនុសាសន៍ និងជម្រើសដើម្បីបង្កើតជាផែនទីបង្ហាញផ្លូវលើកំណែទម្រង់។ ដំណើរការនេះនឹងត្រូវមានតម្លាភាព ហើយសាធារណៈអាចទទួលបាន។ | រយៈពេលខ្លី | • រដ្ឋបាលរាជធានីភ្នំពេញ<br>• ក្រសួងមហាផ្ទៃ<br>• ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| **៧. ពង្រឹងប្រព័ន្ធអនាម័យតាមគ្រួសារនៅតាមតំបន់ជាយក្រុង**<br>គម្រោងនេះនឹងបង្ហាញអំពីការប្រើប្រាស់ប្រព័ន្ធអនាម័យតាមគ្រួសារដែលមានតម្លៃទាប តាមរយៈបច្ចេកវិទ្យាសាមញ្ញក្នុងការទុកដាក់កាកសំណល់ និងកាត់បន្ថយការរីកសាយនៃកាកសំណល់មនុស្ស និងអាចបញ្ចៀសបញ្ហាសុខភាពផ្សេងៗនៅពេលមានទឹកជំនន់។ ការរៀបចំបង្គន់អនាម័យបរិស្ថាន ឬការសាងសង់បង្គន់ដែលគិតពីផលប៉ះពាល់លើបរិស្ថាន អាចត្រូវបានយកមកអនុវត្ត និងប្រើប្រាស់ក្នុងតំបន់ណាមួយសម្រាប់ធ្វើជាគំរូ។ | រយៈពេលខ្លី | • រដ្ឋបាលរាជធានីភ្នំពេញ<br>• ក្រសួងសាធារណការ និងដឹកជញ្ជូន |

| ឈ្មោះគម្រោងទៅតាមវិស័យអាទិភាព | រយៈពេល | ស្ថាប័នអនុវត្តន៍ |
|---|---|---|
| **៨. ការបំពាក់ប្រព័ន្ធប្រព្រឹត្តកម្មសំណល់ទឹក (ខ្នាតតូច) ក្នុងតំបន់ជាយក្រុងដែលមិនស្ថិតនៅក្នុងប្រព័ន្ធប្រព្រឹត្តកម្មរបស់ក្រុងសម្រាប់ជាគំរូបង្ហាញ**<br>គម្រោងនេះនឹងបង្ហាញពីភាពប្រាកដប្រជា និងលទ្ធភាពក្នុងការប្រើប្រាស់ប្រព័ន្ធប្រព្រឹត្តិកម្មសំណល់ទឹក (ទឹកកខ្វក់) ក្នុងតំបន់ជាយក្រុងដែលជាតំបន់មិនត្រូវបានបញ្ចូលក្នុងទីតាំងប្រព្រឹត្តកម្មសំណល់ទឹករួមរបស់ទីក្រុងភ្នំពេញ ដែលនឹងបង្កើតឡើងឆាប់ៗខាងមុខ។ ប្រព័ន្ធប្រព្រឹត្តកម្មខ្នាតតូចអាចបង្កើតក្នុងទំហំច្រើន ងាយស្រួលដំឡើង ហើយទឹកដែលបានធ្វើប្រព្រឹត្តកម្មហើយត្រូវបញ្ចេញចោលទៅតាមតំបន់។ | រយៈពេលខ្លី | • រដ្ឋបាលរាជធានីភ្នំពេញ<br>• ក្រសួងសាធារណការ និងដឹកជញ្ជូន<br>• ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់<br>• ក្រសួងឧស្សាហកម្ម និងសិប្បកម្ម<br>• ក្រសួងបរិស្ថាន<br>• អាជ្ញាធរឃុំ សង្កាត់ក្នុងរាជធានី |
| **៩. ការបង្ហាញអំពីការរៀបចំឡើងវិញនៃតំបន់សួនឧទ្យានដែលមានស្រាប់ សម្រាប់ពង្រឹងលើការស្តុកទឹកនិងបញ្ចុះកម្តៅទឹក**<br>ឧទ្យាន និងសួនជាច្រើននៅក្នុងទីក្រុងមិនបានរៀបចំឱ្យបានល្អ ក្នុងការគ្រប់គ្រងទឹកភ្លៀងនិងការបញ្ចុះកម្តៅដោយធម្មជាតិ។ ឧទ្យាន និងសួនមួយចំនួនត្រូវបានពង្រីកយ៉ាងធំ ដោយសាងសង់ពីសម្ភារដែលមិនជ្រាបទឹក ដែលការពារទឹកមិនឱ្យចូលទៅក្នុងដីបាន។ បន្ថែមពីនេះ ដើមឈើ និងចុល្លព្រឹក្សលម្អនៅក្នុងឧទ្យាន និងសួនទាំងនេះ មិនអាចផ្តល់ម្លប់និងរក្សាទឹកបានគ្រប់គ្រាន់នោះទេ។ | រយៈពេលខ្លី | • រដ្ឋបាលរាជធានីភ្នំពេញ<br>• ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់<br>• ក្រសួងបរិស្ថាន |
| **១០. ការបង្ហាញអំពីការបង្កើតតំបន់ដីសើមក្នុងទ្រង់ទ្រាយតូច សម្រាប់ប្រព្រឹត្តកម្មសំណល់ទឹក**<br>រាជធានីភ្នំពេញមានតំបន់ដីសើមមួយចំនួន ដែលធ្លាប់បានប្រើប្រាស់ជាប្រព័ន្ធធម្មជាតិសម្រាប់ប្រព្រឹត្តកម្មសំណល់ទឹក ។ ប៉ុន្តែ ខណៈដែលចំនួនប្រជាជនតាមតំបន់ក្រុងកើនឡើង បរិមាណសំណល់ទឹកបានបង្កបញ្ហាដល់ប្រព័ន្ធប្រព្រឹត្តកម្មធម្មជាតិ។ បន្ថែមពីនេះ តំបន់ដីសើមធម្មជាតិត្រូវបានរំលោភបំពាន និងបំផ្លាញយ៉ាងធ្ងន់ធ្ងរដោយសារការអភិវឌ្ឍតំបន់ក្រុង។ គម្រោងនេះនឹងបង្ហាញពីភាពប្រាកដប្រជា និងលទ្ធភាពក្នុងការបង្កើតតំបន់ដីសើមសម្រាប់ប្រព្រឹត្តកម្មសំណល់ទឹកដែលមានទំហំតូចៗ ដើម្បីអាចធ្វើជាគំរូសម្រាប់តំបន់ផ្សេងទៀត។ | រយៈពេលខ្លី | • រដ្ឋបាលរាជធានីភ្នំពេញ<br>• ក្រសួងបរិស្ថាន |
| **១១. ការធ្វើបទប្បញ្ញត្តិច្បាប់ ការបែងចែកតំបន់ និងការរក្សា ដើម្បីការពារតំបន់បៃតង**<br>ផែនការមេរាជធានីភ្នំពេញស្តីពី ការប្រើប្រាស់ដី ឆ្នាំ២០៣៥ បានរួមបញ្ចូលនូវគោលដៅអភិវឌ្ឍន៍ក្នុងការ រក្សាប្រព័ន្ធធម្មជាតិដូចជា បឹង និងតំបន់ដីសើម និងបង្កើតជាតំបន់បៃតងថ្មីៗក្នុងទីក្រុង។ គម្រោងនឹងរៀបចំជាបទប្បញ្ញត្តិ និងការរក្សាការបែងចែកតំបន់ប្រើប្រាស់ដី ដែលកំណត់លើតំបន់បៃតងសំខាន់ៗសម្រាប់ការអភិរក្ស។ | រយៈពេលមធ្យម | • រដ្ឋបាលរាជធានីភ្នំពេញ<br>• ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |

| ឈ្មោះគម្រោងទៅតាមវិស័យអាទិភាព | រយៈពេល | ស្ថាប័នអនុវត្តន៍ |
|---|---|---|
| **១២. កាត់បន្ថយការគំរាមកំហែងដោយសារការប្រែប្រួលអាកាសធាតុសម្រាប់រាជធានីភ្នំពេញ**<br>គម្រោងរួមមានការទាញយកទិន្នន័យអាកាសធាតុពីសេណារីយ៉ូ IPCC ដូចជាការសិក្សាទៅលើ ទម្រង់ចែកចាយសកលទូទៅ (Global General Circulation Models) ការសិក្សាម៉ូដែលអាកាសធាតុតំបន់ (Regional Climate Models) និងម៉ូដែលស្រាវជ្រាវនិងព្យាករណ៍ធាតុអាកាសចំពោះតំបន់រាជធានីភ្នំពេញ (Weather Research and Forecasting Models to Phnom Penh) ហើយប្រើប្រាស់ទិន្នន័យដែលទទួលបានទៅជាធាតុចូល ដើម្បីបង្កើតបទដ្ឋានសម្រាប់ម៉ូដែលប្រព័ន្ធទឹកនិងប្រព័ន្ធបង្ហូរទឹកជំនន់។ | រយៈពេលខ្លី | • រដ្ឋបាលរាជធានីភ្នំពេញ<br>• ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព<br>• ក្រសួងបរិស្ថាន<br>• ក្រសួងធនធានទឹក និងឧតុនិយម<br>• សាកលវិទ្យាល័យ |
| **១៣. គម្រោងសាកល្បងប្រើប្រាស់ថាមពលបំភ្លឺផ្លូវសាធារណៈប្រកបដោយប្រសិទ្ធភាព**<br>ការដាក់ភ្លើងបំភ្លឺផ្លូវនៅរាជធានីភ្នំពេញមានសក្តានុពលខ្លាំងក្នុងការពង្រឹងប្រសិទ្ធភាពថាមពល និងការដំឡើងភ្លើងបំភ្លឺដែលមានប្រសិទ្ធភាពសម្រាប់តំបន់អភិវឌ្ឍន៍ថ្មីៗ។ មានជម្រើសសំខាន់ៗបីដើម្បីពង្រឹងប្រសិទ្ធភាពភ្លើងបំភ្លឺដូចជា៖ (១)ជំនួសភ្លើងបំភ្លឺចាស់ៗដោយប្រភេទភ្លើង LED វិញ (២) ពង្រឹង/ដំឡើងកុងដង់ដែលអាចបន្ថយពន្លឺបាន ទៅនឹងអំពូលលោហៈផ្សំពីហាលូហ្សែននិងសូដ្យូមដែលមានស្រាប់ គោលដៅដើម្បីពង្រឹងប្រសិទ្ធភាពថាមពល គ្រប់គ្រងពន្លឺ និង(៣) ប្រព័ន្ធគ្រប់គ្រងពន្លឺភ្លើងដោយឆ្លាតវៃសម្រាប់ចំណុចទី ១ និងទី ២។ | រយៈពេលខ្លី | • រដ្ឋបាលរាជធានីភ្នំពេញ<br>• ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព<br>• ក្រសួងរ៉ែ និងថាមពល<br>• អគ្គិសនីកម្ពុជា<br>• វិស័យឯកជន |
| **១៤. ការដាក់ស្លាកសញ្ញាសម្គាល់លើឧបករណ៍ប្រើប្រាស់ថាមពលប្រកបដោយប្រសិទ្ធភាព**<br>គម្រោងនេះនឹងជួយគាំទ្រ ១) បង្កើតប្រព័ន្ធដាក់ស្លាកសញ្ញា ២) អភិវឌ្ឍសមត្ថភាពសម្រាប់ធ្វើតេស្ត និងដាក់ស្លាកសញ្ញាផលិតផលដែលមានប្រសិទ្ធភាពថាមពល ៣) ពង្រឹងរបៀបដាក់ស្លាកសញ្ញា និងធ្វើតេស្ត ៤) លើកកម្ពស់ការយល់ដឹងក្នុងចំណោមអ្នកប្រើប្រាស់ និងអ្នកលក់រាយ។ | រយៈពេលខ្លី | • រដ្ឋបាលរាជធានីភ្នំពេញ<br>• ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព<br>• ក្រសួងរ៉ែ និងថាមពល<br>• វិស័យឯកជន |

| ឈ្មោះគម្រោងទៅតាមវិស័យអាទិភាព | រយៈពេល | ស្ថាប័នអនុវត្តន៍ |
|---|---|---|
| **១៥. លើកកម្ពស់ការប្រើប្រាស់ឧបករណ៍កម្តៅទឹកដែលដើរដោយថាមពលពន្លឺព្រះអាទិត្យ**<br>បច្ចេកវិទ្យាកម្តៅទឹកដោយប្រើប្រាស់ថាមពលព្រះអាទិត្យ អាចត្រូវបានគេប្រើប្រាស់ដើម្បីទទួលបានទឹកក្តៅសម្រាប់ប្រើប្រាស់នៅតាមផ្ទះ និងអគារឧស្សាហកម្ម។ គម្រោងនេះមានគោលបំណងផ្តល់នូវមូលនិធិ ដើម្បីគាំទ្រការអនុវត្តបច្ចេកវិទ្យានេះនៅតាមផ្ទះឯកជន តាមសណ្ឋាគារ និងតាមអគារពាណិជ្ជកម្មធំៗ។ | រយៈពេលខ្លី | • រដ្ឋបាលរាជធានីភ្នំពេញ<br>• ក្រសួងរ៉ែ និងថាមពល<br>• ក្រសួងឧស្សាហកម្ម និងសិប្បកម្ម<br>• ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព<br>• អគ្គិសនីកម្ពុជា |
| **១៦. ក្រុមហ៊ុនឯកជនបម្រើសេវាកម្មលើវិស័យថាមពល (ESCO) នឹងអនុវត្តការដាក់ប្រព័ន្ធស្រូបថាមពលពន្លឺព្រះអាទិត្យលើដំបូលនៅតាមអគារឧស្សាហកម្ម ពាណិជ្ជកម្ម និងអគារស្ថាប័នសាធារណៈ**<br>ការបង្កើតឱ្យមានក្រុមហ៊ុនប្រភេទ ESCO ដែលមើលទៅលើការផ្តល់ហិរញ្ញប្បទាន លើការផ្គត់ផ្គង់ លើការដំឡើង និងការគ្រប់គ្រងប្រតិបត្តិការបច្ចេកវិទ្យាប្រភេទនេះ គឺជាវិធីសាស្ត្រមួយ ដែលគេតែងអនុវត្តសម្រាប់ជួយទប់ទល់និងតម្លៃ នៃការប្រើប្រាស់ថាមពល ក៏ដូចជាជួយកាត់បន្ថយហានិភ័យនៃការប្រើប្រាស់ ការដំឡើង និងការស្វែងរកប្រភពទុនសម្រាប់ប្រព័ន្ធបច្ចេកវិទ្យាបែបនេះ។ | រយៈពេលមធ្យម | • រដ្ឋបាលរាជធានីភ្នំពេញ<br>• ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព<br>• ក្រសួងរ៉ែ និងថាមពល<br>• អគ្គិសនីកម្ពុជា |
| **១៧. ការផលិតថាមពលហាយប្រ៊ីត ដោយប្រព័ន្ធស្រូបថាមពលពន្លឺព្រះអាទិត្យ និងម៉ាស៊ូតសម្រាប់ឧស្សាហកម្មធំៗ**<br>ឧស្សាហកម្មធំៗ ដែលប្រើប្រាស់ថាមពលអគ្គិសនី ជាធម្មតា ប្រើប្រាស់ម៉ាស៊ីនម៉ាស៊ូត/HFO បំរុងទុកដើម្បីជំនួស ឬ បំពេញបន្ថែមលើអគ្គិសនីឥតាមបណ្តាញ។ គម្រោងនេះ នឹងជម្រុញឱ្យមានការប្រើប្រាស់បច្ចេកវិទ្យាថាមពលហាយប្រ៊ីតដោយប្រើប្រាស់ថាមពលព្រះអាទិត្តយ និងម៉ាស៊ូតជាជម្រើសប្រកបដោយប្រសិទ្ធភាពក្នុងការចំណាយ និងមិនប៉ះពាល់ដល់បរិស្ថាន ជាជាងការប្រើប្រាស់ម៉ាស៊ីនម៉ាស៊ូត/HFO ។ | រយៈពេលមធ្យម | • រដ្ឋបាលរាជធានីភ្នំពេញ<br>• ក្រសួងរ៉ែ និងថាមពល<br>• ក្រសួងឧស្សាហកម្ម និងសិប្បកម្ម<br>• អគ្គិសនីកម្ពុជា<br>• អាជ្ញាធរអគ្គិសនីកម្ពុជា<br>• ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព |

| ឈ្មោះគម្រោងទៅតាមវិស័យអាទិភាព | រយៈពេល | ស្ថាប័នអនុវត្តន៍ |
|---|---|---|
| **១៨. ក្រុមហ៊ុនប្រភេទ "Super ESCO" សម្រាប់សេវាថាមពលវិស័យសាធារណៈនៅក្នុងរាជធានីភ្នំពេញ**<br>គម្រោងនេះគឺដើម្បីបង្កើតក្រុមហ៊ុនប្រភេទ Super ESCO ដែលនឹងដាក់ឱ្យស្ថិតនៅក្រោមស្ថាប័នរដ្ឋណាមួយនៅក្នុងរាជធានីភ្នំពេញ អាចជា EDC។ ក្រុមហ៊ុន Super ESCO គឺជាស្ថាប័នសាធារណៈរបស់រដ្ឋមួយ ដែលបានបង្កើតឡើងដោយរដ្ឋាភិបាល ហើយដែលមានដើរតួនាទី ដូចក្រុមហ៊ុនឯកជន ESCO តែមានគោលបំណងបម្រើឱ្យតែវិស័យសាធារណៈ (មន្ទីរពេទ្យ សាលារៀន រដ្ឋបាលរាជធានី ស្ថាប័នរដ្ឋ និងអគារសាធារណៈរបស់រដ្ឋផ្សេងៗទៀត)។ | រយៈពេលមធ្យម | • រដ្ឋបាលរាជធានីភ្នំពេញ<br>• ក្រសួងរ៉ែ និងថាមពល<br>• អគ្គិសនីកម្ពុជា<br>• ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព |
| **១៩. គោលនយោបាយ និងការគាំទ្រតាមស្ថាប័នសម្រាប់ផលិតថាមពលអគ្គិសនីកកើតឡើងវិញ**<br>ការបង្កើតឱ្យមានកញ្ចប់គោលនយោបាយគាំទ្រ នឹងរួមបញ្ចូលការសិក្សាស្រាវជ្រាវឱ្យបានច្រើនដើម្បីជាប្រយោជន៍ក្នុងការរិះរកវិធីសាស្ត្រធ្វើគោលនយោបាយឱ្យសមស្រប (ឧទាហរណ៍ កម្រិត Feed-in-Tariff, របបពន្ធ Time-of-day ជាដើម។ល។) ក៏ដូចជាការធ្វើកំណែទម្រង់តាមស្ថាប័ន និងច្បាប់។ | រយៈពេលខ្លី | • រដ្ឋបាលរាជធានីភ្នំពេញ<br>• ក្រសួងរ៉ែ និងថាមពល<br>• អគ្គិសនីកម្ពុជា<br>• ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព<br>• អាជ្ញាធរអគ្គិសនីកម្ពុជា<br>• សមាគមថាមពលព្រះអាទិត្យ |
| **២០. បង្កើតបទដ្ឋាន (គំរូ) នៃការធ្វើសារពើពន្ធ និងការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ (GHG) សម្រាប់រាជធានីភ្នំពេញ**<br>ការបង្កើតបទដ្ឋានធ្វើសារពើពន្ធស្តីពីទំហំនៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងការធ្វើសេណារីយ៉ូ ដើម្បីវិភាគប៉ាន់ប្រមាណ និងសេណារីយ៉ូ កាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ នឹងបង្កភាពងាយស្រួលដល់ទីក្រុងក្នុងការ (១) កំណត់ឱកាសក្នុងការរិះរកវិធីសាស្ត្រកាត់បន្ថយការបញ្ចេញឧស្ម័ន ហើយដែលវាមានប្រសិទ្ធភាពចំណាយ (២) បង្កើតយន្តការគណនា រាយការណ៍ និងផ្ទៀងផ្ទាត់ (MRV) ដ៏រឹងមាំ (៣) អនុវត្តគម្រោង ឬ កម្មវិធីកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ប្រកបដោយប្រសិទ្ធិភាព និងល្អប្រសើរជាងមុន ដូច្នេះ (៤) បង្កឱ្យមានភាពងាយស្រួលលើការកៀរគរហិរញ្ញវត្ថុពីទីផ្សារកាបូនសម្រាប់ការវិនិយោគគម្រោង។ | រយៈពេលមធ្យម | • រដ្ឋបាលរាជធានីភ្នំពេញ<br>• ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព<br>• ក្រសួងធនធានទឹក និងឧតុនិយម |

| ឈ្មោះគម្រោងទៅតាមវិស័យអាទិភាព | រយៈពេល | ស្ថាប័នអនុវត្តន៍ |
|---|---|---|
| **២១. ការជំរុញឱ្យមាន រ៉ឺម៉កកង់បីដើរដោយថាមពលពន្លឺព្រះអាទិត្យ**<br>ម៉ូតូរ៉ឺម៉កកង់បីដែលដោយថាមពលអគ្គិសនី សម្រាប់ដឹកជញ្ជូនអ្នកដំណើរ ឬសម្រាប់ដឹកជញ្ជូនទ្រង់ទ្រាយតូច ដែលមានភ្ជាប់អាគុយប្រភេទ lead-acid និង lithium ion បញ្ចូលថាមពលដោយប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យ បំពាក់លើដំបូលយានយន្ត គឺវាបង្ហាញពីជម្រើសដ៏ល្អ និងមានសក្តានុពល ខ្ពស់ ដែលអាចជំនួយការប្រើប្រាស់ម៉ូតូរ៉ឺម៉កកង់បីធម្មតាដែលប្រើប្រាស់សាំង។ | រយៈពេល<br>ខ្លី | • រដ្ឋបាលរាជធានីភ្នំពេញ<br>• ក្រសួងរ៉ែ និងថាមពល<br>• ក្រសួងសាធារណការ និងដឹកជញ្ជូន |
| **២២. ការជំរុញឱ្យមានការប្រើប្រាស់កង់អគ្គិសនី**<br>កង់អគ្គិសនី គឺជាបច្ចេកវិទ្យាមួយដែលគួរឱ្យទុកចិត្ត និងកំពុងតែទទួលបានការចាប់អារម្មណ៍ខ្លាំង។ វានឹងមានសក្តានុពលខ្លាំង ជាមួយនឹងការពង្រីកនូវថាមពលកកើតឡើងវិញ។ គម្រោងនេះស្នើសុំឡើងឱ្យមានការផ្សព្វផ្សាយ និងជំរុញឱ្យមានការប្រើប្រាស់កង់អគ្គិសនីបានកាន់តែច្រើន ក៏ត្រូវមានគោលនយោបាយស្តីពីសុវត្ថភាពចរាចរណ៍ផងដែរ ដែលគួរតែរួមបញ្ចូលជាកញ្ចប់គោលនយោបាយរួមមួយ។ | រយៈពេល<br>មធ្យម | • រដ្ឋបាលរាជធានីភ្នំពេញ<br>• កស្រួងបរិស្ថាន<br>• ក្រសួងសាធារណការ និងដឹកជញ្ជូន |
| **២៣. កញ្ចប់វិធានការជួយគាំទ្រដល់ការរៀបចំ ចំណតយានយន្ត នៅរាជធានីភ្នំពេញ**<br>នៅកន្លែងជាច្រើន រថយន្ត និងម៉ូតូដែលគេចត និងការរីករាលដាលនៃសកម្មភាពអាជីវកម្មតាមចញ្ចើមផ្លូវ បានធ្វើឱ្យចិញ្ចើមផ្លូវសម្រាប់អ្នកថ្មើរជើង មិនអាចឆ្លងកាត់បាន។ គម្រោងនេះគិតអំពីការដាក់ចេញនូវកញ្ចប់វិធានការ ដើម្បីធ្វើនិយ័តកម្មលើចំណតយានយន្តឱ្យ បានល្អប្រសើរជាងមុន។ | រយៈពេល<br>មធ្យម | • រដ្ឋបាលរាជធានីភ្នំពេញ<br>• ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់<br>• ក្រសួងសាធារណការ និងដឹកជញ្ជូន<br>• អាជ្ញាធរឃុំ សង្កាត់ |
| **២៤. ការដាក់សាកល្បងតំបន់សម្រាប់អ្នកថ្មើរជើង**<br>គម្រោងនេះនឹងគាំទ្រដល់ (ក) ដំណើរការលើកកម្ពស់ការប្រឹក្សាយោបល់ និងការយល់ដឹងទៅដល់ប្រជាជនទូទៅ និងអាជីវករ អ្នកធ្វើផែនការទីប្រជុំជន រដ្ឋបាលខណ្ឌ និងក្រុង និងអាជ្ញាធរមានសមត្ថកិច្ចតាមដងផ្លូវ ដែលវានឹងបង្ហាញឱ្យឃើញពីផលប្រយោជន៍ និងការដោះស្រាយបញ្ហាប្រឈមចរាចរណ៍បាន។ (ខ) ត្រូវបិទផ្លូវសម្រាប់អ្នកថ្មើរជើងឆ្លងកាត់អំឡុងពេលមានពិធីដើរកម្សាន្ត (time window) (គ) ធ្វើការរៀបចំសាជាថ្មីហេដ្ឋារចនាសម្ព័ន្ធ ដើម្បីពង្រឹងតំបន់សម្រាប់អ្នកថ្មើរជើង និងការធ្វើពាណិជ្ជកម្ម។ | រយៈពេល<br>មធ្យម | • រដ្ឋបាលរាជធានីភ្នំពេញ<br>• ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់<br>• ក្រសួងសាធារណការ និងដឹកជញ្ជូន |

| ឈ្មោះគម្រោងទៅតាមវិស័យអាទិភាព | រយៈពេល | ស្ថាប័នអនុវត្តន៍ |
|---|---|---|
| **២៥. ការត្រួតពិនិត្យគុណភាពខ្យល់**<br>គម្រោងនេះមានគោលដៅបង្កើតប្រព័ន្ធត្រួតពិនិត្យគុណភាពខ្យល់ដែលមានលក្ខណៈធំទូលាយជាងមុន ភ្ជាប់មកជាមួយនឹងសមត្ថភាពគ្រប់គ្រាន់ក្នុងការថែទាំប្រព័ន្ធនេះនៅតាមមន្ទីរបរិស្ថានរាជធានីភ្នំពេញ ដោយមានការគាំទ្រពីក្រសួងបរិស្ថាន។ | រយៈពេលមធ្យម | • រដ្ឋបាលរាជធានីភ្នំពេញ<br>• ក្រសួងបរិស្ថាន |
| **២៦. ការសិក្សាស្រាវជ្រាវ ពីការប្រែប្រួលក្នុងស្តង់ដាគុណភាពប្រេងឥន្ធនៈ សម្រាប់ប្រេងឥន្ធនៈដឹកជញ្ជូន**<br>ការសិក្សាដែលបានស្នើឡើង នឹងក្រឡេកមើលលើសក្តានុពលសម្រាប់ពង្រឹងការត្រួតពិនិត្យលើគុណភាពប្រេងឥន្ធនៈ ដូចជា៖ (ក)វាយតម្លៃលើផលប៉ះពាល់នៃប្រេងឥន្ធនៈដឹកជញ្ជូនដែលមានគុណភាពទាបទៅលើគុណភាពខ្យល់នៅតំបន់ក្រុង (ខ) វាយតម្លៃលើការពង្រឹង និងប្រព័ន្ធសាកល្បងសម្រាប់ប្រេងឥន្ធនៈដឹកជញ្ជូននៅប្រទេសកម្ពុជា (គ) វាយតម្លៃពីលទ្ធភាពនៃប្រេងឥន្ធនៈដឹកជញ្ជូនដែលមិនប៉ះពាល់ដល់បរិស្ថាន និងធ្វើការប្រៀបធៀបតម្លៃជាមួយប្រេងឥន្ធនៈក្នុងពេលបច្ចុប្បន្ន (ឃ) បង្កើតនូវទិសដៅអនុវត្តសម្រាប់ណែនាំពីបទដ្ឋានប្រេងឥន្ធនៈដឹកជញ្ជូនដែលមិនប៉ះពាល់ដល់បរិស្ថាន។ | រយៈពេលខ្លី | • រដ្ឋបាលរាជធានីភ្នំពេញ<br>• ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់<br>• ក្រសួងសាធារណការ និងដឹកជញ្ជូន<br>• ក្រសួងពាណិជ្ជកម្ម<br>• ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព |
| **២៧. ដំណើរការសាកល្បងបង្ហាញពីការសាងសង់ផ្ទះប្រកបដោយចីរភាព និងមានតម្លៃទាប**<br>គម្រោងនេះ នឹងបង្ហាញពីលទ្ធភាពនៃការប្រើប្រាស់សំណង់ផ្ទះដែលមានតម្លៃទាបនៅតំបន់ជាយទីក្រុងដោយប្រើប្រាស់សម្ភារ និងបរិក្ខាសាងសង់ដែលមានតម្លៃទាបនិងអាចរកបានក្នុងស្រុក។ | រយៈពេលខ្លី | • រដ្ឋបាលរាជធានីភ្នំពេញ<br>• ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |
| **២៨. ការបង្ហាញពីការកែលម្អ នូវអគារបេតិកភណ្ឌវប្បធម៌សម្រាប់គោលបំណងពាណិជ្ជកម្ម ដោយប្រើប្រាស់ការរចនាដែលមានប្រសិទ្ធភាពថាមពល និងការសាងសង់ដែលគិតពីបរិស្ថានបៃតង**<br>គម្រោងនេះ នឹងរចនាធ្វើការកែលម្អ ឡើងវិញសំណង់អគារបេតិកភណ្ឌវប្បធម៌ចាស់ៗ (ទាំងអគារដែលមានរចនាបទជំនាន់បារាំង និងអគាររចនាបទខ្មែរសម័យទំនើប) សម្រាប់គោលបំណងពាណិជ្ជកម្មដោយបញ្ចូលនូវគំនិតក្នុងការសន្សំសំចៃថាមពល និងបរិស្ថានបៃតង ដែលគោលដៅចុងក្រោយគឺការទទួលបាននូវវិញ្ញាបនបត្រអន្តរជាតិជាអគារឈានមុខនៅក្នុងការរៀបចំថាមពលនិងបរិស្ថាន (LEED)។ | រយៈពេលខ្លី | • រដ្ឋបាលរាជធានីភ្នំពេញ<br>• ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ<br>• ក្រសួងរ៉ែ និងថាមពល |

| ឈ្មោះគម្រោងទៅតាមវិស័យអាទិភាព | រយៈពេល | ស្ថាប័នអនុវត្តន៍ |
|---|---|---|
| **២៩. វិធានណែនាំពីការពារទឹកជំនន់នៅតាមផ្ទះ**<br>ទឹកជំនន់កើតឡើងជាទៀងទាត់ ឬតាមរដូវកាល ដែលមានការជន់លិចតាមផ្ទះជាច្រើន និងតាមអាជីវកម្មខ្នាតតូចជាច្រើន នៅរាជធានីភ្នំពេញ។ ការណែនាំការការពារទឹកជំនន់ អាចផ្តល់ព័ត៌មានអំពីរបៀបធ្វើឱ្យផ្ទះទប់ទល់នឹងទឹកជំនន់បាន។ វិធានការណែនាំនេះមានបទដ្ឋានបច្ចេកទេសសាងសង់ផ្ទះសម្រប ទៅនិងទឹកជំនន់។ | រយៈពេលខ្លី | • រដ្ឋបាលរាជធានីភ្នំពេញ<br>• ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់<br>• គណៈកម្មាធិការជាតិសម្រាប់ការគ្រប់គ្រងគ្រោះមហន្តរាយ (NCDM)<br>• ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព |
| **៣០. វិធានការណែនាំសម្រាប់ការសាងសង់ផ្ទះនិងអគារពាណិជ្ជកម្ម ដែលប្រកបដោយប្រសិទ្ធភាពថាមពល**<br>វិធានណែនាំប្រសិទ្ធភាពថាមពលអាចដោះស្រាយនូវបញ្ហាសន្សំសំចៃ និងប្រសិទ្ធភាពថាមពល បានដូចខាងក្រោម៖ ការសាងសង់អគារ និងទំហំនៃការបើកចំហររចនាសម្ព័ន្ធ ដើម្បីបង្កើនខ្យល់អាកាសចេញចូល ធម្មជាតិ កញ្ចក់បង្អួចក្នុងការកាត់បន្ថយចំណាំងកាំរស្មីព្រះអាទិត្យ ស្រមោលបង្អួចខ្លាំង/បង្អួតកញ្ចក់ louver ស្វ័យប្រវត្តិ ដើម្បីកាត់បន្ថយការជ្រៀតចូលរបស់កម្តៅព្រះអាទិត្យ ឧបករណ៍កម្តៅទឹកដោយប្រើប្រាស់ថាមពលព្រះអាទិត្យ ការបង្កើតអគ្គិសនីដោយប្រើប្រាស់ថាមពលព្រះអាទិត្យ ប្រព័ន្ធគ្រប់គ្រងថាមពលដោយឆ្លាតវៃ ការប្រើប្រាស់សម្ភារអ៊ីសូឡង់កម្តៅ និងចង្កៀងបំភ្លឺប្រកបដោយប្រសិទ្ធភាពថាមពល។ | រយៈពេលមធ្យម | • រដ្ឋបាលរាជធានីភ្នំពេញ<br>• ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់<br>• ក្រសួងរ៉ែ និងថាមពល<br>• ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព |
| **៣១. វិធានការណែនាំស្តីពីការគ្រប់គ្រងទឹកជំនន់ក្នុង វិស័យសំណង់អចលនទ្រព្យ**<br>ការណែនាំមានវិធានការគ្រប់គ្រងទឹកភ្លៀងដូចខាងក្រោមនេះ៖ ប្រភេទដើមឈើល្អបំផុត ស្លឹករុក្ខជាតិពណ៌បៃតង និងសួនច្បារក្នុងការចាប់យកទឹកភ្លៀង ការប្រមូលទឹកភ្លៀង និងបឹងស្តុកទុកទឹក ទេសភាព និងរណ្តៅក្រោមដើមឈើសម្រាប់ផ្ទុកទឹកដែលកើតមកពីខ្យល់ព្យុះ ដើម្បីចាប់យក និងបង្កើនជម្រាបទឹកភ្លៀង និងការប្រើប្រាស់ផ្ទៃជ្រាបទឹកសម្រាប់ស្រូបយកទឹកភ្លៀងនៅកន្លែងសម្រាប់ចតយានយន្ត។ | រយៈពេលមធ្យម | • រដ្ឋបាលរាជធានីភ្នំពេញ<br>• ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់<br>• គណៈកម្មាធិការជាតិសម្រាប់ការគ្រប់គ្រងគ្រោះមហន្តរាយ (NCDM) |
| **៣២. ការបង្កើតមូលនិធិគ្រប់គ្រងការបំពុលពីសំណល់ទឹកកខ្វក់**<br>គម្រោងនេះនឹងផ្តល់ហិរញ្ញវត្ថុរយៈពេលវែងសម្រាប់គម្រោងការពារបរិស្ថាន នៅតាមឧស្សាហកម្មកម្មន្តសាលក្នុងទីក្រុងតាមរយៈការអភិវឌ្ឍមូលនិធិវិលជុំ និងគ្រឿងបរិក្ខារគាំទ្របច្ចេកទេស។ | រយៈពេលមធ្យម | • រដ្ឋបាលរាជធានីភ្នំពេញ<br>• ក្រសួងឧស្សាហកម្ម និងសិប្បកម្ម<br>• ក្រសួងបរិស្ថាន |

| ឈ្មោះគម្រោងទៅតាមវិស័យអាទិភាព | រយៈពេល | ស្ថាប័នអនុវត្តន៍ |
| --- | --- | --- |
| **៣៣. ការប្រើប្រាស់ទឹកប្រកបដោយប្រសិទ្ធភាព សាកល្បងនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស រាជធានីភ្នំពេញ (PPSEZ)**<br>មានសក្តានុពលដ៏សំខាន់ក្នុងការកាត់បន្ថយការប្រើប្រាស់ទឹកនៅតាមឧស្សាហកម្មផលិតកម្មដែលនឹងធ្វើឱ្យមានការកាត់បន្ថយការចំណាយថ្លៃទឹក កាត់បន្ថយតម្រូវការថាមពល និងធ្វើឱ្យការបញ្ចេញទឹកកខ្វក់មានកម្រិតទាប។ ការកាត់បន្ថយការប្រើប្រាស់ទឹក អាចធ្វើទៅបានតាមរយៈការកែសម្រួលនៃដំណើរការ និងបច្ចេកទេសក្នុងការប្រើប្រាស់ទឹកដែលកំពុងអនុវត្តសព្វថ្ងៃ រួមផ្សំនិងការដាក់ឱ្យប្រើប្រាស់នូវបច្ចេកវិទ្យាថ្មីប្រកបដោយប្រសិទ្ធភាពជាងមុនក្នុងការប្រើទឹក អាចកាត់បន្ថយការបាត់បង់ទឹកតាមរយៈការលិចតាមបំពង់បង្ហូរទឹកនិងក្បាលរ៉ាល់។ | រយៈពេលខ្លី | • រដ្ឋបាលរាជធានីភ្នំពេញ<br>• ក្រសួងឧស្សាហកម្ម និងសិប្បកម្ម<br>• ក្រសួងបរិស្ថាន<br>• ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>• ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព |
| **៣៤. ការសាកល្បងអនុវត្តគម្រោង ក្រុមហ៊ុនប្រភេទ ESCO នៅក្នុង PPSEZ**<br>គម្រោងនេះផ្តល់ការគាំទ្រការអភិវឌ្ឍរបស់ក្រុមហ៊ុនសេវាកម្មថាមពលសាកល្បង (ESCO) ដើម្បីគាំទ្រការប្រើប្រាស់បច្ចេកវិទ្យាប្រសិទ្ធភាពថាមពលជាមួយការផ្តោតទៅលើ PPSEZ យ៉ាងពិសេស។ ESCO នឹងផ្តល់ការត្រួតពិនិត្យថាមពលនិងគម្រោងគ្រប់គ្រង និងការកំណត់ និង អនុវត្តគម្រោងប្រសិទ្ធភាពថាមពលសម្រាប់ក្រុមហ៊ុន។ | រយៈពេលខ្លី | • រដ្ឋបាលរាជធានីភ្នំពេញ<br>• ក្រសួងឧស្សាហកម្ម និងសិប្បកម្ម<br>• ក្រសួងរ៉ែ និងថាមពល<br>• ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព |
| **៣៥. ការសាកល្បងគម្រោងក្នុងការបង្កើនលទ្ធភាពទទួលបានប្រភពហិរញ្ញវត្ថុសម្រាប់ការអនុវត្ត EE នៅតាមសហគ្រាសធុនតូច និងមធ្យម (ការបណ្តុះបណ្តាល/មូលនិធិដើមទុនគ្រាដំបូងនៅធនាគារពាណិជ្ជ)។**<br>ឧបសគ្គធំៗមួយចំនួនដែលប្រឈមនឹងរោងចក្រផលិតកម្ម ជាពិសេសសហគ្រាសធុនតូច និងមធ្យមក្នុងប្រទេសកម្ពុជា ក្នុងការអនុវត្តកម្មវិធីផលិតប្រកបដោយបរិស្ថានស្អាត និងមានប្រសិទ្ធភាពជាងមុន គឺការទទួលបានហិរញ្ញប្បទាន និងសេវាកម្មប្រកបដោយ គុណភាពខ្ពស់និងបច្ចេកទេសដែលមានតម្លៃសមរម្យ។ គម្រោងនេះនឹងស្វែងរកវិធីដើម្បីបង្កើនចំនួនហិរញ្ញប្បទានដែលមាននៅក្នុងលក្ខខណ្ឌសមស្របសម្រាប់ប្រសិទ្ធភាពថាមពលនិងគម្រោងផលិតកម្មបរិស្ថានស្អាតនៅតាមសហគ្រាសផលិតកម្មនៅក្នុងរាជធានីភ្នំពេញ។ | រយៈពេលខ្លី | • រដ្ឋបាលរាជធានីភ្នំពេញ<br>• ក្រសួងឧស្សាហកម្ម និងសិប្បកម្ម<br>• ក្រសួងរ៉ែ និងថាមពល<br>• ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព |

| ឈ្មោះគម្រោងទៅតាមវិស័យអាទិភាព | រយៈពេល | ស្ថាប័នអនុវត្តន៍ |
|---|---|---|
| **៣៦. ការសិក្សាស្តីអំពីសក្តានុពលក្នុងការផ្លាស់ប្តូរកាកសំណល់ក្នុងវិស័យឧស្សាហកម្ម ផ្តោតជាពិសេសទៅលើតំបន់សេដ្ឋកិច្ចពិសេស**<br>ការសិក្សានេះនឹងផ្តោតទៅលើសក្តានុពលសម្រាប់ការកែច្នៃឡើងវិញនូវអនុផលពីរោងចក្រដែលត្រូវបានប្រើប្រាស់ជាធាតុចូលនៅក្នុងឧស្សាហកម្មផ្សេងគ្នា។ ឧទាហរណ៍មានដូចជាការប្រើប្រាស់កាកសំណល់ដែកពីការផលិតដែកនៅក្នុងផលិតកម្មស៊ីម៉ង់ ការផលិតឥដ្ឋពីកាកសំណល់រោងចក្រផ្សេងៗ។ល។ | រយៈពេលខ្លី | • រដ្ឋបាលរាជធានីភ្នំពេញ<br>• ក្រសួងឧស្សាហកម្ម និងសិប្បកម្ម<br>• ក្រសួងបរិស្ថាន<br>• ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព<br>• សាកលវិទ្យាល័យ |
| **៣៧. ផលិតកម្មដែលមានលក្ខណៈបៃតង នៅតាមភូមិឧស្សាហកម្ម ផលិតកម្មកែច្នៃដោយដៃ (ភូមិមួយផលិតផលមួយ)**<br>ការសិក្សានេះនឹងស្វែងរកការឱកាសសក្តានុពលសម្រាប់ការបង្កើតនូវ "ភូមិមួយផលិតផលមួយ" សម្រាប់ជាគំរូដល់ភូមិសិប្បកម្មដែលធ្លាប់ទទួលបានជោគជ័យនៅកន្លែងផ្សេងក្នុងតំបន់ ហើយក៏ផ្តោតជាសំខាន់ទៅលើផលិតកម្មបៃតងដែលមានសក្តានុពល។ | រយៈពេលមធ្យម | • រដ្ឋបាលរាជធានីភ្នំពេញ<br>• ក្រសួងឧស្សាហកម្ម និងសិប្បកម្ម |
| **៣៨. ការសិក្សាលើការគ្រប់គ្រងទំហំសារធាតុពុល និងសំណល់ប្រកបដោយគ្រោះថ្នាក់នៅក្នុងវិស័យផលិតកម្ម**<br>គម្រោងនេះនឹង ក) បង្កើតជាការព្យាករគ្រប់ជ្រុងជ្រោយលើបរិមាណសារធាតុពុល និងកម្រិតជាតិពុល និងការបែងចែកភូមិសាស្ត្រនៅក្នុងក្រុង ខ) ការព្យាករព័ត៌មានអង្កេតដោយផ្ទាល់តាមរយៈការត្រួតពិនិត្យនៅតាមទីតាំងដែលបានជ្រើសរើស គ) ការព្យាករអំពីផលប៉ះពាល់លើគុណភាពបរិស្ថាន (ខ្យល់ ទឹក សំណល់រឹងនិងសំណល់គ្រោះថ្នាក់) និងកំណត់ទីតាំងបំពុលខ្លាំង ឃ) ការព្យាករផលប៉ះពាល់ផ្អែកលើព័ត៌មានអង្កេតផ្ទាល់ដោយមានការវាស់វែងនៅតាមទីតាំងដែលជ្រើសរើស ង) អនុវត្តសវនកម្មបច្ចេកវិទ្យាគ្រប់គ្រងសារធាតុពុល និងការអនុវត្តការគ្រប់គ្រងក្នុងទីក្រុង ច) ពិនិត្យក្របខណ្ឌច្បាប់ទាក់ទងនឹងលទ្ធផល និងបង្កើតសេចក្តីស្នើលើការការពារបរិស្ថានតាមរយៈការពង្រឹងនីតិកម្ម ការអនុវត្ត និងការត្រួតពិនិត្យ។ | រយៈពេលខ្លី | • រដ្ឋបាលរាជធានីភ្នំពេញ<br>• ក្រសួងឧស្សាហកម្ម និងសិប្បកម្ម<br>• ក្រសួងបរិស្ថាន |
| **៣៩. ការបែងចែកប្រភេទសំណល់ និងការបង្ហាញពីការសាកល្បងគោលការណ៍ 4R សម្រាប់ខណ្ឌមួយ**<br>គម្រោងនេះនឹងបង្កើតជាការបង្ហាញការសាកល្បងលើការបែងចែកប្រភពកាកសំណល់ក្នុងខណ្ឌមួយរួមមាន ការអនុវត្តយុទ្ធនាការលើកកម្ពស់ស្មារតីសាធារណៈ ការផ្តល់ជាកុងតឺន័របែងចែកកាកសំណល់ បង្កើតជាទីតាំងប្រមូលសំរាមដោយឡែកពីគ្នា និងកំណត់អំពីជម្រើសក្នុងការកែច្នៃ និងបំបែកសមាសធាតុដែលអាចប្រើប្រាស់ឡើងវិញបានពីសំរាមដែលបានបែងចែកហើយ។ | រយៈពេលខ្លី | • រដ្ឋបាលរាជធានីភ្នំពេញ<br>• ក្រសួងបរិស្ថាន<br>• អាជ្ញាធរឃុំ សង្កាត់ |

| ឈ្មោះគម្រោងទៅតាមវិស័យអាទិភាព | រយៈពេល | ស្ថាប័នអនុវត្តន៍ |
|---|---|---|
| **៤០. ការសាកល្បងគម្រោងលើការកែច្នៃសំណល់ទៅជាថាមពល (ដើម្បីបង្ហាញជាគំរូដល់គម្រោងផ្សេងទៀត)**<br>គម្រោងនេះនឹងអនុវត្តការបង្ហាញគំរូការកែច្នៃកាកសំណល់ទៅជាថាមពលក្នុងខណ្ឌសាកល្បង ដែលអនុវត្តការបែងចែកប្រភពកាកសំណល់។ សំណល់ទីក្រុងដែលជាប្រភេទសមាសធាតុសរីរាង្គនិងងាយឆេះនឹងត្រូវដុតនៅតាមឡដុតសំណល់ដែលបានកំណត់ ដើម្បីបង្កើតជាចំហាយទឹកនិងអគ្គិសនី។ | រយៈពេលមធ្យម | • រដ្ឋបាលរាជធានីភ្នំពេញ<br>• ក្រសួងរ៉ែ និងថាមពល<br>• ក្រសួងបរិស្ថាន<br>• ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព<br>• អាជ្ញាធររាជធានី ភ្នំពេញ |
| **៤១. យុទ្ធសាស្ត្រគ្រប់គ្រងកាកសំណល់រឹងសម្រាប់រាជធានីភ្នំពេញ**<br>គម្រោងនេះនឹងរៀបចំជាយុទ្ធសាស្ត្រគ្រប់គ្រងសំណល់រឹងសម្រាប់រាជធានីភ្នំពេញដែលនឹងកំណត់អំពីយន្តការសម្របសម្រួលរវាងខណ្ឌនីមួយៗ ដែលអាចរួមមាននូវការបញ្ចូលខណ្ឌជាអង្គភាពសហករណ៍ដើម្បីគ្រប់គ្រងទៅលើសំណល់រៀងៗខ្លួន។ សហករណ៍នេះអាចផ្តល់ប្រយោជន៍ដល់ខណ្ឌមួយចំនួនដែលមិនមានសមត្ថភាព ឬធនធាន ដើម្បីគ្រប់គ្រងសំណល់របស់ខ្លួនបាន។ | រយៈពេលខ្លី | • រដ្ឋបាលរាជធានីភ្នំពេញ<br>• ក្រសួងបរិស្ថាន<br>• អាជ្ញាធររាជធានី ភ្នំពេញ |
| **៤២. បទប្បញ្ញត្តិស្តីពីការហាមឃាត់ការប្រើប្រាស់ថង់ប្លាស្ទិច**<br>គម្រោងនេះនឹងបង្កើតជាសេចក្តីព្រាងបទប្បញ្ញត្តិស្តីពីការហាមឃាត់ការប្រើប្រាស់ថង់ប្លាស្ទិចប្រើតែមួយដង ដើម្បីបញ្ចូលទៅក្នុងច្បាប់ស្តីពីការការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ អនុក្រិតស្តីពីការគ្រប់គ្រងសំណល់រឹង។ វិសាលភាពនៃបទប្បញ្ញត្តិនេះរាប់បញ្ចូលទីផ្សារ ភោជនីយដ្ឋាន និងហាងលក់រាយទាំងអស់។ ការលើកលែងអាចអនុវត្តបានសម្រាប់ទំនិញធំៗផ្សេងៗ។ | រយៈពេលខ្លី | • រដ្ឋបាលរាជធានីភ្នំពេញ<br>• ក្រសួងបរិស្ថាន<br>• អាជ្ញាធររាជធានីភ្នំពេញ |
| **៤៣. ការពង្រឹងសមត្ថភាពគ្រប់គ្រងសំណល់រឹងនៅកម្រិតខណ្ឌ**<br>គម្រោងនេះនឹងអនុវត្តជាកម្មវិធីបណ្តុះបណ្តាលការកសាងសមត្ថភាពការគ្រប់គ្រងសំរាមក្នុងខណ្ឌមួយ សាកល្បងនៅភ្នំពេញ សម្រាប់ជាគំរូអនាគតដល់ខណ្ឌដទៃ។ កម្មវិធីកសាងសមត្ថភាពនឹងបញ្ចូលនៅគ្រប់ផ្នែកនៃការគ្រប់គ្រងសំរាមរួមមាន ការបង្កើតពន្ធប្រមូលសំរាម ការគ្រប់គ្រងហិរញ្ញវត្ថុ សេវាកម្មអតិថិជន និងការគ្រប់គ្រងក្រុមហ៊ុនសំរាម។ | រយៈពេលខ្លី | • រដ្ឋបាលរាជធានីភ្នំពេញ<br>• ក្រសួងបរិស្ថាន<br>• អាជ្ញាធររាជធានី ភ្នំពេញ |
| **៤៤. សួនកម្សាន្ត ដែលបម្រើដល់ការកម្សាន្តបានច្រើនមុខងារ**<br>គម្រោងនេះនឹងរចនាទីតាំងនោះឱ្យទៅជាសួនសាធារណៈពហុបំណងសម្រាប់ហាត់ប្រាណ ជិះស្គី និងលំហែអារម្មណ៍ជាដើម។ ទីធ្លាសាធារណៈក៏នឹងត្រូវបន្ថែមដោយគម្របព្រៃឈើ ដើម្បីជាម្លប់ និងដាំបន្លែ និងចុល្លព្រឹក្សបន្ថែមដើម្បីរក្សាទឹកទុក។ | រយៈពេលខ្លី | • រដ្ឋបាលរាជធានីភ្នំពេញ<br>• ក្រសួងសាធារណការ និងដឹកជញ្ជូន<br>• ក្រសួងបរិស្ថាន<br>• ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព<br>• ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |

| ឈ្មោះគម្រោងទៅតាមវិស័យអាទិភាព | រយៈពេល | ស្ថាប័នអនុវត្តន៍ |
|---|---|---|
| **៤៥. ការបង្ហាញការស្តារឡើងវិញនូវទីតាំងបេតិកភណ្ឌវប្បធម៌**<br>គម្រោងនេះនឹងជ្រើសរើសអគារសម័យអាណានិគមបារាំង ឬអគារ ស្ថាបត្យកម្មខ្មែរសម័យថ្មីដែលទំនេរ ដើម្បីធ្វើការបង្ហាញ ហើយនឹងត្រូវបានកែលម្អលើរចនាសម្ព័ន្ធដើម្បីប្រើប្រាស់និងទេសចរណ៍។ | រយៈពេលខ្លី | • រដ្ឋបាលរាជធានីភ្នំពេញ<br>• ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ |
| **៤៦. ការបង្ហាញពីការបង្កើតសាកល្បង តំបន់របៀងបៃតង/ខៀវ (Green / Blue Corridor) ដែលអាចប្រើប្រាស់បានច្រើនមុខងារ**<br>តំបន់សាកល្បងបៃតង/ខៀវនឹងបញ្ចូលប្រព័ន្ធទឹកធម្មជាតិចូលទៅក្នុងការបង្កើនសោភ័ណ្ឌភាពតំបន់កម្សាន្តពហុមុខងារ និងទីក្រុងនិរន្តរភាព។ មុខងារពហុបំណងនេះ អាចមានផ្លូវដើរធម្មជាតិសម្រាប់ជាការកម្សាន្ត ការរត់ឃីតៗ និងផ្លូវជិះកង់ជាដើម។ តំបន់សាកល្បងក៏នឹងបង្កើនជីវៈចម្រុះតំបន់ក្រុង និងទាក់ទាញប្រភេទបក្សីមកតំបន់ទីក្រុងវិញ។ | រយៈពេលមធ្យម | • រដ្ឋបាលរាជធានីភ្នំពេញ<br>• ក្រសួងសាធារណការ និងដឹកជញ្ជូន<br>• ក្រសួងបរិស្ថាន<br>• ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |
| **៤៧. បទប្បញ្ញត្តិស្តីពីការថែរក្សាបេតិកភណ្ឌវប្បធម៌**<br>គម្រោងនេះនឹងបង្កើតជាសេចក្តីព្រាងច្បាប់ស្តីពីការអភិរក្សបេតិកភណ្ឌវប្បធម៌សម្រាប់កម្ពុជា ដែលយកគំរូស្រដៀងនឹងប្រទេសផ្សេងទៀតដែរ។ ច្បាប់នេះនឹងកំណត់អំពីប្រភេទទីតាំងនិងតំបន់ បេតិកភណ្ឌវប្បធម៌ដែលត្រូវការពារ បញ្ចូលនូវការទទួលខុសត្រូវនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ប្រមូលឯកសារ និងព័ត៌មានអំពីគ្រប់ទីតាំង និងបង្កើតជាយន្តការហិរញ្ញប្បទានតាមរយៈរដ្ឋវិភាគទានអន្តរជាតិនិងឯកជន ព្រមទាំងលើកកម្ពស់ ស្ថាប័នរដ្ឋសម្រាប់ការអនុវត្តបទប្បញ្ញត្តិនេះ និងបង្កើតយន្តការមូលនិធិដែលអាចទទួលបានពីរដ្ឋ ឬការចូលរួមរបស់វិស័យឯកជន និងអន្តរជាតិជាដើម។ | រយៈពេលមធ្យម | • រដ្ឋបាលរាជធានីភ្នំពេញ<br>• ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ |
| **៤៨. ការបង្កើតមូលនិធិសម្រាប់គម្រោងថែរក្សាបេតិកភណ្ឌវប្បធម៌**<br>គម្រោងនឹងវិភាគយន្តការហិរញ្ញប្បទានដែលមានសក្តានុពលមួយចំនួនក្នុងការអភិរក្សបេតិកភណ្ឌវប្បធម៌នៅរាជធានីភ្នំពេញ។ នៅពេលយន្តការហិរញ្ញប្បទានសមស្របមួយត្រូវបានជ្រើសរើសហើយ គម្រោងនឹងដំណើរការយន្តការនេះដើម្បីបង្កើតជារចនាសម្ព័ន្ធគ្រប់គ្រង ដើម្បីរៀបចំ និងអនុវត្តលើមូលនិធិនេះ។ | រយៈពេលមធ្យម | • រដ្ឋបាលរាជធានីភ្នំពេញ<br>• ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ |




© GGGI

Global
Green Growth
Institute

Follow our activities
on Facebook and Twitter

www.gggi.org